ទស្សនាវដ្ដីស្រាវជ្រាវ

# រាជបណ្ឌិត្យសភាកម្ពុជា

# Royal Academy of Cambodia Journal

លេខ១១ ខែធ្នូ ឆ្នាំ២០២៣ | Vol.11-December-2023




រក្សាសិទ្ធិគ្រប់យ៉ាង

**នាយកការផ្សាយ**

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**

**និពន្ធនាយក**

ឯកឧត្តមបណ្ឌិត **យង់ ពៅ**

**គណៈកម្មការនិពន្ធ**

ឯកឧត្តមបណ្ឌិត **នូ ចាន់សុភី**
ឯកឧត្តមបណ្ឌិត **ផុន កសិកា**
ឯកឧត្តមបណ្ឌិត **អ៊ឹម បុណ្ណា**
ឯកឧត្តមបណ្ឌិត **នុត សម្បត្តិ**
ឯកឧត្តមបណ្ឌិត **គិន តា**
ឯកឧត្តមបណ្ឌិត **មាឃ បូរ៉ា**
ឯកឧត្តមបណ្ឌិត **គី សេរីវឌ្ឍន៍**
ឯកឧត្តម **ស្សូត្រ សំណាង**
ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម**
លោក **ហេង វីរិទ្ធិ**
លោក **សាន សុរាវនិត**

**លេខាធិការដ្ឋានបោះពុម្ពផ្សាយ**

លោកស្រី **កែវ ខេមរា**
លោក **ធឿន សុត្ថា**
លោក **ហេង ហុកវេន**
លោកស្រី **សំរិទ្ធ ចរិយា**
លោក **កៅ សុម៉ាឡេត**
លោក **ទ្រឿង មករា**
លោក **ភួយ បញ្ញា**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងការបោះពុម្ពផ្សាយជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍសង្គមជាតិដែលក្នុងនោះរាជបណ្ឌិត្យសភាកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវលើជំនាញផ្សេងៗនិងបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាជាច្រើនលេខរួចមកហើយ។ នៅក្នុងលេខទីដប់មួយនេះមានអត្ថបទជាច្រើនទៀតដែលទាក់ទងនឹងអប់រំ វិទ្យាសាស្ត្រសត្វ សេដ្ឋកិច្ច នីតិសាស្ត្រ ទស្សនវិជ្ជា បុរាណវិទ្យា និងរដ្ឋបាលសាធារណៈជាដើម សុទ្ធសឹងជាអត្ថបទសិក្សាស្រាវជ្រាវ និងវិភាគបែបវិទ្យាសាស្ត្រ ដែលអាចជាជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវផងដែរ។

ទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាបានរួមចំណែកផ្សព្វផ្សាយស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់បណ្ឌិត្យសភាចារ្យ អ្នកស្រាវជ្រាវ និងអត្ថបទសិក្សាស្រាវជ្រាវរបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបេក្ខជនបណ្ឌិត។ ការបោះពុម្ពផ្សាយនូវស្នាដៃស្រាវជ្រាវថ្មីៗបែបវិទ្យាសាស្ត្រគឺដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រជូនដល់សង្គមជាតិ និងជួយសម្រួលដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់ ក៏ដូចជាជួយជំរុញដល់អ្នកស្រាវជ្រាវទាំងឡាយកាន់តែមានឆន្ទៈស្រាវជ្រាវប្រកបដោយវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំទស្សនាវដ្ដីសង្ឃឹមថា អត្ថបទទាំងអស់ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវនេះនឹងក្លាយជាឯកសារដ៏សំខាន់មួយ សម្រាប់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំរង់ចាំទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអាននិងអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋានដើម្បីកែលម្អនូវចំណុចខ្វះខាតនិងកំហុសឆ្គងដែលអាចកើតមានដោយអចេតនា ទាំងលើខ្លឹមសារ និងផ្នែកបច្ចេកទេសឱ្យកាន់តែមានសុក្រឹតភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

**គណៈកម្មការទស្សនាវដ្ដីស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា


១. លទ្ធផលពិសោធន៍វិទ្យាសាស្ត្រផូស៊ីលអង្ករដំបូងនៅកម្ពុជា បណ្ឌិត **ធុយ ចាន់ធួន**------------------ ១

២. របបមាតាធិបតេយ្យក្នុងសង្គមខ្មែរ បេក្ខជនបណ្ឌិត **ឈុន ផារ៉េង**----------------------------------១៦

៣. ឥទ្ធិពលចំណូលពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា បេក្ខជនបណ្ឌិត **គង់ ចន្ថា**-------------------២៦

៤. ការធ្វើឱ្យប្រសើរឡើងលើមាន់ស្រុកតាមរយៈការបង្កាត់ពូជសិប្បនិម្មិត បេក្ខជនបណ្ឌិត **ហ៊ាន់ ហៀក** ------------------------------------------------------------------------------------------------------ ៣៥

៥. បញ្ហាប្រឈមរបស់សិស្សលើការប្រឡងមុខវិជ្ជាភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិជាមុខវិជ្ជាស្ម័គ្រចិត្ត បេក្ខជនបណ្ឌិត **តាក់ ជា** -------------------------------------------------------៤២

៦. បញ្ហាប្រឈមនៃការគ្រប់គ្រងធនធានមនុស្ស បេក្ខជនបណ្ឌិត **ហ៊ុន ដានី** ------------------------៤៨

៧. យុត្តិសាស្ត្រតុលាការយុត្តិធម៌អន្តរជាតិចំពោះការអនុវត្តសាលដីកា បេក្ខជនបណ្ឌិត **យោង ចាន់សុភារ** -------------------------------------------------------------------------------------------------------៥៤

៨. សារសំខាន់នៃការអប់រំកម្រិតមត្តេយ្យសិក្សា បេក្ខជនបណ្ឌិត **ប្រាក់ កុសល**---------------------៦៨

៩. ការប្រតិបត្តិរបស់ពុទ្ធសាសនិកក្នុងការលើកកម្ពស់សន្តិភាពនៅកម្ពុជា បេក្ខជនបណ្ឌិត **ព្រំ ឌី** ---៨០

១០. ប្រព័ន្ធគាំពារសង្គមសេដ្ឋកិច្ចកម្ពុជា បេក្ខជនបណ្ឌិត **អ៊ុង វិសិដ្ឋ** --------------------------------៨៧

១១. គោលគំនិតនៃការវិវត្តន៍ និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យរដ្ឋបាលសាធារណៈ បេក្ខជនបណ្ឌិត **ភូន ភូម៉ូនីរតន៍** -------------------------------------------------------------------៩៧

# លទ្ធផលពិសោធន៍វិទ្យាសាស្ត្រផូស៊ីលអង្ករដំបូងនៅកម្ពុជា

ស្រាវជ្រាវដោយ៖ បណ្ឌិត **ធុយ ចាន់ធួន**
អនុប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា
អនុប្រធានសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ
Tel: 011 424 767 Email: chanthourn@yahoo.com

ស្រូវ-អង្ករ ជាធញ្ញជាតិចម្បងរបស់ប្រជាជននៅតំបន់អាស៊ីអាគ្នេយ៍តាំងពីយុគថ្មរំលីង។ ការស្រាវជ្រាវថ្មីៗបានបង្ហាញ ពូជស្រូវជាច្រើនប្រភេទមានប្រភពចេញពីអាស៊ី ដូចជាពូជស្រូវ ឥណ្ឌីកា និង ស្រូវជប៉ុនីកា (Indica and Japonica) ដែលជាពូជតែមួយមានកំណើតតាំងពីប្រមាណជា ៨ ២០០ ទៅ ១៣ ៥០០ ឆ្នាំមកហើយ នៅក្នុងតំបន់ជ្រលងទន្លេគុជរបស់ចិន(Pearl River valley region of China)។ តំបន់ផលិតស្រូវ ឬកន្លែងដាំស្រូវដំបូងៗជាច្រើនកន្លែងផ្សេងទៀតនៅប្រទេសចិនដូចជាតំបន់ជ្រលងទន្លេយ៉ង់សេ (Yangtze River valley in China)។ នៅកំឡុងសហស្សវត្សទី៣មុនគ្រិស្តសករាជ ស្រូវត្រូវបានគេយកមកដាំដុះ ដកស្ទូងនៅតំបន់អាស៊ីអាគ្នេយ៍ដីគោក និងតំបន់ភាគខាងលិចនៅឥណ្ឌា និងនេប៉ាល់។ អ្នកបុរាណវិទូជនជាតិឥណ្ឌា បានជំទាស់និងមតិខាងលើ ហើយបានលើកឡើងថា ស្រូវត្រូវបានដាំដុះយូរមកហើយនៅជ្រលងទន្លេគង្គា (rice cultivation began in the Ganges river valley)។ លទ្ធផលរួមមួយបានបង្ហាញថា ពូជស្រូវ ឥណ្ឌីកា និងជប៉ុនីកា ជាពូជស្រូវដែលមានប្រភេទតែមួយដែលចេញពីស្រូវព្រៃដែលមានឈ្មោះថា អូរីសា រ៉ុយហ្វីប៉ូហ្គូន (Oryza Rufipogon) (ខ្មែរយើងហៅថាស្រងែ)។

តាមការសិក្សាដោយក្រសួងកសិកម្មកម្ពុជាយើងបានបញ្ជាក់ថា ប្រភេទស្រូវក្នុងប្រទេសកម្ពុជាមានជាង ពីរពាន់ប្រភេទ (more than 2000 variety of species)យោងតាមការទំនាក់ទំនងផ្ទាល់ជាមួយបណ្ឌិត គង់ គា ប្រធាននាយកដ្ឋានដំណាំស្រូវកម្ពុជា)។

## តើស្រូវបានដាំនៅស្រុកខ្មែរយើងតាំងពីពេលណាមក? ហើយនៅកន្លែងណា?

ក្នុងដំណើររុករកប្រាសាទបុរាណនៃអរិយធម៌សម្ពុបុរៈនៅខេត្តក្រចេះ និងស្ទឹងត្រែង ជាមួយលោកគ្រូ ហេ សុខសាយ និងភរិយាគាត់ ថង ទេពី ជាមួយនឹងរូបខ្ញុំ នាថ្ងៃពុធ ទី២២ ខែឧសភា ឆ្នាំ ២០១៩ ត្រូវនឹងថ្ងៃទី៤រោច ខែពិសាខ ព.ស.២៥៦៣ បានបន្តទៅសិក្សាទីទួលអង្ករខ្មៅ ស្ថិតនៅចំណុច 602719 1498047 ភាគខាងត្បូងប្រាសាទព្រះគោ ប្រមាណជា៥០០ម៉ែត្រ តែប៉ុណ្ណោះ ក្នុងភូមិកាំងតេដោ ឃុំថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់(ធារាបរិព័ទ្ធ)។ ក្នុងបញ្ជីបេតិកភ័ណប្រាសាទ របស់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ឆ្នាំ២០១៨ បានបញ្ជាក់ថា មានទួលអង្ករខ្មៅនៅខាងលិចទន្លេមេគង្គនៃទីរួមខេត្តនេះ (លោកស្រី ញ៉ោច សារឿន ប្រធានស្តីទីមន្ទីរ.វ.វ.)។ យើងខ្ញុំបានសួរទៅអ្នកភូមិដែលមានដីកម្មសិទ្ធិរបស់គាត់ជាប់នឹងទីទួលស្ថានីយនោះថា នៅក្រោយផ្ទះជាដីទួលដែលមានទន្ទ្រាំង

ខេត្តដុះដុំដិត និងចំការឈើម៉ៃសាក់ គឺជាទួលអង្ករខ្មៅ។ លោកគ្រូ ហេ សុខសាយ និងខ្ញុំបានយកនាស់ដែកតូចមួយមកឈូសដីទួលនោះមើល ក៏ប្រទះគ្រាប់ធ្យូងខ្មៅតូចៗមួយចំនួននៅលាយឡំជាមួយល្បាយដីខ្សាច់ និងស្លឹកឈើ យើងអាចសំគាល់ឃើញបានច្បាស់ថាមានគ្រាប់អង្ករ តែមានពណ៌ខ្មៅដូចធ្យូង។ យើងក៏រើសដាក់បាតដៃបញ្ជាក់ថា នោះជាគ្រាប់ធ្យូងអង្ករមែនពិត។ ខ្ញុំបានដើរពិនិត្យលើទួលនេះ ជាស្នាមគ្រឹះឥដ្ឋប្រាសាទបុរាណពិត ដោយមានដុំឥដ្ឋធ្វើអំពីដីដុត នៅរាយប៉ាយ ប្រជាជនរស់នៅជាប់នោះយកឥដ្ឋធ្វើជាកំណល់សសរផ្ទះ និងប្រើប្រាស់ផ្សេងៗ។ ការអង្កេតរយៈពេលខ្លីយើងមិនបានឃើញសំណល់មេទ្វារ ផ្តែរ ឬសសរពេជ្រ ដែលសំគាល់ថាទីនោះជាប្រាសាទបុរាណឡើយ តែតាមរយៈដុំឥដ្ឋដែលរាយប៉ាយនៅទីនោះ និងសណ្ឋានដីជាទីទួល ខ្ញុំសន្និដ្ឋានថាទីទួលអង្ករខ្មៅនេះប្រហែលជាទីតាំងគ្រឹះប្រាសាទបុរាណ។

## អ្វីទៅជាអង្ករខ្មៅ?

នៅថ្ងៃទី២២ ខែឧសភា ដដែលនោះខ្ញុំបានទៅផ្ទះលោកអនុសេនីយ៍ឯក ឡាយ ហ៊ិន នាយផ្នែកឱសថមន្ទីរពេទ្យយោធាភូមិភាគទី១ របស់ខេត្តស្ទឹងត្រែង និងភរិយាគាត់ឈ្មោះ ថង វិស័យ នៅក្នុងភូមិរាជានុគោល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ដែលបានដឹកយកកំណប់អង្ករខ្មៅកាលពីកំឡុងខែឧសភាឆ្នាំ២០១៨ មករក្សាទុកនៅក្នុងផ្ទះ។ លោកស្រី ថង វិស័យ បានប្រាប់ខ្ញុំថា៖ គាត់បានដឹងអំពីអង្ករខ្មៅនេះតាំងពីកំឡុងទសវត្សឆ្នាំ១៩៩០ មកម្ល៉េះ បងស្រីធ្លាប់ដឹងថា មានពួកសៀមបានមកទីនេះដើម្បីពិនិត្យមើល ព្រោះគេដឹងថា អង្ករខ្មៅនេះជាវត្ថុស័ក្តសិទ្ធិពូកែក្នុងផ្នែកអរូបី។ លោកអនុសេនីយ៍ឯក ឡាយ ហ៊ិន និងភរិយាគាត់ឈ្មោះ ថង វិស័យ បានបង្ហាញកញ្ចប់អង្ករខ្មៅចំណុះប្រមាណជា១៥ សម គុណ ១៥សម ជូនមកខ្ញុំដើម្បីពិនិត្យមើល លោកសួរមកខ្ញុំថា លោកគ្រូដែលឃើញទេ? ខ្ញុំធ្លាប់ឮអំពីអង្ករខ្មៅនេះតាំងពីឆ្នាំ១៩៩៦ ពេលនោះខ្ញុំចុះកម្មសិក្សាមកប្រាសាទព្រះគោ (កាលនោះខ្ញុំនៅជានិស្សិតមហាវិទ្យាល័យបុរាណវិទ្យា) តែកាលនោះមិនបានឃើញផ្ទាល់ភ្នែកដែរ ធ្លាប់បានឮអំពីភាពស័ក្តសិទ្ធិនៃអង្ករនេះ។ នេះជាលើកទី១ហើយដែលខ្ញុំបានទៅកាយផ្ទៃខាងលើពិនិត្យមើលទីតាំងអង្ករខ្មៅនោះ បានជួបអង្ករខ្មៅ។

## សណ្ឋានរូបអង្ករខ្មៅ

ខ្ញុំបានពិនិត្យហើយរើសយកគ្រាប់ដែលធំជាងគេយកមកធ្វើការពិនិត្យផ្ទាល់ភ្នែក ដោយប្រើខ្នាតម៉ាទ្រិច និងអង្ករលើក្រដាសមីលីម៉ែត្រជាជំនួយ ឃើញថាគ្រាប់អង្ករខ្មៅធំជាងគេនេះមានរាងមូលទ្រវែងទំហំប្រមាណបណ្តោយ ៦មម ទទឹង ២មម ខ្ញុំបានប្រើកែវពង្រីក (Magnify glass) នេះជាគ្រាប់អង្ករពិតៗ ព្រោះមានទម្រង់ឆ្នូតៗតាមសសៃនៃស្រទាប់គ្រាប់ស្រូវ។ វាជាគ្រាប់អង្ករសុទ្ធ ដែលមានទំហំ ធំ តូច ខុសៗគ្នានៅលាយឡំជាមួយគ្នា។ សភាពនៃគ្រាប់អង្ករនេះ ប្រហែលជាប្រភេទអង្ករបុរាណដែលមនុស្សយើង បក បុក ឬជាន់ស្រូវ តាមបែបប្រពៃណី ដូច្នេះគ្រាប់អង្ករមានបាក់ជាកំណាត់តូចៗ និងខ្លះនៅរលូន (សភាពនេះខុសគ្នាស្រឡះទៅនឹងការកិនស្រូវតាមម៉ាស៊ីនទំនើបបច្ចុប្បន្នដែលគ្រាប់អង្ករមានសភាពរលូនល្អ)។ គ្រាប់អង្ករខ្មៅទាំងនេះមានស្នាមអុចៗដូចជាគ្រាប់អង្ករដែលបានបកដោយដៃមិនបានបាត់ស្នាមដូចបុក ឬកិនឡើយ។



ផូស៊ីលអង្ករ ដែលរែងសំអាតរួច




ទំហំ ផូស៊ីលអង្ករ

## អំពីអង្ករខ្មៅ

យោងតាមភស្តុតាងបុរាណវត្ថុវិទ្យាបញ្ជាក់ថា មនុស្សជាតិចេះធ្វើកសិកម្មតាំងពីក្នុងយុគថ្មរំលីងមកម្ល៉េះ ក្នុងយុគនោះគេសម្គាល់បាននូវលក្ខណៈ ក/ មនុស្សចេះផ្សាំងសត្វ និងធ្វើកសិកម្ម ខ/មនុស្សចេះផលិតកុលាលភាជន៍ គ/មនុស្សប្រើឧបករណ៍ថ្មរំលីង ឃ/ មនុស្សចេះដោះដូរទំនិញ។ ខ្ញុំបានលើកភស្តុតាងមនុស្សចេះធ្វើកសិកម្មដំបូងៗនៅកម្ពុជាយើងមកបង្ហាញ នោះមានភស្តុតាងនៅស្ថានីយល្អាងស្ពាន ភ្នំទាក់ទ្រាំង ខេត្តបាត់ដំបង តាំងពីប្រមាណជាង២០០០ឆ្នាំមុនគ្រឹស្តសករាជ និងនៅស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់ មនុស្សបានបន្សល់ភស្តុតាងការផលិតស្រូវ តាំងពីប្រមាណជាង២០០០ឆ្នាំមុនគ្រិស្តសករាជ ផងដែរ។



(ភស្តុតាងគ្រាប់ស្រូវដែលមាននៅបន្ទាយគូ ធុយ ចាន់ធួន ១៩៩៧)

នៅសៀវភៅសរសេរអំពីស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់ (*ឌុយ ចាន់ធួន ២០០២*) បាន បង្ហាញថា មនុស្សនៅតំបន់ខាងកើតទន្លេមេគង្គ រស់នៅក្នុងបន្ទាយគូតំបន់ដីក្រហម ដប់ ក្រែក មេមត់ សួង ស្នួល.. មានការធ្វើកសិកម្មដោយការដាំស្រូវប្រមាណ១៥០០ឆ្នាំ ទៅ២០០០ឆ្នាំ មុនគ្រិស្តសករាជ។ ភស្តុតាងបង្ហាញតាមរយៈការផលិតកុលាលភាជន៍ ដែលសហគមន៍មនុស្សនោះ បានបន្សល់ដូចរូប ខាងលើបង្ហាញ គឺជាប្រភេទសំបកអង្កាម ដែលគេបានដាក់លាយជាមួយដីឥដ្ឋ មុននឹងសូនធ្វើជាក្អម ឬ ឆ្នាំងដី នៅក្នុងសម័យបុរេប្រវត្តិសាស្រ្ត។ គ្រាប់ស្រូវនោះ អាចជាគ្រាប់ស្រូវភ្នំ ឬស្រូវបុកដាំ ដែលប្រជាជន តំបន់ភ្នំនៅប្រកបដល់បច្ចុប្បន្ននេះ។ ប្រសិនបើយើងសិក្សាឱ្យបានលម្អិតថែមទៀតនោះ ការផលិតស្រូវ អាចរកបានភស្តុតាងបានថែមទៀតនៅក្នុងស្ថានីយបុរេប្រវត្តិសាស្រ្តខ្មែរយើង។

ប្រវត្តិនៃការផលិតស្រូវនៅកម្ពុជាមានតាំងពីសម័យយុគថ្មរំលីង មិនមានអ្វីសង្ស័យអំពីអង្ករខ្មៅ នេះឡើយ យើងអាចនិយាយបានថា៖

១/ អង្ករដាក់ក្នុងប្រាសាទតាមរយៈរូបសណ្ឋានគ្រាប់អង្ករខ្មៅទាំងនោះ ខ្ញុំអាចសន្និដ្ឋានបានថា ជាអង្ករ បុរាណដែលជាដង្វាយព្រះ ឬជាឃ្លាំងអង្ករសម័យបុរាណនៅតំបន់ក្បែរប្រាសាទព្រះគោនិងប្រាសាទ ប្រាំបួនល្វែង ក្នុងអរិយធម៌សម្បុរៈ ឬចេនឡាទឹកនេះឯងយើងបានភស្តុតាងដាក់លាក់នូវកាលបរិច្ឆេទ ពិតតាមតែវិទ្យុសកម្មសេ១៤ (C14) ដែលឆ្លើយការពិតនៃអង្ករខ្មៅនេះថា មានអាយុកាលនៅក្នុងឆ្នាំ ៩១៥ $\pm^{២៤}$ នៃគ្រិស្តសករាជ។

២/ ប្រសិនបើយើងមើលប្រវត្តិសាស្រ្តនៃការឈ្លានពានរបស់ប្រទេសជិតខាង មកលើប្រទេសខ្មែរយើង ឃើញថា ប្រទេសសៀមឈ្លានពានចូលកាន់កាប់ខ្មែរច្រើនលើកច្រើនគ្រា តែចុងសម័យអង្គរពួកសៀម ចូលបានរយៈពេលខ្លីៗ តែកំឡុងសតវត្សទី១៧ ដល់ដើមទី២០ ខ្មែរយើងត្រូវសៀមកៀបសង្កត់រហូត។ តំបន់ថាឡាបរីវ៉ាត់ អាចជាឃ្លាំងអង្ករ តែអាចត្រូវបានដុតចោលដោយសត្រូវ ឬសង្គ្រាមនៅពេលនោះ?

សូមរំលឹកអំពីប្រវត្តិសាស្រ្តបន្តិច ដែលមានសរសេរបញ្ជាក់ថាក្នុងសៀវភៅ Géographie, Physique, Économique et Historique du Cambodge, Monographie de la Province de Kratié, Saigon 1908. ស្ទឹងត្រែងជាផ្នែកមួយ នៃទីក្រុងសម្បុរៈដែរ គេបានសរសេរថា៖ ក្នុងចុងសតវត្ស ទី១៦ ស្តេចជ័យជេដ្ឋា ជាស្តេចក្រុងលង្វែកត្រូវបានរុញច្រានចាញ់សង្គ្រាមចាកចេញពីទីក្រុងលង្វែក ដោយសារពួកសៀមក្នុងឆ្នាំ១៥៨៣។ ស្តេចបានរត់ចេញទៅជ្រកនៅស្ទឹងត្រែង បន្ទាប់មកស្តេចបាន ចូលទិវង្គត ហើយក៏យកព្រះធាតុមកបញ្ចុះនៅសំបូរវិញ។ ទីនោះហើយប្រហែលព្រះអង្គចូលទិវង្គត នៅ ឆ្នាំ១៥៨៥ ដូចគ្នានឹងបុត្រច្បងរបស់ព្រះអង្គដែរ។ ចេតិយនៅវត្តសំបូរ មានរាងជាដួងនោះ ប្រហែលជា ចេតិយរបស់ព្រះអង្គ។ មានចេតិយតូច១នៅជាប់នោះ ប្រហែលជាចេតិយបុត្ររបស់ព្រះអង្គ។ ស្តេច បាត់បង់រាជសម្បត្តិនេះ ប្រហែលជាអ្នកកសាងសំបូរ ឡើងវិញ។ យ៉ាងណាក៏ដោយហាក់ដូចជា សម្បុរៈ បុរាណ ត្រូវបានខ្ទេចខ្ទីមុនព្រះអង្គយាងទៅទីនោះ។ ស្តេចអង្គនេះបានបង្កើតឡដែក ព្រះអង្គបានបង្កើត រូបបដិមា ដែលអ្នកស្រុកបង្ហាញនៅមាត់ទន្លេកាលពីរ ឬបីឆ្នាំមុន។ ក្នុងសៀវភៅដដែលបានសរសេរថា ប្រជាជនចាស់ៗបាននិយាយថា៖ ក្រុងនោះនៅតែមានប្រជាជនរស់នៅ ក្នុងរវាង ៦០០០ ទៅ៨០០០នាក់

រហូតដល់កំឡុងឆ្នាំ១៨៣៣ មុននិងទីក្រុងនេះត្រូវបំផ្លាញដោយសៀម និងការចាប់ពង្រត់ប្រជាជនទាំងនោះ ទៅតំបន់បាសាក់ និងបាងកក។ អ្វីដែលជាភស្តុតាងពិតប្រាកដនោះគឺលោក Gerard Van Wustorff និយាយថាសំបូរ គឺជាទីក្រុងយ៉ាងសំខាន់។ បន្ទាប់ពីការរុករានរបស់ពួកសៀម ប្រជាជនត្រូវបាន ចាប់ចងទៅដាក់នៅបាសាក់ និងបាងកក។ អ្នកទោសទាំងនោះមិនមានម្ហូបចំណី ធ្វើឱ្យអ្នកទោសរាប់រយអ្នកស្លាប់តាមផ្លូវ។ ការអធិប្បាយថា៥០%នៃអ្នកទោសទាំងនោះស្លាប់ បន្ទាប់មកស្ត្រី និងក្មេងៗត្រូវបោះចោលឱ្យសត្វព្រៃស៊ី (សត្វព្រៃដើរតាមក្រោយតាមស៊ីមនុស្សនិងខ្មោចមនុស្សទាំងនោះ)។ អ្នកទោសខ្លះអាចរត់រួចពីបាសាក់ហើយរត់ទៅសំបូរវិញ។ ពេលដល់សំបូរ មិនមានឃើញផ្ទះណាមួយនៅសល់ឈរឡើយ ផ្ទះទាំងនោះត្រូវបានដុតបំផ្លាញចោលទាំងអស់ គេមិនបានឃើញនរណាម្នាក់រស់នៅក្នុងក្រុងនេះទេ ព្រោះពួកគេខ្លះបានរត់គេចចេញពីសៀម ពួកគេរត់ទៅទិសខាងត្បូង ហើយតាំងទីនៅតំបន់ក្រចេះសព្វថ្ងៃ។ (ក្នុងកំណត់ហេតុចុងទំព័រ របស់សៀវភៅនេះ បានសរសេរថា៖ អ្នកដែលរស់នៅមួយចំនួនតូច ដែលកៀរទៅបាងកក ត្រូវគេឃើញរស់នៅក្នុងភូមិ Lokkhon-Si-Say ជិតក្រុងបាងកក)។

ប្រវត្តិសាស្ត្រខាងលើ ចង់បញ្ជាក់ថា តំបន់ថាឡាបរិវត្តិ និងតំបន់សម្ពុបុរៈ ត្រូវរងក្នុងសង្គ្រាមខ្មែរសៀម តាំងពីសម័យលង្វែករហូតដល់ឆ្នាំ១៩០៤ ដែលសៀមដកទ័ពចេញពីកម្ពុជា។ សូមបញ្ជាក់ថា នៅពេលសង្គ្រាមប្រហែលជាឃ្លាំងអង្ករ ឬឃ្លាំងស្រូវត្រូវបានដុតបំផ្លាញ។ សំណល់គ្រាប់ស្រូវ ឬអង្ករខ្មៅនៅស្ថានីយកាំងតេជោ នោះអាចជាសំណល់នៃឃ្លាំងស្រូវ ឬអង្ករ។

## សិលាចារិកសម័យមុនអង្គរ និយាយអំពីស្រូវ

ចង់បញ្ជាក់ថាទីតាំងអង្ករខ្មៅនៅថាឡាបរិវ៉ាត់ (ធារាបរិព័ទ្ធ) អាចជាឃ្លាំងអង្ករ របស់សម្ពុបុរៈតែត្រូវដុតចោលពេលសង្គ្រាមខ្មែរសៀមក្រោយសម័យអង្គរ។ ដូចបានជម្រាបជូនជាប្រវត្តិ នៅថាឡាបរិវ៉ាត់ នេះជាផ្នែកមួយនៅចន្លោះភវបុរៈ និងសម្ពុបុរៈ ដែលជាទីក្រុងព្រហ្មញ្ញសាសនា មានជំនឿលើការបូជាច្រើនប្រការ ស្រូវឬអង្គ ប្រហែលជាពិធីមួយត្រូវបានយកមកបូជាដល់ព្រះ ឬអទិទេព។ គ្រឹះប្រាសាទដែលមានកំណាប់អង្គខ្មៅនៅស្ទឹងត្រែងនោះ ជាគ្រឹះប្រាសាទព្រហ្មញ្ញសាសនាសម័យចេនឡា(បុរេអង្គរ) អាចជាកន្លែងពិធីសាសនានៃការបូជាស្រូវនេះឯង។

នៅទីក្រុងបុរាណឥន្ទ្របុរៈ(ព្រៃនគរក្នុង)នាតំបន់ស្រឡប់ពិជ័យ ខេត្តត្បូងឃ្មុំ ជាទីក្រុងសម័យចេនឡា មានសំណង់កំពែងប្រមាណជាង៤គីឡូម៉ែត្រក្រឡា និងមានប្រាសាទឥដ្ឋបុរាណបាក់បែកផងនោះ ក៏ជាបុរាណស្ថានសម័យចេនឡាផងដែរ។ នៅភាគឦសានក្រុងបុរាណនេះ ជាខ្សែបន្ទាត់នៃសំណង់ប្រាសាទឥដ្ឋបុរាណជាច្រើនទៀតដូចជាប្រសាទព្រៃគីឬប្រាសាទអណ្ដោត ប្រាសាទព្រះធាតុប្រាសាទជើងអង្គ ជាដើម។ សូមបញ្ជាក់ថា តំបន់ឥន្ទ្របុរៈនោះ ជាតំបន់វាលទំនាប ដែលប្រជារាស្ត្រជាអ្នកអាស្រ័យជីវភាពលើការដាំស្រូវ តាំងពីបុរាណកាលមក។ នៅលើមេទ្វារប្រាសាទជើងអង្គ មានសិលាចារិកដែលបរិយាយអំពីការធ្វើស្រែ លោក កំ វណ្ណារ៉ា បានបកប្រែផ្នែកខ្លះនៃសិលាចារិកនោះថា៖ *ទ្វស្រេ ថ្ប៉ោង ត្បក ប្រែធ្វើស្រែត្បូងដេក។* ក្នុងលក្សណៈជាទូទៅមួយពាក្យ *ថា ថ្វេ មានសំណេរនៅសម័យមុនអង្គរថា ត្វេ សម័យអង្គរថា ថ្វេ និងក្នុងសាស្ត្រានិងក្រាំងបុរាណខ្លះសសេរថា ធ្វេ ខ្លះសសេរធ្វិ ឬធ្វើ។*

*ចំណែកពាក្យថា ស្រេ យើងសំកេតថាមានសំណេរដូចគ្នាក្នុងសម័យមុនអង្គរ និងអង្គរហើយបន្តរសេសេរបែបនេះរហូតដល់សម័យកណ្តាលចាប់ពីចុងសម័យកណ្តាលមកទើបមានសំណេរថា ស្រែ។ ប៉ុន្តែ ស្រេ ទោះបីក្នុងសម័យបច្ចុប្បន្នតំបន់ខ្លះនៅអានថា ស្រេ ខ្លះអាន សេ ខ្លះឆេ ដូច្នេះខ្លះក៏មាន។ ចំណែកពាក្យថា ថ្បោងនេះ ជួនកាលសសេរជាថ្បូងដូច្នេះក៏មាន ដែលមានន័យថាក្បាល ឬកំពូល ខ្មែរយើងនៅប្រើដូចជា ត្បូងចប ត្បូងក្រពើ បង្គំត្បូង ។ ត្យក =ដេក។*

សិលាចារិក K.99 របស់ប្រាសាទដើងអង្គ ត្បូងឃ្មុំ នេះនាមនិយាយច្រើនជងពីភ្ញុំដែលគេទុកឱ្យរក្សាប្រាសាទ និងធ្វើស្រែសម្រាប់ផ្គត់ផ្គង់ប្រាសាទ។



(សិលាចារិក K.99 ប្រាសាទដើងអង្គ ត្បូងឃ្មុំ)

សិលាចារិកសម្ពុបុរៈ (ប្រាសាទត្រពាំងប្រិយ)

សិលាចារិក បណ្តោយ១.៧៦ម ទទឹង០.៤៦ម កម្រាស់០.១ម មានអក្សរចំនួន២២ជួរ។ លោកសាស្ត្រាចារ្យបណ្ឌិត វង់ សុធារ៉ា អ្នកសិលាចារិកវិទ្យានៃមហាវិទ្យាល័យប្រវត្តិសាស្ត្រ បានវាយតម្លៃសិលាចារិកនេះថា ប្រហែលចារនៅក្នុងកំឡុងសតវត្សទី៧នៃគ្រិស្តសករាជ ដោយយោងលើតួអក្សរបុរាណ។

លោកសាស្ត្រាចារ្យ ហ៊ិន ឈុនតេង ដែលបានបកប្រែសិលាចារឹកនេះបានអះអាងដូចគ្នានឹងសាស្ត្រាចារ្យ បណ្ឌិត វង់ សុធារ៉ា ថាសិលាចារិកនេះគឺចារក្នុងកំឡុងសតវត្សទី៧ នៃគ្រិស្តសករាជ ជាភាសាខ្មែរសុទ្ធ។

សិលាចារិកនេះចារក្នុងគោលដៅ ថ្វាយជាតង្វាយដល់អាទិទេពព្រហ្មញ្ញសាសនា ព្រះគម្តែង អញស្រីព្រឹទ្ធេស្វរ[១](/ស្រីព្រឹទ្ធេស្វរៈ) ជានិកាយព្រះឥស្វរ ដែលមានវណ្ណាប់ជាច្រើនសម្រាប់ថ្វាយ សម្រាប់ថ្ងៃសីល ថ្ងៃថ្វាយផ្កាមាន អង្ករ១២លិះ ប្រេងចន្ទន៍១ចន្លូរ ស្លា២ដំបរ កន្លែងគ្របយជ្ញ១ គឺសម្រាប់ចតុមាស(បួនខែ)ប៉ុណ្ណោះ។ ខ្ញុំបម្រើ ស្រែ ច្បារដំណាំ គោ គឺថ្វាយជាចតុជាតក[២]ដល់អាស្រម។ វណ្ណាប់បូជាដល់អាស្រមមានស្រូវ១កញ្ចើ សម្ល២ផ្នែក(មុខ) ស្លា២ដំបរ សម្លៀក១យៅ។

**សិលាចារឹកថ្មីមកពីត្រពាំងឬស្សី ឃុំសំបុក**



- **ដោយ ហ៊ិន ឈុនតេង**
- **អំណានអត្ថបទ**
- ១- គិចំនាំម្រតាញ៑[គ្រី]លចនិអំវិតគិអាគ្រមអាយ៑
- ២- តវ្រះកំម្រតាង៑អញ៑គ្រីវ្ឫទ្ធេគ្វរចតុពាត្សវស្លា
- ៣- ស្មាង៑១រង្គោលិះ[៣]បរេង៑ចនិឱរ៑២តគិ
- ៤- ត្ងៃវ្រះត្ងៃវ្សរង្គោលិះ២បរេង៑ចនិ
- ៥- ចនិឱរ៑១ស្លាតំបរ៑២ កនិសេង៑ករប
- ៦- យជ្ញ១តគិចតុម៌ាសគុស៑គិ[ក្ញុំ]គិ
- ៧- ស្រែគិទំរិង៑គិត្នុរ៑តេល៑ឱយ៑ចា
- ៨- តុជ្ជ៌ាតកតគិអាគ្រមចនាម៑
- ៩- តគិអាគ្រម[ស្រុ]កញ្ជេ១សំលោ
- ១០- វ្នេក៑២ ស្លាតំបរ៑២ ចនិលេក៑
- ១១- យៅ១ គេតទង៑សក៑គិគេត
- ១២- ទង៑ទប៑គិគេតទង៑[លោបេ]គិ
- ១៣- គេលង៑ល្យង៑កំលុង៑ស
- ១៤- ប្តាវិគនិរយយាវត្សូយ្យ
- ១៥- ស្យចន្ទ្រស្យតារ៑តិគេស៑
- ១៦- ង៑កំលុង៑គិគេម្រតាញ៑បំនោ
- ១៧- ស៑តអង្គោយ៑តគិអាគ្រ[យ]គេម្រ
- ១៨- តាញ៑តប្ដុះគេក្លោញ៑ស្រុក៑នៅតវាំ
- ១៩- កថា[រ]គិអ្នក៑តសក្កលេង៑វ្រះ

[១] ទេពអង្គនេះត្រូវនឹងពាក្យហៅក្នុងសិលាចារឹកខ្មែរសម័យមុនអង្គរថា «វ្រះចស៑»។

[២] ចតុជាតក = គ្រឿងដង្វាយដែលមានបួនមុខ។

- ២០- លេង៉អាគ្រមគេបនិទបិតគិនិរ
- ២១- យឌក្ក
- ដោយសាររូបថតពុំច្បាស់ ពាក្យនេះអាចជា «ចំនំ» ផងដែរ។

**សិលាចារឹកថ្មីមកពីត្រពាំងប្រី ឃុំសំបុក**
**ដោយ ហ៊ុន ឈុនតេង**
**សេចក្ដីប្រែសម្រួល**

(១-២) (នេះ)គឺរណ្ដាប់បូជារបស់ម្រតាញសីលចាន់ចំពោះអាស្រមនិងព្រះគម្តែងអញស្រីព្រឹទ្ធេស្វរ(/ស្រីព្រឹទ្ធេស្វរៈ)។
(២-៦) (សម្រាប់)បុណ្យទាំងបួនមាន ស្លា២ស្នែង អង្ករ៣លិះ ប្រេង២ចន្លូរ។ សម្រាប់ថ្ងៃសីល ថ្ងៃថ្វាយផ្កាមាន អង្ករ២លិះ ប្រេងចន្ទន៍១ចន្លូរ ស្លា២ដំបរ កន្លែងគ្របយដ្ធ១ គឺសម្រាប់ចតុមាស(បួនខែ)ប៉ុណ្ណោះ។
(៦-១១) ខ្ញុំបម្រើ ស្រែ ច្បារដំណាំ គោ គឺថ្វាយជាចតុជាតកដល់អាស្រម។ រណ្ដាប់បូជាដល់អាស្រមមានស្រូវ១កញ្ជើ សម្លូ២ផ្នែក(មុខ) ស្លា២ដំបរ សម្លៀក១យៅ។
(១១-១៥) អ្នកណាដែលយក(ទ្រព្យទាំងនេះ) អ្នកណាដែលរារាំង អ្នកណាដែលបំផ្លាញ គឺអ្នកនោះលន្លឹងក្នុងនរក២៧ជាន់ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យនៅតែមាន។
(១៥-២១) អ្នកសិងកំឡុង(ទីនោះ) គឺម្រតាញជាបំនួសរស់នៅអាស្រម ម្រតាញជាផ្ទះ អ្នកជាប្រធានស្រុកដែលពុំពោលប្រាប់ដល់អ្នកដែលដកយក(ទ្រព្យទាំងនោះ)ចេញពីព្រះ ចេញពីប្រាសាទ (និង)អ្នកដែលមករារាំង ក៏ធ្លាក់ទៅនរកដែរ។
ទេពអង្គនេះត្រូវនឹងពាក្យហៅក្នុងសិលាចារឹកខ្មែរសម័យមុនអង្គរថា «វ្រះចស៊»។
ចតុជាតក = គ្រឿងដង្វាយដែលមានបួនមុខ។
ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យនៅតែមាន ដរាបនោះអ្នកទាំងនោះនៅតែលន្លឹងក្នុងនរកនោះពុំលែង។
សិង = ស្នាក់នៅរៀបចំបូជាពិធីកម្មផ្សេងៗក្នុងប្រាសាទឬអាស្រម។
ម្រតាញផ្ទះ = បព្វជិតប្រោសព្រំជម្រះមន្ទិល...។
សិលាចារិកសម័យអង្គរ និយាយអំពីស្រូវ

សិលាចារិកប្រាសាទបន្ទាយស្រី K.571 សតវត្សទី១០ នៅគោបុរៈទី៣ ខាងកើត ទ្វារខាងក្នុងលើស៊ុមទ្វារ អំពីការធ្វើតង្វាយស្រូវដល់ប្រាសាទ។



(សិលាចារិកសម័យអង្គរបរិយាយអំពីអំណោយស្រូវ)

សម័យអង្គរមានភស្តុតាងច្រើនដែលបានបរិយាយ និងឆ្លាក់ ការបុកស្រូវ និងចារជាអំណោយស្រូវ នៅលើផ្ទាំងសិលានៅតាមប្រាសាទនានា។



(ចម្លាក់ទាបនៅប្រាសាទព្រះខ័ណ្ឌបង្ហាញសកម្មភាពបុកស្រូវ រូបភាពដោយ ស៊ឹម សុកក្រា ២០១៩)

យោងលើភស្តុតាងជាច្រើននៅក្នុងសម័យអង្គរ យើងអាចសន្និដ្ឋានបានថា ផូស៊ីលអង្ករ ដែលបានយកមកពីប្រាសាទនៅតំបន់ជារាបរិព័ទ្ធ ប្រហែលជាប្រភេទស្រូវដែលបានដាំដុះនៅក្នុងសម័យសម្ភុបុរៈ ជាតំបន់ដែលរងសង្គ្រាមរវាងខ្មែរ-សៀម បន្ទាប់ពីសម័យអង្គរ។

## កាលបរិច្ឆេទផូស៊ីលអង្ករខ្មៅ

កាលពីខែកក្កដា ឆ្នាំ២០១៩ ខ្ញុំបានផ្ញើសំណាកអង្ករខ្មៅមួយចំនួនទៅមន្ទីរពិសោធន៍សម្រាប់ពិសោធន៍នៅសាកលវិទ្យាល័យជាតិអូស្ត្រាលី ដែលមានលោកស្រីបណ្ឌិត **Dr. Rachel Wood** ជាអ្នកជំនាញបុរាណវិទ្យា និងជានរវិទ្យា នៅវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រដី និងកាបូន នៃមហាវិទ្យាល័យស្រាវជ្រាវវិទ្យាសាស្ត្រដី (Senior Lecturer in Archaeology; Archaeology and Anthropology, Research School of Earth Sciences; Radiocarbon Facility, Research School of Earth Sciences, Australian National University, Building 142 Mills Road, Acton, ACT 2601CRICOS Provider #00120C.) ។ យើងបានធ្វើកាបរិច្ឆេទទៅលើសំណាកគ្រាប់អង្ករមួយគ្រាប់ ដែលបានសំអាតរួចរាល់ជាមួយ scalpel និងប្រភេទអាស៊ីត បាស អាស៊ីត រក្សាទុកមួយរយៈ បន្ទាប់មកយកទៅវាស់ជាមួយម៉ាស៊ីនAMS។ កូដ្ឋសម្រាប់ពិសោធន៍ (S-ANU 63310) ។ អង្ករខ្មៅនេះ មានកាលបរិច្ឆេទប្រមាណជា ៩០០-១០០០ មុនឆ្នាំបច្ចុប្បន្ន ត្រូវគ្នានឹងឆ្នាំ ៩១៥ ±២៤ នៃគ្រិស្តសករាជ អាចនិយាយថា ៩៥% ជាចម្លើយភវនីយភាព។




| | | | | | | |
|---|---|---|---|---|---|---|
| **Radiocarbon Laboratory** | | | | | | |
| The Australian National University | | | | | | |
| $^{14}$C results | | | | | | |
| Submitter: T. Chanthourn | | | | DATE: | October 11, 2019 | |
| | | | | | | |
| **S-ANU#** | **Sample ID** | **internal ID** | **F14C** | **±** | **$^{14}$C age** | **±** |
| | | | | | | |
| 63310 | Rice Fossil | 21013 | 0.8923 | 0.0021 | 915 | 24 |
| | | | | | | |

## ជំនឿ

ខ្ញុំបានជួបផ្ទាល់ជាមួយអ្នកស្រុករស់នៅស្ទឹងត្រែង និងមនុស្សមួយចំនួនទៀត ដែលបានរក្សាទុកអង្ករខ្មៅ តាមតំបន់នានាក្នុងប្រទេសកម្ពុជាយើង ចំនួន១០នាក់ (តំណាងឱ្យ១០គ្រួសារ អ្នកខ្លះសុំមិនបញ្ចេញឈ្មោះ) លោកអនុសេនីយ៍ឯក ឡាយ ហ៊ន នាយផ្នែកឱសថមន្ទីរពេទ្យយោធភូមិភាគទី១ របស់ខេត្តស្ទឹងត្រែង និងភរិយាគាត់ឈ្មោះ ថង វិស័យ នៅក្នុងភូមិរាជានុគោល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង បានប្រាប់មកខ្ញុំថា តាំងពីមានអង្ករខ្មៅ នៅក្នុងផ្ទះកាលណាធ្វើឱ្យគ្រួសារគាត់រកស៊ីមានបាន និងរីកចម្រើន ព្រមទាំងត្រជាក់ត្រជុំមិនដែលមានជំងឺអ្វីបៀតបៀនក្រុមគ្រួសារឡើយ។ លោកស្រី (មួយរូបសុំមិនបញ្ចេញឈ្មោះ) ដែលទទួលបានអង្ករខ្មៅពីបងប្អូនរបស់គាត់នៅស្ទឹងត្រែងដែរនោះ បានបញ្ជាក់ថា លោកស្រីរីករាយណាស់បន្ទាប់ពីបានអង្ករខ្មៅនេះមកទុកក្នុងគេហដ្ឋានកាលណា គឺរកស៊ីមានបាន និងការងារល្អជានិច្ច។ ៩០% នៃអ្នកមានអង្ករខ្មៅនិយាយថាគឺរកស៊ីមានបាន សុភមង្គល ការងារល្អជានិច្ច។

## សេចក្ដីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ស្ថាប័នស្រាវជ្រាវរាជបណ្ឌិត្យសភាកម្ពុជា ព្រមទាំងមិត្តរួមអាជីព និស្សិត និងអាជ្ញាធរដែនដីដែលបានផ្ដល់ភាពកក់ក្ដៅ និងរាល់ការគាំទ្រទាំងឡាយសម្រាប់គម្រោងស្រាវជ្រាវមួយនេះ។ សូមថ្លែងអំណរគុណ ឯកឧត្ដមបណ្ឌិត ទី សុគន្ធ លោក បណ្ឌិត គង់ គា នៃក្រសួងកសិកម្ម។ រាល់ការគាំទ្រទាំងនោះបានផ្ដល់មកខ្ញុំនូវរបកគំហើញថ្មីយ៉ាងសម្បើមនូវទីក្រុងសម្ពុបុរៈ និងស្ថានីយផូស៊ីលអង្ករខ្មៅ។ ខ្ញុំសូមលំឱនកាយអរគុណដល់អស់លោក លោកស្រី ទាំងអស់។ ជាបន្ទាប់ សុំអរគុណកូនស្រី ធឿនធួន ម៉ាលីនដា ធឿនធួន ម៉ារីណា ធឿនធួន ម៉ានីកា ដែលបានបកអត្ថបទនេះជាភាសាអង់គ្លេស សុំអរគុណមិត្ត Mr. Marc Baudinet ដែលបានជួយសម្រួលអត្ថបទ។ សូមជម្រាបថា ប្រសិនបើមិនមានមូលនិធិសម្រាប់ធ្វើការពិសោធន៍វិទ្យាសាស្ត្រទេ ការស្រាវជ្រាវអំពីផូស៊ីលអង្ករខ្មៅនេះក៏នៅតែមិនច្បាស់លាស់ដែរ។ ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ ឯកឧត្ដមកិត្តិបរិក្សបណ្ឌិត គាត ឈន់ លោកជំទាវ គាត បុប្ផា បណ្ឌិត ប៉ូល វ៉ាន់ វែលសិន (Dr. Paul Van Velsen) បណ្ឌិត ម៉ៅ ឈាងឡេង លោក ម៉ៅ វុត្ថា លោក ធុយ ចាន់សុទ្ធា លោក ហេ សុខសាយ និងភរិយា ឯកឧត្ដម អ៊ឹម សុធី ឯកឧត្ដម ស៊ិន សុវណ្ណនិ លោកស្រី ស្រី ធារី លោក ឃី សុខូយ លោក ផាន់ ចាន់សី លោក សិរី មុន្នី បណ្ឌិត យែន យ៉ាត ព្រះភិក្ខុ ហ៊្វី សុក្រាត ព្រះភិក្ខុ វ័ន្ធ សុតា៉ លោក ហួត គាង លោក ស៊ឹម សុភក្ត្រា និស្សិតប្រវត្តិវិទ្យាឆ្នាំទី២ (២០១៨-២០១៩) ម្ចាស់អាហារដ្ឋានម៉ាម៉ា (ផ្សារអូរឫស្សី) ប្អូនស្រី វណ្ណៈ គឹមយី និងឯកឧត្ដម លោកជំទាវ លោក លោកស្រី ទាំងអស់ ដែលបានជួយគាំទ្រថវិការជួយដល់ការពិសោធន៍នេះ។ ខ្ញុំសូមថ្លែងអំណរគុណលោកស្រីសាស្ត្រាចារ្យ Cynthia N. Zayas ដែលបានផ្ដល់យោបល់ និងអត្ថបទនានានិយាយដល់ផូស៊ីលអង្ករ។ ខ្ញុំសូមថ្លែងអំណរគុណលោកនាយក និងសហសេវិកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលតែងតែលោកទឹកចិត្តក្នុងការស្រាវជ្រាវសម្ពុបុរៈ។ ជាថ្មីម្ដងទៀតខ្ញុំសូមចែករំលែករបកគំហើញនេះដល់អ្នកស្រាវជ្រាវទាំងអស់សម្រាប់ជាអត្ថបទសិក្សា និងដើម្បីពង្រីកការសិក្សាអំពីស្រូវអង្ករ ដែលបានផលិត ឬដាំដុះនៅអាស៊ីអាគ្នេយ៍ជាភស្តុតាងសិក្សា និងពិភាក្សាបន្តទៀត។

## សេចក្ដីសន្និដ្ឋាន

ប្រទេសកម្ពុជាមានភស្តុតាងផលិត ឬធ្វើកសិកម្មដំណាំស្រូវអង្ករ តាំងពីយុគសម័យថ្មរំលីងដែលយើងមានឃើញភស្តុតាងនៅស្ថានីយបន្ទាយគូ ក្នុងតំបន់ខ្ពង់រាបដីក្រហមខាងកើតទន្លេមេគង្គ។ គ្រាប់ស្រូវត្រូវបានយកមកលាយជាមួយដីឥដ្ឋដុតធ្វើជាក្អមឆ្នាំងសម្រាប់ការប្រើប្រាស់របស់ខ្លួន ដែលយើងបានធ្វើកាលបរិច្ឆេទទៅលើស្ថានីយនោះតាំងពីជាង២០០០ឆ្នាំមុនគ្រិស្តសករាជជាភស្តុតាងដែលយើងអាចនិយាយថាការផលិតស្រូវមានតាំងពីពេលនោះមក។ ការសិតស្រូវ និងភស្តុតាងលើចម្លាក់ប្រាសាទ បានបង្ហាញថាស្រុកខ្មែរយើងមានការផលិតស្រូវច្រើននៅក្នុងសម័យបុរេអង្គរ និងអង្គរ ក្នុងសិលាចារិកក៏បាននិយាយពីអំណោយស្រូវអង្ករផង និងអ្នកធ្វើស្រែដើម្បីផ្គត់ផ្គង់ប្រាសាទព្រមទាំងសង្គមខ្មែរទាំងមូលផងដែរ។ ការសិក្សាស្រាវជ្រាវថ្មីរបស់ខ្ញុំនៅទីក្រុងសម្ពុបុរៈ ក្នុងតំបន់ប្រាសាទព្រះគោ ស្រុក

ជាប់បរិព័ទ្ធ ខេត្តស្ទឹងត្រែង ក្នុងចុងឆ្នាំ២០១៩នេះ បានឃើញផូស៊ីលអង្ករ នៅក្នុងគ្រឹះប្រាសាទដូចបាន អធិប្បាយខាងលើ គឺជាផ្នែកមួយនៃការបូជាដល់សាសនាក្នុងលិទ្ធិព្រហ្មញ្ញ។ ខ្ញុំបានធ្វើការពិសោធន៍ ដើម្បីរកអាយុកាលនៅមន្ទីរពិសោធន៍នៃសាកលវិទ្យាល័យជាតិអូស្ត្រាលី លទ្ធផលនៃការបរិច្ឆេទនេះ បានបង្ហាញថាផូស៊ីលអង្ករខ្មៅនេះមានអាយុកាល៩១៥ $\pm^{២៤}$ នៃគ្រិស្តសករាជ។ ដូច្នេះលទ្ធផលនេះ បញ្ជាក់ថាជាលទ្ធផលពិសោធន៍វិទ្យាសាស្ត្រទៅលើការផលិត ឬការធ្វើកសិកម្មស្រូវអង្ករដំបូងគេបង្អស់ មួយនៅកម្ពុជាយើង។ ខ្មែរយើងអាចជាប្រទេសដែលចេះ ដាំស្រូវ ឬផលិតស្រូវដ៏ចំណាស់មួយនៅក្នុង តំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជាក្នុងពិភពលោក យើងត្រូវសិក្សាស្រាវជ្រាវបន្តទៀត។

## ឯកសារយោង ( Reference )


១/ វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ១៩៦៨

២/ អេង សុត ព្រះរាជពង្សាវតារខ្មែរ/មហាបុរសខ្មែរ, ភាគទី១ដល់ភាគទី៧ចប់ (បោះពុម្ពផ្សាយឡើង វិញតាមច្បាប់ដើម ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ នៃក្រសួងអប់រំ យុវជន និងកីឡា គ.ស ២០០៩ ព.ស ២៥៥៣)

៣/ អាដេម៉ា ឡឺក្លែរ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ប៉ារីស ឆ្នាំ១៩១៤ (ប្រែសម្រួលដោយ ទេព ម៉េងឃាង , ភ្នំពេញ, ២០០៦)។

៤/ The French Presence in Cochinchina and Cambodia: Rule and Response ( 1859-1905 ) by Milton E. Osborne, 1997,. PP 213

៥/ The Ancient Khmer Empire, Lawrence Palmer Briggs, 1999, The American Philosophical Society. Bangkok, Thailand.

៦/ Fonds de la Résidence Supérieure du Cambodge………………

៧/ Adhemard LECLÈRE, History du Cambodge, Paris, 1914.

៨/ Géographie Physique, Économique et Historique du Cambodge, Monographie de la Province de Kratié, Saigon 1908.

៩/ SORN Samnang, Octobre 1995, L´Evolution de la Société Cambodgienne Entre les deux Guerres Mondiales ( 1919-1939 ), These pour le Doctorat d´Histoire, Université Paris VII.

១០/ Zimmermann Maurice, La navigation du Mékong. In: Annales de Géographie, t. 5, n° 20, 1896.pp.250-252.

១១/ The Ancient Khmer Empire, Lawrence Palmer Briggs, 1999

១២/ 1902 Inventaire Descriptif des Monuments du Cambodge par E. Lunet de Lajonquière

១៣/ 1907 Inventaire Descriptif des Monuments du Cambodge par E. Lunet de Lajonquière

១៤/ 1911 Inventaire Descriptif des Monuments du Cambodge par E. Lunet de Lajonquière

១៥/ the ANU Radiocarbon Dating Centre. S.J. Fallon, L.K. Fifield, J.M. Chappell, (2010) d13C values measured on the AMS Australian National University: Status report on the single stage AMS, Nuclear Instruments and Methods in Physics Research B 268 898–901.

១៦/the ANU Radiocarbon Dating Centre. S.J. Fallon, L.K. Fifield, J.M. Chappell, (2010). The quoted age is in radiocarbon years using the Libby half life of 5568 years and following the conventions of Stuiver and Polach (Radiocarbon, v. 19, p.355, 1977).

១៧/ the ANU Radiocarbon Dating Centre. S.J. Fallon, L.K. Fifield, J.M. Chappell, (2010) Radiocarbon concentration is given as F14C and conventional radiocarbon age.

១៨/ the ANU Radiocarbon Dating Centre. S.J. Fallon, L.K. Fifield, J.M. Chappell, (2010)Sample preparation backgrounds have been subtracted, based on measurements of samples of 14C-free CO2.



លោកអនុសេនីយ៍ឯក ឡាយ ហ៊ន នាយផ្នែកឱសថមន្ទីរពេទ្យយោធភូមិភាគទី១របស់ខេត្តស្ទឹងត្រែង និងភរិយាគាត់ឈ្មោះ ថង វិស័យ នៅក្នុងភូមិរាជានុគោល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ២០១៩



ទីតាំងស្ថានីយអង្គរខ្មៅ ២០១៩




ទីតាំងស្រាវជ្រាវផូស៊ីលអង្គរខ្មៅ



ភស្តុតាង អង្គរខ្មៅ ២០១៩ នៅលើទីតាំងស្ថានីយ

# របបមាតាធិបតេយ្យក្នុងសង្គមខ្មែរ

បេក្ខជនបណ្ឌិតៈ **ឈុន ផារ៉េង**
ជំនាញៈ **ទស្សនវិជ្ជា**

## ១.សេចក្តីផ្តើម

ចាប់តាំងពីសម័យដើមនៃប្រវត្តិសាស្ត្ររហូតមកដល់សព្វថ្ងៃនេះ ឥទ្ធិពលនៃព្រលឹងមាតាធិបតេយ្យ បានរស់រវើកនៅក្នុងសង្គមខ្មែរ ទោះបីកាលៈទេសៈខ្លះបានធ្លាក់ចុះឥទ្ធិពលរបស់ខ្លួនក៏ដោយ។ ព្រលឹងមាតាធិបតេយ្យដែលមានក្នុងវប្បធម៌ខ្មែរនិងបន្តអនុវត្តទស្សនៈយេនឌ័រ ដែលតែងតែអប់រំបុរសស្ត្រី ឱ្យទទួលយកតួនាទីភារកិច្ចជាគ្រួសារល្អ ញាតិមិត្តល្អ និងពលរដ្ឋល្អ ។

ប្រជារាស្ត្រខ្មែរ ចាត់ទុកព្រលឹងមាតាធិបតេយ្យជារបៀបរៀបរយមួយនាំឱ្យសុខចម្រើន ព្រមទាំងនាំគ្នាខំជួយថែរក្សាការពារ ដោយប្រតិបត្តិតាមជំនឿទំនៀមទម្លាប់ប្រពៃណី អក្សរសាស្ត្រ វប្បធម៌ និងសង្គមធម៌ជាដើម។ ទន្ទឹមនេះដែរ របបបិតាតេយ្យនិងទស្សនៈយេនឌ័រ ក៏បាននឹងកំពុងផ្សព្វផ្សាយយ៉ាងសកម្មក្នុងជីវភាពរស់នៅក្នុងសង្គមខ្មែរតាំងពីអតីកាលរហូតដល់បច្ចុប្បន្នដែរដោយទស្សនៈជំនឿនៃជនអន្តោប្រវេសន៍ និងឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយនានា។ លទ្ធិទាំងពីរក្រោយនេះបានត្រូវប្រតិបត្តិដោយជនបរទេសដែលមានវប្បធម៌ផ្អែកលើគំនិតសាសនាខុសពីវប្បធម៌ខ្មែរ។ ប្រឈមនឹងឥទ្ធិពលបិតាតេយ្យ និង យេនឌ័រ តើរបបមាតាធិបតេយ្យខ្មែរមានជំហរដូចម្តេច? អត្ថបទនេះនឹងបង្ហាញអំពី អត្ថន័យ, ប្រវត្តិ, និង ឥទ្ធិពលនៃរបបមាតាធិបតយ្យខ្មែរ តាមរយៈវប្បធម៌ និងសង្គមធម៌ខ្មែរ ដូចខាងក្រោមៈ

## ២. និយមន័យរបបមាតាធិបតេយ្យ

របបមាតាធិបតេយ្យចេញមកពីពាក្យៈ

របប (ន.) របៀបរៀបរយ, សណ្តាប់ធ្នាប់ ។
មាតា (អានថា មាដា) បា.; សំ. (ន.) (< មាតុ,) ម្តាយ, ម៉ែ, មេ ,
អធិបតេយ្យ (អានថា អៈធិប៉ៈតៃ) បា.(ន.) អធិបតីភាព, "ភាវៈនៃ...ជាអធិបតី" ឬ ភាពជាអ្នកធំ ឬភាពជាម្ចាស់ ឬភាពជាឥស្សរជន។

របបមាតាធិបតេយ្យមានន័យថា របៀបរៀបរយដែលកំណត់យកភាពនៃម្តាយជាធំលើសគេ។ និយាយដោយខ្លីថា របៀបដែលចាត់ទុកមេជាធំ ឬថា លទ្ធិដែលចាត់ទុកស្ត្រីជាធំ ជាអ្នកដឹកនាំ ជាមេ។

*មាតាធិបតេយ្យមានន័យថា មាតាអធិបតី ភាពនៃម្តាយជាធំ ម្ចាស់លើគេ ជាប្រមុខ ជាប្រធាន។ ក្នុងន័យទូលាយមាតាធិបតេយ្យ ជារបបមួយដែលឱ្យតម្លៃទៅលើម្តាយក្នុងការដឹកនាំគ្រួសារ សង្គមទាំងមូល។ ជួនកាល គេនិយមប្រើពាក្យមេដែលមានន័យថា យកមេជាធំក្នុងគ្រួសារនិងសង្គម*[១]។

---

[១] ក្រសួងអប់រំយុវជននិងកីឡា, *សិក្សាសង្គមថ្នាក់ទី១០*, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, បោះពុម្ពទី៦ ឆ្នាំ២០១៥, ភ្នំពេញ, ទំព័រ ២៣៩

## ៣. អត្ថន័យនៃពាក្យ មេ

ពាក្យ មេ នៅក្នុងវប្បធម៌ខ្មែរបានក្លាយជាន័យពិសេសសម្រាប់អ្នកដែលមាននាទីសំខាន់ក្នុងការគ្រប់គ្រងក្នុងផ្ទះ ក្នុងសហគមន៍ ក្នុងប្រទេស ដែលហៅថា មេដឹកនាំ។ លើសពីនេះ មេ សម្គាល់លើមនុស្ស សត្វ ឬអ្វីដែលជាធំ ជាប្រធាន ជាចម្បងលើគេ ដូចជា មេកង មេពួក មេការ មេកោយ មេផ្ទះ មេវត្ត មេក្រុម ឬមេគណ មេទ័ព មេទាហាន មេព្រៃ មេខ្លោង មេចង្ក្រាន់ មេចោរ មេជើង មេដែក មេដៃ មេដំបូល មេទឹក មេបទ មេបន្ទុក មេពាក្យ មេលេខ មេសូត្រ។ល។ [២]

លើសពីនេះ ពាក្យ ថា មេ ឃើញមាននៅតាមលំដាប់ឋានានុក្រមដូចជា មេ បា តា ព្រះ ចៅ ដែលជាទស្សនវិជ្ជាខ្មែរស្តីអំពីគោលគំនិតស្តីពីចេនាសម្ព័ន្ធគ្រប់គ្រងសង្គម ដែលបញ្ជាក់ថា ខ្មែរនិយមគោរព មេ (មាតា ម្តាយ ម៉ែ) ជាចម្បងបំផុត។

## ៤.អត្ថន័យនៃមាតាធិបតេយ្យក្នុងសង្គមខ្មែរ

វប្បធម៌ខ្មែរគោរពរបបមាតាធិបតេយ្យ ពោលគឺលើកតម្លៃរបបមេជាធំ [៣]។ មេ ឬម៉ែ ឬមាតា ឬមាតុ ឬម្តាយ មានន័យថា ស្ត្រីអ្នកបង្កើតកូន។ មេជាអ្នកបង្កើតកូនពូនជាចៅ មាននាទីដឹកនាំពូជពង្សវង្សត្រកូល ជាធម្មតាមានឥទ្ធិពលខ្លាំងច្រើនជាងបិតា(ឪពុកឬបា)។

ក្នុងនាមជាភរិយាល្អរបស់ស្វាមី និងជាមាតាល្អរបស់បុត្រ ស្ត្រីមាននាទីទទួលខុសត្រូវខ្ពស់ចំពោះគ្រួសារ។ ទស្សនៈ ក្រមុំដណ្តឹងម្តាយមេម៉ាយដណ្តឹងចិត្ត មានន័យថាមាតាមានសិទ្ធិអំណាចខ្ពស់ក្នុងការសម្រេចស្ទើរគ្រប់កិច្ចការទាំងអស់ ជាពិសេសរឿងទុកដាក់កូនចៅក្នុងបន្ទុកឱ្យមានគូស្រករ។ នៅពេលកូនស្រីចេះដឹងខុសត្រូវហើយ ទើបម្តាយបានផ្តល់នូវសេរីភាពពេញលេញដល់កូនក្នុងការសម្រេចជោគវាសនាអនាគតរបស់ខ្លួនដោយខ្លួនឯង។ ពាក្យស្លោកថា សូវស្លាប់បាកុំឱ្យស្លាប់មេ សូវលិចទូកកណ្តាលទន្លេកុំឱ្យតែភ្លើងឆេះផ្ទះ កាន់តែបញ្ជាក់ថា មេ(ឬម៉ែ) មានភាពឆ្លាត ពូកែ និងដើរតួនាទីសំខាន់ក្នុងការចិញ្ចឹមបីបាច់កូនបានល្អជាងឪពុក ព្រោះខ្មែរជឿជាក់ថា សម្លឆ្ងាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយសារភរិយាជា។ ស្ត្រីខ្មែរដើរតួនាទីជាមេគ្រួសារ មានតម្លៃជាមាតុភរិយា(ប្រពន្ធមាននាទីទុកស្មើម្តាយ)។ ភាគច្រើនប្តីមាននាទីធ្វើការរកលុយ ចំណែកប្រពន្ធមាននាទីជាអ្នកចាត់ចែងទុកដាក់លុយកាក់ទាំងនោះ។ ពេលរៀបអាពាហ៍ពិពាហ៍ខ្មែរបានរៀបចំពិធីមួយហៅថា ព្រះថោងតោងស្បៃនាងនាគ ដែលជាទស្សនវិជ្ជាសង្គមមួយសំខាន់ចង់ឱ្យបុរសជាប្តីត្រូវតែចេះស្តាប់មតិយោបល់ប្រពន្ធ មិនត្រូវរឹងរូសតវ៉ាប្រឆាំងប្រកែងប្រកាងដោយខ្វះហេតុផលនោះឡើយ។ ភស្តុតាងខ្លះទៀតដែលបង្ហាញរបបមេជាធំ(ឬមាតាធិបតេយ្យ) មានដូចតទៅ៖ នាងគង្ហីង (មេ) និងក្រពើ(បា)ដែលជានិមិត្តរូបតំណាងឥទ្ធិពលធាតុស្រីនិងប្រុសរួមសាមគ្គីគ្នា និងរឿងភ្នំស្រីភ្នំប្រុសដែលជារឿងនិទានបែបប្រវត្តិសាស្ត្រខ្មែរក្នុងការលើកកម្ពស់ឥទ្ធិពលនិងភាពវៃឆ្លាតរបស់ស្ត្រី។ល។

---

[២] សូមមើល ជួនណាត *វចនានុក្រមខ្មែរ ភាគ១ ភាគ២* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧ ទំព័រ៥៦៥-៥៦៧

[៣] របបមេជាធំ ឬរបបមាតាធិបតេយ្យ (អ. Matriachal regime / បារ. Régime Matriacal) កម្រមាននៅប្រទេសដទៃក្រៅពីនៅខ្មែរណាស់

## ៥. ប្រវត្តិនៃរបបមាតាធិបតេយ្យខ្មែរ

មានកត្តាជាច្រើនដែលជម្រុញខ្មែរប្រកាន់របបមាតាធិបតេយ្យ។ ខ្មែរបានប្រកាន់យករបបមាតាធិបតេយ្យ តាំងពីសម័យបុរេប្រវត្តិប្រវត្តិសាស្ត្រមកម្ល៉េះ គឺឆ្លងកាត់សម័យកាលគោកធ្លក អាណាចក្រហ្វូណន(ឬនគរភ្នំ) អាណាចក្រចេនឡា អាណាចក្រអង្គរ មកដល់បច្ចុប្បន្ន។ ស្តេចសោយរាជ្យនៅសម័យគោកធ្លក គឺនាងនាគ (ព្រះនាងសោមា ឬ លីវយី)។ តាមធម្មតា ព្រះរាជាខ្មែរ ដែលត្រូវឡើងសោយរាជ្យ ត្រូវជ្រើសរើសឡើងតាមរយៈការស្នងរាជ្យពីបិតាទៅបុត្រាជាដើម ប៉ុន្តែក្នុងករណីខ្លះ បុរសមានឥទ្ធិពលអំណាចគ្រប់គ្រងដោយសារតែស្ត្រី ឧទាហរណ៍ ប្រសិនបើស្តេចមានតែបុត្រី នោះបុត្រសុណិសា(កូនប្រសាប្រុស)មានតួនាទីជាអ្នកសោយរាជ្យ។

ស្ត្រីមានថាមពលអាចកំបាំងក្នុងការជួយបុរសឱ្យបំពេញការងារធំៗឱ្យសម្រេចជោគជ័យ ហេតុនេះទើបព្រះរាជា ត្រូវមានអគ្គមហេសីដែលអាចជួយប្រឹក្សាយោបល់បន្ធូរអារម្មណ៍និងជំនួយកិច្ចការផ្សេងៗ។ ធម្មតាបុរសអាងកម្លាំង ចេញបរបាញ់ នេសាទ ធ្វើការធ្ងន់ និងជាអ្នកការពារ ចំណែកស្ត្រីនៅចាំផ្ទះមើលថែខ្លួន កូនចៅ ទ្រព្យ ដំណាំ។ល។ ដំណើរយល់ដឹងពីធម្មជាតិ នៃសម្ព័ន្ធភាពជីវិតបុរសនិងស្ត្រីតាមបែបជីវសាស្ត្រ គឺជាដំណើរប្រវត្តិសាស្ត្រធម្មជាតិដែលមនុស្សជាតិតំបន់សុវណ្ណភូមិមានតាំងពីសម័យបុព្វកាលមកម្ល៉េះ។ ការទទួលស្គាល់កម្រិតខ្ពស់អំពីតម្លៃស្ត្រីគឺជាទស្សនវិជ្ជាសង្គមនិងនយោបាយពិសេសមួយរបស់ខ្មែរ។

## ៦.ព្រលឹងមាតាធិបតេយ្យក្នុងវប្បធម៌ខ្មែរ

តាមរយៈអរិយធម៌ខ្មែរ ឃើញថា សង្គមខ្មែរបានរក្សាជំនឿលើ មាតាធិបតេយ្យ ដោយឱ្យតម្លៃស្ត្រីពីរយ៉ាងគឺ៖ ស្ត្រីជាធំនិងស្ត្រីជាមង្គល។ ស្ត្រីជាធំ ជាប្រមុខ ជាអ្នកដឹកនាំ ជាមេគំនិតក្នុងការចូលរួមដោះស្រាយបញ្ហាផ្សេងៗនៅក្នុងគ្រួសារនិងនៅក្នុងសង្គមចាប់តាំងពីការកកើតទឹកដីខ្មែរដំបូងម្ល៉េះ។ ស្ត្រីមានអំណាចលើប្តីនិងលើកូន មានន័យថា ស្ត្រីអាចជាអ្នកដឹកនាំគ្រួសារឱ្យសម្រេចគោលដៅក្នុងគ្រួសារ។ បច្ចុប្បន្ន ស្ត្រីកាន់តែមានចំនួនច្រើនឡើងៗដែលកំពុងតែចូលរួមនៅក្នុងសកម្មភាព សេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយនៅក្នុងសង្គម ហើយស្ត្រីនៅរក្សាបានអំណាចរបស់ខ្លួនក្នុងគ្រួសារទៀតដូចជា ការសម្រេចកិច្ចការផ្សេងៗនៅក្នុងផ្ទះ និងក្នុងសង្គម។

ស្ត្រីជា មង្គលផ្តល់សិរីសួស្តី ជោគជ័យដល់គ្រួសារនិងសង្គមថែមទៀតផង ដូចពាក្យស្លោកបានពោលថា សំណាបយោងដីស្រីយោងប្រុស និងស៊ូស្លាប់បាកុំឱ្យស្លាប់មេ[៤]។ អំណាចនិងមង្គលទាំងនេះវាជាលទ្ធផលនៃការចូលរួមផ្តល់តម្លៃពីសំណាក់ស្ត្រីគ្នាឯងនិងជាពិសេសភាគីបុរស។

តម្លៃស្ត្រីតាមរយៈទំនៀមទម្លាប់ប្រពៃណី មានដូចជា ក្នុងពិធីឡើងផ្ទះ ពិធីសែនមេបា ពិធីចូលម្លប់និងពេលមានគភ៌ឆ្លងទន្លេជាដើម។ តាមទំនៀមទម្លាប់ នៅពេលសង់ផ្ទះថ្មី ស្ត្រីត្រូវបានប្រគល់ភារកិច្ចត្រឹមតែការងារស្រាល ដូចជាចាត់ចែងទិញសម្ភារៈ រៀបចំចម្អិនម្ហូបអាហារ គឺហាមប្រាមមិនឱ្យម្ចាស់ផ្ទះស្រីធ្វើការ

---

[៤] ក្រសួងអប់រំយុវជននិងកីឡា, *សិក្សាសង្គមថ្នាក់ទី១០*, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, បោះពុម្ពទី៦ ឆ្នាំ២០១៥, ភ្នំពេញ, ទំព័រ២៣៩

ក្នុងការងារសំណង់ដូចជាលីសែង ដើរចុះឡើងក្បែរបរិវេណសំណង់ឡើយ ប៉ុន្តែនៅពេលរៀបចំពិធីឡើងផ្ទះដើម្បីសិរីសួស្តី គេអញ្ជើញមនុស្សស្រីឱ្យចូលផ្ទះមុនគេ។

ចំណែកផ្នែកជំនឿវិញខ្មែរ បានច្នៃរូបសំណាកអ្នកតាឱ្យទៅជានិមិត្តរូបទេវៈដែលមានស្នាដៃការពារទឹកដី ដូចជា មេ-ស[៥] នៅបាភ្នំ ដែលមានរូបរាងជាព្រះនាង ឧមា មហេសីព្រះឥសូរ ជាដើម។ លើសពីនេះខ្មែរបុរាណបានជឿលើព្រលឹងមេបា។ ប្រសិនបើកូនចៅណាដែលប្រព្រឹត្តខុសពីសីលធម៌របស់មេបា នោះព្រលឹងមេបានឹងខឹងសម្បារនិងតាមមកកាច់ដាក់ទារុណកម្មឱ្យឈឺដល់សមាជិកគ្រួសារណាមួយ ដើម្បីឱ្យតាមស្រាវជ្រាវរាវរកអ្នកដែលបានប្រព្រឹត្តកំហុសនោះ។ ក្រៅពីនេះខ្មែរនៅជឿពីការបួងសួងបន់ស្រន់អង្វរករឱ្យអ្នកតា ឱ្យខមាទោស និង ជួយឱ្យគេបានសុខចម្រើនផងដែរ ដូចជាបន់សូមឱ្យយាយម៉ៅ និង យាយយ៉ាតជួយតាមថែរក្សាជាដើម។ យាយម៉ៅជាវីរៈនារីក្នុងទេវកថាពីបុរាណដ៏ពេញនិយមរបស់ប្រជាជនខ្មែរ ដែលនិទានអំពីស្ត្រីមានភក្តីទន្ទឹងចាំស្វាមីឯនាយសមុទ្រនៅទិសខាងលិច ត្រូវបានគេគោរពបូជា ធ្វើសក្ការៈនៅតាមតំបន់ឆ្នេរសមុទ្រ ឬច្រាំងសមុទ្រ ក៏ដូចជានៅចន្លោះផ្លូវពីក្រុងភ្នំពេញទៅក្រុងកំពង់ផែ ព្រះសីហនុ កំពតនិងក្រុងកែប ជាដើម។ ចំណែកយាយយ៉ាត ជាអ្នកល្បីពូកែនៅប៉ៃលិន មានបារមីថែរក្សាទឹកដីត្បូងពេជ្រឱ្យទទួលបានតែសេចក្តីសុខ និងចម្រុងចម្រើន ។ល។

## ៧. ជំហរមាតាធិបតេយ្យ និង ឥទ្ធិពលបិតាធិបតេយ្យក្នុងសង្គមខ្មែរ

សង្គមខ្មែរក៏ដូចសង្គមនានាដែរតែងមានរចនាសម្ព័ន្ធ៣គឺ៖ ក្រុមគ្រួសារ ក្រុមញាតិមិត្ត ក្រុមការងារ។ យើងអាចសង្កេតជំហរមាតាធិបតេយ្យខ្មែរ នៅក្នុងសង្គមខ្មែរតាមរយៈរចនាសម្ព័ន្ធក្រុមទាំងនេះដូចតទៅ៖

### ៧.១.ជំហរមាតាធិបតេយ្យខ្មែរក្រុមគ្រួសារ

នៅកម្ពុជាសម័យបុរាណ ស្ត្រីអាចយកប្តីច្រើនក្នុងពេលតែមួយ។ សម័យនគរភ្នំ ស្ត្រីត្រូវទៅដណ្តឹងប្រុស[៦] តែចាប់ពីសម័យចេនឡាមក ប្រុសៗត្រូវទៅដណ្តឹងស្រី ហើយតាមសិលាចារឹកឱ្យដឹងថាគេនិយមរាប់ញាតិដោយយកខ្សែតាមម្តាយ[៧]។

សម័យបុរាណជាធម្មតា មុននឹងសម្រេចផ្សំផ្គុំ ទុកដាក់កូនចៅឱ្យមានគូស្រករ ឪពុកម្តាយឬអាណាព្យាបាលបានប្រើប្រាស់តួនាទីរបស់ខ្លួន ដើម្បីជ្រើសរើសយ៉ាងសម្រិតសម្រាំងរកកូនប្រសារប្រុសឬស្រីរបស់ខ្លួនដោយហ្មត់ចត់បំផុត[៨] ដោយប្រើសុភាសិតថា ធ្វើស្រែឱ្យមើលស្មៅ ទុកដាក់កូនចៅមើលផៅសន្តាន[៩]។

---

[៥] មេ-ស (អានថា មេ-ស) ( ន. ) បិសាចស្រី, យាយទេព, អ្នកតាស្រី :ដូចជា មេ-សជ្រៃ, មេ-សប្រចណ្ឌ ។ល។

[៦] ត្រឹង ងា ១៩៧៣, *ប្រវត្តិសាស្ត្រខ្មែរ* ទំព័រ ៩៨

[៧] ត្រឹង ងា ១៩៧៣, *ប្រវត្តិសាស្ត្រខ្មែរ* ទំព័រ ១២៦

[៨] អង្គការទិន្នន័យអំពីអភិវឌ្ឍ, ប្រជាជន និង ជំរឿន ២០១៥ https://opendevelopmentcambodia.net/km/topics/population-and-censuses/

[៩] អ៊ុក ជា *លោកនីតិបករណ៍*, ១៩៥៣ http://5000year.space/0datacenter/book/28072017/ពុទ្ធសាសនា/លោករណ៏.pdf

ឪពុកម្ដាយមានតួនាទី ហាមឃាត់កូនចាកអំពើអាក្រក់ ឱ្យកូនតម្កល់នៅក្នុងអំពើល្អ ឱ្យកូនរៀនសូត្រសិល្បសាស្ត្រ ដណ្ដឹងភរិយាស្វាមីសមគួរឱ្យ ចែកទ្រព្យឱ្យកូនក្នុងសម័យគួរ[១០] មុនសម្រេចថាឱ្យរៀបការជាប្ដីប្រពន្ធ គេត្រូវអង្កេតមើលកិរិយាមាយាទ សម្ដីសំដៅ ចិត្តគំនិត តាមរយៈការពិនិត្យជាក់ស្ដែងទៅលើសាមីជនផ្ទាល់ ស៊ើបសួរចាស់ទុំជិតខាង និងរហូតដល់ទៅរកគ្រូទាយធ្វើការគន់គូរលេខអត្ថៈ ដើម្បីឱ្យប្រាកដថាអ្នកទាំងពីរនាក់ កូនកម្លោះនិងកូនក្រមុំ ជាគូព្រេងនឹងគ្នាពិតប្រាកដ ចៀសវាងគូកម្ម ទើបអាចអនុញ្ញាតឱ្យរៀបការបាន។

ទ្រឹស្តីនំមិនធំជាងនាឡី ដែលជាអន្តរាគមន៍របស់ម្ដាយឪពុកចំពោះជីវិតគ្រួសារគូស្រករលើកូនដោយអំណាចមេបាខ្លាំងដោយមិនបានផ្ដល់សិទ្ធិដល់កូនត្រូវបានយកមកប្រើ។ មុននឹងសម្រេចថាឱ្យរៀបការជាមួយកូនស្រីខ្លួន កូនកម្លោះត្រូវទៅនៅបម្រើខាងស្រីដើម្បីឱ្យឪពុកម្ដាយខាងស្រីដឹងច្បាស់ពីអត្តចរិកជាមុនសិន។ លុះកាលៈទេសៈក្រោយមក ការទៅនៅបម្រើក៏ត្រូវកាត់បន្ថយដោយសារការវិវត្តនៃវិស័យការងារ និងរបៀបរស់នៅ។ ទោះយ៉ាងនេះក្ដី ក៏ចាស់ទុំនៅរក្សាអំណាចរបស់ខ្លួន ដោយពោលថា ក្រមុំដណ្ដឹងម្ដាយ ម៉េម៉ាយដណ្ដឹងចិត្ត ។

សម័យសង្គមរាស្ត្រនិយម របបមាតាធិបតេយ្យ មានភាពអាប់អួរ ដោយច្បាប់រដ្ឋប្បវេណីអនុញ្ញាតឱ្យស្ត្រីយកប្ដីបានតែមួយនាក់ខណៈដែលបុរសអាចយកប្រពន្ធបានច្រើននាក់ ក្នុងពេលតែមួយ ហើយកំណត់ឱ្យប្រពន្ធទាំងឡាយត្រូវទទួលស្ដាប់ឱវាទប្ដី ត្រូវឱនលំទោន ហើយស្លូតត្រង់នឹងប្ដីផង ចំណែកប្ដីត្រូវទំនុកបម្រុងប្រពន្ធទាំងឡាយឱ្យចាយវាយតាមសមគួរដល់មុខរបរនិងធនធានដែលខ្លួនមាន[១១] ។ ស្ត្រី ខំតស៊ូខាំមាត់សង្កត់ចិត្ត ទ្រាំទ្រការលំបាកសព្វបែបយ៉ាង តាមទស្សនៈស៊ូលំបាកផ្លូវកាយ កុំឱ្យតែលំបាកផ្លូវចិត្ត។ ស្ត្រីខ្មែរខ្លាចណាស់ការរិះគន់ពីញាតិជិតឆ្ងាយ, ខ្លាចណាស់ពាក្យថាមេម៉ាយ ព្រោះមេម៉ាយចាយមាត់ញាតិ ជាពិសេសមេម៉ាយប្ដីលែង និងមេម៉ាយលែងប្ដី។

ក្នុងសម័យខ្មែរក្រហមយុវជនយុវនារីខ្មែរជាច្រើនម៉ឺននាក់ ត្រូវបានអង្គការខ្មែរក្រហមចាប់បង្ខំឱ្យយកគ្នាជាប្ដីប្រពន្ធ ដោយមិនបានរៀបការតាមប្រពៃណីខ្មែរ ដែលមានតាំងពីដូនតាយូរលង់ណាស់មកហើយនោះទេ។ ពិធីរៀបការតាមរបបនយោបាយកុម្មុយនីស្តបែបលទ្ធិម៉ៅនិយមបានឱ្យស្ត្រីបុរសរៀបការដោយបង្ខំ ហើយម្ដងៗមានចំនួនមនុស្សចាប់ពី ២០គូ ដល់ ១០០គូ។ អង្គការខ្មែរក្រហមមិនអនុញ្ញាតឱ្យកូនកំលោះក្រមុំស្មគ្រចិត្តរើសគូប្រចាំជីវិតដោយខ្លួនឯងទេ គឺអង្គការផ្គូផ្គងគូស្រករដែលពួកគេមិនដែលស្គាល់គ្នា ឬក៏មិនបានស្រឡាញ់គ្នា ហើយបើអ្នកណាម្នាក់ហ៊ានប្រកែក អង្គការចាត់ទុកថាជាខ្មាំងដែលប្រឆាំងបដិវត្ត ហើយត្រូវបានកងឈ្លបចាប់ចងស្លាបសេកយកទៅសម្លាប់ចោល។ ខណៈនេះស្ត្រីរងគ្រោះថ្នាក់ជាងបុរស ព្រោះអង្គការពិនិត្យតាមដានយ៉ាងហ្មត់ចត់ បន្ទាប់ពីបានផ្សំផ្គុំរួច ។

---

[១០] ព្រះត្រៃបិដក សិង្គាលកសូត្រ ខ.៧០ https://5000-years.org/kh/read/275។

[១១] រដ្ឋសភា, ១៩៦៧, *ក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧* មាត្រា១៤០, ១៤១, ១៨៧, និង១៩៣ http://cdslawcambodia.com/wp-content/uploads/2018/12/ក្រមរដ្ឋប្បវេណី-១៩៦៧.pdf

នៅឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យ បានដួលរលំ ប្តីប្រពន្ធដែលខ្មែរក្រហមបានផ្សំផ្គុំភាគច្រើន ក៏បានលែងលះគ្នាផងដែរ ហើយសិទ្ធិសេរីភាពនៃជំនឿ មនោសញ្ចេតនាស្នេហា ដែលអង្គការខ្មែរក្រហមបានបំបិទសិទ្ធិជាង ៣ឆ្នាំមកហើយនោះ ក៏បានកើតមាននៅក្នុងអារម្មណ៍របស់ពលរដ្ឋខ្មែរយើងផងដែរ។ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ដូច រដ្ឋកម្ពុជា បានផ្តល់សិទ្ធិស្មើគ្នាដល់បុរសនិងស្ត្រី ដូចប្រទេសជឿនលឿន នានាដែរ ដោយរៀបចំចែកច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ ដើម្បីគ្រួសារមានសុភមង្គល ដោយចែងឱ្យមានប្តីមួយប្រពន្ធមួយ ប៉ុណ្ណោះ[១២]។

បច្ចុប្បន្ន ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ដោយត្រូវមានការចុះបញ្ជីអាពាហ៍ពិពាហ៍ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ[១៣] ស្រាប់។ ច្បាប់មានការហាមឃាត់មិនឱ្យមានទ្វេពន្ធភាពឡើយ។ បុគ្គលដែលជាសហព័ទ្ធ(មានប្តីឬប្រពន្ធហើយ) ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀត បានឡើយ[១៤]។ បច្ចុប្បន្នទោះបីមានគ្រួសារមួយចំនួនជ្រើសរើសគូស្រករតាមអំណាចម្តាយឪពុកក៏ដោយ ក៏សាមីខ្លួនភាគច្រើន ក៏បានធ្វើការសម្រេចចិត្តដោយខ្លួនគេផ្ទាល់ក្នុងការជ្រើសរើសគូអនាគតដែរ[១៥]។

ស្ថិតនៅក្នុងរចនាសម្ព័ន្ធគ្រួសារ ស្ត្រីដើរតួជាមេផ្ទះដឹកនាំផ្ទះសម្លៀងមើលថែទាំប្តីនិងកូន។ បើប្តីមានតួនាទីខ្ពស់នៅក្នុងក្រុមការងារ ប្រពន្ធនៅផ្ទះក៏ឡើងបុណ្យតាមនោះដែរ។ បើប្តីសក្តិ៤នៅក្នុងក្រុមការងារនោះប្រពន្ធសក្តិ៥នៅផ្ទះ ឬបើប្តីជាឯកឧត្តមក្នុងក្រុមការងារ នោះប្រពន្ធក្លាយជាជំទាវក្នុងក្រុមគ្រួសារ។ បុរសច្រើនស្លាប់រស់ក្រោមកន្ទុយក្បិន ហើយជាទូទៅញាតិមិត្តខាងម្តាយមានភាពស្និទ្ធស្នាលជាងសាច់ញាតិខាងឪពុក។ រូបភាពអំពើហិង្សាក្នុងគ្រួសារ រួមមានហិង្សាសេដ្ឋកិច្ច ហិង្សាភេទ ហិង្សាពាក្យសំដី ហិង្សារូបកាយ និងរូបភាពហិង្សាខ្លះទៀតទៅលើស្ត្រី នៅពេលបុរសជាប្តីមិនបានយល់ដឹងនិងប្រតិបត្តិតាមគោលការណ៍មាតាធិបតេយ្យរបស់ខ្មែរ។ ប្តីកាន់លុយ(ប្តីមិនប្រគល់តួនាទីឱ្យប្រពន្ធមានសិទ្ធិគ្រប់គ្រងចំណូលចំណាយ) គឺជារូបភាពនៃហិង្សាសេដ្ឋកិច្ចមួយក្នុងសង្គមខ្មែរ។ ទោះយ៉ាងណាក៏ដោយ ក៏ស្ត្រីដែលឆ្លាតមានសមត្ថភាពយល់ដឹងពីអត្តចរិកប្តី អាចដោះស្រាយស្ថានភាពទាំងនេះបាន តាមរយៈទស្សនវិជ្ជា ទន់បង្ក្រាបរឹង ឬទន់ភ្លន់មិនទន់ជ្រាយ រឹងប៉ឹងមិនរឹងទទឹង។ តាមវប្បធម៌ខ្មែរ(ដូចមានចែងក្នុងច្បាប់ស្រី ឬបណ្តាំក្រមង៉ុយជាដើម) បានបង្រៀនស្ត្រីខ្មែរឱ្យមានចរិយាសម្បត្តិសុភាពរៀបសារ ទន់ភ្លន់ រួសរាយរាក់ទាក់ប្រកបដោយភាពថ្លៃថ្នូរ។ ខ្មែរយល់ថា សម្លឆ្ងាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយភរិយាជា។ ប៉ុន្តែក៏មានស្ត្រីខ្លះខ្វះ

---

[១២] រដ្ឋសភា, *ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ* ១៩៨៩ មាត្រា៣

[១៣] រដ្ឋសភា, *ច្បាប់ស្តីពី ឯកព័ន្ធភាព* ២០០៦ មាត្រា២

[១៤] រដ្ឋសភា, ច្បាប់ស្តីពីក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៩

[១៥] UNHR K, ១៩៤៨ សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធមនុស្ស, ឆ្នាំ១៩៤៨ មាត្រា ១៦។ https://www.ohchr.org/sites/default/files/UDHR/Documents/UDHR_Translations/khm.pdf

លក្ខណៈ(ស្រីខាតលក្ខណ៍) មានចរិយាសម្បទាមិនគ្រប់គ្រាន់ស្របតាមគោលការណ៍មាតាធិបតេយ្យរបស់ខ្មែរដែរ ដែលជាហេតុនាំឱ្យមានការវាយតម្លៃទាបលើមាតាធិបតេយ្យ។

## ៧.២.ជំហរមាតាធិបតេយ្យខ្មែរក្នុងទំនាក់ទំនងញាតិមិត្ត

តាមចិត្តសាស្ត្រគេសង្កេតឃើញថា ស្ត្រីមានឥទ្ធិពលទំនាក់ទំនងប្រសើរជាងបុរស។ ទំនាក់ទំនងរវាងស្ត្រីមេផ្ទះនិងស្ត្រីមេផ្ទះមានភាពស្និទ្ធស្នាលនិងចាំបាច់ជាងទំនាក់ទំនងបុរសជាប្តីនិងបុរសដទៃ។ ដោយសារតែស្ត្រីពូកែឈានមុខខាងទំនាក់ទំនង ជាហេតុនាំឱ្យបុរសភាគច្រើនបានយកស្ត្រីធ្វើជាប្រមុខ អាងតែស្រីព្រោះស្ត្រីពូកែដោះស្រាយ ឬចរចារដោយសន្តិវិធីបានល្អជាងបុរស។ ស្ត្រីខ្មែរអាចចេះដឹងពីការរីករាយរាក់ទាក់រាប់អានគ្នាដោយមិនរើសអើងដោយសារមរតកវប្បធម៌របស់ខ្លួន។ ស្ត្រីខ្មែរមានទម្លាប់ចូលចិត្តរាប់អានសាច់ញាតិ មិត្តភ័ក្តិ ពូជពង្សវង្សត្រកូល ប្រកបដោយមនោសញ្ចេតនាដ៏ជ្រាលជ្រៅបំផុត ប៉ុន្តែក៏ចិត្តដាច់ណាស់ដែរប្រសិនបើនរណាម្នាក់ធ្វើឱ្យខកបំណងឬខូចចិត្ត។ គេពោលថា *សូមឱ្យមានកម្លាំងដូចស្រមោច មានរិទ្ធិដូចខ្មោច មានចិត្តដូចមនុស្សស្រី*[១៦] ព្រោះស្ត្រីចិត្តដាច់ជាងបុរស(សម្រេចចិត្តឆាប់និងច្បាស់លាស់) ក្នុងការទំនាក់ទំនង គឺឆាប់ឈ្លោះហើយក៏ឆាប់ជានាត្រូវរ៉ូវគ្នាវិញដែរ។ ជាទូទៅស្ត្រីខ្មែរចូលចិត្តរក្សាញាតិច្រើនជាងការបង្កើនសត្រូវ។ ទៅដល់ទីណាចូលចិត្តជជែកពិភាក្សារៀបរាប់បូរបាច់ពីនេះពីនោះ ដែលជួនកាលជជែកខ្វែងគំនិតគ្នាខ្លះរហូតមានជម្លោះ ទំនាស់ខ្លះ ប៉ុន្តែក៏ឆាប់សះជាគ្នាវិញដែរ បើប្រៀបនឹងបុរស។

## ៧.៣.ជំហរមាតាធិបតេយ្យខ្មែរក្នុងវិស័យការងារ

ទស្សនៈស្តីពី មេនិយម មានតាំងពីសម័យនគរភ្នំរហូតដល់បច្ចុប្បន្ន។ ស្ត្រីមានតួនាទីសំខាន់នៅក្នុងសង្គមខ្មែរហើយត្រូវបានគេលើកតម្កើងទុកជាមេដឹកនាំ, ស្ត្រីអាចឡើងសោយរាជ្យជាមហាក្សត្រិយានី ជាកវី ជាអ្នកនិពន្ធ ជាអ្នកដឹកនាំការងារ ជាអ្នកទទួលខុសត្រូវក្នុងផ្ទះ(មេផ្ទះ)ជាដើម។ នៅសម័យនគរភ្នំ(ហ្វូណន) ព្រះនាងលីវយីជារាជនី សម័យអង្គរព្រះនាងឥន្ទ្រទេវីជាអ្នកនិពន្ធ ជាសកលវិទ្យាធិការិនីនៃសកលវិទ្យាល័យជ័យស្រី ជាដើម។ រឿងភ្នំប្រុសភ្នំស្រីបានបង្ហាញឱ្យឃើញពីសមត្ថភាព ការឈ្លាសវៃ និងល្បិចរបស់នារីដែលអាចដណ្តើមយកជោគជ័យក្នុងការពូនភ្នំ ។

បច្ចុប្បន្ន ស្ត្រីត្រូវបានលើកតម្កើងក្នុងសង្គម ដោយស្ត្រីមានសេរីភាពសមត្ថភាពចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិដូចបុរសដែរ។ ស្ត្រីបានកាន់តំណែងខ្ពស់ៗ ចូលរួមក្នុងជីវភាពនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ប្រទេសជាតិរបស់ខ្លួនក្នុងលក្ខណៈស្មើភាព។[១៧] លើសពីនេះស្ត្រីត្រូវបានសង្គមលើកកម្ពស់ឱ្យមានឋានៈខ្ពស់បំផុត ដោយប្រើពាក្យស្លោកថា ស្ត្រីជាមាតានៃពិភពលោក។ ពាក្យស្លោកនេះមានន័យថា ស្ត្រីមានតួសំខាន់ក្នុងការបង្កើតមនុស្សជាតិ ព្រមទាំងអប់រំកសាងធនធានមនុស្សតាមរយៈការជួយអប់រំកូនចៅជំនាន់ក្រោយឱ្យមានអត្តចរិតល្អថ្លៃថ្នូរ មានជំនាញច្បាស់លាស់ ដើម្បីក្លាយជាពលរដ្ឋល្អ។

---

[១៦] ប្រជុំរឿងព្រេងខ្មែរភាគទី៦ និងសិលាចារឹករបស់បណ្ឌិតសិវាចារ្យនៅប្រាសាទភ្នំជីសូរ ក្នុងរជ្ជកាលសុរ្យវរ្ម័នទី១ គ. ស.១០១៧។

[១៧] ក្រសួងអប់រំយុវជននិងកីឡា, សិក្សាសង្គមថ្នាក់ទី១០, របបមាតាធិបតេយ្យ, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, បោះពុម្ពលើកទី៦ ឆ្នាំ២០១៥, ភ្នំពេញ, ទំព័រ ២៤២

សម័យបុរាណស្ត្រីខ្មែរភាគច្រើនចូលចិត្តទទួលយកការងារផ្ទះជាងការងារក្រៅផ្ទះ។ បច្ចុប្បន្ន ផ្នត់គំនិតនេះបានអស់ឥទ្ធិពលជាបន្តបន្ទាប់។ ស្ត្រីខ្លះដែលមានសមត្ថភាពអាចមានឱកាសដឹកនាំអង្គភាពស្ថាប័នកំពូល ដូចជា អាជ្ញាធរដែនដី មន្ទីរ ក្រសួង និងរដ្ឋសភាជាដើម។ ថ្វីត្បិតស្ត្រីខ្មែរ ពុំសូវមានតួនាទីឋានៈជាអ្នកដឹកនាំកំពូលក្នុងក្រុមការងារដូចបណ្តាប្រទេសមួយចំនួនក៏ដោយ ក៏ស្ត្រីខ្មែរភាគច្រើនដើរតួរជាលេខា ជាជំនួយការជាអ្នកសម្របសម្រួល ដែលជាកត្តាចាំបាច់មិនអាចខ្វះបានសម្រាប់គ្រប់អង្គភាព ព្រោះស្ត្រីខ្មែរទទួលផ្នត់គំនិតពីវប្បធម៌សង្គមនូវសេចក្តី ព្យាយាម ម៉ត់ចត់ តស៊ូអំណត់ក្នុងការងារ និងបានទទួលការអប់រំពីសាលា ដែលបានក្លាយជាមនុស្សពូកែ ពោរពេញទៅដោយចំណេះដឹងទូទៅ។ បច្ចុប្បន្នស្ត្រីខ្មែរមានភាពងាយរកបានការងារធ្វើជាងបុរស។

ប្រសិនបើអ្នកដឹកនាំមានស្ត្រីជាប្រពន្ធដែលមានគំនិតជាតិនិយម នោះប្រទេសជាតិនឹងជួបប្រទះភាពរុងរឿងរីកចម្រើនតាមនោះដែរ។ ផ្ទុយទៅវិញ ប្រសិនបើស្ត្រីមានគំនិតគ្រួសារនិយម បក្សពួកនិយម អាត្មានិយម ហើយចូលជ្រៀតជ្រែកក្នុងការងារប្តីដែលមាននាទីតំណែងខ្ពស់ នោះប្រទេសជាតិក៏ជួបវិបត្តិផ្សេងៗច្រើនដែរ។ គេបានរិះគន់ខ្លាំងអំពីផ្នត់គំនិតក្នុងសង្គម ដែលលើកឡើងថា ប្តីសក្តិ៤ប្រពន្ធសក្តិ៥។ គំនិតនេះមានន័យថា កិច្ចការនានារបស់ប្តីក្នុងតួនាទីជាអ្នកដឹកនាំ ត្រូវបានប្រពន្ធដែលគ្មានតំណែងតួនាទីភារកិច្ចអ្វីសោះជាអ្នកសម្រេចទៅវិញ ជាពិសេសទាក់ទងនឹងអំពើពុករលួយស៊ីសំណូក ជាដើម។

តាមការសង្កេត ជាទូទៅក្នុងក្រុមការងារ ស្ត្រីខ្មែរមានអំណាចស្រមោលក្នុងការសម្រេចចិត្តនិងការផ្តល់គំនិតទស្សនៈ។ នៅក្នុងវិស័យការងារ គំនិតស្ត្រីត្រូវបានយកចិត្តទុកដាក់ តែងដាក់ចូលទៅក្នុងរបៀបវារៈពិភាក្សានិងយកទៅអនុវត្ត។ អ្វីដែលជាគោលបំណង និងគោលដៅរបស់ស្ត្រី តែងត្រូវមនុស្សប្រុសយកមកពិចារណា។ ស្ត្រីខ្មែរភាគច្រើនមានការសម្រេចចិត្តច្បាស់លាស់ មានឥទ្ធិពល និងអំណាចខាងក្នុង ដែលជាអំណាចដ៏អាចកំបាំងពោរពេញទៅដោយថាមពលដ៏អស្ចារ្យ។ បុរសដែលឱ្យតម្លៃស្ត្រីកម្រហ៊ានឈ្លោះជាមួយស្រីណាស់ ព្រោះមានពាក្យស្លោកមួយពោលថា «កុំឈ្លោះនឹងស្រី កុំក្តីនឹងចិន» ជាដើម។

ដោយសារសង្គមខ្មែរបច្ចុប្បន្ន មានការវិវត្តឥតឈប់ឈរ ស្ត្រីមានភារកិច្ចត្រូវធ្វើច្រើនដូចបុរសដែរ គឺខំរៀនសូត្រនិងបំពេញការងារ មុខរបរចិញ្ចឹមជីវិតដោយខ្លួនឯង មិនរង់ចាំតែដេកស៊ីកម្លាំងពលកម្មគេឡើយ ហេតុនេះទើបពិធីទំនៀមទម្លាប់ខ្លះ ក៏ត្រូវកាត់បន្ថយដែរ ដូចជា ពិធីចូលម្លប់ ជាដើម។

## ៨. គោលគំនិតយេនឌ័រ

យេនឌ័រ គឺជាដំណើរស្មើមុខគ្នារវាងបុរសនិងស្ត្រីក្នុងសង្គម ក្នុងការប្រើសិទ្ធិសេរីភាព សមត្ថភាព និងតួនាទីរបស់ខ្លួន។ តាមគោលគំនិតយេនឌ័រ សមាជិកសង្គមម្នាក់ៗ ទាំងបុរសនិងស្ត្រី មានឱកាសដូចគ្នាក្នុងការចូលរួមសកម្មភាពសង្គម។ ទស្សនៈស្តីពីយេនឌ័រ បាននិងកំពុងមានការពេញនិយមនិងរីកដុះដាលនៅបស្ចិមប្រទេសនិងរីករាលដាលដល់តំបន់ផ្សេងៗទៀតជាបន្តបន្ទាប់។ សង្គមវិទូចាត់ទុកថា ការសិក្សាអំពីទំនាក់ទំនងយេនឌ័របានក្លាយជាផ្នែកមួយដ៏សំខាន់បំផុតសម្រាប់ពិភពលោកបច្ចុប្បន្ន។

គោលគំនិតយេនឌ័រយល់ថា ស្ត្រីនិងបុរស គួរមានសិទ្ធិអំណាចស្មើគ្នាក្នុងការទទួលខុសត្រូវក្នុងការសម្រេចចិត្តនិងធ្វើសកម្មភាពនានាក្នុងសង្គមដើម្បីជោគវាសនានៃជីវិតរបស់ខ្លួន។ ប្រសិនបើសមត្ថភាពដូចគ្នា

ការងារដូចគ្នា តួនាទីដូចគ្នា នោះសមាជិកសង្គមម្នាក់ៗត្រូវទទួលផលប្រយោជន៍ប្រាក់កម្រៃ និងផលលាភដូចគ្នា ដោយមិនត្រូវបែងចែករើសអើងថាជាបុរសឬស្ត្រី ឬភេទអ្វីឡើយ។

ឆ្នាំ១៩១០ សន្និសីទអន្តរជាតិនារីដែលមានប្រទេស១៧ ចូលរួមប្រជុំនៅគូពនហាក បានសម្រេចយកថ្ងៃ ៨ មីនា ជា "ទិវានារីអន្តរជាតិ " ជាមហាសាមគ្គីតស៊ូរបស់នារីពលករ សកលលោកដើម្បីសិទ្ធិ សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនសង្គម ភ្ជាប់ជាមួយពាក្យស្លោកៈ ១-ធ្វើការមួយថ្ងៃ៨ម៉ោង ២-ធ្វើការស្មើគ្នា ប្រាក់ឈ្នួលស្មើគ្នា ៣-ធានាសុខភាពមាតានិងទារក។[១៨] នៅកម្ពុជាប្រតិទិនឈប់សម្រាកប្រចាំឆ្នាំ ក៏មានថ្ងៃ៨ មីនាដែរ ដោយបានអនុញ្ញាតឱ្យពលរដ្ឋទូទៅបានឈប់សម្រាក១ថ្ងៃ ដើម្បីអបអរសាទរទិវាសិទ្ធិនារីអន្តរជាតិនេះជាដរាបរៀងមក ។

## ៩. គោលគំនិតបិតាធិបតេយ្យ[១៩]

តាមការសង្កេតក្នុងលទ្ធិសាសនាស្ទើរទាំងអស់ អាទិទេពធំៗ មានភេទជាបុរស ដូចជា ព្រះអាឡាហ៍ ក្នុងឥស្លាមសាសនា ព្រះវរបិតា(ឬព្រះបុត្រា)ក្នុងគ្រិស្តសាសនា ព្រះសិវៈ វិស្ណុ ព្រះព្រហ្មញ្ញ ក្នុងព្រាហ្មណ៍សាសនាជាដើម។

ក្នុងទំនាក់ទំនងគ្រួសារ ឥទ្ធិពលនៃគំនិតបិតាធិបតេយ្យ ចាត់ទុក ស្ត្រីជាប្រពន្ធមានឋានៈហាក់ដូចជាអ្នកបម្រើ( ទាសភរិយា )។ បុរសជាប្តីក្តោបក្តាប់ប្រាក់ចំណូលចំណាយនិងត្រួតត្រាលើប្រពន្ធ។ បុរសមានតម្លៃក្នុងការរក្សានាមត្រកូលរបស់ខ្លួន។ នៅប្រទេសចិន ការនិយមឱ្យតម្លៃមនុស្សប្រុស បូករួមផ្សំជាមួយគោលនយោបាយកូនមួយរបស់ប្រទេសចិនពីឆ្នាំ១៩៧៩ដល់ឆ្នាំ២០១៦ ការរំលូតគភ៌ទារិកាកើតមានជារឿយៗ។ លោក ច្យ៉ង ក្វាងប៉ាវ (Jiang Quanbao) សាស្ត្រាចារ្យផ្នែកប្រជាសាស្ត្រនៃសាកលវិទ្យាល័យស៊ីយ៉ាង ចាវថុង (Xi'an Jiaotong) បាននិយាយថា៖ «គេប៉ាន់ប្រមាណថានៅចន្លោះ ឆ្នាំ ១៩៨០ និង ២០២០ នៅប្រទេសចិន មានមនុស្សប្រុសប្រហែលជា ៣០លានទៅ ៤០លាននាក់ កើតច្រើនជាងស្ត្រី ដែលធ្វើឱ្យមានកង្វះមនុស្សស្រីសម្រាប់រៀបអាពាពិពាហ៍»[២០] ការណ៍នេះនៅតែបន្ត ដែលអាចនាំឲ្យមានការប្រែប្រួលផ្នត់គំនិតស្តីពីតម្លៃរវាងបុរសនិងស្ត្រីដែរ។ នៅកម្ពុជាគេឃើញមាន គ្រួសារដែលជាប់ខ្សែស្រឡាយចិន ប្តីនៅតែប្រើឥទ្ធិពលអំណាចខ្លាំងលើប្រពន្ធ និងឲ្យតម្លៃកូនប្រុសច្រើនជាងកូនស្រី ។

## ១០. សេចក្តីសន្និដ្ឋាន

ជនជាតិខ្មែរតែងលើកតម្កើងផ្តល់តម្លៃខ្ពស់ដល់ស្ត្រី ក្នុងការគ្រប់គ្រងថែរក្សាក្រុមគ្រួសារ ក្នុងការងារប្រឹក្សាផ្តល់យោបល់បញ្ចុះបញ្ចូលនិងទំនាក់ទំនងការងារនិងញាតិមិត្ត។ ចំណែក ទស្សនៈយេនឌ័រ មាន

---

[១៨] United Nations, "International Women's Day, 8 March" Retrieved March 7, 2020.

[១៩] របបបិតាធិបតេយ្យ (អ. Patriarch regime / បារ. régime partriarcal )មានក្នុងស្ទើរគ្រប់សាសនា ។

[២០] ប្រទេសចិន មានបុរសច្រើនជាងស្ត្រី ដែលបណ្តាលឱ្យមានមនុស្សប្រុសជាច្រើននៅលីវ https://www.postkhmer.com/អន្តរជាតិ/ប្រទេសចិន-មានបុរសច្រើនជាងស្ត្រី-ដែលបណ្តាលឱ្យមានមនុស្សប្រុសជាច្រើននៅលីវ

បំណងឱ្យស្ត្រីចាកចេញពីការងារផ្ទះសម្បែងទៅរកការងារខាងក្រៅ ដោយចុះប្រឡូកក្នុងការងារសង្គមដើម្បីបានតួនាទីខ្ពស់ក្នុងឋានៈជាអ្នកដឹកនាំ។ នេះជាចរន្តគំនិតសម្រាប់មនុស្សជំនាន់ថ្មី ដើម្បីជៀសវាងជំណៀលថា ស្ត្រីបង្វិលជើងក្រានមិនជុំ។ ការណ៍នេះនាំឱ្យស្ត្រីខ្មែរកាន់តែច្រើនឡើងបានខិតពង្រឹងនិងពង្រីកសមត្ថភាពទេពកោសល្យជំនាញចំណេះដឹងការងាររបស់ខ្លួនឱ្យមានលក្ខណៈកាន់តែប្រសើរ ដែលធ្វើឱ្យតម្លៃស្ត្រីខ្មែរកាន់តែកើនឡើងខ្ពស់ថែមទៀត។ គោលគំនិតយេនឌ័រនៅកម្ពុជាបាននិងកំពុងជំរុញរបបមាតាធិបតេយ្យឱ្យកាន់តែមានជំហររឹងមាំខ្លាំងក្លាថែមទៀត ប្រឈមតទល់យ៉ាងស្វិតស្វាញនឹងទស្សនៈបិតាធិបតេយ្យ។

យើងអាចនិយាយបានថា ព្រលឹងមាតាធិបតេយ្យនៅតែរស់រវើកក្នុងសង្គមខ្មែរ ទោះបី បិតាធិបតេយ្យដែលមាននៅក្នុងលទ្ធិសាសនាធំៗ កំពុងមានអត្ថិភាពពេញពិភពលោកយ៉ាងណាក៏ដោយ។ នៅក្នុងកម្ពុជារបបបិតាធិបតេយ្យគ្រាន់តែមានទម្រង់ខាងក្រៅប៉ុណ្ណោះ មិនអាចកាច់បំបាក់ឥទ្ធិពលមាតាធិបតេយ្យខ្មែរបានឡើយ។ ថ្វីត្បិតមានស្ថាប័នមួយចំនួនមានការព្រួយបារម្ភខ្លាំងលើអំពើហិង្សាខ្លះដែលរំលោភបំពានសិទ្ធិរបស់ស្ត្រីក៏ដោយ ក៏យើងអាចដោះស្រាយបានជាប្រព័ន្ធតាមគោលការណ៍ច្បាប់និងវប្បធម៌បានដែរ ព្រោះអំពើហឹង្សាទាំងនោះមិនមែនមានតែលើស្ត្រីទេគឺវាកើតមានលើបុរសច្រើនជាងស្ត្រីទៅទៀត។ ករណីទាំងនេះត្រូវឃោសនាចលនាមហាជនទាំងមូលឱ្យយល់ពីសមភាពយេនឌ័រ និងរបបមាតាធិបតេយ្យខ្មែរ ឱ្យបានត្រឹមត្រូវ និងទូលំទូលាយថែមទៀត ហើយស្ត្រីខ្លួនឯងក៏គួរតែពង្រឹងការអប់រំសីលធម៌ វិជ្ជាមេផ្ទះនិងមុខវិជ្ជាសង្គមផ្សេងៗដើម្បីស័ក្តិសមជាមាតាល្អ ជាប្រពន្ធល្អ និងពលរដ្ឋល្អក្នុងសង្គមឱ្យកាន់តែខ្លាំងក្លាទៀតដែរ។

## ១១.គន្ថនិទ្ទេស

## ក-ឯកសារជាភាសាខ្មែរ


1. ក្រសួងអប់រំយុវជននិងកីឡា,*សិក្សាសង្គមថ្នាក់ទី១០*, បោះពុម្ពលើកទី៦, ឆ្នាំ២០១៥
2. ខ្លូត ធីតា, *ព្រះពុទ្ធសាសនានិងការអភិវឌ្ឍសង្គមខ្មែរ* គ.ស. ១៩៩៦
3. ងួន ញ៉ិល *ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ* ភ្នំពេញ ១៩៩២
4. ជួនណាត *វចនានុក្រមខ្មែរ ភាគ១ ភាគ២* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧
5. ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ* ១៩៧៣
6. ត្រឹង ងា *អរិយធម៌ខ្មែរ* ភ្នំពេញ បោះពុម្ពឆ្នាំ១៩៧៤
7. សរ សារុន *សង្គមវិជ្ជាខ្មែរ* ភ្នំពេញ ១៩៧៣
8. សុង ស៊ីវ *ចលនាអារ្យធម៌* ភ្នំពេញ ១៩៧១។


## ខ-ឯកសារតាមប្រព័ន្ធអ៊ីនធឺណិត


1. វិទ្យុបារាំងអន្តរជាតិជាភាសាខ្មែរ, https://www.rfi.fr/km
2. វិគីភីឌា (សព្វវចនាធិប្បាយសេរី), https://km.wikipedia.org
3. វិទ្យុសម្លេងសហរដ្ឋអាម៉េរិក, http://khmer.voanews.com
4. គេហទំព័រថ្មីៗ, www.thmeythmey.com

# ឥទ្ធិពលចំណូលពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា

បេក្ខជនបណ្ឌិត៖ **គង់ ចន្ថា**
ជំនាញ៖ **វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## ១.ចំណូលពន្ធដារ

ដើម្បីជានាបាននូវសមត្ថភាព សមធម៌ តម្លាភាព ការប្រកួតប្រជែងស្មើភាព និងជួយកាត់បន្ថយបន្ទុកប្រជាពលរដ្ឋ ដែលជាអ្នកប្រកបអាជីវកម្មតូចតាច និងដើម្បីផ្តល់លទ្ធភាពឱ្យរដ្ឋបាលសារពើពន្ធអាចគ្រប់គ្រងការប្រមូលចំណូលពន្ធបានចំទិសដៅប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកែសម្រួលលើការកំណត់របបពន្ធនៅកម្ពុជា។ កំណើនចំណូលពន្ធដារប្រចាំឆ្នាំ ក្នុងរយៈពេលជិតបីទសវត្សរ៍កន្លងមកនេះ(១៩៩៤-២០២២) គឺជាសមិទ្ធផល និងជោគជ័យជាប្រវត្តិសាស្ត្រដែលកើតចេញពីការខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល។ កត្តាចម្បង និងសមាសធាតុសំខាន់ៗជាច្រើន ដែលជះឥទ្ធិពល និងជាចំណែកដ៏ធំដល់ការសម្រេចបានទាំងនេះ រួមមាន (១) កត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច (២) កត្តាគោលនយោបាយ និងយុទ្ធសាស្ត្រកែទម្រង់ស៊ីជម្រៅដ៏មុតស្រួច និងមានលក្ខណៈប្រទាក់ក្រឡាគ្នាល្អពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន (៣) កត្តាឆន្ទៈ និងការប្តេជ្ញាចិត្តដ៏អង់អាចក្លាហាន និងហ្មត់ចត់ជាទីបំផុតរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និង (៤)កត្តាកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិជុំវិញកិច្ចការពន្ធដារជាមួយអន្តរក្រសួង និងស្ថាប័នរដ្ឋ វិស័យឯកជន និងអ្នកបង់ពន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងមជ្ឈដ្ឋានពាក់ព័ន្ធមួយចំនួនទៀតដោយឈរលើជំហរគោរព និងផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមកជាដៃគូដើម្បីប្រយោជន៍រួម។ ចំណូលពន្ធដារកើនឡើងពី ១៦.៦៨២លានរៀល រហូតដល់ ១៣.៩៩៩.២០០លានរៀល ដែលគិតជាមធ្យមស្មើនឹង ៣០,១% ក្នុងរយៈពេលជិតបីទសវត្សរ៍(១៩៩៤-២០២២)កន្លងមក និងប្រមាណ១៧% សម្រាប់រយៈពេលមួយទសវត្សរ៍(២០១៣-២០២២)ចុងក្រោយ។ នៅឆ្នាំ១៩៩៧ ច្បាប់ស្តីពីសារពើពន្ធត្រូវបានអនុម័តប្រកាសឱ្យប្រើដំបូង នាំឱ្យការប្រមូលចំណូលពន្ធមានកំណើនខ្ពស់ ដែលគិតជាទឹកប្រាក់ប្រមាណ ១១១.៩៧៥ លានរៀលស្មើនឹង៦៨,២% ធៀបនឹងឆ្នាំចាស់។ ក្រោយការដាក់ចេញនូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី១ឆ្នាំ២០០៤-២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានប្រមូលចំណូលពន្ធដារសរុបគិតជាទឹកប្រាក់មានចំនួន ៤៨១.១៨៦លានរៀលនៅឆ្នាំ២០០៤ កើនឡើងប្រមាណ ២៥%ធៀបនឹងឆ្នាំចាស់ ហើយបន្តកំណើនរហូតដល់ ១.៧៣៦.២៥២លានរៀលនៅឆ្នាំ២០០៨ កើនឡើង៣៧,៩%។ ចាប់ពីឆ្នាំ២០០៩-២០១៥ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ត្រូវបានដាក់ចេញក្នុងអំឡុងដំណាក់កាលនេះ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រូវបានចាប់បដិសន្ធិឡើង ដែលនាំឱ្យកំណើនចំណូលពន្ធឡើងដល់ ១,៧៤៥,៤២៨លានរៀលនៅឆ្នាំ២០០៩ កើនឡើង ០,៥% ធៀបនឹងឆ្នាំចាស់ និងបន្តហើយបន្តកំណើនរហូតដល់៥.២១០.២២២លានរៀលនៅឆ្នាំ

២០១៥ កើនឡើង២២,១%ធៀបនឹងឆ្នាំចាស់។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៦-២០២០ដំណាក់កាលទី៣ និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៩-២០២៣ ដែលញ៉ាំងឱ្យការប្រមូលចំណូលពន្ធសម្រេចបានចំនួន ៦.០១០.៤៨២ លានរៀលនៅឆ្នាំ២០១៦ កើនឡើង១៥,៤%ធៀបនឹងឆ្នាំចាស់ និងបន្តកំណើនរហូតដល់២,៩% គិតជាទឹកប្រាក់ចំនួន ១១.៦០៨.៨៣២លានរៀល នៅឆ្នាំ២០២០។ នៅដំណាក់កាលទី៤ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២១-២០២៥ និងការបន្តអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ធ្វើឱ្យកំណើនចំណូលពន្ធសម្រេចបានគិតជាទឹកប្រាក់សរុបប្រមាណ ១១.២៦៦.៧៩០លានរៀលនៅឆ្នាំ២០២១ ដែលថយចុះ-២,៩% ដោយសារទទួលរងឥទ្ធិពលពីការរីករាលដាលនៃជំងឺកូវីដ១៩ នៅកម្ពុជាចាប់ផ្ដើមពីចុងឆ្នាំ២០១៩ និងបន្តរីករាលដាលខ្លាំងរហូតដល់ចុងឆ្នាំ២០២១ ប៉ុន្តែកំណើននេះបានបន្តឡើងមកវិញនៅឆ្នាំ២០២២ គិតជាទឹកប្រាក់ ១៣.៩៩៣.២០០លានរៀល កើនឡើងចំនួន២៤,២% ក្រោយពេលកម្ពុជាឆ្លងផុតពីវិបត្តិជំងឺកូវីដ១៩ និងចាប់ផ្ដើមបើកដំណើរការសកម្មភាពសេដ្ឋកិច្ចឡើងវិញ។

រូបភាព១៖ ចំណូលពន្ធដារសរុប ចាប់ពីឆ្នាំ១៩៩៤-២០២២ (គិតជាលានរៀល)




ប្រភព៖ ឯកសារកំណែទម្រង់ពន្ធដារកម្ពុជា ២០១៣-២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ បោះពុម្ពឆ្នាំ២០២១

គួរកត់សម្គាល់ផងដែរថា ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ កំណើនចំណូលពន្ធកើនឡើងជាអតិបរមារហូតដល់១១.២៧៩.២៤៦លានរៀល ស្មើនឹងអត្រាកំណើន ២៨,៣% ក្នុងឆ្នាំ២០១៩។ ដូចនេះ ផ្លែផ្កាដ៏ត្រចេះត្រចង់នៃកំណើនចំណូលថវិកាជាតិជារៀងរាល់ឆ្នាំ ជាភស្តុតាងយ៉ាងច្បាស់ឆ្លុះបញ្ចាំងឱ្យឃើញពី ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការបន្តអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាលកម្ពុជាទាំងមូលផងដែរ។(សូមមើលរូបភាព១ និងរូបភាព២ បន្ថែមស្ដីពីចំណូលពន្ធដារសរុបចាប់ពីឆ្នាំ១៩៩៤-២០២២ និង កំណើនចំណូលពន្ធដារប្រចាំឆ្នាំ)។

រូបភាព២៖ កំណើនចំណូលពន្ធដារប្រចាំឆ្នាំ




ប្រភព៖ គណនាចេញពីមូលដ្ឋានឯកសារកំណែទម្រង់ពន្ធដារកម្ពុជា ២០១៣-២០២០ របស់អគ្គនាយដ្ឋានពន្ធដារ បោះពុម្ពឆ្នាំ២០២១

អនុបាតចំណូលពន្ធដារធៀបជាមួយផ.ស.សគិតចាប់ឆ្នាំ១៩៩៤ ដល់២០២២ ជាមធ្យម ៧,៧៤% ក្នុងមួយឆ្នាំ។ ម្យ៉ាងទៀត អនុបាតពន្ធធៀបជាមួយ ផ.ស.ស នៅឆ្នាំ១៩៩៤ មានត្រឹមតែ ០,១៩%ប៉ុណ្ណោះ ហើយនិន្នាការនេះបានបន្តកើនឡើងជាអតិបរមា ២៣,៥២% គិតត្រឹមឆ្នាំ២០២២។ (សូមមើលរូបភាព ៣ បន្ថែមស្តីពីចំណូលពន្ធដារធៀបជាមួយ ផសស)។

រូបភាព៣៖ ចំណូលពន្ធដារធៀបជាមួយ ផ.ស.ស




ប្រភព៖ គណនាចេញពីមូលដ្ឋានទិន្នន័យឯកសារកំណែទម្រង់ពន្ធដារកម្ពុជា ២០១៣-២០២០ របស់អគ្គនាយដ្ឋានពន្ធដារបោះពុម្ពឆ្នាំ២០២១ និងទិន្នន័យពី វិទ្យាស្ថានជាតិស្ថិតិ

## ២.កំណើនសេដ្ឋកិច្ចនៅកម្ពុជា

ការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយជាតិសំខាន់ៗ ជាពិសេសការដាក់ចេញនូវគោលនយោបាយកំណែទម្រង់ទៅលើវិស័យអទិភាព និងការអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាលសេដ្ឋកិច្ចកម្ពុជា រក្សាបាននូវកំណើនខ្ពស់គួរឱ្យកត់សម្គាល់ ទោះបីជាជួបប្រទះបញ្ហាប្រឈមមួយចំនួនក្តី។ ក្នុងរយៈពេលជាងពីរទសវត្សរ៍មកនេះ កម្ពុជារក្សាបាននូវអត្រាកំណើនម៉ាក្រូសេដ្ឋកិច្ចក្នុងរង្វង់៧% ក្នុងមួយឆ្នាំ ព្រមទាំងសម្រេចបាននូវមហិច្ឆតាប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ និងមានចក្ខុវិស័យឆ្ពោះទៅសម្រេចឱ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ សម្រាប់រយៈពេលខ្លី និងមធ្យម(០៥ឆ្នាំ) ពោលគឺចាប់ពីឆ្នាំ២០០៣ ដល់ ២០០៨ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចជាទីមោនទនៈ ជូនជាតិមាតុភូមិ និងប្រជាជន ពោលគឺរក្សាបានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ១០%(២០០៥-២០០៨) ក្នុងនោះសម្រេចបាននូវអត្រាកំណើនជាអតិបរមា ១៣,៣% នៅឆ្នាំ២០០៥ និងកំណើនអប្បបរមាត្រឹមតែ ៦,៧% នៅឆ្នាំ២០០៨។ ការណ៍នេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការសម្រេចបានការអនុវត្តប្រកបដោយភាពជោគជ័យនូវការដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីមួយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងគោលដៅជំរុញលើកកម្ពស់កំណើនសេដ្ឋកិច្ច បង្កើតការងារជូនប្រជាពលរដ្ឋ ធានាសមធម៌ ក្នុងសង្គមនិងបង្កើនប្រសិទ្ធភាពនៃវិស័យសាធារណៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ អត្រាកំណើនសេដ្ឋកិច្ចមធ្យមប្រចាំឆ្នាំសម្រាប់រយៈពេលមធ្យម (២០០៨-២០១៣)ស្ថិតក្នុងរង្វង់ប្រមាណ ៥,៧% ក្នុងនោះអត្រាកំណើនអប្បបរមា ០,១% នៅឆ្នាំ២០០៩ និងអត្រាកំណើនអតិបរមា ៧,៤% នៅឆ្នាំ២០១៣។ ក្នុងន័យនេះ សមទ្ធិផលសម្រេចបាន បង្ហាញឱ្យឃើញពីផ្លែផ្កានៃការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់គោលដៅជាសារវន្តដើម្បីធានាដល់កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព តាមរយៈការបន្តជំរុញការអនុវត្តវិធានការពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជាជាដើម។ បន្ទាប់ពីដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបីរវាងឆ្នាំ២០១៣-២០១៨ ក្នុងគោលដៅជាយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិកម្ពុជារក្សាបានអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំសម្រាប់រយៈពេលមធ្យម៧,១% និងមានកំណើនអតិបរមា៧,៥% នៅឆ្នាំ២០១៨។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបួនរវាងឆ្នាំ២០១៨-២០២៣ ត្រូវបានដាក់ចេញដើម្បីរក្សាសមទ្ធិផលដែលសម្រេចបានកន្លងមក និងក្នុងគោលដៅធានាឱ្យបានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងអត្រា

មធ្យមប្រចាំឆ្នាំ៧% និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចថ្មីៗដោយទូលំទូលាយ និងមានភាពប្រកួតប្រជែង ជាមួយនឹងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប ការធានាស្ថិរភាពអត្រាប្តូរប្រាក់ ការខិតខំបង្កើន ទុនបម្រុងជាប្រចាំ និង ការគ្រប់គ្រងបំណុលសាធារណៈដោយគត់មត់នោះ អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានសម្រាប់រយៈពេលមធ្យម(៥ឆ្នាំ) ៤%ប្រចាំឆ្នាំ និងមានអត្រាកំណើនអប្បបរមា -៣,១%នៅឆ្នាំ២០២០។ ការធ្លាក់ចុះនេះបណ្តាលមកវិបត្តិនៃជំងឺកូវីដ១៩ ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក ក្រោមឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ចចិន និងអាមេរិក ព្រមទាំងវិបត្តិសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែនជាដើម។(សូមមើលរូបភាព៤បន្ថែមស្តីពីកំណើនសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ១៩៩៤-២០២២)

រូបភាព៤៖ កំណើនសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ១៩៩៤-២០២២




ប្រភព៖ទិន្នន័យប្រមូលពីវិទ្យាស្ថានជាតិស្ថិតិ

## ៣. ការវាយតម្លៃពីឥទ្ធិពលចំណូលពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា

ផ្អែកតាមលទ្ធផលវិភាគ និងប៉ាន់ស្មានក្នុងតារាង១ ឃើញថា តម្លៃស្ថិតិ F មានចំនួន ១១,៥៦១ ធំជាងតម្លៃដែនកំណត់ខាងលើ(Upper Bounds)។ សម្មតិកម្មសូន្យត្រូវបានបដិសេធនៅគ្រប់កម្រិតសារសំខាន់ ១% ៥% និង ១០% ពោលគឺមានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា ចំណូលពន្ធដារមានទំនាក់ទំនងរយៈពេលវែង(Cointegration)ជាមួយនឹងកំណើនសេដ្ឋកិច្ចកម្ពុជា។ ក្នុងរយៈពេលវែងចំណូលពន្ធដារមានតម្លៃ P-Value ស្មើនឹង 0,000 បង្ហាញថាសម្មតិកម្មសូន្យត្រូវបានបដិសេធនៅគ្រប់កម្រិតសារសំខាន់ ១% ៥% និង១០%។ ដូចនេះ ចំណូលពន្ធដារជះឥទ្ធិពលនិងមានទំនាក់ទំនងជាវិជ្ជមានលើកំណើនសេដ្ឋកិច្ចកម្ពុជា ពោលគឺចំណូលពន្ធដារកើន១% ជះឥទ្ធិពលធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាកើនឡើង0,៣២% ក្នុងរយៈពេលវែង។ ក្នុងរយៈពេលខ្លី ចំណូលពន្ធដារជះឥទ្ធិពល និងមានទំនាក់ទំនងជាមួយកំណើនសេដ្ឋកិច្ចផងដែរ។ ចំណូលពន្ធក្នុងឆ្នាំ(t) មានតម្លៃ P-Value ស្មើនឹង 0,៨% បញ្ជាក់ថា គេមានភស្តុតាងគ្រប់គ្រាន់ក្នុងការបដិសេធសម្មតិកម្មសូន្យនៅគ្រប់កម្រិតសារៈសំខាន់ ១% ៥% និង១០% ដែលមានន័យថា ចំណូលពន្ធដារ

ក្នុងឆ្នាំ(t) កើន ១% ជះឥទ្ធិពលធ្វើឱ្យកំណើនសេដ្ឋកិច្ចកើនឡើងជាវិជ្ជមាន ០,១៣%ក្នុងរយៈពេលខ្លី។ ចំណែកចំណូលពន្ធដារនៅរយៈពេល t-១ និង t-២ មានតម្លៃ P-Value ស្មើនឹង ៩០,១% និង ៣០,៧% រៀងគ្នា បញ្ជាក់ថាគេមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបដិសេធសម្មតិកម្មសូន្យនៅកម្រិតសារសំខាន់ ១% ៥% និង១០%។ ដូចនេះ ចំណូលពន្ធដារក្នុងរយៈពេលទាំងពីរនេះ មិនបានជះឥទ្ធិពល និងមិនមានទំនាក់ទំនងរយៈពេលខ្លីលើកំណើនសេដ្ឋកិច្ចកម្ពុជានោះទេ។ ផ្ទុយទៅវិញ ចំណូលពន្ធដារនៅរយៈពេល t-៣ បានជះឥទ្ធិពលជាអវិជ្ជមានលើកំណើនសេដ្ឋកិច្ច ក្នុងនោះមានតម្លៃ P-Value ស្មើនឹង ០,០០% ដែលបង្ហាញថាគេមានភស្តុតាងគ្រប់គ្រាប់ដើម្បីបដិសេធសម្មតិកម្មសូន្យនៅកម្រិតសារសំខាន់ ១% ៥% និង ១០%។ ដូចនេះ ចំណូលពន្ធដារនៅរយៈពេល t-៣ កើន ១% ជះឥទ្ធិពលធ្វើឱ្យកំណើនសេដ្ឋកិច្ចថយចុះ ០,១១%។

តារាង១៖ លទ្ធផលធ្វើតេស្តឥទ្ធិពលចំណូលពន្ធដារលើកំណើនសេដ្ឋកិច្ច

| Variable | Coefficient | Std. Error | t-Statistic | P-Value |
|---|---|---|---|---|
| Co-integration ( Long-run relationships ) | | | | |
| $\log TXR_t$ | 0.32 | 0.022 | 14.22 | 0.000 |
| ECM (Short-run relationships) | | | | |
| $\Delta\log TXR_t$ | 0.13 | 0.042 | 2.97 | 0.008 |
| $\Delta\log TXR_{t-1}$ | -0.01 | 0.036 | -0.13 | 0.901 |
| $\Delta\log TXR_{t-2}$ | -0.04 | 0.036 | -1.05 | 0.307 |
| $\Delta\log TXR_{t-3}$ | -0.11 | 0.025 | -4.28 | 0.000 |
| Constant | 4.28 | 1.859 | 2.30 | 0.034 |
| $ECM_{t-1}$ | -0.33 | 0.155 | -2.16 | 0.045 |
| $R^2$=78.03% | $Adj\ R^2$ =70.70% | Root MSE =1.81% | | |

| ARDL Bounds Test | | |
|---|---|---|
| Variables | F-Statistics | K |
| F(logGDPG,logTXR) | 11.561 | 1 |
| Critical Value Bounds | I(0) [Lower Bound] | I(1) [Upper Bound] |
| 1% | 6.84 | 7.84 |
| 5% | 4.94 | 5.73 |
| 10% | 4.04 | 4.78 |

ប្រភព៖ គណនាចេញពីកម្មវិធី STATA ១៥.០

ចំណែកល្បឿននៃការកែតម្រូវ($ECM_{t-1}$)អវិជ្ជមានតូចជាង១ និងមានតម្លៃ P-Value ស្មើនឹង ៤,៥% បដិសេធសម្មតិកម្មសូន្យនៅកម្រិតសារសំខាន់៥% មានន័យថា គម្លាតរយៈពេលខ្លីចេញពីលំនឹងរយៈពេលវែង ត្រូវធ្វើការកែតម្រូវ ៣៣% ដើម្បីឈានទៅដល់កម្រិតលំនឹងរយៈពេលវែងជារៀងរាល់ឆ្នាំ។ ចំពោះ $R^2$ ស្មើនឹង ៧៨,០៣% មានន័យថាចំណូលពន្ធដារបានចូលរួមពន្យល់ពីបំរែបំរួលកំណើនសេដ្ឋកិច្ចបានរហូតដល់ ៧៨,០៣% នៅក្នុងម៉ូដែល និងបង្ហាញពី $Adj\ R^2$ ស្មើនឹង ៧០,៧០% មានន័យថា ចំណូលពន្ធដារ

មានសារៈសំខាន់ក្នុងការចូលរួមជួយពន្យល់ពីបំរែបំរួលកំណើនសេដ្ឋកិច្ចក្នុងម៉ូដែលរហូតដល់៧០,៧០% ។ ចំណែកឬសនៃលម្អៀងមធ្យមការេ( Root MSE )ស្មើ ១,៨១% មានន័យថា លម្អៀងមធ្យមនៃតម្លៃប៉ាន់ស្មានក្នុងម៉ូដែលជាមួយនឹងតម្លៃជាក់ស្តែងមានត្រឹមតែ១,៨១%ប៉ុណ្ណោះ។ ម្យ៉ាងទៀតទិន្នន័យវិភាគនិងប៉ាន់ស្មាននេះ គ្មានវត្តមាន Serial Correlation និង Heteroskedasticity នោះទេ ក្នុងនោះឃើញថា តម្លៃP-Value នៃការធ្វើតេស្ត Serial Correlation មាន ២៩,២៩% និងតម្លៃ P-Value នៃការធ្វើតេស្ត Heteroskedasticity មាន ២៥,០៤% ដែលបញ្ជាក់ថា គេមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបដិសេធសម្មតិកម្មសូន្យ ( Null Hypothesis ) នៅកម្រិតសារៈសំខាន់ ១% ៥% និង ១០%។ លទ្ធផលក៏បង្ហាញថា ទិន្នន័យវិភាគនេះ មានបំណែងចែក Normality ដែលមានតម្លៃ P-Value ស្មើនឹង ៥២,៣៣% ដែលមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបដិសេធសម្មតិកម្មសូន្យនៅកម្រិតសារៈសំខាន់៥%។ ដូចនេះ ការធ្វើតេស្តសុពលភាពម៉ូដែលបញ្ជាក់ថា ម៉ូដែលនិទស្សភាពសម្រាប់ធ្វើការវិភាគ និងប៉ាន់ស្មានមានសុពលភាពវិភាគល្អ និងផ្តល់នូវលទ្ធផលប៉ាន់ស្មានទិន្នន័យបានត្រឹមត្រូវ ( No Spurious Regression )។

## ៤. ការពិភាក្សាពីឥទ្ធិពលចំណូលពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា

ចំណូលពន្ធដារជះឥទ្ធិពល និងមានទំនាក់ទំនងជាវិជ្ជមានរយៈពេលវែង និងរយៈពេលខ្លីទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា។ សម្រាប់រយៈពេលវែង ចំណូលពន្ធដារកើន ១% ធ្វើឱ្យកំណើនសេដ្ឋកិច្ចកិច្ចកើនឡើង ០,៣២% និងសម្រាប់រយៈពេលខ្លី ចំណូលពន្ធឆ្នាំបច្ចុប្បន្ន t ( ឆ្នាំ២០២២ ) កើន ១% ជះឥទ្ធិពលធ្វើឱ្យកំណើនសេដ្ឋកិច្ចកើនឡើង ០,១៣%។ ចំណែកឯ ចំណូលពន្ធដារឆ្នាំ t-១( ឆ្នាំ២០២១ ) និង t-២ ( ឆ្នាំ២០២០ ) មិនមានទំនាក់ទំនង និងឥទ្ធិពលរយៈពេលខ្លីលើកំណើនសេដ្ឋកិច្ចនោះទេ។ គួរឱ្យកត់សម្គាល់ថា ក្នុងឆ្នាំ២០២០ និង២០២១ សកម្មភាពសេដ្ឋកិច្ចតាមវិស័យអាទិភាពមួយចំនួនជាចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជារួមមាន វិស័យឧស្សាហកម្ម វិស័យសេវាកម្ម និងវិស័យកសិកម្ម បាននឹងកំពុងផ្អាកសកម្មភាពស្ទើរទាំងស្រុងដោយសារវិបត្តិជំងឺកូវីដ១៩ ហើយវិធានការអនុគ្រោះពន្ធ និងលើកលែងពន្ធជាច្រើនរបស់រាជរដ្ឋាភិបាលត្រូវបានដាក់ចេញ ដែលជាមូលហេតុនាំឱ្យ ចំណូលពន្ធដារមិនមានទំនាក់ទំនង និងឥទ្ធិពលលើកំណើនសេដ្ឋកិច្ច។ ផ្ទុយទៅវិញ ចំណូលពន្ធឆ្នាំ t-៣ ( ឆ្នាំ២០១៩ ) កើន ១% ជះឥទ្ធិពលធ្វើឱ្យកំណើនសេដ្ឋកិច្ចថយចុះ ០,១១% បណ្តាលមកពីអនុវត្ត និងការដាក់ចេញនូវវិធានការ ច្បាប់ បទបញ្ញត្តិ និងគោលនយោបាយសារពើពន្ធមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់ និងមិនទាន់សមស្រប។ យោងលើទស្សនាទានគោលនយោបាយសារពើពន្ធ ដែលកំណត់ថាការជំរុញតម្រូវការនាំឱ្យមានកំណើនសេដ្ឋកិច្ច ឬអាចនិយាយដោយឡែកថា ការបង្កើនចំណាយដើម្បីធ្វើឱ្យមានកំណើនចំណូល និងតាមរយៈលទ្ធផលសិក្សាស្តីពីឥទ្ធិពលនៃចំណូលពន្ធដារលើកំណើនចំណាយសាធារណៈបង្ហាញថា ចំណូលពន្ធដារជះឥទ្ធិពលជាវិជ្ជមានរយៈពេល

វែងលើកំណើនចំណាយសធារណៈ។ ដូចនេះ សេចក្តីសន្និដ្ឋានដែលមានលក្ខណៈតក្កមួយត្រូវបានលើកឡើង ចំណូលពន្ធដារពិតជាអាចជះឥទ្ធិពលធ្វើឱ្យមានបំរែបំរួលដល់កំណើនសេដ្ឋកិច្ចនៅកម្ពុជា តាមរយៈកំណើនតម្រូវការ ដែលជាលទ្ធផលនាំឱ្យមានកំណើនសេដ្ឋកិច្ច ហើយអភិបាលកិច្ចសារពើពន្ធល្អ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពត្រូវតែជាលក្ខខណ្ឌចាំបាច់។ គួរបញ្ជាក់ថា លទ្ធផលសិក្សាខាងលើនេះមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងការសិក្សានៅបណ្ដាប្រទេសមួយចំនួនដូចជា ការសិក្សានៅប្រទេសនីហ្សេរីយ៉ា (២០១៣) ការសិក្សានៅប្រទេសអាហ្វ្រិកខាងលិច(ECOWAS) រួមមាន នីហ្សេរីយ៉ា ហ្គាណា សៀរ៉ាឡេអូន បេនីន និងប៊ូគីណាហ្វាសូ (២០១៨) ការសិក្សានៅប្រទេសតួគី(២០១២) ការសិក្សានៅប្រទេសកេនយ៉ា (២០១២) ការសិក្សានៅសហរដ្ឋអាមេរិក(២០១៧) និងការសិក្សានៅប្រទេសក្រិក(២០០៥)។ ម្យ៉ាងទៀត ក៏មានការសិក្សាតាមបណ្ដាប្រទេសមួយចំនួនទៀត រកឃើញលទ្ធផលខុសគ្នាពីការសិក្សានៅកម្ពុជាផងដែររួមមាន ការសិក្សានៅប្រទេសប៉ាគីស្ថាន(២០២២) ការសិក្សានៅប្រទេសនីហ្សេរីយ៉ា(២០១៩) ការសិក្សានៅប្រទេសអាហ្វ្រិចខាងត្បូង(២០១៨) និងការសិក្សានៅប្រទេសហ្សកដានី(២០១៧)ជាដើម។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលសិក្សាស្តីពី"**ឥទ្ធិពលពន្ធចំណូលពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា**" ដោយប្រើប្រាស់ម៉ូដែល ARDL (ARDL Bounds Test) បង្ហាញថា ចំណូលពន្ធដារជះឥទ្ធិពល និងមានទំនាក់ទំនងជាវិជ្ជមានរយៈពេលវែងនិងរយៈពេលខ្លីលើកំណើនសេដ្ឋកិច្ចកម្ពុជា ពោលគឺចំណូលពន្ធដារត្រូវបានប្រើប្រាស់ជាឧបករណ៍គោលនយោបាយដ៏មានឥទ្ធិពលទាំងសម្រាប់រយៈពេលវែង និងរយៈពេលខ្លី ដើម្បីសម្រេចគោលដៅលើកកម្ពស់កំណើនសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ការប្រមូលចំណូលពន្ធដារកើនឡើងតម្រូវឱ្យមានអភិបាលកិច្ចសារពើពន្ធល្អ ប្រកដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពជាលក្ខខណ្ឌចាំបាច់ ដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ច។ ផ្អែកលើទ្រឹស្តីនយោបាយសង្គម(Socio political theory) បានកំណត់ថាប្រព័ន្ធពន្ធដារមិនគួរត្រូវបានបង្កើតឡើងដើម្បីបម្រើបុគ្គលនោះទេ ប៉ុន្តែគួរតែត្រូវបានប្រើដើម្បីព្យាបាលជំងឺរបស់សង្គមទាំងមូល ហើយតម្រូវការសម្រាប់រដ្ឋាភិបាលក្នុងការប្រើប្រាស់ចំណូលពន្ធប្រកបដោយប្រសិទ្ធភាព គឺដើម្បីផ្តល់មធ្យោបាយសេដ្ឋកិច្ច និងសង្គមដល់ប្រជាជន តាមរយៈការពង្រីក និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ទ្រឹស្តីនេះបានបញ្ជាក់បន្ថែមថា ដើម្បីទទួលបានប្រាក់ចំណូលជាតិកាន់តែច្រើន គោលនយោបាយពន្ធត្រូវតែអាចទទួលយកបានដោយប្រជាជន ពោលគឺប្រព័ន្ធពន្ធដារមួយ ត្រូវតែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ដូចនេះ រាជរដ្ឋាភិបាលគួរអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយស្តីពីសារពើពន្ធឱ្យមានភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងដាច់ខាត ហើយបន្តផ្សព្វផ្សាយព័ត៌មាន និងអប់រំស្តីពី ច្បាប់ បទបញ្ញត្តិនិងគោលនយោបាយស្តីពីសារពើពន្ធ ឱ្យបានទូលំទូលាយជ្រាបដល់ប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ និងនៅគ្រប់ទីកន្លែងទូទាំងប្រទេស ដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងពីសិទ្ធ និងកាតព្វកិច្ចបង់ពន្ធរបស់ខ្លួនបានច្បាស់លាស់

បន្តប្រើប្រាស់យន្តការបច្ចេកវិទ្យាឌីជីថលឱ្យបានទូលំទូលាយ និងជាពិសេសត្រូវឆ្ពោះទៅរកការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិមិត្ត(AI)ក្នុងកិច្ចការសារពើពន្ធ បន្តលើកស្ទួយវប្បធម៌បង់ពន្ធ និងដោយស្ម័គ្រចិត្ត បន្តពង្រឹងសមត្ថភាពមន្ត្រីនៅតាមមូលដ្ឋានឱ្យអនុវត្ត និងយល់ដឹងពីច្បាប់ បទបញ្ញត្តិស្តីពីសារពើពន្ធឱ្យបានច្បាស់លាស់ និងមានសង្គតិភាពជាមួយគ្នាជាឯកច្ឆន្ទក្នុងចំណោមមន្ត្រីរដ្ឋបាលសារពើពន្ធចំពោះការបកស្រាយ និងការពន្យល់ដល់អ្នកជាប់ពន្ធ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលគួររៀបចំ និងចងក្រងរាល់បទប្បញ្ញត្តិស្តីពីសារពើពន្ធឱ្យមានភាពប្រទាក់ក្រឡាគ្នា ពិភាក្សានិងត្រួតពិនិត្យឱ្យបានច្បាស់លាស់ប្រកបដោយគណនេយ្យភាព និងការទទួលខុសត្រូវមុនដាក់ចេញឱ្យអនុវត្ត។ ទន្ទឹមគ្នាផងដែរ រាជរដ្ឋាភិបាលគួរទប់ស្កាត់អំពើគេចវេះពន្ធ លុបបំបាត់អំពើពុករលួយក្នុងកិច្ចការសារពើពន្ធ និងទប់ស្កាត់ការបន្លំពន្ធ ក្នុងចំណោមអ្នកជាប់ពន្ធឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពតាមរយៈការពង្រឹងនីតិវិធីសវនកម្មសារពើពន្ធ ឬនីតិវិធីស៊ើបអង្កេតបទល្មើសសារពើពន្ធ ឬអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយដោយឆ្លើយតបឱ្យបានទាន់ពេលវេលា។

# ការធ្វើឱ្យប្រសើរឡើងលើមាន់ស្រុកតាមរយៈការបង្កាត់ពូជ ដោយសិប្បនិម្មិត

បេក្ខជនបណ្ឌិត៖ **ហ៊ន់ ហៀក**
ជំនាញ៖ **វិទ្យាសាស្ត្រសត្វ**

**សង្ខេប**

ការងារពិសោធន៍នេះធ្វើឡើងនៅក្នុងស្ថានីយ៍ចិញ្ចឹមសត្វរបស់មហាវិទ្យាល័យវិទ្យា ស្រាស្ត្រសត្វនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ការពិសោធនេះប្រើរយៈពេល ៧០ថ្ងៃ គឺគិតចាប់ពីថ្ងៃទី៨ ខែមិថុនា ដល់ទី១៨ ខែសីហា ឆ្នាំ២០២១។ ការពិសោធនេះបានបែងចែកតាមគំរូប្លង់ពិសោធន៍ (CRD) ដែលមានមាន់សរុបចំនួន៤២ក្បាល បែងចែកជា ៣ក្រុម ($T_1$, $T_2$, $T_3$) និង ២សា ហើយក្នុងមួយសាៗមានមាន់ចំនួន២១ក្បាល ក្នុងនោះមានមេចំនួន១៨ក្បាល និងបាចំនួន៣ក្បាល។ ក្នុងមួយក្រុមៗមានបាចំនួន១ក្បាល និងមេចំនួន៦ក្បាល។ ដោយពិសោធន៍លើបាចំនួនបីពូជផ្សេងៗគ្នា៖ ពូជមាន់ជល់ ពូជមាន់ស្លួយ និងពូជមាន់កណ្ដូង ដោយបង្កាត់ជាមួយមេមាន់នៅក្នុងស្រុក។ ក្រុម$T_1$= ពូជមាន់ជល់ ក្រុម$T_2$= ពូជមាន់ស្លួយ ក្រុម$T_3$= ពូជមាន់កណ្ដូង ដែលការបង្កាត់ពូជដើម្បីប្រៀបធៀបរកបរិមាណស៊ុត អត្រាបង្កកំណើត អត្រាញាស់ និងគុណភាពកូន។ ជាលទ្ធផលនៃការពិសោធខាងលើបានបង្ហាញថា បរិមាណស៊ុតក្រុម$T_1$=( ១៧,៦៥ ±២,៦៨៧) ហើយក្រុមបន្ទាប់ $T_2$=( ១៧,៥ ±២,៦៨៧ ) និង $T_3$=(១៧,៥ ± ៣,១៩៣ មានបរិមាណស៊ុតដូចគ្នា តែខុសគ្នាត្រង់គម្លាតស្តង់ដា $T_2$=( ± ២,៦៨៧) និង $T_3$=( ± ៣,១៩៣)។ ចំណែកឯអត្រាបង្កកំណើតវិញនោះ $T_1$=(១៦,៥ ± ៧,៦៣៦ ), $T_2$= ( ១២,០៥±០,០៣០), $T_3$= (៨,៩០±៤,៤៥៥) ($T_1$>$T_2$>$T_3$)ដោយ$p$<០,០៥។

ចំពោះអត្រាញាស់វិញនោះគឺ $T_1$=±២,១៩២) $T_2$=(១១,២៥±១,៩៨០)$T_3$=(៩,១០±៧,០៧១) ($T_1$>$T_2$>$T_3$

តាមទិន្នន័យខាងលើនេះបានបញ្ជាក់ថា ក្រុម$T_1$ មានអត្រាបង្កកំណើត អត្រាញាស់ ទម្ងន់ និងការលូតលាស់របស់កូនល្អជាងគេ ($T_1$> $T_2$ > $T_3$)។

ដូច្នេះ យើងអាចសន្និដ្ឋានបានថា ក្រុម$T_1$= ពូជមាន់ជល់ មានលទ្ធផលល្អជាងក្រុមផ្សេងៗទៅលើលទ្ធភាពបង្កកំណើត អត្រាញាស់ ទម្ងន់ និងការលូតលាស់របស់កូនល្អជាងគេយ៉ាងពិតប្រាកដ។

## ១. សេចក្ដីផ្ដើម

នាពេលបច្ចុប្បន្ននៅបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍បានអនុវត្តចិញ្ចឹមមាន់ក្នុងកសិដ្ឋានធំៗ ដោយប្រើប្រាស់ការបង្កាត់ពូជដោយសិប្បនិម្មិត។ ដើម្បីឱ្យការចិញ្ចឹមសត្វរបស់គេមានលក្ខណៈជឿនលឿនទាំងបរិមាណ គុណភាព និងផ្គត់ផ្គង់តម្រូវការតាមទីផ្សារដែលគេចង់បាន(យុត យុនចក្រី, សារណាបញ្ចប់ឆ្នាំ២០០១)។ បើតាមសន្និបាតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការបរទេស(២០១៨-២០១៩) ការចិញ្ចឹមសត្វត្រូវគេចាត់ទុកជាអាទិភាពទី២ បន្ទាប់ពីដំណាំស្រូវ។ ក្នុងនោះការចិញ្ចឹមសត្វមានច្រើនប្រភេទណាស់ តែសត្វដែលងាយស្រួលចិញ្ចឹមជាងគេ គឺពពួកបក្សី បក្សីដើរត្តួយ៉ាងសំខាន់នៅក្នុងផលិតកម្ម

ដោយវដ្តផលិតកម្មរបស់វាមានរយៈពេលខ្លី ហើយសត្វមាន់គេនិយមចិញ្ចឹមយ៉ាងខ្លាំងជាងគេ ព្រោះវាមានភាពធន់ទ្រាំទៅនឹងឥទ្ធិពលបរិយាកាសខាងក្រៅបានល្អ បើធៀបទៅនឹងបក្សីដទៃទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការចិញ្ចឹមមាន់ឱ្យទទួលបានទិន្នផលខ្ពស់នោះគឺ អាស្រ័យលើកត្តាមួយចំនួនដូចជា កត្តាពូជ ចំណី ការថែទាំ និងការគ្រប់គ្រង។ បើក្រឡេកមកមើលប្រទេសកម្ពុជាយើងវិញ ការចិញ្ចឹមមាន់ពុំទាន់មានការរីកចម្រើននៅឡើយទេ ជាពិសេស ការចិញ្ចឹមសត្វរបស់ប្រជាកសិករនៅមានកម្រិតទាបនៅឡើយលើការបង្កាត់ពូជដោយសិប្បនិម្មិត និងកសិករផ្សេងៗទៀតនៅមានគំនិតបែបបុរាណនៅឡើយក្នុងការអនុវត្តការបង្កាត់ពូជតាមបែបធម្មជាតិដែលជាហេតុធ្វើឱ្យមាន់របស់ពួកគាត់មានការជាន់ឈាម រីឯទិន្នផលដែលទទួលបាន គឺសត្វមានមាឌតូចៗ និងមានការលូតលាស់យឺត(គម្រោងបង្ហាញបច្ចេកវិទ្យាតំបន់ទន្លេសាប, ២០១៣)។ ចំណែកនៅតាមបណ្តាកសិដ្ឋានធំៗ គេចិញ្ចឹមមាន់តាមបែបឧស្សាហកម្ម ដោយប្រើប្រាស់ពូជនាំចូលពីបរទេស ហើយសុទ្ធតែពូជមាន់ល្អៗដែល គេយកមកបង្កាត់ពូជដោយសិប្បនិម្មិត ដែលប្រើប្រាស់បាតិចសម្រាប់ការបង្កាត់ជាមួយមេបានច្រើនក្បាល ហើយទទួលបានលទ្ធផលគួរជាទីគាប់ចិត្តទាំងផ្នែកបរិមាណ គុណភាព ចំណេញពេលវេលា ថវិកា និងកម្លាំងពលកម្មទៀតផង (គម្រោងបង្ហាញបច្ចេកវិទ្យាតំបន់ទន្លេសាប, ២០១៣)។

## ២. វិធីសាស្ត្រស្រាវជ្រាវ

### ២.១. ទីតាំង និងពេលវេលាពិសោធន៍

ការសិក្សាពិសោធន៍នេះ បានធ្វើឡើងនៅស្ថានីយពិសោធន៍សត្វរបស់មហាវិទ្យាល័យ វិទ្យាសាស្ត្រសត្វនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ ការពិសោធន៍នេះធ្វើឡើងនៅថ្ងៃទី៨ ខែមិថុនា ដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១។

### ២.២ ការបែងចែកក្រុមពិសោធន៍

ការពិសោធនេះរៀបចំតាមគំរូ Completely Randomized Design (CRD)។ មាន់ដែលយកមកពិសោធន៍ចំនួន៤២ក្បាលដែលត្រូវបែងចែកជាបីក្រុម ($T_1$ $T_2$ $T_3$) ក្នុងមួយក្រុមៗមានមាន់ចំនួន៧ក្បាល មេចំនួន៦ក្បាល និងបាចំនួន១ក្បាល ដែលក្រុមនីមួយៗត្រូវធ្វើពិសោធន៍ចំនួនពីរសា។ ក្នុងការពិសោធនេះ ប្រើបាបីពូជផ្សេងៗគ្នា គឺក្រុម$T_1$ =ពូជមាន់ជល់ ក្រុម$T_2$=ពូជមាន់ស្លួយ និងក្រុម$T_3$= ពូជមាន់កណ្តូងដែលការបង្កាត់ជាមួយមេមាន់ក្នុងស្រុក។

ការបែងចែកប្លង់ពិសោធន៍

| | | |
|---|---|---|
| $T_3R_1$ | $T_1R_2$ | $T_2R_1$ |
| $T_2R_2$ | $T_1R_1$ | $T_3R_2$ |

### ២.៣ ការប្រមូលទិន្នន័យ

ទិន្នន័យដែលប្រមូលបានមាន បរិមាណស៊ុត អត្រាបង្កកំណើត អាត្រាញាស់ និងទម្ងន់កូន ហើយរក្សាទុកក្នុងកម្មវិធី (Microsoft office Excel 2010) និងវិភាគតាមកម្មវិធី (SPSS 18.0 statistical package for Social Science)។

## ៣. លទ្ធផល

យោងតាមតារាងទី៤,១ ក្រាហ្វិចទី៤,២ និងដ្យាក្រាមទី៤,១ ខាងលើនេះបានបង្ហាញថា ចំនួនស៊ុតប្រចាំសប្តាហ៍នីមួយៗរបស់ក្រុមនីមួយៗគឺ ចាប់ពីសប្តាហ៍ទី១ រហូតដល់សប្តាហ៍ទី១០ មានលក្ខណៈខុសគ្នាតាមស្ថិតិសាស្ត្រ ដោយ P< 0,05។

ដូច្នេះហើយក្រុមដែលមានបរិមាណស៊ុតច្រើនជាងគេក្នុងការពិសោធនោះ គឺៈ

ក្រុម$T_1$=(១៧,៦៥±២,៦៨៧) ហើយក្រុមបន្ទាប់ $T_2$=(១៧,៥±២,៦៨៧) និង $T_3$=(១៧,៥±៣,១៩៣) មានបរិមាណស៊ុតដូចគ្នា តែខុសគ្នាត្រង់គម្លាតស្តង់ដា $T_2$=(±២,៦៨៧) និង $T_3$=(±៣,១៩៣)។




សប្តាហ៍ទី១ ដល់សប្តាហ៍ទី៣ មានការថយចុះទម្ងន់ ព្រោះស៊ុតនីមួយៗមានការថយចុះនៅសារជាតុទឹក។

### ៣.១ អត្រាបង្កកំណើតរបស់ស៊ុតគិតជាមធ្យមប្រចាំសប្តាហ៍

តារាងទី ៣,១ អត្រាបង្កកំណើតរបស់ស៊ុតគិតជាមធ្យម (N =១២)

| សប្តាហ៍ | ប៉ារ៉ាម៉ែត | $T_1$ | $T_2$ | $T_3$ | p |
|---|---|---|---|---|---|
| សប្តាហ៍ទី១ | S ± | ៤,៩៥0 | ២,៨២៨ | ២,៨២៨ | 0,៩១៥ |
| សប្តាហ៍ទី២ | S ± | ៨,៤៨៤ | ៨,៤៨៥ | ៤,២៤៣ | 0,៧២0 |
| សប្តាហ៍ទី៣ | S ± | ១៤,១៤២ | ៩,៨៩៩ | ៤,៩៥0 | 0,៦៤៤ |
| សប្តាហ៍ទី៤ | S ± | ២,៨២៨ | ១,៤១៤ | ៥,៦៥៧ | 0,៧២៨ |
| សប្តាហ៍ទី៥ | S ± | ៦,៣៦៤ | ៧,៧៧៨ | ៧,0៧១ | 0,៩៨៩ |
| សប្តាហ៍ទី៦ | S ± | ៤,៩៥0 | ៥,៦៥៧ | ២,៨២៨ | 0,៨៥៩ |
| សប្តាហ៍ទី៧ | S ± | ១២,0២១ | ៨,៤៨៥ | ៤,៩៥0 | 0,៨២៣ |
| សប្តាហ៍ទី៨ | S ± | ១៣,៤២៥ | ៦,៣៦៤ | ២,១២១ | 0,៤៥១ |
| សប្តាហ៍ទី៩ | S ± | ៣,៥៣៦ | ៤,៤៤៣ | ៦,៣៦៤ | 0,៩៥0 |
| សប្តាហ៍ទី១0 | S ± | ៥,៦៥៧ | ៤,៩៥0 | ៣,៥៣៦ | 0,៨៦៧ |
| មធ្យមភាគ | S ± | ៧,៦៣៦ | ៦,0៣0 | ៤,៤៥៥ | 0,៩៥៣ |

សម្គាល់៖ អក្សរ a,b តំណាងកម្រិតនៃការប្រៀបធៀបមធ្យមភាគនៃអត្រាបង្កកំណើតរបស់ស៊ុតដែលកំណត់ដោយ $a>b$ ។

យោងតាមតារាងទី៣,១ ក្រាហ្វិចទី៣,១ និងដ្យាក្រាមទី៣,២ ខាងលើនេះបានបង្ហាញថា ចំនួនស៊ុតប្រចាំសប្តាហ៍នីមួយៗរបស់ក្រុមនីមួយៗគឺ ចាប់ពីសប្តាហ៍ទី១ រហូតដល់សប្តាហ៍ទី១០ មានលក្ខណៈខុសគ្នាតាមស្ថិតិសាស្ត្រ ដោយ $P< 0,05$។

ដូច្នេះហើយក្រុមដែលមានបរិមាណស៊ុតច្រើនជាងគេក្នុងការពិសោធនោះ គឺ៖

ក្រុម$T_1$=(១៧,៦៥ ±២,៦៨៧) ហើយក្រុមបន្ទាប់ $T_2$=(១៧,៥ ± ២,៦៨៧) និង $T_3$=(១៧,៥±៣,១៩៣) មានបរិមាណស៊ុតដូចគ្នា តែខុសគ្នាត្រង់គម្លាតស្តង់ដា $T_2$=(±២,៦៨៧) និង$T_3$=(±៣,១៩៣)។

ក្រាហ្វិចទី ៣.១ អត្រាបង្កកំណើតរបស់ស៊ុតប្រចាំសប្តាហ៍




ដ្យាក្រាមទី ៣.១ អត្រាបង្កកំណើតរបស់ស៊ុតប្រចាំសប្តាហ៍



យោងតាម ក្រាហ្វិចទី៤.១ និងដ្យាក្រាមទី៤.១ ខាងលើបានបង្ហាញថា អត្រាបង្កកំណើត របស់ស៊ុតនៃក្រុមទាំង៣ មានការបង្កកំណើតខ្ពស់នៅសប្តាហ៍ទី៣ សប្តាហ៍ទី៧ សប្តាហ៍ទី៨ ដែលមាន ការបង្កកំណើតខ្ពស់ជាងសប្តាហ៍ទី១ សប្តាហ៍ទី២ សប្តាហ៍ទី៤ សប្តាហ៍ទី៥ សប្តាហ៍ទី៩ និងសប្តាហ៍ទី ១០ ហើយក្រុមដែលមានអត្រាបង្កកំណើតទាបជាងគេនៅសប្តាហ៍ទី៨ ក្រុមទីT3 និងក្រុមដែលមាន អត្រាបង្កកំណើតខ្ពស់ជាងគេនៅសប្តាហ៍ទី៨ ក្រុមទី១ ជាស្ថិតិសាស្ត្រដោយ P < 0,05 ។

## ៣.២ អត្រាញាស់របស់ស៊ុតគិតជាមធ្យមប្រចាំសប្តាហ៍ ( N =១២)

| សប្តាហ៍ | ប៉ារ៉ាម៉ែត | $T_1$ | $T_2$ | $T_3$ | P |
|---|---|---|---|---|---|
| សប្តាហ៍ទី១ | $S\pm$ | ២,៨២៨ | ០,៧០៧ | ០,០០០ | ០,៤០៦ |
| សប្តាហ៍ទី២ | $S\pm$ | ៤,២៤៣ | ១,៤១៤ | ០,០០០ | ០,៤១៤ |
| សប្តាហ៍ទី៣ | $S\pm$ | ០,៧០៧ | ១,៤១៤ | ០,០០០ | ០,០២១ |
| សប្តាហ៍ទី៤ | $S\pm$ | ២,៨២៨ | ១,៤១៤ | ០,០០ | ០,០៧២ |
| សប្តាហ៍ទី៥ | $S\pm$ | ០,៧០៧ | ២,៨២៨ | ០,០០០ | ០,៣៥៩ |
| សប្តាហ៍ទី៦ | $S\pm$ | ១,៤១៤ | ១,៤១៤ | ០,០០០ | ០,២៨១ |
| សប្តាហ៍ទី៧ | $S\pm$ | ០,៧០៧ | ៤,៩៥០ | ០,០០០ | ០,៤៧០ |
| សប្តាហ៍ទី៨ | $S\pm$ | ២,៨២៨ | ១,៤១៤ | ០,០០ | ០,០០៥ |
| សប្តាហ៍ទី៩ | $S\pm$ | ៣,៥៣៦ | ២,៨២៨ | ០,០០០ | ០,៥៩៩ |
| សប្តាហ៍ទី១០ | $S\pm$ | ២,១២១ | ១,៤១៤ | ៧,០៧១ | ០,៦៨៣ |
| មធ្យមភាគ | $S\pm$ | ២,១៩២ | ១,៩៨០ | ៧,០៧១ | ០,៨៥១ |

ដ្យាក្រាមទី៣.២ អត្រាញាស់របស់ស៊ុតគិតជាមធ្យមប្រចាំសប្តាហ៍




យោងតាម ក្រាហ្វិចទី៣.២ និងដ្យាក្រាមទី៣.២ ខាងលើនេះបានបង្ហាញថា ក្រុមទាំង៣ ដែលមានអត្រាញាស់ខ្ពស់នៅសប្តាហ៍ទី៣ និងសប្តាហ៍ទី៧ ហើយក្រុមដែលមានអត្រាញាស់ទាបជាងគេ សប្តាហ៍ទី៨ ក្រុម$T_3$ ហើយ ក្រុម$T_2$ ក្រុម$T_3$ នៅសប្តាហ៍ទី៥ មានអត្រាញាស់ដូចគ្នា និងអត្រាញាស់ពី សប្តាហ៍ទី១ ដល់សប្តាហ៍ទី១០ មានលក្ខណៈខុសគ្នាជាស្ថិតិសាស្ត្រដោយ P<0,05។

ដូច្នេះ អត្រាញាស់របស់ក្រុមនីមួយៗគិតជាមធ្យមគឺ៖

- $T_1$ = (១២,៤០±២,១៩២)
- $T_2$ = (១១,២៥±១,៩៨០)
- $T_3$ = (៩,១០±៧,០៧១)
- ($T_1$>$T_2$>$T_3$)

ដ្យាមក្រាមទី៣.៣ ទម្ងន់ជាមធ្យមគិតជាក្រាម




បើយោងតាម ដ្យាក្រាមទី៣,៣ បានបង្ហាញថា ទម្ងន់កូនមាន់នៃក្រុមទាំង៣ មានលក្ខណៈខុសគ្នា $T_1$>$T_2$>$T_3$។

## ៤.ការពិភាក្សា

### ៤.១ បរិមាណស៊ុត

យោងតាមការពិសោធទាំងក្រុម៣ខាងលើ បានបង្ហាញថា ក្រុមដែលបង្កាត់ជាមួយបាពូជមាន់ដល់ផ្តល់បរិមាណស៊ុតច្រើនជាងក្រុមដែលបង្កាត់ជាមួយបាពូជមាន់ស្អួយ និងពូជមាន់កណ្តូង ពិសេសនៅសប្តាហ៍ទី៣ គិតជាមធ្យម ក្រុម$T_1$= ២៧,០០, ក្រុម$T_2$= ១៩,០០ និងក្រុម$T_3$= ២២,០០។ បើគិតជាមធ្យមភាគនៅសប្តាហ៍ទី៣ $T_1$=៣២,១៤%, $T_2$= ២២,៦១%, និង$T_3$= ២៦,១៩%។

បើយើងធៀបជាមួយពូជ Kaen Thong = ៦៤,៨២%,ពូជ Mook Esarn = ៥៩,៤៦% និងពូជ Soi Nin = ៥៧,៨៦% (លោក ស្រ៊ីវ ធារ៉ា)។

### ៤.២ អត្រាញាស់

មានអត្រាញាស់ខ្ពស់នៅសប្តាហ៍ទី៣ និងសប្តាហ៍ទី៧ ហើយក្រុមដែលមានអត្រាញាស់ទាបជាងគេសប្តាហ៍ទី៨ ក្រុមT3 ហើយក្រុមT2 ក្រុមT3 នៅសប្តាហ៍ទី៥ មានអត្រាញាស់ដូចគ្នា និងអត្រាញាស់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី១០ មានលក្ខណៈខុសគ្នាជាស្ថិតិសាស្ត្រ។ ពូជ Kaen Thong នៅក្នុងជំនានទី៥ វិញ គឺមានភាគរយកូនញាស់ចំនួន៥៩,៣៧% បន្ទាប់មកគឺពូជ Soi Pet មានភាគរយកូនញាស់ចំនួន៥៤,១៤% និងពូជ Soi Nin មានភាគរយកូនញាស់ចំនួន៤៨,៣២% ហើយពូជ Khai Mook Esarn មានភាគរយកូនញាស់ចំនួន៤៧,៤៧%។

## ៥. សន្និដ្ឋាន

បន្ទាប់ពីពិសោធន៍អស់រយៈពេល ៧០ថ្ងៃ ការបង្កាត់ពូជដោយសិប្បនិម្មិត ដោយប្រើពូជមាន់ជល់ ពូជមាន់ស្លួយ និងពូជមាន់កណ្តូង បង្កាត់ជាមួយមេមាន់នៅក្នុងស្រុកប។ ក្រុម$T_1$= ពូជមាន់ជល់ ក្រុម$T_2$= ពូជមាន់ស្លួយ ក្រុម$T_3$= ពូជមាន់កណ្តូង ដោយការបង្កាត់ដើម្បីប្រៀបធៀបរិមាណស៊ុត អត្រាបង្កកំណើត អត្រាញាស់ និងគុណភាពកូន។

ជាលទ្ធផលនៃការសិក្សាខាងលើបានបង្ហាញថា បរិមាណស៊ុតរបស់ក្រុមទាំង៣ មានការកើនឡើងខ្ពស់ចាប់ពីសប្តាហ៍ទី១ ដល់ទី៣ រួចបរិមាណស៊ុតថយចុះមកចាប់ពីសប្តាហ៍ទី៤ មកសប្តាហ៍ទី៦ បរិមាណស៊ុតនៃក្រុមនីមួយៗមានការកើនឡើង និងថយចុះរៀងរាល់ ៣សប្តាហ៍ម្តង។ ចំណែកឯទម្ងន់របស់ស៊ុតរបស់ក្រុមនីមួយមានការថយចុះទម្ងន់រហូតចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៣ (ញាស់)។ អត្រាបង្កកំណើតក្រុមដែលប្រើពូជមាន់ជល់មានការបង្កកំណើតខ្ពស់ជាងក្រុមដែលប្រើពូជមាន់ស្លួយ និងពូជមាន់កណ្តូង។

ចំពោះអត្រាញាស់វិញឃើញថា ក្រុមដែលប្រើបាពូជមាន់ជល់ គឺស៊ុតមានអត្រាញាស់ខ្ពស់ជាងក្រុមផ្សេងៗផងដែរ ហើយក្រុមដែលប្រើបាពូជមាន់កណ្តូងស៊ុតមានអត្រាញាស់ទាបបើធៀបជាមួយបាពូជមាន់ជល់ ពូជមាន់កណ្តូង។ ម្យ៉ាងវិញទៀត បើនិយាយពីសុខភាពកូនគឺឃើញកូនមាន់ដែលចេញពីបាពូជមាន់ជល់គឺមានសុខភាពល្អជាក្រុមផ្សេងៗ និងកូនមាន់រឹងមាំ កម្លាំងខ្លាំងក្លា តែបើយើងមកប្រៀបធៀបជាមួយកូនមាន់កណ្តូង ព្រោះកូនមាន់កណ្តូងមិនសូវមានរោមច្រើននោះទេ។

ចងចាំថាពូជមាន់ជល់ជាពូជមួយដែលមានឥទ្ធិពលខ្លាំងខ្លាទាំងកាយសម្បាទារឹងមាំ ទាំងកម្លាំងក្នុងការប្រយុទ្ធជាមួយសត្រូវ។ ម្យ៉ាងវិញទៀត ពូជនេះជាមួយដែលមានការជ្រើសរើសត្រឹមត្រូវបំផុតសម្រាប់ទុកមេបាពីសំណាក់អ្នកចិញ្ចឹមសត្វ និងពូជមាន់មួយនេះមានការថែទាំយ៉ាងយកចិត្តទុកពីម្ចាស់បានយ៉ាងល្អប្រសើរ។

## ឯកសារយោង


១. E.S.E.Hafez.B.Gafez: Reproduction In Farm Animal.7h Edication , 2000

២. Lam Quang 1994

៣. By Jean E.Sander 28 June 2019

៤. Msc Thesis Habtie Arega Kidie ( February 2019 )

៥. Nigussie D ( 2011 ). Breeding Programs For Indigenous Chicken In Ethiopia: Analysis Of Diversity In Production Systems And Chicken Populations. Phd Thesis, Wageningen University, The Netherlands ( 2011 ), 148 P

៦. Fisseha M ( 2009 ). Studies On Production And Marketing System Of Local Chicken Ecotypes In Bure Wereda, North West Amhara. M.Sc. Thesis, Hawassa University, Hawassa, Ethiopia. 166 P.

៧. Fisseha M, Abera M, Tadelle Dessie ( 2010 ). Assessment Of Village Chicken Production System And Evaluation Of The Productive And Reproductive Performance Of Local Chicken Ecotype In Bure District, North West Ethiopia. Afr. J. Agric. Res. 5( 13 ):1739-174.

# បញ្ហាប្រឈមរបស់សិស្សលើការប្រឡងមុខវិជ្ជាភាសាអង់គ្លេស
# នៅកម្រិតមធ្យមសិក្សាទុតិយភូមិជាមុខវិជ្ជាស្ម័គ្រចិត្ត

បេក្ខជនបណ្ឌិតៈ **តាក់ ដា**
ជំនាញៈ **វិទ្យាសាស្ត្រអប់រំ**

## សេចក្តីផ្តើម

ការប្រឡងមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាបានបែងចែកជា ២ថ្នាក់ខុសគ្នាគឺថ្នាក់វិទ្យាសាស្ត្រពិត និងថ្នាក់វិទ្យាសាស្ត្រសង្គម។ ថ្នាក់ទាំង២នេះមានមុខវិជ្ជាសិក្សាគោលដូចគ្នាចំនួន៣គឺ គណិតវិទ្យា អក្សរសាស្ត្រខ្មែរ និងភាសាបរទេស គឺភាសាអង់គ្លេស។ ការប្រឡងត្រូវបានក្រសួងអប់រំ យុវជន និងកីឡា រៀបចំ និងមានសេចក្តីណែនាំនៅដើមឆ្នាំសិក្សាទាំងការដាក់របបពិន្ទុ និងនីតិវិធីនានាក្នុងដំណើរការនៃការរៀបចំ និងប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិគ្រប់ឆ្នាំសិក្សា។

## ១- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាអង់គ្លេស

### ១.១- ការរៀបចំវិញ្ញាសា ការកំណត់ថេរវេលា និងរបបពិន្ទុ

| ល.រ. | វិញ្ញាសា | ថ្នាក់វិទ្យាសាស្ត្រពិត | | ថ្នាក់វិទ្យាសាស្ត្រសង្គម | |
|---|---|---|---|---|---|
| | | រយៈពេល(នាទី) | ពិន្ទុអតិបរមា | រយៈពេល(នាទី) | ពិន្ទុអតិបរមា |
| ១ | អក្សរសាស្ត្រខ្មែរ | ៩០ | ៧៥ | ១៥០ | ១២៥ |
| ២ | គណិតវិទ្យា | ១៥០ | ១២៥ | ៩០ | ៧៥ |
| ៣ | រូបវិទ្យា | ៩០ | ៧៥ | | |
| ៤ | គីមីវិទ្យា | ៩០ | ៧៥ | | |
| ៥ | ជីវវិទ្យា | ៩០ | ៧៥ | | |
| ៦ | ផែនដី និងបរិស្ថាន | | | | |
| ៧ | សីលធម៌-ពលរដ្ឋវិជ្ជា | | | ៩០ | ៧៥ |
| ៨ | ភូមិវិទ្យា | | | ៩០ | ៧៥ |
| ៩ | ប្រវត្តិវិទ្យា | | | ៩០ | ៧៥ |
| ១០ | ភាសាបរទេស | ៦០ | ៥០ | ៦០ | ៥០ |

វិញ្ញាសាភាសាអង់គ្លេសនៅថ្នាក់ទាំង២ ត្រូវបានចាត់ទុកជាវិញ្ញាសាតាមស្ម័គ្រដោយពិន្ទុត្រូវយក ផលសងនៃពិន្ទុដែលសិស្សទទួលបានពីការប្រឡងជាប់ពិន្ទុត្រូវដកនឹង២៥ ចេញវិញ[១]។ ចំពោះវិញ្ញាសា អង់គ្លេស មិនត្រូវបានចាត់ចូលជាមុខវិជ្ជាមានមេគុណនោះទេ។

[១] ក្រសួងអប់រំ យុវជន និងកីឡាៈ *សេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សាឯកជន សម្រាប់ឆ្នាំសិក្សា២០១៩-២០២០* ដ.ឯ.ម. ទំព័រទី៣

### ១.២- ការកំណត់លំដាប់ពិន្ទុ

ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិត្រូវបានកំណត់ពិន្ទុជាប់ត្រឹម ២៣៧ឡើងទៅ។ ក្នុងនោះការកំណត់និទ្ទេសត្រូវបានកំណត់តាមលំដាប់នៃពិន្ទុផងដែរ។ ខាងក្រោមនេះគឺ ជាតារាងកំណត់ពីលំដាប់ពិន្ទុ និងនិទ្ទេស[២]៖

| និទ្ទេសរួម | ពិន្ទុសរុប | កំណត់ពិន្ទុសរុបចាប់ពី |
|---|---|---|
| A | 427.50 | 427 |
| B | 380.00 | 380 |
| C | 332.50 | 332 |
| D | 285.00 | 285 |
| E | 237.50 | 237 |
| F | <237 | <237 |

ការកំណត់លំដាប់ពិន្ទុរបស់សិស្សក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ទាំងថ្នាក់វិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គមត្រូវបានកំណត់តាមរូបមន្ត[៣]៖

PR=[( n-i+1 )/n]x100

PR ជាលំដាប់ពិន្ទុ

n ជាចំនួនបេក្ខជនដែលបានមកប្រឡងទាំងអស់

i ជាចំណាត់ថ្នាក់របស់បេក្ខជនណាម្នាក់

ឧទាហរណ៍៖ នៅឆ្នាំ២០១៥ មានបេក្ខជនដែលបានប្រឡងទាំងអស់ចំនួន ៨៨ ៤៨៨នាក់ តើបេក្ខជនឈ្មោះ សុខ ច័ន្ទ ដែលបានចំណាត់ថ្នាក់លេខ១១ មានលំដាប់ពិន្ទុប៉ុន្មាន?

PR=[( 88488-11+1 )/88488]x100=99.988

## ២- ការយល់ឃើញរបស់សិស្សលើការប្រឡងមុខវិជ្ជាភាសាអង់គ្លេស

មុខវិជ្ជាភាសាអង់គ្លេសត្រូវបានគេទទួលស្គាល់ថា គឺជាមុខវិជ្ជាដែលបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទទួលបាននិទ្ទេសធ្លាក់(F) ច្រើនជាងគេទាំងអស់។ បញ្ហាទាំងនោះរួមមាន៖ (១)បទពិសោធរបស់សិស្សពីជំនាន់មុន ដែលមិនទាន់មានការសិក្សាបានច្រើនដូចពេលកន្លងមក និងបានបង្ហាញពីការលំបាកនិងបទពិសោធរបស់ខ្លួននាពេលកន្លង។ (២)ការយល់ឃើញរបស់គ្រូឯកទេស

[២] ក្រសួងអប់រំ យុវជន និងកីឡា៖ *សេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សាឯកជន សម្រាប់ឆ្នាំសិក្សា២០១៩-២០២០* ជ.ឯ.ម. ទំព័រទី១០

[៣] ក្រសួងអប់រំ យុវជន និងកីឡា៖ *សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសលេខ155 អយក.ប្រក. ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម្រាប់ឆ្នាំ២០២២-២០២៣* ទំព័រទី១៧

ផ្សេងដែលមិនមែនជាគ្រូភាសាអង់គ្លេស។ ក្នុងន័យនេះ សិស្សរៀនៅថ្នាក់វិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម បានចាប់ផ្ដើមប្ដូរគំនិតលើការសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដោយមានការណែនាំតម្រង់ទិសសិស្សមិនមានមូលដ្ឋានច្បាស់លាស់លើមុខវិជ្ជាភាសាអង់គ្លេស។ (៣) ការដាក់មុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាស្ម័គ្រចិត្តបាននាំឱ្យគ្រូ និងសិស្សមានការភ័ន្តច្រឡំ រហូតដល់មានការណែនាំសិស្សលើការសម្រេចធ្វើ ឬមិនធ្វើលើសន្លឹកកិច្ចការមុខវិជ្ជាភាសាអង់គ្លេស។ (៤)កម្មវិធីសិក្សាមិនទាន់ត្រូវនឹងសមត្ថភាពសិស្ស ឬម្យ៉ាងទៀតសិស្សមិនទាន់មានមូលដ្ឋានគ្រឹះនៃភាសាបានទូលំទូលាយ។ (៥)គ្រូបង្រៀនមិនទាន់បានប្រើប្រាស់វិធីបង្រៀនឱ្យសមស្របនឹងកម្រិតរបស់សិស្ស ក្នុងនោះការអនុវត្តកិច្ចការដែលមានលំនាំជាវិញ្ញាសាប្រឡងផ្លូវការ។ (៦)សិស្សរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ មានទំនោរ និងទទួលបានឥទ្ធិពលទាំង៥ខាងលើ គួបផ្សំនឹងកត្តាជីវសាស្ត្រដែលសិស្សមិនទាន់មានមូលដ្ឋានគ្រឹះភាសាអង់គ្លេស និងភាសាជាតិ។

## ៣- សេចក្ដីសន្និដ្ឋាននៃការប្រឡង និងមិនប្រឡងមុខវិជ្ជាភាសាអង់គ្លេស

សិស្សដែលប្រឡងបានពិន្ទុទៅតាមមុខវិជ្ជា ត្រូវបានបូកតាមមុខវិជ្ជា និងបូកជាមួយមុខវិជ្ជាភាសាអង់គ្លេសត្រូវដកចេញ២៥ពិន្ទុ។ ខាងក្រោមជាឧទាហរណ៍ពិន្ទុរបស់សិស្សម្នាក់៖

| **វិទ្យាសាស្ត្រពិត** | | សិស្សម្នាក់ | | | A | B | C | D | E |
|---|---|---|---|---|---|---|---|---|---|
| | មុខវិជ្ជា | ពិន្ទុអតិបរមារ | ពិន្ទុទទួលបាន | និទ្ទេស | 90% | 80% | 70% | 60% | 50% |
| ១ | ភូមិវិទ្យា | 75 | 46 | D | 68 | 60 | 53 | 45 | 38 |
| ២ | ប្រវត្តិវិទ្យា | 75 | 45 | E | 68 | 60 | 53 | 45 | 38 |
| ៣ | សីលធម៌-ពលរដ្ឋវិជ្ជា | 75 | 50 | D | 68 | 60 | 53 | 45 | 38 |
| ៤ | គណិតវិទ្យា | 75 | 35 | F | 68 | 60 | 53 | 45 | 38 |
| ៥ | អក្សរសាស្ត្រខ្មែរ | 125 | 50 | D | 113 | 100 | 88 | 75 | 63 |
| ៦ | ភាសាបរទេស (ពិន្ទុ-២៥) | 25 | 25 | F | 23 | 20 | 18 | 15 | 13 |
| ៧ | មុខវិជ្ជាជម្រើស(....) | 50 | 35 | F | 45 | 40 | 35 | 30 | 25 |
| | សរុប | 500 | 286 | D | | | | | |
| | ពិន្ទុសរុប | 237.5 | 286 | D | | | | | |

| វិទ្យាសាស្ត្រសង្គម | | សិស្សម្នាក់ | | | A | B | C | D | E |
|---|---|---|---|---|---|---|---|---|---|
| | មុខវិជ្ជា | ពិន្ទុ អតិបរមារ | ពិន្ទុ ទទួលបាន | និទ្ទេស | 90% | 80% | 70% | 60% | 50% |
| ១ | ភូមិវិទ្យា | 75 | 50 | D | 45 | 40 | 35 | 30 | 25 |
| ២ | ប្រវត្តិវិទ្យា | 75 | 25 | F | 23 | 20 | 18 | 15 | 13 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣ | សីលធម៌-ពលរដ្ឋវិជ្ជា | 75 | 30 | F | 27 | 24 | 21 | 18 | 15 |
| ៤ | គណិតវិទ្យា | 75 | 75 | A | 68 | 60 | 53 | 45 | 38 |
| ៥ | អក្សរសាស្ត្រខ្មែរ | 125 | 75 | A | 68 | 60 | 53 | 45 | 38 |
| ៦ | ភាសាបរទេស (ពិន្ទុ-២៥) | 25 | 25 | F | 23 | 20 | 18 | 15 | 13 |
| ៧ | មុខវិជ្ជាជម្រើស(....) | 50 | 20 | F | 18 | 16 | 14 | 12 | 10 |
| ៨ | សរុប | 500 | 300 | D | | | | | |
| ៩ | ពិន្ទុសរុប | 237.5 | 250 | D | | | | | |

## ៤- សេចក្តីសន្និដ្ឋាន

មុខវិជ្ជាក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ទាំងថ្នាក់វិទ្យាសាស្ត្រពិត និងថ្នាក់វិទ្យាសាស្ត្រសង្គមត្រូវបានកំណត់ពិន្ទុជាប់ចាប់ពី ២៣៧.៥០ ឡើងទៅ ពិន្ទុក្រោម ២៣៧ ត្រូវបានកំណត់ឱ្យធ្លាក់។ ក្នុងនោះមុខវិជ្ជាភាសាអង់គ្លេស ដែលអនុវត្តតាមគោលការណ៍ដក២៥ មិនបានកំណត់បានដល់ពិន្ទុជាប់ ឬធ្លាក់នៃលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនោះទេ ប៉ុន្តែវាជាពិន្ទុកំណត់លំដាប់ពិន្ទុនៃការប្រឡងជាប់និទ្ទេសទៅវិញ។ ទោះបីជាយ៉ាងនេះក្តី ក៏ការប្រឡងមុខវិជ្ជាភាសាអង់គ្លេសត្រូវតែអនុវត្តឱ្យបានគ្រប់គ្រាន់និងត្រឹមត្រូវ។

## ៥- អនុសាសន៍

មុខវិជ្ជាភាសាអង់គ្លេសត្រូវដាក់ចូលក្នុងមុខវិជ្ជាចាំបាច់ និងមានកំណែទម្រង់លើសេចក្តីណែនាំស្តីពីការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយក្រសួងអប់រំ យុវជន និងកីឡា មាននាយកដ្ឋានមធ្យមសិក្សា និងនាយកដ្ឋានកិច្ចការប្រឡងអនុវត្តលើរបបពិន្ទុតាមលំនាំមុន។ ការដាក់មុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាស្ម័គ្រចិត្ត និងមិនមានមេគុណជាការជួយសិស្សមួយកម្រិតក្នុងការទទួលបានលទ្ធផលជាប់ចំណាត់ថ្នាក់។ ប៉ុន្តែខ្លឹមសារនេះមិនត្រូវបាន ផ្សព្វផ្សាយឱ្យបានត្រឹមត្រូវនិងទូលំទូលាយនៅឡើយទេ។ ដូច្នេះ ចំពោះការប្រឡងមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាសិស្សចាំបាច់ត្រូវបំពេញកិច្ចការនោះឱ្យបានល្អ និងគ្រប់គ្នា។

ក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានមានភារកិច្ចត្រូវរៀបចំសេចក្តីណែនាំ និងត្រូវរៀបចំចងក្រងសៀវភៅឯកសារគោលសម្រាប់វិញ្ញាសាប្រឡង និងការអភិវឌ្ឍវិញ្ញាសា ក្នុងគោលបំណងឱ្យគ្រូបង្រៀនឯកទេសរៀបចំកិច្ចការសម្រាប់សិស្សអនុវត្ត។ ការរៀបចំសៀវភៅសិក្សាគោល វិធីបង្រៀនត្រូវសិក្សាឱ្យបានច្បាស់លាស់ពីលក្ខណៈវិនិច្ឆ័យលើការលំបាករបស់សិស្សលើការសិក្សាភាសាអង់គ្លេស និងត្រូវបង្កើតមានវគ្គបណ្តុះបណ្តាលបន្ថែមដល់គ្រូបង្រៀនឱ្យបានយ៉ាងហោចណាស់មួយឆ្នាំម្តង។

ការអនុវត្តលើវិញ្ញាសាគ្រប់មុខវិជ្ជា ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានជួយជំរុញឱ្យការសិក្សារបស់សិស្សនៅជំនាន់បន្តបន្ទាប់កាន់តែមានភាពស្វាហាប់ ខិតខំប្រឹងប្រែង និងទទួលបានលទ្ធផលល្អជាងមុន។

ដូច្នេះ ការប្រឡងមុខវិជ្ជាភាសាអង់គ្លេសចាំបាច់ត្រូវតែដាក់ជាមុខវិជ្ជាទូទៅដូចមុខវិជ្ជាដទៃ និងមិនដកពិន្ទុ ដែលទទួលបាននឹង ២៥បន្តទៀតនោះទេ។ ក្រសួងអប់រំ យុវជន និងកីឡា មានលទ្ធភាពគ្រប់គ្រាន់ក្នុងការដាក់ពង្រាយគ្រូភាសាអង់គ្លេសនៅតាមសាលាមធ្យមសិក្សានៅទូទាំងប្រទេសសម្រាប់បង្រៀនលើមុខវិជ្ជាភាសាអង់គ្លេសនេះបាន។

## គន្ថនិទ្ទេស

### ក- ឯកសារជាភាសាខ្មែរ

១- ក្រសួងអប់រំ៖ *កម្មវិធីសិក្សាជីវភាសាអង់គ្លេស សម្រាប់មធ្យមសិក្សាចំណេះទូទៅ* គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ ឆ្នាំ១៩៩១

២- ក្រសួងអប់រំ យុវជន និងកីឡា៖ *កម្មវិធីសិក្សាភាសាអង់គ្លេស គម្រោងកម្មវិធីសិក្សាលម្អិត សម្រាប់ថ្នាក់ទី៦-៨* មិថុនា ១៩៩៤

៣- ក្រសួងអប់រំ យុវជន និងកីឡា៖ *ស្ដីពីការសិក្សាភាសាបារាំង ឬភាសាអង់គ្លេស នៅមធ្យមសិក្សាចំណេះទូទៅ* សេចក្ដីណែនាំលេខ ២៩៨៨ អ.យ.ក. ស.ណ.ន ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៩

៤- ក្រសួងអប់រំ យុវជន និងកីឡា៖ *កម្មវិធីសិក្សាគោល សម្រាប់មធ្យមសិក្សាទុតិយភូមិ* នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០០៨

៥- ក្រសួងអប់រំ យុវជន និងកីឡា៖ *ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅ ថ្នាក់ទី១១-ទី១២* នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ឆ្នាំ២០១១

៦- ចាន់ រដ្ឋសុផា៖ *ប្រវត្តិអប់រំកម្ពុជា ភាគទី៦ ពីឆ្នាំ១៩៧៩ ដល់សព្វថ្ងៃ* ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ២០១២

៧- យិន ធី៖ *បទបង្ហាញស្ដីពីទស្សនទានប្រវត្តិសាស្ត្រនៃកំណែទម្រង់កម្មវិធីសិក្សា ពីឆ្នាំ១៩៧៩ដល់ឆ្នាំ២០១៦* នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ភ្នំពេញ ឆ្នាំ២០១៤

៨- ក្រសួងអប់រំ យុវជន និងកីឡា៖ *English for Cambodia Book 4* គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ២០១៦

៩- ក្រសួងអប់រំ យុវជន និងកីឡា៖ *English for Cambodia Book 6* គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ២០១៦

១០- ក្រសួងអប់រំ យុវជន និងកីឡា៖ *English for Cambodia Book 5* គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ២០១៧

១១- ក្រសួងអប់រំ យុវជន និងកីឡា៖ *កម្មវិធីសិក្សាលម្អិត មុខវិជ្ជាភាសាអង់គ្លេស សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ* ឆ្នាំ២០១៨

១២- ក្រសួងអប់រំ យុវជន និងកីឡា៖ *សេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យម សិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សាឯកជន សម្រាប់ឆ្នាំសិក្សា២០១៩-២០២០* លេខ៣៣ អយក.សណន ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០

១៣- ក្រសួងអប់រំ យុវជន និងកីឡា៖ *សេចក្តីណែនាំស្តីពីការអនុវត្តប្រកាសលេខ155 អយក.ប្រក. ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម្រាប់ឆ្នាំ២០២២-២០២៣*

១៤- ឃិន សុផល៖ *ស្ថិតិសិក្ខាកាមគ្រូបង្រៀនកម្រិតមូលដ្ឋានតាមឆ្នាំសិក្សានីមួយៗ* ការិយាល័យសិក្សានៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ព្រៃវែង ឆ្នាំ២០២៣

**ខ- ឯកសារជាភាសាអង់គ្លេស**

១៥- Claire F. Thorne: < *Education Handbook- Cambodia EDUCAM 1993*> Phnom Penh 1993

១៦- Ministry of Education Youth and Sports: <*English for Cambodia: Teacher Guide Book 4-6*> 1999

**គ- របាយការណ៍លទ្ធផលពីក្រសួងអប់រំ យុវជន និងកីឡា**

១៧- ក្រសួងអប់រំ យុវជន និងកីឡា៖ *លទ្ធផលលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេស មណ្ឌលខេត្តព្រៃវែង ឆ្នាំសិក្សា២០១៣-២០១៤*

១៨- ក្រសួងអប់រំ យុវជន និងកីឡា៖ *លទ្ធផលលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេស មណ្ឌលខេត្តព្រៃវែង ឆ្នាំសិក្សា២០១៤-២០១៥*

១៩- ក្រសួងអប់រំ យុវជន និងកីឡា៖ *លទ្ធផលលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេស មណ្ឌលខេត្តព្រៃវែង ឆ្នាំសិក្សា២០១៥-២០១៦*

២០- ក្រសួងអប់រំ យុវជន និងកីឡា៖ *លទ្ធផលលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេស មណ្ឌលខេត្តព្រៃវែង ឆ្នាំសិក្សា២០១៦-២០១៧*

២១- ក្រសួងអប់រំ យុវជន និងកីឡា៖ *លទ្ធផលលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេស មណ្ឌលខេត្តព្រៃវែង ឆ្នាំសិក្សា២០១៧-២០១៨*

២២- ក្រសួងអប់រំ យុវជន និងកីឡា៖ *លទ្ធផលលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មុខវិជ្ជាភាសាអង់គ្លេស មណ្ឌលខេត្តព្រៃវែង ឆ្នាំសិក្សា២០១៨-២០១៩*

# បញ្ហាប្រឈមនៃការគ្រប់គ្រងធនធានមនុស្ស

បេក្ខជនបណ្ឌិត៖ **ហ៊ុន ដានី**
ជំនាញ៖ **រដ្ឋបាលសាធារណៈ**

ក្នុងដំណើរការនៃការគ្រប់គ្រងធនធានមនុស្ស មានកត្តាជាច្រើនដែលបង្កការរាំងស្ទះក្នុងការគ្រប់គ្រងបុគ្គលិកឱ្យអនុវត្តការងារបានល្អ បើទោះបីជារឿងខ្លះមើលទៅហាក់ដូចជាសាមញ្ញធម្មតា ឬគ្រាន់តែជាកិច្ចការដែលងាយដោះស្រាយបានក៏ដោយ។ ផ្ទុយទៅវិញវាតែងតែកើតមានឡើងជារឿយៗត្រូវបានទទួលស្គាល់ថាជាការណ៍ពិតនៃចំណុចខ្វះខាត ឬជាឧបសគ្គ ក្នុងការគ្រប់គ្រងធនធានមនុស្ស ដែលបញ្ហាទាំងនោះមានដូចជា៖ កង្វះពេលវេលាបំពេញការងាររបស់បុគ្គលិក ការវិវាទគ្នាខាងតម្រូវការសម្ភារៈ និងមធ្យោបាយបំពេញការងារមិនគ្រប់គ្រាន់ គោលនយោបាយតឹងតែង ខ្វះកិច្ចសហប្រតិបត្តិការពីបុគ្គល ផ្នែកឬអង្គភាពដទៃ ការផ្លាស់ប្តូរកន្លែងធ្វើការញឹកញាប់ ការចំណាយខ្ជះខ្ជាយទៅលើម៉ាស៊ីន ឬឧបករណ៍ប្រតិបត្តិការ បរិស្ថាននៅកន្លែងធ្វើការមិនសមស្របជាដើម។ល។ ដែលបញ្ហាទាំងអស់នេះសុទ្ធតែជាបច្ច័យរាំងដល់ផលិតភាពការងារនៅក្នុងអង្គភាព[១]។

បើយោងតាមគេហទំព័រ https://theinvestorsbook.com/human-resource-management-hrm.html បានសរសេរថាអ្នកគ្រប់គ្រងធនធានមនុស្សតែងតែជួបឧបសគ្គក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សដោយសារតែការលេចឡើងនៃបច្ចេកវិទ្យា និងការផ្លាស់ប្តូរលក្ខខណ្ឌនយោបាយ និងសង្គម-សេដ្ឋកិច្ច។ បញ្ហាប្រឈមទាំងនោះមានដូចជា៖

(១)-ការរំពឹងទុកខ្ពស់របស់និយោជិត (Growing Employee Expectation) : ជាមួយនឹងការសិក្សាពីជំនាញថ្មី និងលក្ខណៈសម្បត្តិល្អ ការរំពឹងទុករបស់និយោជិតនៅតែកើនឡើង ដែលបញ្ហានេះវាបានបង្កឱ្យមានការលំបាកសម្រាប់អ្នកគ្រប់គ្រងក្នុងការឆ្លើយតបនឹងការរំពឹងទុកខ្ពស់បែបនេះ។

(២)-កំណើនការងារ និងកម្លាំងពលកម្ម (Growing Size of Workforce) : ជាមួយការកើនឡើងនៃរចនាសម្ព័ន្ធការងាររបស់អង្គភាព ទាមទារបន្ទុកការងារ និងទំហំការងារកាន់តែរីកធំដែរ ដែលបញ្ហានេះដឹកនាំទៅរកការកើនឡើងហួសកម្រិតនៃចំនួនបុគ្គលិក។

(៣)-ការលេចឡើងនៃបច្ចេកវិទ្យាថ្មី (The emergence of New Technology) បច្ចេកវិទ្យាផ្តល់គុណសម្បត្តិច្រើននៅក្នុងដំណើរការការងារ ប៉ុន្តែវាក៏ជាបញ្ហាប្រឈមមួយដែរ ដោយសារវាការវិវត្តថ្មីៗនៅចំពោះមុខ។ បញ្ហានេះទាមទារឱ្យអ្នកគ្រប់គ្រងត្រូវផ្តល់នូវការបណ្តុះបណ្តាលជាប់ជាប្រចាំដល់បុគ្គលិកចាស់ៗ ដើម្បីស្វែងរកសមត្ថភាព ឬទេពកោសល្យថ្មីឱ្យឆ្លើយតបនឹងបរិការណ៍។

(៤)-នយោបាយផ្ទៃក្នុង (Internal Politics) : ពេលខ្លះអ្នកគ្រប់គ្រងធនធានមនុស្សត្រូវប្រឈមជាមួយស្ថានភាពខ្លះដែលមិនសូវអំណោយផលដូចជា ប្រព្រឹត្តកំហុសឆ្គង ឬកង្វះខាតក្នុងការ

[១] Lloyd L. Byars & Leslie W. Rue, *Human Resource Management*, Ninth Edition, 2008, p.216-217

ដឹកនាំ និងការបង្ខំឬដាក់កំហិតឱ្យបុគ្គលិកបំពេញការងាររបស់ពួកគេ ដែលជាបញ្ហាមួយធ្វើឱ្យបុគ្គលិកពុំពេញចិត្ត ហើយធ្វើការផ្លាស់ប្តូរ ឬលាឈប់ពីការងារក៏ថាបាន។

(៥)-ចិត្តវិទ្យាមនុស្ស (Human Psychology) : ការគ្រប់គ្រងធនធានមនុស្សទាក់ទងទៅនឹងកត្តាចិត្តសាស្ត្រ និងជះឥទ្ធិពលដល់អង្គភាពផងដែរ ដោយសារមនុស្សម្នាក់ៗមានចិត្តគំនិតមិនដូចគ្នានោះទេ រីឯការយល់ឃើញក៏មិនដូចគ្នាដែរនៅពេលខ្លះ។ ចំពោះបញ្ហានេះបង្កឱ្យមានភាពស្មុគស្មាញក្នុងការបំពេញចិត្ត និងរកដំណោះស្រាយ។

(៦)-ការផ្លាស់ប្តូរច្បាប់ និងបទប្បញ្ញត្តិ (Changes in Law and Regulations) ដើម្បីការពារផលប្រយោជន៍របស់បុគ្គលិក រដ្ឋាភិបាលដាក់ចេញនូវច្បាប់ និងបទប្បញ្ញត្តិជាក់លាក់ ហើយតម្រូវឱ្យស្ថាប័ន ឬអង្គភាពត្រូវតែអនុវត្តតាម។ ខណៈភ្លាមៗវាជាបញ្ហាលំបាកមួយសម្រាប់អ្នកគ្រប់គ្រងធនធានមនុស្ស ដែលត្រូវងាកមកអនុវត្ត ឬប្រកាន់ខ្ជាប់តាមគោលការណ៍ច្បាប់បែបនេះ ឬបែបនោះ។

(៧)-ការរក្សាទំនាក់ទំនង (Maintenance of Human Relations) : អ្នកគ្រប់គ្រងធនធានមនុស្ស មិនត្រឹមដើរតួនាទីជាអ្នកសម្របសម្រួលក្នុងអង្គភាពប៉ុណ្ណោះទេ ប៉ុន្តែត្រូវព្យាយាមរក្សាទំនាក់ទំនងល្អនៅគ្រប់ផ្នែក ដែលកិច្ចការនេះទាមទារឱ្យមានវិធីសាស្ត្រ និងសិល្បៈក្នុងកិច្ចការទូតជាច្រើន។

**រូបភាពទី១៖ បញ្ហាប្រឈមនៃការគ្រប់គ្រងធនធានមនុស្ស**




ប្រភព៖ គេហទំព័រ https://theinvestorsbook.com/human-resource-management-hrm.html

បទពិសោធន៍មួយចំនួនទៀតដែលអាចចាត់ទុកថាជាចំណុចខ្សោយ ជាការបំផ្លិចបំផ្លាញ ការអាក់ខាន ភាពអន់ថយ ភាពមិនច្បាស់លាស់ក្នុងការគ្រប់គ្រងធនធានមនុស្ស ដែលបង្កើតជាបញ្ហាប្រឈមដ៏ធំក្នុងការគ្រប់គ្រងធនធានមនុស្ស។ បញ្ហាទាំងនោះ មានដូចជាភាពអន់ថយក្នុងការគ្រប់គ្រងមន្ត្រី កង្វះគោលនយោបាយមុខងារសាធារណៈ ឬគោលនយោបាយមិនច្បាស់លាស់ កង្វះប្រព័ន្ធត្រួតពិនិត្យមន្ត្រីរាជការ ការអនុវត្តការងារគ្មានវិជ្ជាជីវៈ កង្វះវិន័យ គ្រួសារនិយម និងអំពើពុករលួយ។ល។[២] មួយវិញ

[២] កៅ មុយថង និងលីវ សុកក្រ្កា ***ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យសាធារណៈ*** ឆ្នាំ២០១៦ ទំព័រ ៤៩

ទៀតសេវាសាធារណៈមានការផ្លាស់ប្តូរលឿន និងជំពេកធ្វើឱ្យមានការលំបាកនិងមិនមានប្រសិទ្ធភាព ជម្លោះខាងនយោបាយ សង្គ្រាមស៊ីវិល ចំនួនមន្ត្រីរាជការមានការរីកប៉ោងឡើង មុខតំណែងត្រូវបានកាន់ច្រើនគ្នា ហើយមានមុខងារត្រួតគ្នា ការកែប្រែតវិយាបថមន្ត្រី ភាពលើសកម្រិតនៃមន្ត្រីដែលខ្វះសមត្ថភាព កង្វះមន្ត្រីដែលមានឆន្ទៈនិងមានជំនាញការងារ។ ករណីខ្លះទៀត មន្ត្រីរើសបានហើយ ប៉ុន្តែបានត្រឹមតែផ្ញើខ្លួនហើយគេចទៅរកការងារធ្វើនៅកន្លែងដទៃ។

បញ្ហាប្រឈមមួយទៀតនៅក្នុងការគ្រប់គ្រងធនធានមនុស្ស គឺការផ្តល់ប្រាក់ខែជូនមន្ត្រីឱ្យបានសមស្រប។ ចំណុចនេះស្ថិតនៅត្រង់ថា អង្គភាពត្រូវការធនធានមនុស្សដែលមានទេពកោសល្យ ប៉ុន្តែអង្គភាពនោះមិនអាចទូទាត់ផ្តល់ជាប្រាក់ខែសមរម្យសម្រាប់មន្ត្រីទាំងនោះបាន ជាហេតុធ្វើឱ្យពួកគេត្រូវចាកចេញពីកន្លែងការងារ ហើយដើរទៅរកកន្លែងការងារជាមួយប្រាក់ខែខ្ពស់ៗ។ បញ្ហានេះក៏ជាហេតុធ្វើឱ្យអង្គភាពនៅតែខ្វះខាតធនធានមនុស្ស ឯការផ្តល់សេវាសាធារណៈនៅតែស្ថិតនៅក្នុងភាពប្រឈមនឹងការលំបាកដដែល។

ចំពោះបណ្តាប្រទេសដែលងើបចេញផុតពីស្ថានភាពជម្លោះ តែងត្រូវបានញាំញីដោយភាពចលាចលក្នុងសង្គម ហេដ្ឋារចនាសម្ព័ន្ធខូចខាត នាំឱ្យកាត់បន្ថយសមត្ថភាពផលិត កង្វះហិរញ្ញវត្ថុធ្ងន់ធ្ងរ ធនធានមនុស្សចុះអន់ខ្សោយ និងសន្តិសុខមានភាពយ៉ាប់យ៉ឺនខ្លាំង។ បញ្ហាប្រឈមនេះ គឺជាការងារដ៏ពិបាក ខណៈដែលរដ្ឋាភិបាលតែងខិតខំគ្រប់យ៉ាងដើម្បីធានាឱ្យមានសុខសន្តិភាព ការផ្សះផ្សាជាតិ និងលើកកម្ពស់ការអភិវឌ្ឍជាតិឱ្យបានឆាប់រហ័ស។ ប្រទេសខ្លះក្រោយបញ្ចប់សង្គ្រាមស៊ីវិលតែងជួបបញ្ហាប្រឈមនឹងការកែលម្អការគ្រប់គ្រងធនធានមនុស្សនៅក្នុងវិស័យសាធារណៈ ជាពិសេសការខ្វះខាតធនធានមនុស្សដោយសារមន្ត្រីដែលមានជំនាញជាច្រើនបានស្លាប់ ឬរត់ភៀសខ្លួនទៅកាន់ប្រទេសដទៃទៀត[៣]។

ម្យ៉ាងវិញទៀត នៅពេលមានវិបត្តិសេដ្ឋកិច្ចក្នុងពិភពលោក ក៏អាចជះឥទ្ធិពលផងដែរដល់ចំណូលរបស់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ បញ្ហាបន្ទាប់ពីវិបត្តិសេដ្ឋកិច្ច និងចំណូលថវិការដ្ឋថយចុះ គឺការបាត់បង់ការងាររបស់ប្រជាពលរដ្ឋ។ ការលំបាកជាងនេះទៀតរដ្ឋាភិបាលក៏ត្រូវយកចិត្តទុកដាក់ និងចំណាយបន្ថែមលើកម្មករនិងប្រជាជនដែលរងផលប៉ះពាល់ ដើម្បីឱ្យពួកគាត់មានចំណូលសម្រាប់ការចំណាយចាំបាច់ប្រចាំថ្ងៃ។ ការលំបាកទាំងនេះជំរុញឱ្យរដ្ឋាភិបាលត្រូវកាត់បន្ថយការចំណាយលើបុគ្គលិក ចំណាយរដ្ឋបាលនៅតាមក្រសួង-ស្ថាប័នត្រូវកាត់ ព្រមទាំងបញ្ឈប់នូវការឧបត្ថម្ភផ្សេងៗដែលជាបញ្ហាប្រឈមខ្លាំងក្នុងការគ្រប់គ្រងធនធានមនុស្ស រាប់ទាំងការរក្សាទុកមន្ត្រីល្អៗដែលមានបទពិសោធន៍ និងមានសមត្ថភាព ជាពិសេសការផ្តល់សេវាសាធារណៈនានា។

បើក្រឡេកមើលបញ្ហាប្រឈមដែលកើតឡើង ក្នុងការគ្រប់គ្រងធនធានមនុស្សនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ពិតជាមានភាពស្មុគស្មាញ និងគួរឱ្យព្រួយបារម្ភ។ ភាគច្រើននៃបញ្ហាដែលលេចឡើងគឺ

---

[៣] កៅ មុយថង និង លីវ សុភក្រ្តា *ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យសាធារណៈ* ឆ្នាំ២០១៦ ទំព័រ ៧៧

ដោយសារតែការផ្លាស់ប្តូរនៅក្នុងបរិយាកាសសេដ្ឋកិច្ច សកលភាវូបនីយកម្ម និងជាពិសេសការប្រកួតប្រជែងជាអន្តរជាតិ ដែលបាននាំមកនូវតម្រូវការសម្រាប់អង្គភាពនានាក្នុងការទទួលយកការអនុវត្តការគ្រប់គ្រងធនធានមនុស្ស ដែលមានភាពសមស្របក្នុងការស្វែងរកអត្ថប្រយោជន៍ផ្នែកប្រកួតប្រជែង។ ក្នុងយុគសម័យសកលភាវូបនីយកម្មនេះ សម្ពាធនៃការប្រកួតប្រជែង បានដាក់កម្រិតមកលើគំរូនៃការគ្រប់គ្រងបែបប្រពៃណី នៅបណ្តាប្រទេសមួយចំនួននៃតំបន់អាស៊ីប៉ាស៊ីហ្វិក[៤]។ ជាក់ស្តែងការផ្លាស់ប្តូរបរិយាកាសធុរកិច្ចនៅក្នុងប្រទេសជប៉ុន បានដាក់សម្ពាធយ៉ាងខ្លាំងចំពោះនិយោជក ឱ្យផ្លាស់ប្តូរទម្លាប់ការងារបែបប្រពៃណីរបស់ពួកគេដើម្បីបន្តជង្រើមសេដ្ឋកិច្ច។ ហេតុនេះ និយោជកជប៉ុន បានរៀបចំរចនាសម្ព័ន្ធការងារឡើងវិញ ដើម្បីឆ្លើយតបទៅនឹងកំណើនទាប សកលភាវូបនីយកម្ម និងការប្រកួតប្រជែងជាអន្តរជាតិ។ បញ្ហាទាំងនេះត្រូវបាន Harukiyo and Hook (១៩៩៨) ធ្វើការអះអាងថាធាតុសំខាន់ៗនៃការគ្រប់គ្រងធនធានមនុស្សបែបជប៉ុនមានដូចជា៖ ការងារពេញមួយជីវិត ប្រព័ន្ធលើកកម្ពស់អតីតភាពការងារ សហជីពសហគ្រាស និងទំនាក់ទំនងកិច្ចសន្យាការងារ ត្រូវតែបន្តអភិវឌ្ឍដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចខ្ពស់ និងឆាប់រហ័សក្នុងអំឡុងពេលឧស្សាហូបនីយកម្មក្រោយសង្គ្រាម។ កត្តាទាំងអស់ខាងលើនេះ ត្រូវធ្វើការផ្លាស់ប្តូរជាចាំបាច់សម្រាប់ការគ្រប់គ្រងធនធានមនុស្ស[៥]។

ដូចទៅនឹងអ្វីដែលលោក សាល ម៉ុន (Salmon) បានលើកឡើងអំពីការគ្រប់គ្រងធនធានមនុស្សនៅក្នុងប្រទេសជប៉ុនដែរ គឺថាការផ្លាស់ប្តូរទាំងនេះ មិនបានប្រព្រឹត្តទៅដោយរលូននោះទេ។ ជាពិសេសលោក សាល ម៉ុន (Salmon) អះអាងថា ប្រឆាំងនឹងបរិការណ៍នៃកំណើនទាប វិបត្តិសេដ្ឋកិច្ច និងការកើនឡើងនៃភាពអត់ការងារធ្វើ និយោជិតជប៉ុនកំពុងជួបប្រទះបញ្ហាជាច្រើនក្នុងការគ្រប់គ្រងធនធានមនុស្ស។ អាស្រ័យហេតុនេះ មានការអំពាវនាវឱ្យមានការវាយតម្លៃឡើងវិញអំពីក្របខ័ណ្ឌជាមូលដ្ឋាននៃ "គំរូការគ្រប់គ្រងធនធានមនុស្ស" របស់ជប៉ុនដែលបានបង្កើតឡើង។ ដូច្នេះហើយ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមហ៊ុនរបស់ជប៉ុនមួយចំនួន បានកាត់បន្ថយចំនួនបុគ្គលិកពេញម៉ោង ហើយងាកទៅពឹងផ្អែកលើកម្លាំងកម្មករបណ្តោះអាសន្ន ដោយសារតែកម្មករបណ្តោះអាសន្នមានតម្លៃពលកម្មថោកជាង និងជម្រើសថែទាំទាបជាង[៦]។ ចំពោះកម្មករវ័យចំណាស់ កំពុងត្រូវបានលើកទឹកចិត្តឱ្យស្ម័គ្រចិត្តចូលនិវត្តន៍មុនអាយុកំណត់។ រីឯក្រុមកម្មករថ្មីមានជំនាញដែលក្រុមហ៊ុនត្រូវការ ត្រូវបានទាក់ទាញឱ្យមកជំនួសកម្មករវ័យចំណាស់ ដើម្បីចាកចេញពីការងារបែបប្រពៃណី។ ក្នុងការចាកចេញ

---

[៤] Pawan S. Budhwar, *Managing Human Resources in Asia-Pacific*, London, First Published, 2004, p.277

[៥] Pawan S. Budhwar, *Managing Human Resources in Asia-Pacific*, London, First Published, 2004, p.270

[៦] -ibid-, p.270

ពីការងារបែបប្រពៃណី និយោជកបានជួលបុគ្គលិកដែលចេះជំនាញកុំព្យូទ័រនិងអ្នកបច្ចេកទេសជាន់ខ្ពស់ជាច្រើនប្រភេទ ដោយធ្វើពហិការមិនអនុវត្តការជួលក្រោមប្រព័ន្ធការងារពេញមួយជីវិតនោះទេ ហើយប្រើប្រាស់ភ្នាក់ងារបណ្តោះអាសន្នជំនួសវិញ។ ដូចគ្នានឹងប្រទេសមួយចំនួនរបស់លោកខាងលិចដែរ និយោជក ឬក្រុមហ៊ុនជប៉ុន កំពុងអនុវត្តសកម្មភាពដោយពឹងផ្អែកលើបុគ្គលិកបណ្តោះអាសន្នកាន់តែច្រើន។ ក្នុងន័យនេះ Alexander (១៩៩៩) កត់សម្គាល់ថា នេះគឺជាការផ្លាស់ប្តូរដ៏រសើបជាមួយនឹងបញ្ហាប្រឈមរយៈពេលវែង ក្នុងការគ្រប់គ្រងធនធានមនុស្សនៅក្នុងប្រទេសមួយដែលល្បីល្បាញសម្រាប់ការផ្តល់ការងារពេញមួយជីវិត[៧]។

នៅប្រទេសអូស្ត្រាលី Patrickson និង Sutiyono បានពិភាក្សាអំពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលអូស្ត្រាលីក្នុងការលើកកម្ពស់ការយល់ដឹងពីអត្ថប្រយោជន៍នៃការអនុវត្តការងាររួម ដែលទាក់ទងនឹងជនជាតិភាគតិចនៅកន្លែងធ្វើការ។ ជនចំណាកស្រុកដែលមានជំនាញជាច្រើនបានមកដល់ប្រទេសអូស្ត្រាលី ហើយក្នុងចំណោមពួកគេ ភាគច្រើនជាជនជាតិអាស៊ី។ បញ្ហានេះទាមទារឱ្យអ្នកគ្រប់គ្រងធនធានមនុស្សមានការអភិវឌ្ឍគោលនយោបាយ ដើម្បីប្រើប្រាស់ជំនាញរបស់ពួកគេក្នុងការប្តូរតាមបំណង និងទីផ្សារពិសេស។ បញ្ហាប្រឈមនៅទីនេះរបស់អ្នកគ្រប់គ្រងគឺការដកចេញនូវរបាំងនិងការបង្កើតយុទ្ធសាស្ត្រដើម្បីធានាថា បុគ្គលិកទាំងអស់ក្នុងអង្គភាពអាចរួមចំណែកដោយពេញដៃពេញជើងក្នុងចំណេះដឹងនិងជំនាញរបស់ពួកគេ មិនថាក្នុងផ្លូវការឬក្រៅផ្លូវការនោះ(Bertone,1998)[៨]។

ដោយឡែកនៅក្នុងប្រទេសចិន ការគ្រប់គ្រងធនធានមនុស្ស ប្រឈមនឹងបញ្ហាជាច្រើនដូចជា៖ ទី១-សហគ្រាសជាទូទៅមិនមានវិធីសាស្ត្រជាប្រព័ន្ធចំពោះការគ្រប់គ្រងធនធានមនុស្ស ដែលស្របនឹងយុទ្ធសាស្ត្រអាជីវកម្មរបស់ខ្លួន។ ទី២- ទោះបីជាកម្លាំងពលកម្មលើសពីការផ្គត់ផ្គង់ក៏ដោយ ក៏និយោជកជាច្រើនកំពុងជួបប្រទះបញ្ហាក្នុងការជ្រើសរើសនិងការរក្សាទុកបុគ្គលិក។ ទី៣-កង្វះព្រព័ន្ធលើកទឹកចិត្តដែលមានប្រសិទ្ធភាពរយៈពេលវែង និងការអនុវត្តការផ្តល់រង្វាន់។ ទី៤-កង្វះភាពស៊ីចង្វាក់គ្នាក្នុងការបណ្តុះបណ្តាលបុគ្គលិកនៅតាមសហគ្រាស។ ទោះយ៉ាងណាក៏ដោយ បញ្ហាទាំងនេះមានកម្រិតមិនដូចគ្នានោះទេ ទាំងក្នុងវិស័យសាធារណៈ និងឯកជន ។ បញ្ហាមួយចំនួនអាចមានលក្ខណៈទូទៅ ប៉ុន្តែបញ្ហាមួយចំនួនទៀតអាចមានភាព ជាក់លាក់សម្រាប់វិស័យទាំងពីរ[៩]។

សរុបមកអង្គភាពក្នុងវិស័យសាធារណៈ និងឯកជន គេចមិនផុតឡើយពីការផ្លាស់ប្តូរសង្គម និងគោលនយោបាយដែលទាមទារឱ្យភ្នាក់ងារឬអ្នកគ្រប់គ្រងធនធានមនុស្សត្រូវតែចេះលៃលកដោះស្រាយ

---

[៧] Pawan S. Budhwar, *Managing Human Resources in Asia-Pacific*, London, First Published, 2004, p.270-271

[៨] -ibid-, p.274

[៩] -ibid-, p.27-28

បញ្ហាឱ្យបានទាន់ពេលវេលា ឆ្លើយតបទាំងកត្តាខាងក្នុង និងកត្តាខាងក្រៅ។ ទន្ទឹមនេះ ត្រូវចេះប្រមើល មើលនូវបញ្ហាដែលនឹងអាចកើតឡើងនាពេលខាងមុខផងដែរ ជាពិសេសជំរុញឱ្យមុខងារទាំងឡាយនៃធនធានមនុស្សមានភាពសកម្មនៅក្នុងអង្គភាព៕

# គន្ថនិទ្ទេស


១- John M. Pynes, ***Human Resource Management***, McGraw-Hill it'l, 11th Edition,2010.

២- Joan E. Pynes, ***Human Resource Management for Public and Nonprofit Organizations***, The United States of America, 2nd Edition, 2004.

៣- Lloyd L. Byars & Leslie W. Rue, ***Human Resource Management***, Ninth Edition, 2008.

៤- Manmohan Joshi, ***Human Resource Management***, 2013.

៥- Michael Armstrong, ***Strategic Human Resource Management,*** 4th Edition, 2008.

៦- Oxford University Press, ***Strategic Human Resource Management,*** 2007.

៧- Petter Boxall, John Purcell and Patrick Wright, ***Human Resource Management,*** Oxford University Press, First Published, 2007.

៨- Pawan S. Budhwar, ***Managing Human Resources in Asia-Pacific***, London, First Published, 2004.

៩- Zorlu Senyucel, ***Managing the Human Resource in the 21st Century***, 2009.

១០-កៅមុយថង និងលីវសុកត្រា ***ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យសាធារណៈ*** ២០១៦

១១-វេបសាយ៖ https://theinvestorsbook.com/human-resource-management-  hrm.html ។

# យុត្តិសាស្ត្រតុលាការយុត្តិធម៌អន្តរជាតិ ចំពោះការអនុវត្តសាលដីកា

បេក្ខជនបណ្ឌិត៖ **យោង ចាន់សុភារ**
ជំនាញ៖ **នីតិសាស្ត្រ**

តុលាការយុត្តិធម៌អន្តរជាតិមានលក្ខណៈពិសេស ដោយហេតុថា តុលាការនេះ ជាអង្គភាពមួយនៃអង្គការសហប្រជាជាតិ និងលេចធ្លោផងដែរ ដោយហេតុថា តុលាការនេះមានយុត្តាធិការលើរាល់រឿងក្តីដែលភាគីបានស្នើមក[១] ដែលតុលាការអន្តរជាតិផ្សេងទៀតកម្រិតត្រឹមយុត្តាធិការលើកម្មវត្ថុនៃរឿងក្តីមួយចំនួនប៉ុណ្ណោះ។ តុលាការនេះ មានភាពលេចធ្លោផងដែរ ដោយហេតុថា តុលាការទទួលយកបណ្តឹងនៃរដ្ឋដែលជាសមាជិក របស់អង្គការសហប្រជាជាតិ ក្នុងករណីដែលភាគីក្តីទទួលស្គាល់យុត្តាធិការតុលាការ ទៅតាមលក្ខន្តិកៈដែលបានចែង។

ប៉ុន្តែសាលដីកានៃតុលាការនេះ ពុំត្រូវបានអនុវត្តដោយតុលាការទេ តែបែរជាប្រគល់អំណាចទៅក្រុមប្រឹក្សាសន្តិសុខ ដែលជំពាក់ដោយភាពស្មុគស្មាញទាំងផ្នែកច្បាប់ និងទិដ្ឋភាពនយោបាយ។ ការសិក្សាខាងក្រោមនេះ ជាការបកស្រាយ និងវិភាគលើពីរចំណុចគឺ វង្វង់សមត្ថកិច្ចតុលាការ និងអំណាចមាត្រា៩៤ (២) នៃធម្មនុញ្ញអ.ស.ប ដោយយើងនឹងឆ្លើយសំណួរថា៖ តើតុលាការយុត្តិធម៌អន្តរជាតិ មានយុត្តិសាស្ត្រអនុវត្តសាលដីកាដូចម្តេច?

## I. វង្វង់សមត្ថកិច្ចតុលាការ

### ១. សមត្ថកិច្ចតុលាការ និងការវិវត្ត

**សមត្ថកិច្ច៖** តុលាការយុត្តិធម៌អន្តរជាតិមានសមត្ថកិច្ចរបស់ខ្លួនលើរឿងក្តីផ្អែកតាមលក្ខន្តិកៈតុលាការ វិធានផ្ទៃរបស់តុលាការ ដែលត្រូវគោរព ទាំងតុលាការខ្លួនឯង និងដោយភាគីក្តី។ មិនត្រឹមតែត្រឹមនេះទេ តុលាការក៏មានអំណាចឈរលើមូលដ្ឋាន និយាមអន្តរជាតិ ទំនៀមទម្លាប់ និងព្រមទាំងវិធានទាំងឡាយដែលជាបច្ច័យមុនៗរបស់តុលាការ អន្តរជាតិពីបូរាណ រួមទាំងមជ្ឈត្តការផងដែរ។

រដ្ឋមានអធិបតេយ្យពេញលេញក្នុងការចូលជាភាគីនៃសន្ធិសញ្ញាណាមួយដែលហៅថា គោលការណ៍ "យល់ព្រម" ពីរដ្ឋ ប៉ុន្តែនៅពេលដែលរដ្ឋទទួលស្គាល់ ឬចូលជាភាគីហើយ រដ្ឋមានកាតព្វកិច្ចគោរពសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិនោះដោយសុទ្ធចិត្ត[២] និងមានកាតព្វកិច្ចមិនធ្វើឱ្យខូចខាតដល់ គោលដៅ

---

[១] មាត្រា៣៦ (១) លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ

[២] មាត្រា២៦ នៃអនុសញ្ញាស្តីពីសន្ធិសញ្ញាអន្តរជាតិ បានចែងពីគោលការណ៍ ការគោរពដោយសុទ្ធចិត្ត *"Pacta sunt servanda"*

និងគោលបំណងនៃសន្ធិសញ្ញា សូម្បីនៅមុនកិច្ចព្រមព្រៀងអន្តរជាតិចូលជាធរមានក៏ដោយ[៣]។ ការចូលជាភាគីនេះ ទៀតសោត គឺធ្វើទៅតាមនិតិវិធីនៃរដ្ឋនីមួយៗដូចជា តាមរយៈការផ្តល់សច្ចាប័ន សំណើចូលជាភាគី ឬការអនុម័តចូលជាភាគី ដោយមានភ្ជាប់លក្ខ័ណ្ឌ ឬគ្មានភ្ជាប់លក្ខខណ្ឌដែលរដ្ឋបានស្នើ។ ដូចគ្នានេះដែរ ការទទួលស្គាល់យុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិ ក៏ដូចគ្នាដែរ គឺរដ្ឋមានអធិបតេយ្យពេញលេញ ដូចបានអធិប្បាយ។ ប៉ុន្តែការយល់ព្រមទាំងនេះ ត្រូវតបស្នងមកវិញដោយទាំងកាតព្វកិច្ចត្រូវគោរពលក្ខន្តិកៈតុលាការ និងកាតព្វកិច្ចគោរពអនុវត្តសាលដីកា ដែលតុលាការបានសម្រេច។

សាលដីការបស់តុលាការ ចងភ្ជាប់កាតព្វកិច្ចចំពោះភាគីក្តី[៤] និងមានភាពរឹងមាំផ្នែកច្បាប់ ព្រោះរដ្ឋបានសុខចិត្តលះបង់អធិបតេយ្យរបស់ខ្លួនដើម្បីភ្ជាប់នឹងអំណាចរបស់តុលាការរួចហើយ។ ក្នុងន័យនេះរដ្ឋត្រូវបានចងភ្ជាប់កាតព្វកិច្ចក្រោមអំណាចតុលាការ ដោយអធិបតេយ្យរដ្ឋត្រូវបានប្រគល់ឱ្យតុលាការក្នុងករណីរឿងក្តីនេះរួចជាស្រេចហើយ។

សមត្ថកិច្ចតុលាការ ជាអំណាចដាច់ខាតពុំមានអំណាចណាគ្របដណ្តប់លើទេ។ មាត្រា៣៦(៥) នៃលក្ខន្តិកៈតុលាការចែងប្រគល់សមត្ថកិច្ចឱ្យតុលាការជាអ្នកសម្រេចនៅពេលដែលមានជម្លោះ ឬការយល់ផ្សេងពីគ្នារវាងភាគីក្តីលើយុត្តាធិការតុលាការ។ ម្យ៉ាងទៀតក្រៅពីមានផ្តល់ឱ្យដោយលក្ខន្តិកៈតុលាការនៅមានសមត្ថកិច្ចទាំងឡាយផងដែរ។ ករណីជាក់ស្តែងបានបង្ហាញថា តុលាការជាអ្នកមានសមត្ថកិច្ចដោះស្រាយកម្មវត្ថុបណ្តឹងទាំងស្រុង ឬបដិសេធខ្លះទៅតាមសម្អាងហេតុរបស់តុលាការ។ ការបិទសំណុំរឿងជាសមត្ថកិច្ចរបស់តុលាការក្នុងពេលដែលមានការស្នើសុំពីភាគីក្តីស្នើមិនបន្តដំណើរការក្តី ឬនៅពេលដែលវិវាទលែងមានអត្ថិភាព។

តុលាការមានអំណាចចាត់តាំងអ្នកជំនាញ ឬក្រុមជំនាញចុះទៅទីតាំងជម្លោះដើម្បីវាស់វែង និងផ្តល់របាយការណ៍មកឱ្យតុលាការ យោងមាត្រា៥០នៃលក្ខន្តិកៈ។ តុលាការមានសមត្ថកិច្ចផ្តល់អ្នកបច្ចេកទេសដែលចាត់ដោយតុលាការ តាមការស្នើសុំរបស់ភាគីផងដែរ។ គេកត់សម្គាល់ឃើញថា មាត្រា៤១(២)នៃលក្ខន្តិកៈបានផ្តល់អំណាចឱ្យតុលាការនាំយកវិធានការណ៍បណ្តោះអាសន្នទៅកាន់ភាគីក្តី និងទៅជម្រាបជូនក្រុមប្រឹក្សាសន្តិសុខអ.ស.ប។ ប៉ុន្តែបែរជាសាលដីកា ពុំមានមាត្រាចែងថា ត្រូវធ្វើដូចម្តេច ឬត្រូវនាំទៅជម្រាបក្រុមប្រឹក្សាសន្តិសុខ ឬមានសមត្ថកិច្ចបង្ខំអនុវត្តក្នុងទម្រង់ណាមួយ។

**ការវិវត្តៈ** តុលាការមានអំណាចចាត់តាំងអ្នកជំនាញចុះដល់ទីកន្លែង និងផ្តល់របាយការណ៍ជំនាញត្រឡប់មកតុលាការយោងមាត្រា៤៨ និង៥០ នៃលក្ខន្តិកៈតុលាការ និងវិធានផ្ទៃក្នុងតុលាការមាត្រា៦៧។

---

[៣] មាត្រា១៨ នៃអនុសញ្ញាស្តីពីសន្ធិសញ្ញាអន្តរជាតិ

[៤] មាត្រា៥៩ នៃលក្ខន្តិកៈតុលាការ ចែងថា៖ "សេចក្តីសម្រេចតុលាការ មិនចងភ្ជាប់កាតព្វកិច្ច ក្រៅតែពីរវាងភាគី នៃរឿងក្តីដោយឡែកនេះទេ។"

ដាក់ស្តែង ជារបត់ថ្មីមួយ ដែលតុលាការ បានប្រើប្រាស់មាត្រាទាំងនេះ បំពេញមុខងារផ្តល់អ្នកបច្ចេកទេស ចាត់តាំងអ្នកជំនាញ តាមការស្នើសុំរបស់ភាគី ដែលនឹងធ្វើឡើងក្រោយការចេញសាលដីកា។ នោះគឺក្នុងរឿងក្តីជម្លោះព្រំដែន បួគីណាហ្វាសូ តទល់ នីហ្សែរ៍ *( Burkina Fas vs. Niger)* គឺតុលាការបានចេញដីកាបង្គាប់បញ្ជា នាខែតុលា ឆ្នាំ២០២០[៥] ក្រោយសាលដីកាឆ្នាំ២០១៣។

ក្នុងករណីទំនាស់ព្រំដែនរវាងបួគីណាហ្វាសូ តទល់ នីហ្សែរ៍ ឆ្នាំ២០១៣ ប្រទេសទាំងពីរចុះកិច្ចព្រមព្រៀងពិសេស ដាក់ទំនាស់ព្រំដែនជូនតុលាការសម្រេច ដែលក្នុងនោះ មាត្រា៧(៤)នៃកិច្ចព្រមព្រៀងពិសេស បានស្នើសុំតុលាការចាត់តាំងអ្នកជំនាញ នៅក្នុងខ្លឹមសារនៃសាលដីកា ដើម្បីចុះខណ្ឌសីមាព្រំដែននៅក្នុងតំបន់មានទំនាស់ តាមទិសដើរនៃព្រំដែនដែលតុលាការបានកំណត់នៅក្នុងផ្នែកសេចក្តីសម្រេចនៃសាលដីកា។ ករណីនេះ តុលាការយុត្តិធម៌បានយល់ព្រមជាវិជ្ជមានតាមសំណើរបស់គូភាគី ក៏ប៉ុន្តែពុំអាចសម្រេចអំពីបញ្ហានេះក្នុងទម្រង់សាលដីកាបានទេ ពោលគឺសម្រេចក្នុងទម្រង់ជា *«ដីកាសម្រេច»* វិញ។ ពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣ តុលាការបានចាត់ជំនាញការឯករាជ្យបីរូបឱ្យចុះជួយប្រទេសទាំងពីរក្នុងការខណ្ឌសីមាព្រំដែនតាមស្មារតីសាលដីកា។[៦] តុលាការបានចេញ ដីកាបង្គាប់បញ្ជានា ខែតុលា ឆ្នាំ២០២០[៧] ដោយផ្អែកលើសាលដីកាឆ្នាំ២០១៣នេះ។

យោងមាត្រា៥០នៃលក្ខន្តិកៈតុលាការ ក្នុងករណីមួយចំនួន ដែលមានភាពស្មុគស្មាញហួសពីសមត្ថភាពរបស់ខ្លួន តុលាការអាចប្រគល់ភារកិច្ចជូនបុគ្គល ស្ថាប័នគណៈកម្មការ ឬអង្គការណាមួយ ដើម្បីអនុវត្តការងារស្រាវជ្រាវ និងផ្តល់យោបល់ជំនាញជូនតុលាការ ពោលគឺស្វែងរកភស្តុតាងដែលមានលក្ខណៈឯករាជ្យពីភស្តុតាងដែលគូភាគីដាក់ជូនតុលាការរួចហើយ។

ខណៈដែលមាត្រា៤៩នៃលក្ខន្តិកៈតុលាការ តម្រូវឱ្យភាគីនៃរឿងក្តីផ្តល់ភស្តុតាង សាក្សី និងសាក្សីជំនាញដាក់ជូនតុលាការ, មាត្រា៥០នៃលក្ខន្តិកៈតុលាការបានបើកផ្លូវឱ្យតុលាការអាចស្វែងរកព័ត៌មានចាំបាច់បន្ថែមតាមរយៈរបាយការណ៍និងយោបល់ជំនាញការឯករាជ្យ *(proprio motu)*។

ជាឧទាហរណ៍ ក្នុងករណីវិវាទនៅច្រកសមុទ្រក័រហ្វ៊ូ *(Corfu)* អង់គ្លេសបានដាក់បណ្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ ប្រឆាំងនឹងអាល់បានី ដែលបានដាក់ពង្រាយគ្រាប់មីននៅក្នុងច្រកសមុទ្រក័រហ្វ៊ូ បង្កឱ្យមានការខូចខាតនាវា និងការស្លាប់បាត់បង់ជីវិតកងទ័ពជើងទឹកអង់គ្លេស។ ជុំវិញឧប្បត្តិហេតុនេះ តុលាការបានប្រគល់ភារកិច្ចជូន គណៈកម្មការឯករាជ្យ ដែលមានសមាសភាពជំនាញការកងទ័ពជើងទឹកចំនួនបីរូប ដើម្បីកំណត់អំពីទិដ្ឋភាពនៃប្រតិបត្តិការពង្រាយគ្រាប់មីន នៅតាមឆ្នេររបស់ប្រទេសអាល់បានី

---

[៥] ICJ’s Order of 12 October 2020, Armed Activities on the Territory of the Congo (Congo v. Uganda)

[៦] Frontier Dispute (Burkina Faso/Niger), Nomination of Expert, Order of 12 July 2013, p. 5.

[៧] ICJ’s Order of 12 October 2020, Armed Activities on the Territory of the Congo (Congo v. Uganda)

*(Albania)*។[៨] ផ្អែកតាមរបាយការណ៍របស់គណៈកម្មការ តុលាការសម្រេចថា ការពង្រាយគ្រាប់មីនដោយអាល់បានី គឺជាអំពើអនីត្យានុកូល ដែលត្រូវមានការទទួលខុសត្រូវជាអន្តរជាតិ។[៩]

បន្ថែមលើនេះ តុលាការមានសមត្ថកិច្ចសម្រេចអំពីទំហំនៃសំណងរវាងគូភាគី ក្នុងករណីដែលការគណៈសំណងពុំឈានដល់ការព្រមព្រៀងមួយ។ សមត្ថកិច្ចនេះ គឺជាមុខងារមួយមិនអាចផ្តាច់ចេញបានពីការសម្រេចក្តីប្រកបដោយប្រសិទ្ធភាព។

ជាឧទាហរណ៍ ក្នុងករណីវិវាទនៅច្រកសមុទ្រកហ្វ៊ូ*(Albania)* តុលាការសម្រេចថា អាល់បានីមានទំនួលខុសត្រូវតាមច្បាប់អន្តរជាតិចំពោះការផ្ទុះគ្រាប់មីននៅថ្ងៃទី**២២** ខែ**តុលា** ឆ្នាំ**១៩៤៦** ដែលបង្កឱ្យមានការខូចខាតនិងបាត់បង់អាយុជីវិតនាវិកជនជាតិអង់គ្លេស។ ជាមួយគ្នានេះ តុលាការបានបម្រុងសិទ្ធិក្នុងការពិចារណាអំពីទំហំនៃសំណងការខូចខាតដែលខ្លួនបានបង្កឡើង ប្រសិនបើភាគីវិវាទទាំងពីរពុំអាចឈានដល់ការព្រមព្រៀងទេនោះ។[១០] ពាក់ព័ន្ធករណីនេះ អាល់បានីបានប្រកាសជំទាស់ថា កិច្ចព្រមព្រៀងពិសេសពុំបានប្រគល់ជូនតុលាការនូវសមត្ថកិច្ចក្នុងការគណនាសំណងឡើយ ហើយអាល់បានីក៏ពុំមានហេតុផលត្រូវចូលរួមកិច្ចនីតិវិធីនេះដែរ។ ជាលទ្ធផល តុលាការសម្រេចឱ្យអាល់បានីសងអង់គ្លេសនូវប្រាក់សំណងចំនួន **៨៤៣.៩៤៧ ផោន** (តម្លៃប្រហែល **៣៨លានផោន** នាពេលបច្ចុប្បន្ន)។

ជារបត់មួយផងដែរ តុលាការមានសមត្ថកិច្ចសម្រេចក្តីបន្ថែមអំពីសំណងបន្ទាប់ពីចេញសាលដីកាក្នុងករណីដែលភាគី មិនបានដោះស្រាយបាននូវសំណងនោះទេ។ ជាឧទាហរណ៍ ក្នុងរឿងក្តីជម្លោះព្រំដែន *(កុងហ្គោ តទល់ យូហ្គាន់ដា)* តុលាការបានឯកភាពជាឯកច្ឆ័ន្ទថា នឹងរក្សាសិទ្ធចាត់នីតិវិធីបន្តក្នុងករណីពុំមានដំណោះស្រាយចំពោះបញ្ហាសំណង[១១]។ ករណីបុគ្គលិកកុងស៊ុល និងអ្នកការទូតអាមេរិក ត្រូវចាប់ជំរិតនៅអ៊ីរ៉ង់ ក៏ដូចគ្នាដែរ គឺតុលាការបានបង្ការថា ក្នុងករណីដែលការចរចាលើសំណង បរាជ័យ នោះតុលាការរក្សាសិទ្ធិចាត់នីតិវិធីបន្ត[១២]។

---

[៨] The Corfu Channel Case, (UK v. Albania), Order of 17 December 1948, Expert Opinion.

[៩] Corfu Channel case, Judgment of April 9th, 1949: I.C. J. Reports 1949, p. 36.

[១០] --ដ--

[១១] ICJ's Judgment of 19 December 2005, Case Concerning Armed Activities on the Territory of the Congo *(Congo v. Uganda)*, Paragraph 6

[១២] Reports of ICJ: Case Concerning United States Diplomatic and Consular Staff in Tehran, 1980, Paragraph 6 of the Operative Paragraph

តុលាការមានសមត្ថកិច្ចតម្រង់ទិសគូភាគីក្នុងការអនុវត្តសាលដីកា។ ជាឧទាហរណ៍ ក្នុងសំណុំរឿងបកស្រាយសាលដីកាប្រាសាទព្រះវិហារ កម្ពុជាបានដាក់បណ្តឹងស្នើការបកស្រាយ នាឆ្នាំ២០១១ ស្នើសុំតុលាការបកស្រាយសាលដីកាឆ្នាំ១៩៦២។ ជាលទ្ធផល តុលាការបានធ្វើការបកស្រាយដោយកំណត់វិសាលភាពនៃតំបន់ប្រាសាទនិងតំបន់ជុំវិញ ព្រមទាំងកំណត់ព្រំដែននៅបរិវេណនេះ យកតាមខ្សែលើផែនទីឧបសម្ព័ន្ធទី១។ ការស្នើបកស្រាយ គឺក្រោយពេលថៃបានចូលមកឈ្លានពានតំបន់ប្រាសាទព្រះវិហារតាមការបកស្រាយជាឯកតោ- ភាគីទៅលខ្លឹមសារសាលដីកា។ ដើម្បីបង្ការបញ្ហាដដែលនេះកុំឱ្យកើតឡើងជាបន្តទៅទៀត និងធានាការអនុវត្តសាលដីកាប្រកបដោយប្រសិទ្ធភាពខ្ពស់ តុលាការយុត្តិធម៌អន្តរជាតិបន្ថែមលើការបកស្រាយសាលដីកាឆ្នាំ១៩៦២ បានដាក់ចេញត្រីវិស័យតម្រង់ទិសមួយចំនួនដូចខាងក្រោមៈ

*ដោយកត់សម្គាល់ពីបញ្ហាលំបាកលើការកំណត់ទីតាំងពិតប្រាកដនៃបន្ទាត់ក្នុងផែនទីឧបសម្ព័ន្ធទី១ នៅលើដីជាក់ស្តែង តុលាការបានសង្កត់ធ្ងន់អំពីកាតព្វកិច្ចរបស់ភាគីទាំងពីរក្នុងការអនុវត្តដោយសុច្ឆន្ទៈខ្លឹមសារសាលដីកា ពោលគឺ «មិនអនុញ្ញាតឱ្យភាគីណាមួយដាក់ចេញវិធានការបែបឯកតោភាគី» ឡើយ។*[១៣] *ព្រមជាមួយនេះ តុលាការបានរំលឹកឡើងវិញអំពីគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ ក្នុងការគោរពអធិបតេយ្យ និងបូរណភាពទឹកដីផងគ្នាទៅវិញទៅមក និងកាតព្វកិច្ចក្នុងដោះស្រាយវិវាទដោយសន្តិវិធី អនុលោមតាមគោលការណ៍គ្រឹះដូចមានចែងក្នុងធម្មនុញ្ញ អ.ស.ប។*[១៤] *ដោយផ្អែកលើមាត្រា៦ នៃអនុសញ្ញាបេតិកភណ្ឌពិភពលោកដែលមានប្រទេសទាំងពីរជាភាគី តុលាការបានសង្កត់ធ្ងន់លើកាតព្វកិច្ចសហការគ្នានិងក៏ដូចជាកិច្ចសហការជាមួយសហគមន៍អន្តរ- ជាតិ ដើម្បីការពារតំបន់បេតិកភណ្ឌពិភពលោកនេះ។ បន្ថែមលើនេះ តុលាការបានដាក់ការព្រមានមិនឱ្យភាគីណាធ្វើឱ្យខូចខាតដល់សម្បត្តិបេតិកភណ្ឌនេះទេ ទោះដោយប្រយោលឬដោយផ្ទាល់ក្តី។ បន្ថែមលើនេះ ក្នុងកថាខណ្ឌសម្អាងហេតុ តុលាការបានរំលឹកពីគោលការណ៍គោរពដោយសុទ្ធចិត្ត និងពីភារកិច្ចដែលរដ្ឋត្រូវដោះស្រាយជម្លោះដោយសន្តិវិធី យោងតាមគោលការណ៍ចែងក្នុងធម្មនុញ្ញអ.ស.ប។ ជាការសន្និដ្ឋាន ទាំងនេះជាអ្វីដែលតុលាការបានខិតខំបញ្ជាក់សមត្ថកិច្ចដើម្បីបំពេញមុខងារច្បាប់របស់ខ្លួន។*

ជារបត់ថ្មីផងដែរ តុលាការមានសមត្ថកិច្ចសម្រេចក្តីបន្ថែមអំពីសំណងបន្ទាប់ពីចេញសាលដីកា ក្នុងករណីដែលភាគី មិនបានដោះស្រាយបាននូវសំណងនោះទេ។ ជាឧទាហរណ៍ ក្នុងរឿងក្តីជម្លោះព្រំដែន *(កុងហ្គោ តទល់ យូហ្គាន់ដា)* តុលាការបានឯកភាពជាឯកច្ឆ័ន្ទថានឹងរក្សាសិទ្ធិចាត់នីតិវិធីបន្តក្នុងករណីពុំ

---

[១៣] Request for Interpretation of the Judgment of 15 June 1962 in the Case concerning the Temple of Preah Vihear (Cambodia v. Thailand), Judgment, I.C.J. Reports 2013, p. 316, para. 99.

[១៤] Ibid, p. 317, para. 105.

មានដំណោះស្រាយចំពោះបញ្ហាសំណង[១៥]។ ករណីបុគ្គលិកកុងស៊ុល និងអ្នកការទូតអាមេរិក ត្រូវចាប់ជំរិតនៅអ៊ីរ៉ង់ ក៏ដូចគ្នាដែរ គឺតុលាការបានបង្គាប់ថា ក្នុងករណីដែលការចរចាលើសំណងបរាជ័យ នោះតុលាការរក្សាសិទ្ធចាត់នីតិវិធីបន្ត[១៦]។

## ២. ការចេញដីកាសម្រេចរក្សាការពារជាបណ្តោះអាសន្ន និងចម្លងជូនក្រុមប្រឹក្សាសន្តិសុខ

ផ្អែកតាមមាត្រា៤១ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ មានសមត្ថកិច្ចចេញដីកាសម្រេចរក្សាការពារ នូវកម្មវត្ថុនៃបណ្តឹង សិទ្ធិរបស់ភាគី នៃរឿងក្តីដែលនឹងត្រូវវិនិច្ឆ័យ ដោយផ្អែកតាមបណ្តឹងសុំ (Request) ឬតាមឆន្ទានុសិទ្ធិតុលាការក្នុងការផ្តួចផ្តើមដាក់ចេញ *(Proprio Motu)*។ ការផ្តល់ឆន្ទានុសិទ្ធិជូនតុលាការដាក់ចេញវិធានការរក្សាការពារបែបនេះ ត្រូវបានរិះគន់ថា ជាការសម្រេច ដែលហួសពីការស្នើសុំរបស់គូភាគី។ ប៉ុន្តែក្នុងកាលៈទេសៈដែលមានការប្រឈមមុខដោយកម្លាំង សិទ្ធិរបស់គូភាគី ឬកម្មវត្ថុនៃបណ្តឹងត្រូវប្រឈមនឹង ហានិភ័យ នៃការខូចខាតពុំអាចជួសជុលវិញបាន នាំសេចក្តីសម្រេចចុងក្រោយប្រែជាឥតន័យអ្វី។ វិធានការរក្សាការពារជាបណ្តោះអាសន្ន ជាយន្តការចាំបាច់សម្រាប់បង្ការហានិភ័យបែបនេះ។

តើការសេចក្តីសម្រេចរក្សាការពារ មានចំណងគតិយុត្ត ឬទេ?

ជារបត់ថ្មីមួយ ដែលគេត្រូវរង់ចាំអស់ជិត៤ទសវត្ស ទើបមានចម្លើយ។ ក្នុងរឿងក្តី LaGrand *(អាឡឺម៉ង់ តទល់ អាមេរិក* ឆ្នាំ១៩៩៩) តុលាការបានបកស្រាយ និងសម្រេចថា ដីការក្សាការពារបណ្តោះអាសន្ន មានចំណងគតិយុត្តចងភាគីឱ្យគោរព។[១៧] រឿងក្តី LaGrandនេះ បានក្លាយជា ចំណុចលេចធ្លោ នៃសមត្ថកិច្ចតុលាការ ដោយវិធានការរក្សាការពារ ដែលត្រូវសង្កត់ធ្ងន់ជាបន្ត និងត្រូវលើកសម្អាងក្នុងគ្រប់ការចេញសេចក្តីសម្រេចរក្សាការពារ។ ការបកស្រាយនៃសាលដីការឿងក្តីប្រាសាទព្រះវិហារ (កម្ពុជា តទល់ ថៃ)[១៨] ក៏ដូចសំណុំរឿងទាក់ទងនឹងការចោទប្រកាន់ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ (អ៊ុយក្រែន

---

[១៥] ICJ's Judgment of 19 December 2005, Case Concerning Armed Activities on the Territory of the Congo *(Congo v. Uganda)*, Paragraph 6

[១៦] Reports of ICJ: Case Concerning United States Diplomatic and Consular Staff in Tehran, 1980, Paragraph 6 of the Operative Paragraph

[១៧] LaGrand (Germany v. United States of America), Judgment, I.C.J. Reports 2001, p. 506, para. 109

[១៨] Request for Interpretation of the Judgment of 15 June 1962 in the Case concerning the Temple of Preah Vihear (Cambodia v. Thailand) (Cambodia v. Thailand), Provisional Measures, Order of 18 July 2011, I.C.J. Reports 2011, p. 554, para. 67.

តទល់ រុស្ស៊ី)[១៩] ជាដើម ត្រូវបានតុលាការគូសបញ្ជាក់ពីចំណងគតិយុត្ត។ ការមិនគោរព សេចក្តីសម្រេចការពារ គឺជាការរំលោភច្បាប់អន្តរជាតិ ដែលនាំដល់ផលវិបាក។

## II. ការអនុវត្តសាលដីកា

ផ្អែកតាមលក្ខន្តិកៈ តុលាការយុត្តិធម៌អន្តរជាតិមានអំណាចចេញសេចក្តីសម្រេចជា៣ទម្រង់គឺៈ សាលដីកា *(Judgement )* ដីកាសម្រេច *(Binding Order)* និងដីការបៀប *(Interlocutory Order)*។ សេចក្តីសម្រេចចងកាតព្វកិច្ច ដែលសំខាន់ជាងគេគឺ ***«សាលដីកា»***។ ការហៅថា "សាលដីកា" ជាជាង "សាលក្រម" ព្រោះថា តុលាការនេះមានតែមួយថ្នាក់ ហើយសេចក្តីសម្រេចតុលាការ មានលក្ខណៈស្ថាពរ និងចងកាតព្វកិច្ច ពុំមានបណ្តឹងឧទ្ធរណ៍ឡើយ។

### ១. ការអនុវត្តដោយក្រុមប្រឹក្សាសន្តិសុខអ.ស.ប

#### ក. មូលដ្ឋានគតិយុត្តិ

ខាងក្រោមនេះ គឺជាការវិភាគទៅលើមាត្រាសំខាន់ ដែលគេតែងគិតដល់នៅពេលមានការមិនគោរពសាលដីកា។ គេដឹងថា ការអនុវត្តសាលដីកា គឺត្រូវសំដៅឆ្ពោះទៅមាត្រា៩៤ នៃធម្មនុញ្ញ អ.ស.ប និងតើមាត្រានេះ មានកម្លាំងអនុវត្តដូចម្តេចខ្លះ? ជាបឋម មាត្រានេះមាន២ កថាខណ្ឌ ដែលចែងថាៈ

*កថាខណ្ឌទី១ « សមាជិកនីមួយៗនៃអង្គការសហប្រជាជាតិ អនុវត្តតាមសេចក្តីសម្រេច[២០] របស់តុលាការយុត្តិធម៌អន្តរជាតិ ក្នុងរឿងក្តីណាមួយដែលខ្លួនជាភាគី។*

យោងកថាខណ្ឌទី១ គេសង្កេតឃើញថា ការអនុវត្តសាលដីកា គឺអាស្រ័យលើការប្តេជ្ញាចិត្តរបស់គូភាគីនៃរឿងក្តីនីមួយៗ។ គួរបញ្ជាក់ថា សាលដីកាតុលាការចងកាតព្វកិច្ចតែលើ ភាគីនៃរឿងក្តីអនុលោមតាមគោលការណ៍ *res inter alios acta* ដែលមានន័យថា គូភាគីនៃរឿងក្តីត្រូវគោរពសេចក្តីសម្រេចរបស់តុលាការដោយសុទ្ធចិត្ត *(good faith)* អនុលោមតាមគោលការណ៍ *Pacta sun servanda* ដែលបានចែងក្នុងអនុសញ្ញាវីយែនស្តីពីច្បាប់សន្ធិសញ្ញាឆ្នាំ១៩៦៩។

---

[១៩] Allegations of Genocide under the Convention on the Prevention and Punishment of the Crime of Genocide (Ukraine v. Russian Federation), Provisional Measures, Order of 16 March 2022, I.C.J. Reports 2022, p. 230, para. 84.

[២០] ចំណុចគួរឱ្យកត់សម្គាល់គឺថា មាត្រា៩៤តែមួយ បានប្រើពាក្យសេចក្តីសម្រេចផង និងសាលដីកាផង។ កថាខណ្ឌទី១ បានដាក់កាតព្វកិច្ចឱ្យសមាជិកអ.ស.ប គោរពអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលសេចក្តីសម្រេចអាចមានទម្រង់ជាសាលដីកា ដីកាបង្គាប់ ឬដីការបៀបចាត់ចែងកិច្ចនីតិវិធី។ ទោះជាយ៉ាងនេះក្តី កថាខណ្ឌទី២ បានយោងទៅដល់សាលដីកា ប៉ុន្តែពុំបាននិយាយដល់សេចក្តីសម្រេចឯទៀតរបស់តុលាការនោះទេ។ ដូច្នេះ បើតាមវិធីសាស្ត្របកស្រាយបែបតឹងរ៉ឹង កថាខណ្ឌទី១ នៃមាត្រា៩៤ សំដៅដល់សាលដីកាតែមួយមុខប៉ុណ្ណោះ។

ជាមួយគ្នានេះ មាត្រា១០៣នៃធម្មនុញ្ញ អ.ស.ប បានផ្តល់ឧត្តមានុភាពជានិច្ចដល់កាតព្វកិច្ចក្រោមធម្មនុញ្ញ អ.ស.ប ក្នុងករណីដែលមានវិវាទជាមួយកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត។[២១] ក្នុងន័យនេះ កាតព្វកិច្ចក្នុងការគោរពអនុវត្តសាលដីការបស់តុលាការយុត្តិធម៌អន្តរជាតិ ដូចមានចែងក្នុងមាត្រា៩៤ នៃធម្មនុញ្ញ អ.ស.ប ត្រូវមានឧត្តមានុភាពលើកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយ។

ជាក់ស្តែង ករណីជម្លោះនៃរឿងក្តីប្រាសាទព្រះវិហារ កងទ័ពឈុតខ្មៅរបស់ថៃ បានចូលលុកលុយកាត់កាប់តំបន់ប្រាសាទ ក្រោយពេលដែលប្រាសាទព្រះវិហារត្រូវ បានចុះបញ្ជីជាបេតិកភណ្ឌពិភពលោកឆ្នាំ២០០៨ ភ្លាម។ ការណ៍នេះ បាននាំដល់ជម្លោះប្រដាប់អាវុធធ្ងន់ធ្ងរ មានមនុស្សស្លាប់ និងរងរបួស ថែមទាំងមានការដាក់ពង្រាយទ័ពទាំងពីរភាគីនៅតាមបណ្តោយព្រំដែន។ ជាបន្តបន្ទាប់ កម្ពុជាជូនព័ត៌មានទៅកាន់ក្រុមប្រឹក្សាសន្តិសុខអ.ស.ប ប៉ុន្តែពុំបានស្នើកោះប្រជុំបន្ទាន់អំពីការរំលោភបំពាននោះទេ។ ការប្តឹងស្នើឱ្យក្រុមប្រឹក្សាសន្តិសុខអ.ស.ប. កោះប្រជុំបន្ទាន់ ទើបធ្វើឡើងនៅឆ្នាំ២០១១ គេទើបតែឃើញភាគីកម្ពុជាបានសម្អាងលើ មាត្រា៩៤(១) នៃធម្មនុញ្ញ អ.ស.ប. ក្នុងលិខិត[២២] ស្នើកោះប្រជុំបន្ទាន់ ប៉ុន្តែពុំបានប្រើទាល់តែសោះមាត្រា៩៤(២) ដែលជាកថាខណ្ឌសំខាន់ដែលគួរចាត់ទុកថាជាការជួយដាក់ទម្ងន់ដើម្បីប្តឹងទៅក្រុមប្រឹក្សាស្នើឱ្យភាគីក្តីម្ខាងទៀតអនុវត្តសាលដីកា។

កថាខណ្ឌ២ នៃមាត្រា៩៤ នៃធម្មនុញ្ញ អ.ស.ប.ចែងថា៖

*« ប្រសិនបើភាគីណាមួយក្នុងរឿងក្តី ខកខានពុំបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនកំណត់ដោយសាលដីកាចេញដោយតុលាការនោះ ភាគីម្ខាងទៀតអាចប្តឹងទាមទារទៅក្រុមប្រឹក្សាសន្តិសុខ ដែលក្នុងករណីយល់ឃើញថាចាំបាច់ អាចផ្តល់អនុសាសន៍ ឬសម្រេចដាក់ចេញវិធានការនានា ដើម្បីផ្តល់ប្រសិទ្ធភាពឱ្យសាលដីកានោះ។»*

កថាខណ្ឌ២ នៃមាត្រា៩៤នេះ មានចំណុច៣ ដែលគួរលើកយកមកសិក្សា៖

**ទីមួយ៖** ក្នុងករណីដែលភាគីណាមួយនៃរឿងក្តី ពុំបានគោរពសាលដីកា នោះភាគីម្ខាងទៀតមានសិទ្ធដាក់បណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខ ដើម្បីអនុវត្តសាលដីកា។ ឃ្លានេះទី១នេះ ហាក់មានន័យបើកទូលាយលើបណ្តឹងអនុវត្តសាលដីកា ប៉ុន្តែផ្នែកទី២ បែរជាមានបង្កប់នូវន័យចង្អៀត ដោយហេតុថា បណ្តឹងនៃការអនុវត្តពុំអាចត្រូវទទួលយកមកពិចារណាដោយក្រុមប្រឹក្សាដោយត្រង់ៗ នោះទេ ព្រោះការទទួលយករបៀបវារៈមួយមកពិភាក្សា ក៏នៅមានលក្ខខ័ណ្ឌពាក់ព័ន្ធផ្សេងទៀត ផងដែរ។ ឃ្លាទីពីរបានបង្ហាញថា គឺជាអំណាចរបស់តុលាការដែលយល់ថា ចាំបាច់ មិនចាំបាច់ និងពុំមានមាត្រាណាបង្ខំក្រុមប្រឹក្សាសន្តិសុខឱ្យចាំបាច់ត្រូវតែយកបណ្តឹងមកពិភាក្សានោះទេ។

---

[២១] មាត្រា១០៣ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ

[២២] S/2011/58 UNSC document: letter dated 6 February 2011 from H.E. Mr. Hor Namhong, Deputy Prime Minister and Minister of Foreign Affairs of Cambodia

លក្ខខណ្ឌផ្សេងទៀតរបស់ក្រុមប្រឹក្សាត្រូវបានចែងក្នុងមាត្រា៣៣ ឬ៣៤ នៃធម្មនុញ្ញអ.ស.ប ពាក់ព័ន្ធនឹងស្ថានភាពជម្លោះធ្ងន់ធ្ងរ ដែលបង្កការគំរាមកំហែងដល់សន្តិភាព និងសន្តិសុខអន្តរជាតិ។ នេះជាការទទួលខុសត្រូវស្នូលរបស់ក្រុមប្រឹក្សា។

ក្នុងការកោះប្រជុំបាន ក្រុមប្រឹក្សាសន្តិសុខត្រូវដំណើរការតាមនិតិវិធីទូទៅរបស់ខ្លួន។ ជាដំបូង សមាជិកក្រុមប្រឹក្សាសន្តិសុខទាំង១៥ ត្រូវស្វែងរកការឯកភាពជាឯកច្ឆ័ន្ទសិន ប៉ុន្តែបើមានសំឡេង ជំទាស់ ក្រុមប្រឹក្សាសន្តិសុខនឹងធ្វើការបោះឆ្នោតផ្ទៃក្នុង យកសំឡេង៩ លើ១៥។ ប្រសិនបើវិវាទពុំមានស្ថានភាពធ្ងន់ធ្ងរឈានដល់ការប្រើកម្លាំងនោះទេ ក្រុមប្រឹក្សាសន្តិសុខទំនងជាពុំអាចដាក់ចេញសេចក្តីព្រាងសេចក្តីសម្រេច ឬវិធានការណ៍អ្វីឡើយ។ ជាងនេះទៅទៀត ***«សិទ្ធវេតូ»*** ជាសិទ្ធផ្តាច់មុខរបស់មហាអំណាចទាំង៥ ទោះជាក្នុងករណីពាក់ព័ន្ធនឹងបណ្តឹងនៃមាត្រា៩៤(២) នៃធម្មនុញ្ញនេះក៏ដោយ។ ជាក់ស្តែង បណ្តឹងនីការ៉ាហ្គ័រ *(Nicaragua)* ដែលជាបណ្តឹងតែមួយគត់ ដែលបានលើកយកមាត្រា៩៤(២) នេះមកជាសម្អាងច្បាប់ ប្តឹងអនុវត្តចំពោះការបំពានសាលដីកាពីសំណាក់ភាគីក្តីអាមេរិកត្រូវបានប្រើសិទ្ធ "វេតូ" ដោយអាមេរិកទៅលើសេចក្តីព្រាងស្តីពីការពារអំពាវនាវជាបន្ទាន់ ស្នើឱ្យអាមេរិកគោរពសាលដីកា។ ការណីដែលនឹងលើកយកមកបង្ហាញជាឧទាហរណ៍ខាងក្រោមបង្ហាញថា ភាគីឈ្នះក្តីបាត់បង់នូវជំហរចំពោះបណ្តឹងរបស់ខ្លួន ដោយសារតែមុខងារមិនប្រាកដរបស់ក្រុមប្រឹក្សា។

ការពិនិត្យលើគតិយុត្តិឃើញថា ការបាត់បង់នូវសិទ្ធដែលត្រូវក្រុមប្រឹក្សាយកមកពិនិត្យដូចបានអធិប្បាយគួរត្រូវបានចាត់ថាជាការបាត់បង់នូវសិទ្ធ "ម្ចាស់បំណុល" ទៅលើ"កូនបំណុលនៃការអនុវត្ត"[២៣]។

**ទីពីរ៖** ដើម្បីផ្តល់ប្រសិទ្ធភាពឱ្យសាលដីកា ក្រុមប្រឹក្សាសន្តិសុខអាចដាក់ចេញអនុសាសន៍ ឬវិធានការនានាតាមការដែលយល់ឃើញថាចាំបាច់។ ក្នុងន័យនេះ ក្រុមប្រឹក្សាសន្តិសុខអាចដាក់ចេញអនុសាសន៍ដល់ភាគីដែលខកខានពុំបានអនុវត្តសាលដីកា ដោយប្រើភាសាស្រាល ឬធ្ងន់ទៅតាមសភាពធ្ងន់ធ្ងរនៃករណីនីមួយៗ។ និតិវិធីកោះប្រជុំ មានទំនោរទៅរកនយោបាយជាជាង ផ្លូវច្បាប់។ ជាក់ស្តែងសមាជិកនៃក្រុមប្រឹក្សាសន្តិសុខពុំមែនជាអ្នកច្បាប់ តែគឺជាអ្នកការទូតដែលត្រូវតែងតាំងតាមផ្លូវនយោបាយបម្រើឱ្យប្រទេស។ ក្រុមប្រឹក្សាសន្តិសុខពុំស្ថិតក្នុងកាតព្វកិច្ចត្រូវតែឆ្លើយតបបណ្តឹងភាគី ថាត្រូវកោះប្រជុំ ឬត្រូវតែចាត់វិធានការណ៍បែបណានោះទេ ដោយសម្អាងទៅលើពាក្យថា ប្រសិនបើក្រុមប្រឹក្សា *"ចាត់ទុកថាចាំបាច់"*។

ប្រសិនបើជម្លោះមិនស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ ក្រុមប្រឹក្សាពុំអាចឈានដល់ការចេញសេចក្តីព្រាងសេចក្តីសម្រេច ឬវិធានការណ៍អ្វីទេ រីឯសិទ្ធវេតូ ជាសិទ្ធដាច់មុខរបស់ប្រទេសមហាអំណាចទាំង៥ ហើយ

---

[២៣] មាត្រា៣៤៧ ស្តីពីឈ្មោះហៅរបស់ភាគី នៃក្រមរដ្ឋប្បវេណីព្រះរាជណាចក្រកម្ពុជា (អនុម័ត ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០០៦) ដែលត្រូវបាន តាក់តែង និងយកលំនាំតាមក្រមរដ្ឋប្បវេណីជប៉ុន

ក៏គ្មានករណីលើកលែងចំពោះបណ្តឹងសាលដីកាតុលាការនោះទេ។ ក្រុមប្រឹក្សា ត្រូវពិនិត្យមើលមាត្រាផ្សេងទៀត ដូចជាមាត្រា៣៣ ឬ៣៤ នៃធម្មនុញ្ញអ.ស.បជាដើម ថាតើករណីនេះជាការគំរាមកំហែងដល់សន្តិសុខអន្តរជាតិឬទេ?

ទោះកោះប្រជុំក៏ដោយ ពុំមានអំណាចអ្វីបង្គាប់ឱ្យក្រុមប្រឹក្សាសន្តិសុខអ.ស.បត្រូវតែចេញវិធានការអនុវត្តសាលដីកាតាមបណ្តឹង ដោយហេតុថាមាត្រា៩៤(២)នេះជាមាត្រាទោល ដែលទុកចន្លោះឱ្យក្រុមប្រឹក្សាសំឡឹងទៅមាត្រា ឯទៀត។ បន្ថែមលើនេះ សិទ្ធិវេតូនៃមហាអំណាចទាំង៥ ដែលឈរលើផលប្រយោជន៍ជាមួយ ភាគីម្ខាងៗ និងសិទ្ធនៃប្រទេស១០ទៀត ជាការបង្ករឧបសគ្គដល់យុត្តិធម៌អន្តរជាតិ។

ករណីដែលគួរសិក្សាបន្ថែម ថាតើមាត្រា៩៤(២)នៃធម្មនុញ្ញអ.ស.ប មានតម្លៃគតិយុត្តក្នុងការពិនិត្យមើលបណ្តឹងស្តីពីការស្នើអនុវត្តសាលដីកាទាំងស្រុង ឬដោយផ្នែកឬទេ? ជាចម្លើយខ្លី គឺពុំធ្លាប់មានទាល់តែសោះក្នុងប្រវត្តិសាស្ត្រ។

ម្យ៉ាងទៀតកំណត់ហេតុបង្ហាញថាក្នុងសម័យសង្គ្រាមត្រជាក់ ក្រុមប្រឹក្សាសន្តិសុខត្រូវបានជាប់គាំងដោយសារតែសិទ្ធិអំណាចវេតូ តបតគ្នារវាង សហរដ្ឋអាមេរិក និងអតីតសហភាពសូវៀត និងចិនម្តងម្កាលផងដែរ។ ទាំងនេះ គឺជាការឆ្លុះបញ្ចាំងចំពោះការមិនអាចធ្វើបានចំពោះបណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខ អ.ស.ប លើបណ្តឹងសាលដីកា។

ទាំងនេះបង្ការជាភាពស្មុគស្មាញផ្នែកនីតិវិធី និងគេចោទជាសំណួរថា តើភាគីនៃរឿងក្តីអាចរំពឹងស្វះស្វែងបណ្តឹងទៅក្រុមប្រឹក្សា ក្នុងការបង្ខំអនុវត្តសាលដីកា ដ៏មានប្រសិទ្ធភាពឬទេ? ទាំងនេះសបញ្ជាក់ថា ក្រុមប្រឹក្សាសន្តិសុខ ស្ថិតនៅឆ្ងាយពីតួនាទីជាប្រតិបត្តិករ អនុវត្តសាលដីកា។

## ២. ករណីជាក់ស្តែង ចំពោះមុខក្រុមប្រឹក្សាសន្តិសុខអ.ស.ប

### ក. ករណីប្រាសាទព្រះវិហារ (កម្ពុជានិងថៃ)

ក្នុងជម្លោះទាក់ទងនឹងតំបន់ប្រាសាទព្រះវិហារ កម្ពុជាបានដាក់បណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខអ.ស.ប នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៨ ករណីថៃឈ្លានពានអធិបតេយ្យកម្ពុជា និងបំពានស្មារតីនៃសាលដីកាតុលាការយុត្តិធម៌អន្តរជាតិក្នុងសំណុំរឿងប្រាសាទព្រះវិហារ ផ្អែកតាមមាត្រា៩៤(១) តែពុំបានយោងដល់មាត្រា៩៤(២) នៃធម្មនុញ្ញអ.ស.ប នោះទេ។ ឆ្លើយតបនឹងបណ្តឹងនេះ ក្រុមប្រឹក្សាសន្តិសុខគ្រាន់តែបានចេញសេចក្តីប្រកាសព័ត៌មានអំពីបទឈប់បាញ់ និងគាំទ្រដំណោះស្រាយរបស់អាស៊ានតាមរយៈការបញ្ជូនអ្នកសង្កេតការណ៍ ដែលជាគំនិតផ្តួចផ្តើមដោយឥណ្ឌូនេស៊ីជាដើម ប៉ុន្តែពុំបានយោងដល់សាលដីកាតុលាការឡើយ។ រហូតមកដល់ពេលនេះ ពុំមានដំណោះស្រាយ។

## ខ. ករណីវិវាទនៅច្រកសមុទ្រក័រហ្វ៊ូ (អង់គ្លេសនិងអាល់បានី)

ក្នុងករណីវិវាទនៅច្រកសមុទ្រក័រហ្វ៊ូ តុលាការសម្រេចថា អាល់បានីមានការទទួលខុសត្រូវតាមច្បាប់អន្តរ-ជាតិចំពោះ គ្រាប់មីនដែលបានផ្ទុះនៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៤៦ ដែលបង្កឱ្យមានការខូចខាតនិងបាត់បង់អាយុជីវិតនាវិកជនជាតិអង់គ្លេស។[២៤] ទន្ទឹមនេះ តុលាការសម្រេចឱ្យអាល់បានីសងសំណងអង់គ្លេសនូវប្រាក់សំណងចំនួន ៨៤៣.៩៤៧ ផោន។ ទោះបីជាអាល់បានីពុំបានសងសំណងតាមសាលដីកាតុលាការក៏ដោយ ក៏អង់គ្លេសពុំបានដាក់បណ្ដឹងទៅក្រុមប្រឹក្សាសន្តិសុខ អ.ស.បនោះដែរ ដោយសារបារម្ភថាសហភាពសូវៀតបោះឆ្នោតវេតូ។ ករណីនេះបានបង្ហាញថា បញ្ហាវេតូជាឧបសគ្គរាំងការបង្ខំអនុវត្តសាលដីកាដោយស្វ័យប្រវត្តិ ដែលអ្នកច្បាប់អន្តរជាតិហៅថា *«អំណាចទ្វេរវេតូ» (double veto)* ព្រោះថា បញ្ហាមួយចំនួនត្រូវគេដឹងថានឹងករណីវេតូ នឹងកើតឡើង តាំងពីមិនទាន់ចូលដល់ក្រុមប្រឹក្សាសន្តិសុខមកម្ល៉េះ។

## គ. ករណីសិទ្ធិឆ្លងកាត់លើដែនដីឥណ្ឌា (ឥណ្ឌា តទល់ ព័រទុយហ្គាល់)

ក្នុងសំណុំរឿងសិទ្ធិឆ្លងកាត់ដែនដីឥណ្ឌា ព័រទុយហ្គាល់បានដាក់បណ្ដឹងទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ នៅខែ**ធ្នូ** ឆ្នាំ**១៩៥៥** ស្នើសុំឱ្យតុលាការប្រកាសអំពីសិទ្ធិរបស់ព័រទុយហ្គាល់ក្នុងការធ្វើដំណើរចេញ-ចូលបរិព័ទ្ធ Dadra and Nagar-Aveli[២៥] កាត់តាមទឹកដីឥណ្ឌា និងប្រកាសថា សិទ្ធិឆ្លងកាត់នេះត្រូវបានរំលោភបំពានដោយប្រទេសឥណ្ឌា។ ក្នុងសំអាងហេតុនៃសាលដីកា *(Reasoning)* តុលាការរកឃើញថា ភូមិទាំងពីរនេះស្ថិតក្រោមការអធិបតេយ្យរបស់ព័រទុយហ្គាល់ ដែលអង់គ្លេសនិងឥណ្ឌាពុំដែលបានជំទាស់នោះឡើយ។[26] ជាមួយគ្នានេះ ព័រទុយហ្គាល់មានសិទ្ធិឆ្លងកាត់ចេញ-ចូលទៅក្នុងទឹកដីរបស់ខ្លួនកាត់តាមទឹកដីឥណ្ឌា ក្រោមទម្រង់សេវភាពដែលកើតចេញពីការអនុវត្តជាប់លាប់របស់រដ្ឋទាំងពីរ។ ក្នុងផ្នែកសេចក្ដីសម្រេច(Operative part) តុលាការបានទទួលស្គាល់សិទ្ធិឆ្លងកាត់របស់ព័រទុយហ្គាល់ដែលផ្ដល់ជូនចំពោះជនស៊ីវិល ប៉ុន្តែពុំផ្ដល់ជូនកងកម្លាំងប្រដាប់អាវុធនោះទេ។ ក្នុងន័យនេះ តុលាការរកឃើញថា ឥណ្ឌាពុំបានរំលោភបំពានលើសិទ្ធិឆ្លងកាត់របស់ព័រទុយហ្គាល់ឡើយ។

ក្រោយមក ឥណ្ឌាបានបញ្ជូនតំណាងរបស់ខ្លួន លោក KG Badlani ចូលទៅគ្រប់គ្រងរដ្ឋបាលនៅភូមិ Dadra និង Nagar-Aveli របស់ព័រទុយហ្គាល់ ក្រោមមូលហេតុនៃការដង្ហោយហៅនៃប្រជាជនរស់នៅ

---

[២៤] Corfu Channel case, Judgment of April 9th, 1949: I.C. J. Reports 1949, p. 36.

[២៥] ជាស្ថានភាពទឹកដីដែលមានកម្រជួបប្រទះ៖ តំបន់ទាំងពីរនេះគឺជាទឹកដីព័រទុយហ្គាល់ ដែលភូមិសាស្ត្រត្រូវបានហ៊ុមព័ទ្ធជុំជិតដោយទឹកដីឥណ្ឌា ហើយផ្លូវធ្វើដំណើរត្រូវចេញ-ចូលឆ្លងកាត់ទឹកដីឥណ្ឌាដោយខានពុំបាន។

[២៦] Right of Passage on Indian Territory (Portugal v. India), Merit, I.C.J. Report 1960, Para. 39.

ទីនោះ។ ក្រោយមកទៀត លោក Badlani ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនៃតំបន់ខាងលើ ជាឈ្នាន់សម្រាប់ចុះកិច្ចព្រមព្រៀងធ្វើសមាហរណកម្មតំបន់នេះជាមួយទឹកដីឥណ្ឌានាខែសីហា ឆ្នាំ១៩៦១។ ឆ្លើយតបនឹងទង្វើនេះ ព័រទុយហ្គាល់បានដាក់បណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខ អ.ស.ប ករណីឥណ្ឌារំលោភបំពានសាលដីកានៃតុលាការយុត្តិធម៌អន្តរជាតិដែលបានទទួលស្គាល់អធិបតេយ្យព័រទុយហ្គាល់លើភូមិទាំងពីរនេះ។

ជាការកត់សម្គាល់ ថ្វីបើតុលាការទទួលស្គាល់អធិបតេយ្យព័រទុយហ្គាល់លើតំបន់ទាំងពីរនោះមែនក៏ប៉ុន្តែពុំបានយោងបញ្ហានេះក្នុងផ្នែកសេចក្តីសម្រេចឡើយ។ ទន្ទឹមនេះ បណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខពុំបានយោងមាត្រា៩៤ នៃធម្មនុញ្ញ អ.ស.ប ហើយក៏ពុំបានស្នើឱ្យក្រុមប្រឹក្សាសន្តិសុខកោះប្រជុំជាផ្លូវការនោះដែរ។ ដូច្នេះហើយ យើងពុំឃើញមានការពិភាក្សាជាផ្លូវការ និងដាក់ចេញវិធានអ្វីពីក្រុមប្រឹក្សាទេ។

## **ឃ. ករណីបុគ្គលិកកុងស៊ុលនិងអ្នកការទូតអាមេរិក** ( **អាមេរិក** v. **អ៊ីរ៉ង់** )

នៅថ្ងៃ**១៤ ខែកុម្ភៈ ឆ្នាំ១៩៧៩** ក្រុមប្រដាប់អាវុធនៅអ៊ីរ៉ង់ដែលខឹងសម្បារនឹងនយោបាយអាមេរិកបានចូលលុកលុយស្ថានទូតអាមេរិក និងចាប់ចំណាប់ខ្មាំង**៧០នាក់** ប៉ុន្តែក្រោយពីអន្តរាគមន៍ពីរដ្ឋាភិបាលអ៊ីរ៉ង់ ទើបចំណាប់ខ្មាំងត្រូវបានដោះលែងមកវិញ។ ការភ័យខ្លាចបន្តកើតមានជាហូរហែរ។ នៅខែ**វិច្ឆិកា ឆ្នាំ១៩៧៩** អំឡុងពេលធ្វើបាតុកម្មនៅមុខស្ថានទូតអាមេរិក ក្រុមអ៊ិស្លាមជ្រុលនិយមបានលុកលុយស្ថានទូតអាមេរិកម្តងទៀត ចាប់បុគ្គលិកនិងអ្នកការទូតអាមេរិក**៥៣នាក់** ជាចំណាប់ខ្មាំង ទុកជាថ្នូរនឹងមេដឹកនាំរបស់ខ្លួនឈ្មោះ ស្ហា*(sha)*ដែលត្រូវអាមេ-រិកចាប់។ អន្តរាគមន៍ត្រូវបានធ្វើឡើងទាំងនៅក្រុមប្រឹក្សាសន្តិសុខនិងមហាសន្និបាត ប៉ុន្តែពុំបានសម្រេច។ សេចក្តីព្រាងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខដាក់ទណ្ឌកម្មលើអ៊ីរ៉ង់ ត្រូវបានសហភាពសូវៀតបោះឆ្នោតវេតូ។

អាមេរិក បានដាក់បណ្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិប្រឆាំងនឹងអ៊ីរ៉ង់ នៅថ្ងៃទី**២៩ ខែវិច្ឆិកា ឆ្នាំ១៩៧៩**។ ករណីនេះ តុលាការបានដាក់ចេញវិធានរក្សាការពារជាបណ្តោះអាសន្ន ដោយតម្រូវឱ្យអ៊ីរ៉ង់ដោះលែងចំណាប់ខ្មាំង ប៉ុន្តែអ៊ីរ៉ង់ពុំអនុវត្តតាម។ នៅថ្ងៃទី**២៤ ខែឧសភា ឆ្នាំ១៩៨០** តុលាការយុត្តិធម៌អន្តរជាតិបានរកឃើញថា អ៊ីរ៉ង់ បានធ្វើសកម្មភាពនិងបន្តធ្វើសកម្មភាពរំលោភបំពានលើកាតព្វកិច្ចជំពាក់អាមេរិកក្រោមច្បាប់អន្តរជាតិ ដែលទង្វើនេះ ភ្ជាប់នឹងការទទួលខុសត្រូវជាអន្តរជាតិ។ តុលាការបង្គាប់ឱ្យអ៊ីរ៉ង់ដោះលែងចំណាប់ខ្មាំងនិងធានាការចាកចេញពីទឹកដីអ៊ីរ៉ង់ ព្រមទាំងសងការខូចខាតចំពោះអាមេរិក ដែលទំហំនៃសំណងនឹងត្រូវសម្រេចពេលក្រោយ ប្រសិនបើភាគីទាំងពីរពុំអាចឈានដល់កិច្ចព្រមព្រៀងបានទេ។

ក្រោយមក តាមរយៈកិច្ចចរចាតាមផ្លូវការទូតជាមួយអ៊ីរ៉ង់ អាមេរិកបានជម្រាបទៅអគ្គលេខាធិការ អ.ស.ប ដូច្នេះថា ប្រសិនបើចំណាប់ខ្មាំងត្រូវបានដោះលែងនោះ អាម៉េរិកចាត់ទុកថាអ៊ីរ៉ង់គោរពពេញលេញចំពោះសេចក្តីសម្រេចចិត្តក្រុមប្រឹក្សាសន្តិសុខដែលបានសម្រេចនៅឆ្នាំ១៩៧៩និង១៩៨០។ ជាលទ្ធផលចំណាប់ខ្មាំងត្រូវបានដោះលែង ក្រោយការបង្ខាំងទុកអស់រយៈពេល៤៤៤ថ្ងៃ។

អាមេរិកមានប្រៀបទាំងផ្នែកតុលាការ ទាំងអំណាចនយោបាយក្នុងក្រុមប្រឹក្សាសន្តិសុខអ.ស.ប។ ទោះជាប្រទេសធំក្តី តូចក្តី គេនៅតែចាត់ទុកតម្លៃគតិយុត្តនៃសាលដីកាតុលាការ សម្រាប់កៀរគរសហគមន៍អន្តរជាតិគាំទ្រដាក់គំនាបអនុវត្ត។ គេត្រូវចោទសួរផងដែរថា ប្រសិនបើអ៊ីរ៉ង់ជាអ្នកប្តឹងទៅក្រុមប្រឹក្សាសន្តិសុខវិញ តើក្រុមប្រឹក្សាសន្តិសុខ អ.ស.ប នឹងខ្នះខ្នែងលើបណ្តឹងអ៊ីរ៉ង់ដូចដែលគេធ្វើជាមួយអាម៉េរិកដែរឬទេ ?

## III. សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ថា ការមិនគោរពសាលដីកា ជាការរំលោភលើច្បាប់អន្តរជាតិ និងទៅលើធម្មនុញ្ញ អ.ស.ប ដែលនឹងនាំដល់ផលវិបាក។ សាលដីកាតុលាការ ត្រូវតែអាចអនុវត្តបានដោយពេញលេញនិងប្រសិទ្ធភាព ក្នុងន័យធានាការគ្រប់គ្រងនៃវិស័យយុត្តិធម៌ *(administration of justice)*។ ផ្ទុយទៅវិញ ការសិក្សាបានបង្ហាញថា ការអនុវត្តសាលដីកានៅពុំទាន់ច្បាស់លាស់ ដោយហេតុថា ក្រុមប្រឹក្សាសន្តិសុខនៅពុំទាន់ដើរតួជាប្រតិបត្តិករអនុវត្តសាលដីកាស្រប តាមមាត្រា៩៤ នៃធម្មនុញ្ញ អ.ស.ប នៅឡើយ។ ការអនុវត្តជាក់ស្តែងនៅមានឧបសគ្គរាំងរា ជាពិសេស ល្បាយលាយឡំនៃផលប្រយោជន៍នយោបាយអន្តរជាតិនៃសមាជិកក្រុមប្រឹក្សាសន្តិសុខ និងសិទ្ធវេតូរបស់សមាជិកអចិន្ត្រៃយ៍ ដែលអនុវត្តបានដោយគ្មានការលើកលែង សូម្បីតែចំពោះសាលដីកាតុលាការយុត្តិធម៌អន្តរជាតិក៏ដោយ។

ម្យ៉ាងទៀត ក្រុមប្រឹក្សាសន្តិសុខមានមុខងារភារកិច្ចទាក់ទងនឹងសន្តិសុខអន្តរជាតិ ដូច្នេះហើយ គេពុំសង្ឃឹមថា ក្រុមប្រឹក្សាអាចចេញអនុសាសន៍ ឬវិធានការដំណោះស្រាយនោះទេ ប្រសិនបើទំនាស់ពុំទាន់ឈានដល់ជម្លោះប្រដាប់អាវុធ និងការប្រើប្រាស់កម្លាំង។ ករណីនេះ គេអាចចោទជាសំណួរថា តើរដ្ឋមួយដាក់បណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខស្នើសុំអនុវត្តសាលដីកាតុលាការ ឬស្នើសុំឱ្យក្រុមប្រឹក្សាសន្តិសុខដោះស្រាយជម្លោះធ្ងន់ធ្ងរ ដូចជាជម្លោះប្រដាប់អាវុធ ឬការឈ្លានពានជាដើម។

ដើម្បីជាប្រយោជន៍នៃការគ្រប់គ្រងនៃវិស័យយុត្តិធម៌ (administration of justice) ក្នុងន័យធានាការ អនុវត្តបានពេញលេញនិងប្រកបដោយប្រសិទ្ធភាពនូវមុខងារតុលាការ គេពុំអាចប្រកែកបានឡើយនូវសមត្ថកិច្ចចាំបាច់របស់តុលាការ មានជាអាទិ៍អំណាចសម្រេចអំពីយុត្តាធិការរបស់ខ្លួន អំណាចចាត់តាំងអ្នកជំនាញដើម្បីផ្តល់យោបល់បច្ចេកទេសនិងស្វែងរកការពិត អំណាចចាត់អ្នកជំនាញក្នុងការជួយភាគីអនុវត្តសាលដីកា អំណាចដាក់ចេញវិធានការរក្សាការពារ អំណាចតម្រង់ទិសក្នុងការអនុវត្តសាលដីកា អំណាចកំណត់សំណងព្យសនកម្មកើតចេញពីអំពើអនីត្យានុកូល រួមបញ្ចូលទាំងការរំលោភបំពានខ្លឹមសារសាលដីកាផង។ ទន្ទឹមនេះ គេអាចពិចារណាគំរូល្អៗនានាពីតុលាការអន្តរជាតិដទៃទៀត ឬសូម្បីតែតុលាការក្នុងស្រុក ដែលផ្តល់អំណាចឱ្យតុលាការបន្តវិធានការចាំបាច់ក្នុងការតាមដានការអនុវត្ត និងអនុញ្ញាតឱ្យប្តឹងត្រឡប់មកតុលាការវិញ ក្នុងករណីភាគីម្ខាងទៀតខកខានមិនអនុវត្ត ឬបំពានសាលដីកា។

# គន្ថនិទ្ទេស


១. ក្រមរដ្ឋប្បវេណីព្រះរាជណាចក្រកម្ពុជា (អនុម័ត ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦) ដែលត្រូវបាន តាក់តែង និងយកលំនាំតាមក្រមរដ្ឋប្បវេណីជប៉ុន

២. Statute of the International Court of Justice (ICJ)

៣. Rules of the International Court of Justice, adopted on 14 April 1978 and entered into force on 1 July 2078

៤. Vienna Convention on the Law of Treaties 1969

៥. Charter of the United Nations

៦. S/2011/58 UNSC document: letter dated 6 February 2011 from H.E. Mr. Hor Namhong, Deputy Prime Minister and Minister of Foreign Affairs of Cambodia

៧. ICJ's Order of 12 October 2020, Armed Activities on the Territory of the Congo (Congo v. Uganda)


ICJ cases:


១. Request for Interpretation of the Judgment of 15 June 1962 in the Case concerning the Temple of Preah Vihear (Cambodia v. Thailand) (Cambodia v. Thailand), Provisional Measures, Order of 18 July 2011, I.C.J. Reports 2011

២. LaGrand (Germany v. United States of America), Judgment, I.C.J. Reports 2001

៣. Reports of ICJ: Case Concerning United States Diplomatic and Consular Staff in Tehran, 1980

៤. The Corfu Channel Case, (UK v. Albania), Order of 17 December 1948, Expert Opinion

៥. Corfu Channel case, Judgment of April 9th, 1949: I.C. J. Reports 1949

៦. Allegations of Genocide under the Convention on the Prevention and Punishment of the Crime of Genocide (Ukraine v. Russian Federation), Provisional Measures, Order of 16 March 2022, I.C.J. Reports 2022

៧. Rights of Passage on Indian Territory (Portugal v. India), Merit, I.C.J. Report 1960

# សារៈសំខាន់នៃការអប់រំកម្រិតមត្តេយ្យសិក្សា

បេក្ខជនបណ្ឌិតៈ **ប្រាក់ កុសល**
ជំនាញៈ **វិទ្យាសាស្ត្រអប់រំ**

## ១. សេចក្តីផ្តើម

ការផ្តល់សេវាថែទាំសុខភាព និងអាហារូបត្ថម្ភគ្រប់គ្រាន់ ជាពិសេសការផ្តល់ឱកាសរៀនសូត្របានទាន់ពេលវេលាសម្រាប់កុមារតូច ជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍពេញលេញ និងគ្រប់ជ្រុងជ្រោយ ដើម្បីត្រៀមកុមារចូលរៀននៅបឋមសិក្សាប្រកបដោយជោគជ័យ និងកាត់បន្ថយអាត្រាបោះបង់ការសិក្សា ជួយឱ្យកុមារទទួលលទ្ធផលការសិក្សាពេញមួយជីវិត។ ជារួមផ្អែកតាមការស្រាវជ្រាវវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបង្ហាញថាការវិនិយោគ ១ដុល្លារ សម្រាប់កុមារតូច នឹងទទួលផលត្រឡប់មកវិញរហូតដល់ ១៧ដុល្លារ ដើម្បីលើកកម្ពស់ជីវភាពរស់នៅសម្រាប់គ្រួសារ សម្រាប់កុមារ និងសម្រាប់សង្គមជាតិៈ

- **លទ្ធផលចំពោះមុខសម្រាប់គ្រួសារៈ** ឪពុកម្តាយមានពេលវេលាគ្រប់គ្រាន់ប្រកបមុខរបរការងារ សម្រាប់បង្កើនប្រាក់ចំណូលប្រចាំថ្ងៃ និងកាត់បន្ថយការចំណាយលើសេវាសុខភាពរបស់កុមារ ដោយកុមារទទួលបានការថែទាំពេញលេញ មានសុខភាពល្អ និងមានភាពកក់ក្តៅ មានសុភមង្គលក្នុងភាពថ្លៃថ្នូរ គ្មានអំពើហិង្សា ជួយលើកកម្ពស់ជីវភាពរស់នៅរបស់គ្រួសារឱ្យមានភាពកាន់តែប្រសើរឡើង។



Source: Heckman (2008)

- **លទ្ធផលចំពោះសម្រាប់កុមារៈ** ការថែទាំ និងអប់រំជាប្រចាំនៅមត្តេយ្យសិក្សា កុមារនឹងទទួលបានការអប់រំ ការថែទាំប្រកបដោយភាពឆ្លើយតប សន្តិភាពនិងសុវត្ថិភាព ឱកាសរៀនសូត្រទាន់ពេលវេលាបណ្តុះបាននូវសមត្ថភាពចិត្តសង្គម ឥរិយាបថ សីលធម៌ សុជីវធម៌ និងគុណធម៌ ដើម្បីត្រៀមខ្លួនចូលសាលារៀនប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព។
- **លទ្ធផលចំពោះសម្រាប់សង្គមជាតិៈ** កសាងបាននូវធនធានមនុស្សប្រកបដោយសមត្ថភាព ជំនាញវិជ្ជាជីវៈក្នុងយុគ្គសម័យឌីជីថល ឆន្ទៈម្ចាស់ការ នឹងក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួនជាពលរដ្ឋពេញលេញ ធានាបាននូវសុខសន្តិភាព និងសណ្តាប់ធ្នាប់សង្គម ការអភិវឌ្ឍ និងការរក្សាស្ថេរភាពសង្គម-សេដ្ឋកិច្ច ដើម្បីលើកកម្ពស់ជីវភាពប្រជាជន និងរក្សាស្ថេរភាពនយោបាយ

កសាងសង្គមជាតិមួយឱ្យរឹងមាំមានវិបុលភាព រុងរឿង រស់រវើក ក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

## ២. កុមារភាពជាវ័យមូលដ្ឋានក្នុងការអភិវឌ្ឍធនធានមនុស្ស

កុមារតូចវ័យចូលសាលាមត្តេយ្យសិក្សា គឺជារយៈពេលមូលដ្ឋានគ្រឹះដ៏សំខាន់និងមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍរបស់មនុស្ស។ ក្នុងន័យនេះ ខួរក្បាលកុមារក្នុងអំឡុងពេលនេះកំពុងមានការអភិវឌ្ឍខ្ពស់ និងងាយទទួលយកបានសមត្ថភាពនិងបំណិននានា។ ផ្ទុយទៅវិញ ការផ្ដល់នូវទម្លាប់បែបអវិជ្ជមាននឹងធ្វើឱ្យប៉ះពាល់ពន្យារការលូតលាស់ផ្នែកខួរក្បាលកុមារ ដែលពួកគេមិនអាចបំពេញសមត្ថភាពមកវិញនៅវ័យបន្ទាប់ទៀតបានទេ។ ការអភិវឌ្ឍធនធានមនុស្ស មិនពឹងផ្អែកនិងអាស្រ័យតែលើកត្តាដំណពូជនោះទេ ប៉ុន្តែវាក៏អាស្រ័យលើកត្តាមជ្ឈដ្ឋានជុំវិញ ការគាំពារ ការផ្ដល់ក្ដីស្រឡាញ់ ការភ្ញោចបានទាន់ពេលវេលា ការយកចិត្តទុកដាក់ពីបរិយាកាសជុំវិញ និងទទួលបានការអប់រំនិងការថែរក្សាកុមារត្រឹមត្រូវផងដែរ[៩]។

លើសពីនេះទៀត ក្នុងវ័យនេះកុមាររីករាយនឹងបទពិសោធផ្សេងៗតាមរយៈការលេង និងបរិស្ថាន។ បទពិសោធទាំងនេះបង្កើតឱ្យមានបរិយាកាសនិងភាពទាក់ទាញ ធ្វើឱ្យកុមារតូចចង់ដឹងពីបរិស្ថាន និងពិភពលោក។ បទពិសោធដ៏មានអត្ថន័យទាំងនេះ គឺជាឫសគល់ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍរបស់កុមារបានគ្រប់ជ្រុងជ្រោយនាពេលអនាគត។

ភាគច្រើនបំផុតនៃការរីកចម្រើនកោសិកាខួរក្បាលរបស់កុមារ ចាប់ផ្ដើមកើតមាននៅក្នុងវ័យ៥ឆ្នាំដំបូងនៃជីវិត ដែលជាពេលវេលាដែលពួកគេមានឱកាសតិចតួចណាស់ក្នុងការផ្លាស់ប្ដូរមុខងាររបស់ខួរក្បាលនៅវ័យបន្ទាប់។ សូម្បីតែមុខងារមួយចំនួនដែលមានលក្ខណៈភ្ញោចខ្លាំងនៅវ័យបន្ទាប់(ឧទាហរណ៍ ចំនួន និងទំនាក់ទំនងសង្គម) តែកម្រិតរំញោចខ្លាំង គឺកុមារស្ថិតនៅវ័យ ៤ឆ្នាំ ទៅ៥ឆ្នាំដំបូងនេះ។ មុខងារផ្សេងៗក៏ដូចគ្នាដែរ ដូចជាការគ្រប់គ្រងអារម្មណ៍និងប្រតិកម្មឆ្លើយតបមិនត្រឹមតែមានរំញោចខ្លាំងនៅក្នុងវ័យដំបូងនោះទេ ប៉ុន្តែក៏មានស្ថេរភាពនៅមុនអាយុ៥ឆ្នាំ។ ទាំងនេះបានបញ្ជាក់ថា អ្វីដែលកុមារបានអភិវឌ្ឍន៍ក្នុងដំណាក់កាលនេះ មិនងាយនឹងមានការផ្លាស់ប្ដូរការរីកចម្រើននូវវ័យបន្ទាប់ឡើយ។ ហេតុដូច្នេះហើយបានជាការជំរុញការអភិវឌ្ឍក្នុងវ័យនេះមានសារៈសំខាន់បំផុត។

## ៣. ការត្រៀមខ្លួនគ្រប់គ្រាន់របស់កុមារតូច

ការអប់រំកម្រិតមត្តេយ្យសិក្សា ជំរុញឱ្យកុមារបានត្រៀមខ្លួនគ្រប់គ្រាន់មុនពួកគេចូលរៀននៅកម្រិតបឋមសិក្សាប្រកបដោយសមត្ថភាព ជំនាញ និងបំណិនជាមូលដ្ឋានគ្រឹះ កាត់បន្ថយអត្រាបោះបង់ការសិក្សា អត្រាត្រួតថ្នាក់ និងធានាមានភាពជោគជ័យលើការសិក្សាប្រកបដោយនិរន្តរភាពនៅបឋមសិក្សា និងកម្រិត

[៩] Evans, Myers, IIfeld: Early Childhood Counts

ខ្ពស់បន្តបន្ទាប់។ ការអប់រំកុមារតូចមិនត្រឹមតែធ្វើឱ្យកុមារបានត្រៀមខ្លួនរួចរាល់មុនពេលចូលសាលានោះទេ តែក៏ជំរុញដល់ការអភិវឌ្ឍទៅលើផ្នែកសង្គម និងអារម្មណ៍របស់កុមារ ដើម្បីឱ្យពួកគេបានស៊ាំទៅនឹងបរិស្ថានការរៀនសូត្រនៅសាលារៀន។ ដូច្នេះនៅចុងបញ្ចប់នៃកម្រិតមត្តេយ្យសិក្សា កុមារបានត្រៀមខ្លួនរួចរាល់សម្រាប់បន្តការសិក្សានៅសាលាបឋមសិក្សា។ ជាទូទៅកុមារដែលបានទទួលការអប់រំនៅកម្រិតមត្តេយ្យសិក្សា តែងតែទទួយលបានលទ្ធផលនៃការសិក្សាល្អនៅកម្រិតបឋមសិក្សាជាងកុមារដែលមិនបានឆ្លងកាត់ការសិក្សានៅកម្រិតមត្តេយ្យសិក្សា[២]។

មិនត្រឹមតែប៉ុណ្ណោះ ការអប់រំកុមារតូច ចូលរួមកាត់បន្ថយគម្លាតសេដ្ឋកិច្ចរវាងអ្នកមាន-អ្នកក្រ និងចូលរួមទប់ស្កាត់កាត់បន្ថយភាពក្រីកផងដែរ។ កុមារងាយរងគ្រោះជាច្រើនមិនបានទទួលការយកចិត្តទុកដាក់មើលថែពីគ្រួសារ និងការអប់រំគ្រប់គ្រាន់នោះទេ។ ហេតុនេះប្រសិនបើពួកគេពុំទទួលបានការអភិវឌ្ឍពេញលេញទាំងផ្នែករាងកាយ ភាសា បញ្ញា សង្គម និងអារម្មណ៍របស់ខ្លួនសមស្របតាមវ័យទេនោះ វានឹងប្រឈមជួបនូវផលវិបាក និងពុំអាចត្រៀមខ្លួនគ្រប់គ្រាន់សម្រាប់ចូលរៀននៅសាលាបឋមសិក្សាឡើយ ហើយពួកគេពុំអាចទទួលបានជោគជ័យក្នុងការសិក្សាដែលបណ្តាលឱ្យអត្រានៃការត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សាកើនឡើង។ ការអប់រំកុមារនៅកម្រិតមត្តេយ្យសិក្សាបានសមស្រប នឹងផ្តល់ឱកាសស្មើភាពគ្នាដល់កុមារទោះស្ថិតក្នុងស្ថានភាពលំបាកក៏ដោយ នឹងផ្តល់ឱកាសឱ្យពួកគេចាប់ផ្តើមទទួលយកការអប់រំនៅដំណាក់កាលដំបូងក្នុងឆាកជីវិតរបស់ពួកគេ ក៏ដូចជាចូលរួមកាត់បន្ថយភាពក្រីកផងដែរ[៣]។

ទន្ទឹមនឹងនេះ ការអប់រំកម្រិតមត្តេយ្យសិក្សា ក៏បានចូលរួមលើកកម្ពស់ដល់កុមារីឱ្យមានឱកាសបានចូលសិក្សាប្រកបដោយគុណភាពនិងនិរន្តរភាព និងផ្តល់ឱកាសឱ្យមាតាបិតាអាចមានលទ្ធភាពនិងពេលវេលាគ្រប់គ្រាន់បកបរបរបង្កើនប្រាក់ចំណូលក្នុងគ្រួសារថែមទៀតផង។

ការផ្តល់សេវាអប់រំដល់កុមារគឺជាការផ្តល់នូវសិទ្ធិដែលកុមារត្រូវទទួលបាន និងមានសារៈសំខាន់ណាស់សម្រាប់ពួកគ។ កុមារទាំងអស់មានសិទ្ធិទទួលបាននូវការគាំពារ ការថែរក្សាប្រកបដោយក្តីស្រលាញ់ និងរីកចម្រើនលូតលាស់នៅក្នុងបរិយាកាសល្អ។ មនុស្សធំនិងអ្នកនៅជុំវិញកុមារមានតួនាទី និងទទួលខុសត្រូវក្នុងការផ្តល់នូវបរិស្ថានបែបវិជ្ជមាន និងគាំទ្រដល់ការអភិវឌ្ឍរបស់កុមារតូចគ្រប់ជ្រុងជ្រោយ ឆ្លើយតបទៅនឹងសិទ្ធិសំខាន់ៗទាំង៤របស់កុមារ រួមមាន៖ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារ សិទ្ធិទទួលបានការអប់រំ សិទ្ធិក្នុងការចូលរួម។

ដើម្បីជាមូលដ្ឋានក្នុងការកំណត់រៀបចំកម្មវិធីសិក្សា សម្រាប់ការអប់រំនៅកម្រិតមត្តេយ្យសិក្សា និងផ្សារភ្ជាប់កម្មវិធីសិក្សានៃបណ្តាប្រទេសនានាក្នុងតំបន់និងសាកលលោក ក្រសួងអប់រំ យុវជន និងកីឡា

---

[២] រាជរដ្ឋាភិបាល៖ គោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូច ឆ្នាំ២០១០

[៣] អង្គការសន្តិស្ម័គ្រចិត្ត(SVA)៖ សារៈសំខាន់នៃការអប់រំកុមារតូច ឆ្នាំ២០១៩

បានសហការរៀបចំស្តង់ដារសិក្សាសម្រាប់កុមារតូច ដែលផ្តោតលើការអភិវឌ្ឍសមត្ថភាពកុមារអាយុ៣ ទៅ ៥ឆ្នាំ ដែលរួមមាន ៖ ការអភិវឌ្ឍរូបរាងកាយ និងសុខភាព ការអភិវឌ្ឍសីលធម៌ និងវប្បធម៌ ការអភិវឌ្ឍសង្គម និងអារម្មណ៍ ការអភិវឌ្ឍការយល់ដឹង និងការពិចារណា ការអភិវឌ្ឍភាសា។

កុមារអាចចាប់ផ្តើមការសិក្សា និងការរស់នៅរបស់ពួកគេបានយ៉ាងល្អប្រសើរបន្ទាប់ពីពួកគេបានអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ តាមរយៈកម្មវិធីអប់រំ និងការគាំពារកុមារតូច។ ការអភិវឌ្ឍធនធានកុមារតូច ជាដំណើរការមួយដែលពាក់ព័ន្ធនឹងផ្នែកនៃតម្រូវការអភិវឌ្ឍជាច្រើន។ ប្រសិនបើការអភិវឌ្ឍលើផ្នែកណាមួយពុំមានការរីកចម្រើនលូតលាស់ល្អទេនេះ វាក៏នឹងជះឥទ្ធិពលដល់ផ្នែកផ្សេងទៀតផងដែរ។ ឧទាហរណ៍ បញ្ហាកង្វះអាហារូបត្ថម្ភមិនត្រឹមតែធ្វើឱ្យរូបរាងកាយរបស់កុមារលូតលាស់ពុំបានល្អនោះទេ តែវាក៏ធ្វើឱ្យប៉ះពាល់ដល់ការរីកចម្រើនផ្នែកការគិតពិចារណា និងការសិក្សាខ្សោយចុះផងដែរ។ ម្យ៉ាងទៀតបញ្ហាកង្វះការយកចិត្តទុកដាក់ពីសំណាក់មនុស្សធំទៅលើកុមារ ក៏ជះឥទ្ធិពលមិនល្អដល់កុមារផងដែរ រួមមានទាំងខ្សោយបញ្ញាស្មារតី ការគិតស្វែងយល់ ហើយបើសុខភាពមិនល្អក៏ប្រឈមមុខនឹងជំងឺផ្សេងៗ និងមានការរីកលូតលាស់រូបរាងកាយយឺតយ៉ាវជាដើម។

## ៤. ស្ថានភាពអប់រំកម្រិតមត្តេយ្យសិក្សាមុនឆ្នាំ ១៩៨០

នៅកម្ពុជាការអប់រំផ្នែកមត្តេយ្យសិក្សា ត្រូវបានបើកឲ្យដំណើរការជាផ្លូវការជាដំបូង នៅឆ្នាំសិក្សា ១៩៥៤-៥៥ ក្នុងបរិវេណសាលាបឋមសិក្សាកុមារី (សោហី) ខេត្តបាត់ដំបង ។ ថ្នាក់រៀននេះរៀបចំឡើងដោយលោកស្រី ភី ធៀនឡាយ ដោយទទួលអោយកុមារចូលរៀនដំបូងចំនួន ២២នាក់ អាយុពី ៤-៥ឆ្នាំ[៤]។

នៅចន្លោះឆ្នាំ ១៩៥៦-១៩៦៩ ថ្នាក់មត្តេយ្យសិក្សារដ្ឋចំនួន ២៣កន្លែងទៀត ត្រូវបានបើកទ្វារដំណើរការ ដែលក្នុងនោះមាន ៩កន្លែងនៅទីក្រុងភ្នំពេញ និង១៤កន្លែងផ្សេងទៀត នៅតាមបណ្តាខេត្តមានដូចជា ខេត្តបាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កំពង់ធំ ព្រៃវែង ក្រចេះ ស្វាយរៀង កំពង់ចាម កំពង់ស្ពឺ តាកែវ ស្ទឹងត្រែង ក្រុងកំពង់សោម និងក្រុងកែប។ កាលនោះការរៀបចំថ្នាក់មត្តេយ្យសិក្សាភាគច្រើនស្ថិតនៅក្នុងបរិវេណសាលាបឋមសិក្សា ឬបឋមសិក្សាបំពេញវិជ្ជា។

ចំពោះខ្លឹមសារការអប់រំកម្រិតមត្តេយ្យសិក្សាគឺ ជួយកុមារឲ្យមានការរីកចម្រើនគ្រប់ផ្នែក រួមមាន ផ្នែកសុខភាពនិងរាងកាយ បញ្ញា ស្មារតី និងបុគ្គលិកលក្ខណៈ។ ការអនុវត្តសកម្មភាពបង្រៀនផ្តល់បរិយាកាសជាល្បែងលេង ឬការអនុវត្តជាសកម្មភាពស្តែង តាមការអប់រំបែបទំនើបដោយអប់រំកុមារឱ្យមានទំលាប់ល្អ មានសុជីវធម៌ល្អ មានចរិយាថ្លៃថ្នូរ ចេះប្រើភាសាខ្មែរបានត្រឹមត្រូវ ចេះស្រលាញ់អ្វីដែលល្អ ព្រមទាំងបណ្តុះនូវចំណូលចិត្តចំរៀង របាំ និងគំនូរជាដើម។

---

[៤] គី សំភី៖ សារណាមត្តេយ្យសាលានៃមហាវិទ្យាល័យគរុកោសល្យភ្នំពេញ ឆ្នាំ១៩៩៥-៩៦

ចំពោះការជ្រើសរើសគ្រូមត្តេយ្យសិក្សា កាលពីក្នុងអំឡុងឆ្នាំ១៩៦០ អ្នកដែលអាចមានសមត្ថភាពឲ្យគេជ្រើសរើសនោះគឺជា សិស្សថ្នាក់ទី៣ទំនើបជាតិ (សមមូលទៅនិងថ្នាក់ទី ៩ បច្ចុប្បន្ន) ហើយត្រូវចូលទៅបំពេញកិច្ចសិក្សាខាងមត្តេយ្យសាលា ៤ឆ្នាំទៀតទើបអាចមានសមត្ថភាពទៅដឹកនាំសកម្មភាពរបស់កុមារនៅតាមថ្នាក់មត្តេយ្យសិក្សាបាន។ តាមនិយាមកំណត់អ្នកគ្រូមត្តេយ្យសិក្សាម្នាក់ៗត្រូវទទួលដឹកនាំសកម្មភាពកុមារពី៣០-៣៥ នាក់ ក្នុង ១ថ្នាក់។

ក្រោយមកនៅក្នុងអំឡុងឆ្នាំ១៩៧០ អ្នកគ្រូមត្តេយ្យសិក្សា ត្រូវបានជ្រើសរើសចេញពីក្នុងចំណោមគរុសិស្សបឋមសិក្សាដែលមានលក្ខណៈសម្បត្តិពិសេស មានមនសិការវិជ្ជាជីវៈក្នុងចំណោមអ្នករៀនជាប់ចំណាត់ថ្នាក់លេខ១ ដល់លេខ៥។ នៅក្នុងសម័យនោះ រដ្ឋទទួលបន្ទុកផ្តល់អាគារសិក្សា និងបុគ្គលិកសិក្សា រីឯមាតាបិតាត្រូវបង់វិភាគទានមួយចំនួន ដើម្បីជួយការងារកសាងសម្ភារៈឧបទេសសម្រាប់រៀននិងបង្រៀន និងផ្តល់ការលើកទឹកចិត្តដល់អ្នកថែទាំកុមារ។ ក្រៅពីនេះសាលាមត្តេយ្យសិក្សា ស្ថិតនៅក្រោមការទទួលខុសត្រូវ និងគាំទ្របន្ថែមផ្នែកសម្ភារៈពីសំណាក់ចៅហ្វាយក្រុង ឬចៅហ្វាយខេត្តទៀតផង។

ក្នុងមួយរយៈក្រោយពីបាន បើកដំណើរការសាលាមត្តេយ្យសិក្សាដំបូងគេនៅខេត្តបាត់ដំបង ដំណើរការផ្នែកមត្តេយ្យសិក្សា ត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមត្តេយ្យសាលា និងថ្នាក់កុមារដ្ឋានដែលអនុម័តដោយរដ្ឋសភា នាថ្ងៃទី២ ខែមេសា ឆ្នាំ១៩៥៧ និងឡាយព្រះហស្តលេខាដោយព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រឹត នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៥៧។ នៅក្នុងច្បាប់ ស្តីអំពីការរៀបចំនិងការប្រព្រឹត្តទៅនៃមត្តេយ្យសាលានិងថ្នាក់កុមារដ្ឋានបានផ្តោតការយកចិត្តទុកដាក់ទៅលើ[៥]៖

ក. ការរៀបចំបញ្ចូលសាលាមត្តេយ្យនៅក្នុងសាលាបឋមសិក្សា និងការកំណត់អាយុកុមារចូលរៀននៅថ្នាក់មត្តេយ្យសិក្សា។ គឺមានន័យថា ប្រសិនបើក្នុងភូមិណាដែលមានសាលាបឋមសិក្សាជាន់ដំបូង ឬបឋមសិក្សាបំពេញវិជ្ជា មត្តេយ្យអាចផ្លាស់ប្តូរទៅជាថ្នាក់កុមារដ្ឋានភ្ជាប់ទៅសាលាបឋមសិក្សានោះ។ម្យ៉ាងទៀត អាយុកុមារក៏ត្រូវបានកំណត់យ៉ាងច្បាស់ដែរគឺកុមារដែលអាចចូលរៀនថ្នាក់មត្តេយ្យ ឬថ្នាក់កុមារដ្ឋានត្រូវមានអាយុ ៤ឆ្នាំគត់ ហើយនៅរៀនបន្តរហូតដល់អាយុ ៦ឆ្នាំ។

ខ. ការកំណត់តួនាទីរបស់សាលាមត្តេយ្យ គឺមត្តេយ្យសាលាទាំងឡាយមិនគ្រាន់តែជាគ្រឹះស្ថាននៃការអប់រំដំបូងបង្អស់ ដែលកុមារទាំងពីរភេទទទួលបាននូវការរីកចំរើនដល់ផ្នែករាងរាយកាយ បញ្ញា ចរិយាសីលធម៌ ប៉ុណ្ណោះទេ ប៉ុន្តែគឺថែមទាំងជាកន្លែងដែលបានផ្តល់ការថែទាំព្យាបាលផ្នែកសុខភាពដល់កុមារថែមទៀតផង។ ដូចមាត្រា ២ នៃច្បាប់នេះបានចែងថា៖ គ្រូពេទ្យម្នាក់ដែលចៅហ្វាយក្រុង ឬចៅហ្វាយខេត្តបានចាត់តាំងឡើងត្រូវទៅត្រួតពិនិត្យមើលយ៉ាងតិចមួយខែ៤ដង ដល់មត្តេយ្យសាលានិងថ្នាក់កុមារដ្ឋានទាំងឡាយ។ គ្រូពេទ្យជំនាញនោះត្រូវត្រួតពិនិត្យសុខភាពដល់កុមារទាំងអស់ ហើយកត់សេចក្តីយល់ឃើញ

---

[៥] រាជកិច្ចប្រទេសកម្ពុជា៖ អំពីមត្តេយ្យសាលា និងថ្នាក់កុមារដ្ឋាន ឆ្នាំ ១៩៥៧

របស់ខ្លួននៅលើសៀវភៅបញ្ជីមួយដោយឡែក។ ពុំត្រូវទទួលកុមារណាមួយចូលក្នុងមត្តេយ្យសាលា ឬថ្នាក់កុមារដ្ឋាន បើកុមារនោះគ្មានវិញ្ញាបនប័ត្រពេទ្យបញ្ជាក់ថា កុមារនោះឥតមានកើតជំងឺឆ្លងណាមួយទេ ហើយបានទាំងចាក់ថ្នាំផង។

ក្រៅពីការកំណត់តួនាទីឲ្យមត្តេយ្យសាលា នៅមានការរៀបចំនិងកំណត់កម្មវិធីសិក្សា សម្រាប់កុមារដែលមានវ័យ ៤ឆ្នាំ និង ៥ឆ្នាំ ផងដែរ។ ចំពោះកម្មវិធីសិក្សាសម្រាប់អប់រំចែកចេញជាៈ

១. ចំពោះកុមារផ្នែកទី១៖ ការហាត់ប្រាណ ការហាត់ដកដង្ហើម ការលេង ការធ្វើឱ្យកម្រើកខ្លួនប្រាណបង្កើនជាលំដាប់ ព្រមទាំងមានចំរៀងជាលំនាំផង។

២. ការហ្វឹកហ្វឺនវិញ្ញាណ ការហត្ថកម្ម ការហាត់គូរ

៣. ការហាត់ភាសា និងមេសូត្ររត់មាត់ រឿងនិទាន និងរឿងប្រឌិត

៤. ការរៀនពិនិត្យវត្ថុមានវិញ្ញាណ និងឥតវិញ្ញាណទាំងឡាយដែលធ្លាប់ស្គាល់

៥. ការហាត់ ដែលបណ្តាលឲ្យមានការបង្កើតទម្លាប់ជាដំបូងបង្អស់ខាងចរិយា

៦. ចំពោះកុមារទាំងឡាយនៅផ្នែកទី២៖ ការរៀនពិនិត្យខាងលើដែលនេះត្រូវបញ្ចូលការនាំផ្តើមឱ្យរៀនមើល ឱ្យរៀនសរសេរ ឱ្យរៀនលេខ។

លើសពីនេះទៅទៀត ត្រង់មាត្រា១០ នៃច្បាប់បានប្រកាសឱ្យមានការរៀបចំគណៈកម្មាធិការទ្រទ្រង់សាលាមត្តេយ្យសាធារណៈក្រោមអធិបតីភាពនៃមេឃុំផងដែរ។

ផ្អែកលើច្បាប់នៃការរៀបចំមត្តេយ្យសាលា និងឯកសាររូបភាពមួយចំនួនទៀត យើងកត់សម្គាល់ឃើញថា ការអប់រំនៅមត្តេយ្យសាលានាពេលនោះ ត្រូវបានរៀបចំយ៉ាងហ្មត់ចត់ឲ្យមានលក្ខណៈបែបទំនើបដែលសមស្របទៅតាមគរុកោសល្យបែបថ្មីផង។ ក្រៅពីនេះ យើងឃើញមានការរៀបចំយ៉ាងហ្មត់ចត់នូវកម្មវិធីសិក្សា ការកំណត់យ៉ាងតឹងរឹងអំពីអាយុកុមារចូលរៀន និងការទទួលកុមារចូលរៀននៅមត្តេយ្យ។ ក្រៅពីការរៀបចំកម្មវិធីអប់រំតាមបែបទំនើប មត្តេយ្យសាលាក៏ត្រូវបានការទទួលការយកចិត្តទុកដាក់ និងការទទួលខុសត្រូវ ពីសំណាក់រដ្ឋអំណាចមូលដ្ឋានតាំងពីថ្នាក់ឃុំ រហូតដល់ថ្នាក់ចៅហ្វាយខេត្ត-ក្រុង។

ម្យ៉ាងវិញទៀតក៏មានការចូលរួមពីក្រសួង ជាពិសេសពាក់ព័ន្ធក្រសួងសិក្សាធិការជាតិ ក្រសួងសុខាភិបាល និងក្រសួងផ្សេងៗទៀតនៅក្នុងខេត្តនីមួយៗ ព្រមទាំងមានការចូលរួមឧបត្ថម្ភពីមាតាបិតាកុមារផងដែរ។ ប្រការទាំងនេះ អាចឆ្លុះបញ្ចាំងឱ្យឃើញនូវស្ថានភាពនៃការលើកកម្ពស់គុណភាពអប់រំនាពេលនោះ។

ដំណើរការនៃមត្តេយ្យសិក្សាបានប្រព្រឹត្តទៅបានល្អប្រសើរ រហូតដល់ដើមឆ្នាំ១៩៧០ ប៉ុន្តែបរិមាណមត្តេយ្យសាលាត្រូវបានថយចុះវិញជាបណ្តើរៗ ដោយមូលហេតុប្រទេសជាតិកើតសង្គ្រាមជាបន្តបន្ទាប់។ ជាក់ស្តែងចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៨០ កម្ពុជាត្រូវបានធ្លាក់ក្នុងវិបត្តិនយោបាយផ្ទៃក្នុងជាបន្តបន្ទាប់ ជាក់ស្តែងមហាវិនាសសកម្មក្នុងរបបខ្មែរក្រហម ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ដែលឱ្យឈ្មោះថា "របបកម្ពុជាប្រជាធិបតេយ្យ" បានសម្លាប់ធ្វើឱ្យបាត់បង់ធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យ

ត្រូវបានបំផ្លេចបំផ្លាញស្ទើរគ្មានសល់ ក្នុងនោះសាលាមត្តេយ្យសិក្សាក៏ដូចជាគ្រឹះស្ថានអប់រំនានាទូទាំងប្រទេសត្រូវបានលុបបំបាត់និងបំផ្លាញ មិនត្រឹមតែប៉ុណ្ណោះពួកគេប្រើប្រាស់គ្រឹះស្ថានសិក្សាចាប់ពីកម្រិតមត្តេយ្យសិក្សាធ្វើជាមន្ទីរឃុំឃាំង ធ្វើទារុណកម្ម និងសហករ រហូតដល់របបនេះត្រូវបានផ្តួលរំលំនៅថ្ងៃទី ៧ មករា ១៩៧៩ ក្រោមការដឹកនាំរបស់រណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលយើងអាចនិយាយបានថាជាថ្ងៃរស់រានមានជីវិតជាថ្មី ជាថ្ងៃកំណើតនៃសន្តិភាព និងជាថ្ងៃកំណើតនៃការអភិវឌ្ឍលើគ្រប់វិស័យ។ ស្ថិតក្នុងគ្រាដ៏លំបាកនោះ សេវាអប់រំក៏ចាប់ផ្តើមបើកបវេសនកាលជាដំបូងឡើងវិញនាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៧៩ ផងដែរ។

## ៥. ស្ថានភាពអប់រំផ្នែកមត្តេយ្យសិក្សាក្រោយឆ្នាំ ១៩៨០

### ៥.១-ទិសដៅនៃការអប់រំកុមារមត្តេយ្យសិក្សា

កម្មវិធីសិក្សាជាតិផ្នែកមត្តេយ្យសិក្សាត្រូវបានចាប់ផ្តើមមានសកម្មភាពឡើងវិញ ក្រោមការៀបចំរបស់ក្រសួងអប់រំចាប់តាំងពីចុងឆ្នាំ១៩៧៩ រហូតមកទល់បច្ចុប្បន្ន។ ជាដំបូងសាលាមត្តេយ្យសិក្សាសម្រាប់កុមារអាយុចាប់ពី ៣ ឆ្នាំ ដល់ ៤ ឆ្នាំ ដែលត្រូវទទួលជាចាំបាច់នោះគឺកូនរបស់បុគ្គលិករដ្ឋ។ ក្រោយមកការទទួលកុមារឲ្យចូលរៀននៅសាលាមត្តេយ្យសិក្សាត្រូវបានកំណត់អាយុចាប់ពី ៣៦ ខែ ដល់ ៧២ខែ។ នៅក្នុងសម័យនោះ ដោយសារប្រទេសកម្ពុជាប្រកាន់យករបបសង្គមនិយម ដូច្នេះការកំណត់ទិសដៅនៃការអប់រំនៅសាលាមត្តេយ្យសិក្សាក៏មាននិន្នាការស្របនិងគោលនយោបាយរបស់រដ្ឋដែរ។ ទិសដៅ ៣យ៉ាងសំខាន់ៗសម្រាប់ការអប់រំនៅសាលាកម្រិតមត្តេយ្យសិក្សាមានជាអាទិ៍[៦]៖

១. អប់រំកុមារឱ្យក្លាយជាពលករពេញលេញ (កុមារមត្តេយ្យ វៃឆ្លាត ក្លាហាន មានសណ្តាប់ធ្នាប់ មានសុជីវធម៌ ស្រលាញ់មិត្តភ័ក្តិ និងរៀនពូកែនៅពេលឡើងទៅសាលាបឋមសិក្សា)។

២. រួមចំណែករំដោះមាតាពលករ (អាស្រ័យដោយមានសាលារៀនមត្តេយ្យសិក្សា មាតាពលករ ស្ងប់ចិត្តក្នុងការងារបំរើបុព្វហេតុការពារ និងកសាងជាតិមាតុភូមិ)។

៣. រួមចំណែករកសន្តិភាពលើសកលលោក។

### ៥.២-ប្រភេទសាលារៀនកម្រិតមត្តេយ្យសិក្សា

ដំណើរនៃការអប់រំផ្នែកមត្តេយ្យសិក្សាមានការវិវត្តិជាបន្ទាប់រហូតដល់ឆ្នាំសិក្សា១៩៨៨-១៩៨៩។ នៅក្នុងអំឡុងពេល១០ឆ្នាំនោះ ថ្នាក់មត្តេយ្យសិក្សាចំនួនជាង ២០០០ថ្នាក់ ក្នុងនោះក៏មានថ្នាក់មត្តេយ្យសិក្សាមូលដ្ឋាននៅតំបន់ជនបទនានាដែរ[៧]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏ការរៀបចំ ការគ្រប់គ្រង់ និងការ

---

[៦] ក្រសួងអប់រំ៖ កម្រងអត្ថបទមត្តេយ្យសិក្សា ឆ្នាំ១៩៨០

[៧] ក្រសួងអប់រំ យុវជន និងកីឡា៖ ស្ថិតិអប់រំពីឆ្នាំសិក្សា១៩៧៩-១៩៨០ ដល់ឆ្នាំសិក្សា២០១៨-២០១៩

ប្រព្រឹត្តិទៅនៃសាលាមត្តេយ្យសិក្សានាពេលនោះមានលក្ខណៈពុំដូចគ្នាទេគឺ អាស្រ័យទៅតាមលទ្ធភាពនៃការបង្កើតសាលា ឬថ្នាក់របស់ប្រជាជនក្នុងមូលដ្ឋាន។

នៅពេលនោះសាលារៀនមត្តេយ្យសិក្សាមាន ២ប្រភេទ ដែលទទួលកុមារអាយុពី ២-៥ឆ្នាំ គឺះសាលារៀនមត្តេយ្យសិក្សារដ្ឋ សាលារៀនមត្តេយ្យសិក្សាមូលដ្ឋានផលិតកម្មសមូហភាព។

ចំណែកឯក្របខ័ណ្ឌមត្តេយ្យសិក្សាក៏ត្រូវបែងចែកជា ២ ប្រភេទដែរគឺ ៖ ក្របខ័ណ្ឌមត្តេយ្យសិក្សារដ្ឋ ក្របខណ្ឌមត្តេយ្យសិក្សាមូលដ្ឋានផលិតកម្មសមូហភាព(ផ.ស)។

នៅក្នុងល័ក្ខខណ្ឌបែបនេះ គ្រូដែលជាបុគ្គលិកក្របខណ្ឌរដ្ឋត្រូវទទួលប្រាក់បំពេញភារកិច្ច និងរបបឧបត្ថម្ភពីរដ្ឋ។ ចំណែកឯគ្រូដែលមានក្របខណ្ឌមត្តេយ្យសិក្សាមូលដ្ឋានផលិតកម្មសមូហភាព ត្រូវទទួលឧបត្ថម្ភប្រចាំជីវភាព និងរបបអង្ករពីមូលដ្ឋានផលិតកម្មសមូហភាព និងមានសិទ្ធិទិញរបបផ្គត់ផ្គង់ផ្សេងៗដូចគ្រូក្របខណ្ឌរដ្ឋតាមតម្លៃផ្គត់ផ្គង់របស់រដ្ឋ[៨]។

## ៦. កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យរដ្ឋសិក្សារដ្ឋបច្ចុប្បន្ន

ដើម្បីធានាបានការអប់រំប្រកបដោយបរិយាបន្ន សមធម៌ គុណភាព និងលើកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ជាពិសេសឆ្លើយតបចំណុចដៅត្រឹមឆ្នាំ២០៣ ធានាថា កុមារទាំងអស់ទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា ការថែទាំ ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព ដើម្បីពួកគេបានត្រៀមខ្លួនជាស្រេចចូលរៀននៅកម្រិតបឋមសិក្សា ដែលកម្មវិធីសិក្សាមានគោលបំណងរួមផ្តោតលើ[៩]៖

កាយសម្បទាះ កុមារមានសុខភាពល្អទាំងផ្លូវកាយនិងផ្លូវចិត្ត មានថាមពលបរិបូរណ៍ កម្លាំងមាំមួនទាំងកាយ ប្រាជ្ញា និងស្មារតី វាងវៃ ស្វាហាប់ អង់អាចក្លាហាន និងរហ័សរហួន... ។

វិជ្ជាសម្បទាះ កុមារស្គាល់ ចំណាំ ថាតាម ហៅឈ្មោះ និងអានបានតួអក្សរ ពាក្យ ឃ្លា និងល្បះងាយៗដែលធ្លាប់ប្រើប្រាស់ប្រចាំថ្ងៃញឹកញាប់ គូសតាម រាប់ចំនួន លេខពីរខ្ទង់ ស្គាល់រូបរាង ទំហំវត្ថុ និងរង្វាស់រង្វាល់មួយចំនួន។ កុមារប្រាប់បានពីរបៀបថែទាំសុខភាពងាយៗ ដូចជាអនាម័យខ្លួនប្រាណ ការបរិភោគចំណីអាហារ ប្រាប់ពីរបៀបបង្ការខ្លួនពីគ្រោះថ្នាក់ដោយចៃដន្យ ឬដោយធម្មជាតិ.. ។

បំណិនសម្បទាះ កុមារប្រើភាសាខ្មែរសម្រាប់ទំនាក់ទំនងប្រចាំថ្ងៃក្នុងគ្រួសារនិងសហគមន៍ ដូចជាការស្តាប់ និយាយ និងប្រើសំដីសមរម្យប្រកបដោយការទទួលខុសត្រូវ និងប្រើប្រាស់គណិតវិទ្យាដូចជាការចំណាំ រាប់ គូសតាម ប្រៀបធៀប និងប្រើប្រាស់ចលករតូច-ចលករធំ។

---

[៨] ក្រសួងអប់រំះ កម្រងអត្ថបទមត្តេយ្យសិក្សា ឆ្នាំ១៩៨០

[៩] ក្រសួងអប់រំ យុវជន និងកីឡាះ កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ ឆ្នាំ២០១៧

ចរិយាសម្បទា៖ សប្បាយរីករាយចូលរួមលេងល្បែងសិក្សា ក្លាហាន សកម្ម ចែករំលែក ស្រឡាញ់ខ្លួនឯង គ្រួសារ មិត្តភក្តិ លោកគ្រូ អ្នកគ្រូ និងជនរួមជាតិ ស្រឡាញ់បរិស្ថាន វប្បធម៌ និងប្រពៃណីទំនៀមទម្លាប់របស់ជាតិខ្លួន។

ការសិក្សារៀនសូត្ររបស់កុមារ ចាប់ផ្តើមឡើងពីការប្រើប្រាស់ញាណ និងចិត្តចលភាព តាមរយៈការលេងនិងសកម្មភាពដោយផ្ទាល់របស់កុមារ។ ការផ្សារភ្ជាប់ការលេងរបស់កុមារទៅនឹងការច្នៃប្រឌិតតាមរយៈវិធីសាស្ត្រខុសៗគ្នាដែលនឹងផ្តល់នូវមូលដ្ឋានចំណេះដឹង និងជំនាញមួយចំនួន ដូចជា សមត្ថភាពគិតពិចារណា វិនិច្ឆ័យ ម្ចាស់ការ ការចូលរួម និងសហការ[១០]។ សញ្ញាណនៃមុខវិជ្ជាមួយចំនួន ត្រូវបានដាក់បញ្ចូលក្នុងគោលដៅសិក្សានៅកម្រិតមត្តេយ្យសិក្សា ដើម្បីផ្សារភ្ជាប់ចំណេះដឹង និងបំណិនទៅការអប់រំកម្រិតបឋមសិក្សា។ នៅពេលបញ្ចប់មត្តេយ្យសិក្សា កុមារនឹងមានសមត្ថភាពគ្រប់ផ្នែក៖

ការត្រិះរិះពិចារណានិងដោះស្រាយបញ្ហា កុមារសម្តែងអារម្មណ៍និងចេះសង្កត់ចិត្តរបស់ខ្លួន ការយល់ដឹងពីហេតុផល ការគិតនិងវិភាគគ្រប់ជ្រុងជ្រោយ និងគោលវិធីជាវិជ្ជមាននិងជាចំហដើម្បីដោះស្រាយបញ្ហា ។

ចិត្តចលភាព៖ កុមារហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក ការហ្វឹកហាត់បង្កើនកម្លាំង និងសម្រសម្រួលរវាងចលនាសាច់ដុំតូចនិងសាច់ដុំធំ ការបង្កើនកម្លាំង និងការប្រឈមទប់ទល់នឹងឧបសគ្គក្នុងពេលធ្វើសកម្មភាព។

វិទ្យាសាស្ត្រ៖ កុមារមានចំណេះដឹងមូលដ្ឋានអំពីក្រុមអាហារ និងអាហារូបត្ថម្ភ ទម្លាប់រស់នៅមានអនាម័យ យល់ដឹងពីការប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព ស្វែងយល់ដោយការសង្កេតលក្ខណៈវត្ថុគ្មានជីវិត និងសត្វមានជីវិត លក្ខណៈមេឃនិងអាកាសធាតុ លក្ខណៈរូបធាតុអំពីរាងកាយផ្ទាល់ខ្លួន និងការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា។

សិក្សាសង្គម៖ កុមារយល់ដឹងពីតម្លៃនិងចរិតលក្ខណៈមនុស្ស ការលើកតម្កើងវប្បធម៌របស់ខ្លួន អត្តសញ្ញាណរបស់ខ្លួន បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញ យល់ដឹងអំពីទង្វើនិងលទ្ធផល ការពេញចិត្តនិងភាពផ្សេងគ្នា ស្គាល់និមិត្តសញ្ញាតំណាងឱ្យវត្ថុ ភាពខុសគ្នារវាងព្រឹត្តិការណ៍ដែលកើតឡើងក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ការយល់ដឹងអំពីបរិស្ថានធម្មជាតិនិងវិធីការពារ ចំណេះដឹងនៃបញ្ញត្តិសេដ្ឋកិច្ចសាមញ្ញមួយចំនួន ការយល់ដឹងដឹងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព ចំណេះដឹងបច្ចេកទេស ចលនាការច្នៃប្រឌិត និងបទពិសោធន៍ផ្នែកតន្ត្រី។

បុរគណិត៖ កុមារស្គាល់ យល់លេខតាង រាប់ចំនួន និងការគណនាលេខសាមញ្ញៗ បញ្ញត្តិស្តីពីរង្វាស់រង្វាល់ បញ្ញត្តិនៃរូបរាង លំហនិងទំហំ ចំណាត់ក្រុម និងលំដាប់លំដោយ។

---

[១០] Ministry of Education (Singapore): A Curriculum Framewark for Kidergartens in Singapore

ភាសាខ្មែរៈ ស្តាប់គេនិយាយ និងមានសមត្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ សន្ទនាដោយប្រើពាក្យ ឬឃ្លាសមស្រប ទៅតាមវ័យ)ភាសាបង្ហាញអារម្មណ៍និងមនោសញ្ចេតនា (ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ ទំនាក់ទំនងដោយប្រើពាក្យសម្តី ទំនាក់ទំនងដោយប្រើកាយវិការ និងនិមិត្តសញ្ញ បង្ហាញការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង បង្ហាញការយល់ដឹងអំពីបញ្ញត្តិ នៃសំណេរបង្ហាញ ការយល់ដឹងអំពីការប្រើប្រាស់ឯកសារសំណេរ/ឯកសារគោល បង្ហាញការពេញចិត្ត និងភាពរីករាយជាមួយអំណានដំបូង បង្ហាញការយល់ដឹងគោលការណ៍អក្ខរក្រមគូសបំពេញរូបគំនូរដែលមានរាងងាយៗតាមស្នាមចុច និងការយល់ដឹងពីភាសាដទៃ។

របាយម៉ោងនៃការអនុវត្តកម្មវិធីសិក្សា ត្រូវបានកំណត់ឱ្យបង្រៀនចំនួន ៣៥សប្តាហ៍ក្នុង១ឆ្នាំសិក្សា សិក្សា៥ថ្ងៃក្នុង១សប្តាហ៍ ៦ម៉ោងសិក្សាក្នុង១ថ្ងៃ ដែល១ម៉ោងសិក្សាមានរយៈពេល ៣០នាទី[១១]។

តារាងបែងចែកម៉ោងសិក្សា

| លរ. | មុខវិជ្ជា | កម្រិតមត្តេយ្យសិក្សា | | |
|---|---|---|---|---|
| | | **កម្រិតទាប** | **កម្រិតមធ្យម** | **កម្រិតខ្ពស់** |
| ១ | ចិត្តចលភាព | ៦ | ៦ | ៦ |
| ២ | បុរេគណិត | ៣ | ៣ | ៣ |
| ៣ | វិទ្យាសាស្ត្រ | ៤ | ៤ | ៤ |
| ៤ | សិក្សាសង្គម | ៣ | ៣ | ៣ |
| ៥ | ភាសាខ្មែរ | ១៤ | ១៤ | ១៤ |
| | សរុបម៉ោងប្រចាំសប្តាហ៍ | ៣០ | ៣០ | ៣០ |

កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា គឺជាអភិក្រមសមស្របតាមការអភិវឌ្ឍ ដែលគិតគូរពីការលើកកម្ពស់ការរៀនសូត្រដ៏សកម្ម ការប្រើប្រាស់មជ្ឈដ្ឋានសិក្សា ការរៀបចំផែនការ និងការពិនិត្យឡើងវិញ ព្រមទាំងបង្កលក្ខណៈឱ្កុមារអភិវឌ្ឍទៅតាមភាពសមស្របតាមតម្រូវការពិសេស និងដោយឡែករបស់ពួកគេ។ កម្មវិធីសិក្សារៀបចំឡើងដោយឈរលើគោលការណ៍សំខាន់ៗ ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សា គឺអភិវឌ្ឍន៍ផ្នែកកាយសម្បទា វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការអភិវឌ្ឍចំណេះដឹង និងជំនាញជាចំណុចចាប់ផ្តើមការទទួលយករបស់កុមារមុន នឹងមានការប្រែប្រួលផ្នែកកាយសម្បទា និងចរិយាសម្បទា។ បំណិនជាច្រើនរបស់កុមារ ដូចជាបំណិនដោះស្រាយបញ្ហាអន្តរបុគ្គល ទំនាក់ទំនង និងបរិស្ថានជាដើម ត្រូវបានដាក់បញ្ចូលសមស្របតាមការអភិវឌ្ឍរូបរាងកាយ អាយុ និងវប្បធម៌របស់កុមារ។

គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងសកម្មភាពរៀននិងបង្រៀ ដោយសម្របសម្រួលនិងលើកទឹកចិត្តប្រើប្រាស់សម្ភារៈសមស្រប ជំរុញការរៀនសូត្ររបស់កុមារមានភាពរស់រវើក និងសម្រេចគោលដៅ

[១១] ក្រសួងអប់រំ យុវជន និងកីឡាៈ កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ ឆ្នាំ២០១៧

សិក្សាស្របតាមអាយុរបស់កុមារ[២]។ ការរៀបចំបរិស្ថានសាលារៀន ថ្នាក់រៀន ផែនការបង្រៀន ការតាមដានការរៀនសូត្ររបស់កុមារ និងយន្តការនានា ដើម្បីពង្រឹងប្រសិទ្ធភាពការងារ ក៏ជាគោលដៅសំខាន់សម្រាប់កម្មវិធីសិក្សានេះផងដែរ។ គោលការណ៍គ្រឹះសម្រាប់អនុវត្តកម្មវិធីសិក្សាមត្តេយ្យសិក្សាមាន៖ ការរៀន និងបង្រៀន ត្រូវអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល។ ការសិក្សារបស់កុមារ ត្រូវធ្វើឡើងតាមការលេង និងសហការ។ កុមារត្រូវបានផ្ដល់ទំនុកចិត្ត ការលើកទឹកចិត្ត និងការទទួលខុសត្រូវក្នុងការរៀនសូត្រប្រកបដោយសុវត្ថិភាព និងភាពកក់ក្ដៅ។ អន្តរកម្មនៃការសិក្សាប្រកបដោយគុណភាព កុមារនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបថថ្មីៗបន្ថែមទៀតពីបរិស្ថានសិក្សារបស់ខ្លួន។ កុមារជាអ្នកកសាងសមត្ថភាពដោយខ្លួនឯង គ្រូជាអ្នកណែនាំ និងសម្របសម្រួល ដើម្បីឱ្យកុមាររៀនសូត្របានល្អប្រសើរ។ ការរៀបចំកិច្ចតែងការបង្រៀន ត្រូវធ្វើតាមគោលវិធីចម្រុះ។ បង្កើតយន្តការតាមដានការរៀនសូត្ររបស់កុមារប្រកបដោយប្រសិទ្ធភាព។ ការបង្រៀន និងរៀនត្រូវដំណើរការស្របតាមអាយុ វប្បធម៌ និងសមធម៌ ការរៀន និងបង្រៀនត្រូវមានលក្ខណៈជាក់ស្ដែង និងវិទ្យាសាស្ត្រ។ សាលារៀន និងគ្រូបង្រៀនត្រូវធ្វើអន្តរកម្មជាមួយអាណាព្យាបាល និងសហគមន៍ ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាព។ ដើម្បីអនុវត្តកម្មវិធីសិក្សាលម្អិតមត្តេយ្យសិក្សានេះ ប្រកបដោយគុណភាព និងប្រសិទ្ធភាព អ្នកអនុវត្តគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំធនធាន និងយន្តការមួយចំនួនដូចជា៖

- អភិវឌ្ឍសៀវភៅណែនាំការបង្រៀនសម្រាប់គ្រូតាមមុខវិជ្ជាស្របតាមកម្រិតនៃក្របខ័ណ្ឌកម្មវិធីសិក្សា ចំណេះទូទៅ និងបច្ចេកទេស
- អភិវឌ្ឍសម្ភារៈបម្រើឱ្យការរៀននិងបង្រៀន ឯកសារណែនាំប្រើប្រាស់សាមញ្ញ និងងាយស្រួលក្នុងការអនុវត្ត
- អភិវឌ្ឍឯកសារជំនួយ និងអំណានបន្ថែមដទៃទៀត) ល្បែងសិក្សា ពាក្យបណ្ដៅ រឿងរូបភាព រឿងនិទានងាយៗ ( ... ដើម្បីជួយពង្រឹងការរៀន និងបង្រៀន)
- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងឯកជនត្រូវរៀបចំជាបន្ទប់ ឬជ្រុងថ្នាក់រៀនសម្រាប់លេង អានសៀវភៅ សម្ដែង តន្ត្រី ទុកដាក់សម្ភារៈ និទានរឿង...
- គ្រឹះស្ថានមត្តេយ្យសិក្សា ត្រូវរៀបចំទីធ្លាប្រកបដោយបរិស្ថានល្អ មានសុវត្ថិភាព សម្រាប់ដំណើរការ លេងកម្សាន្ត ល្បែង និងលំហាត់ប្រាណជាដើម
- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈត្រូវរៀបចំផែនការបង្រៀនប្រចាំឆ្នាំ ប្រចាំខែ និងប្រចាំថ្ងៃស្របតាម
- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈត្រូវរៀបចំផែនការបង្រៀនប្រចាំឆ្នាំ ប្រចាំខែ និងប្រចាំថ្ងៃស្របតាមពេលវេលា និងកម្មវិធីសិក្សាដែលបានកំណត់

- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈនីមួយៗ ត្រូវរៀបចំយន្តការ និងឯកសារផ្សេងៗ ដើម្បីធ្វើអន្តរកម្ម មានប្រសិទ្ធភាពរវាងសាលារៀន មាតាបិតា ឬអ្នកអាណាព្យាបាល និងសហគមន៍
- គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀន តាមម៉ោងពេលកំណត់ ស្របតាមខ្លឹមសារកម្មវិធីសិក្សា និងសៀវភៅណែនាំ
- រៀបចំធនធាននិងយន្តការថ្មីៗផ្សេងទៀត ដើម្បីពង្រឹងការអនុវត្តការអប់រំកុមារមត្តេយ្យសិក្សានៅកម្ពុជា ប្រកបដោយការទទួលខុសត្រូវ។

ការអនុវត្តកម្មវិធីសិក្សានេះបានបំផុសគំនិតច្នៃប្រឌិត ការប្រើប្រាស់សម្ភារឧបទេស សម្ភាររូបវន្តប្រើប្រាស់ពេលវេលាសិក្សា និងការណែនាំក្នុងការរៀននិងបង្រៀន ដើម្បីធ្វើឱ្យសម្រេចគោលដៅសិក្សាប្រកបដោយគុណភាព។ កុមារគ្រប់រូបដែលទទួលបានការអប់រំនៅកម្រិតមត្តេយ្យសិក្សា មានការអភិវឌ្ឍន៍ផ្នែកគ្រប់ផ្នែក រួមទាំងផ្នែកសុខភាពនិងរាងកាយ បញ្ញា ស្មារតី និងបុគ្គលិកលក្ខណៈ នឹងកាត់បន្ថយបាននូវចរិត«**មជ្ឈត្តនិយម**»( egocentrism )របស់ពួកគេ ដូចជា៖

- ខ្លួនឯងជាមនុស្ស សំខាន់ជាងគេ
- អ្វីៗទាំងអស់ជារបស់ខ្លួន
- អ្នកដែលនៅជុំវិញខ្លួនត្រូវតែយកចិត្តទុកដាក់ទៅលើខ្លួន
- មិនយកចិត្តទុកដាក់ឬផ្តល់តម្លៃដល់អ្នកដទៃ
- មិនសូវស្តាប់បង្គាប់ និងរឹងរូសជាដើម។

# ការប្រតិបត្តិរបស់ពុទ្ធសាសនិក
# ក្នុងការលើកកម្ពស់សន្តិភាពនៅកម្ពុជា

បេក្ខជនបណ្ឌិតៈ **ព្រំ ឌី**
ជំនាញៈ **ទស្សនវិជ្ជា**

## ១. ស្ថានភាពទូទៅនៃព្រះពុទ្ធសាសនា

ធម៌វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង និងបញ្ញត្តិទុកប្រោសសត្វលោក ហៅថា ព្រះពុទ្ធសាសនា។ ព្រះពុទ្ធសាសនាជាវប្បធម៌កើតពីព្រះពុទ្ធ។ ព្រះពុទ្ធ កាលទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ហើយទ្រង់ទេសនាប្រោសសត្វលោកទូទៅ ហៅថា ទ្រង់សាបព្រោះ បណ្តុះ ដាំ ផ្សាំ វប្បធម៌ព្រះពុទ្ធសាសនាក្នុងពិភពលោក[១]។

ពុទ្ធសាសនា ជាសាសនាមានបទនាយកធម៌ធំៗច្រើនជាអនេក មានអហិង្សាជាដើមគឺជាសាសនាខាងបទមិនបៀតបៀនប្រកបដោយមេត្តាករុណា ហើយជាទស្សនវិជ្ជាសម្រាប់បណ្តុះ និស្ស័យមនុស្សឱ្យកាន់សុចរិត យុត្តិធម៌ ឱ្យខ្ពង់ខ្ពស់ ដែលអ្នកត្រូវការសេន្តិភាពគួរសិក្សា គួរប្រតិបត្តិតាម ដើម្បីសុខចម្រើនដល់ខ្លួន ដល់សហគមន៍ និងដល់ប្រទេស[២]។

ពុទ្ធសាសនា ត្រូវបានបង្កើតឡើងអស់រយៈពេលជាង ២៥០០ ឆ្នាំកន្លងមកហើយ ដោយក្សត្រមួយព្រះអង្គព្រះនាមព្រះសិទ្ធត្ថគោតម ជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈ និងព្រះនាងសិរិមហាមាយា។ ទ្រង់បានរាជាភិសេកជាមួយព្រះនាងពិម្ពាយសោធរា ដែលមានព្រះជន្មជំណាលគ្នាគឺ ១៦ ព្រះវស្សា មានបុត្រមួយព្រះអង្គព្រះនាម **រាហុល** លុះដល់ព្រះជន្ម២៩ឆ្នាំក៏ចេញសាងព្រះផ្នួសហើយក៏បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធក្នុងព្រះជន្មាយុ ៣៥ព្រះវស្សា និងបរិនិព្វាន ក្នុងព្រះជន្មាយុ ៨០ ព្រះវស្សា។ ពេលដែលទ្រង់បរិនិព្វានទៅព្រះពុទ្ធសាសនាបានធ្លាក់ចុះជាលំដាប់ដោយកត្តាផ្សេងៗមានការមិនចុះសម្រុងគ្នារវាងពុទ្ធសាសនិកខ្លួនឯងជាដើម។

“ព្រះពុទ្ធសាសនា បានចូលមកប្រទេសខ្មែរតាមរយៈព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ ជាសមណទូតនៃព្រះមហាមោគ្គលីបុត្តតិស្ស ដែលជាប្រធានក្នុងតតិយសង្គាយនា បាននាំចូលមកកាន់សុវណ្ណភូមិក្នុងពុទ្ធសករាជ២៣៤ មុនគ្រិស្តសករាជ ៣០៩ឆ្នាំ ក្រោមសាសនូបត្ថម្ភ នៃព្រះបាទធម្មាសោកមហារាជ ដែលជាព្រះមហារាជាកាន់ពុទ្ធសាសនាមុតមាំក្នុងប្រទេសឥណ្ឌា”[៣]។ ព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសកម្មបំផុតក្នុងការកសាង និងថែរក្សាសន្តិភាពនៅប្រទេសខ្មែរតាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ព្រោះហេតុដូច្នោះហើយ ទើបប្រជាជនខ្មែរមិនលះបង់ព្រះពុទ្ធសាសនាចោល ទោះបីជាប្រទេសមានវិបត្តិយ៉ាងណាក៏ដោយ ព្រោះរសជាតិនៃព្រះ ធម៌របស់ព្រះពុទ្ធបានជ្រាបចូលទៅក្នុងជម្រៅ នៃទឹកចិត្តដោយមិនអាចកាត់ចេញបាន។

---

[១] វ៉ាន សាឌុំ, *វប្បធម៌ពុទ្ធសាសនា,* ទស្សនាវដ្តីកម្ពុជសុរិយាឆ្នាំទី៣០ លេខ៦-៧ ខែមិថុនា-កក្កដា ,ព.ស.២៥០១

[២] ពុទ្ធសាសនា ២៥០០, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥៤៥, ទំព័រក

[៣] ប៉ាង ខាត់, *ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ,* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥០៤, ទំព័រច

## ២.ព្រះពុទ្ធសាសនា និងសន្តិភាព

តើអ្វីទៅជាហេតុដែលធ្វើឱ្យគ្មានសន្តិភាពក្នុងសង្គមមនុស្ស? នៅក្នុងព្រះពុទ្ធសាសនាបានចង្អុលបង្ហាញថា មិនមានអ្វីក្រៅពីមូលនៃអកុសលដែលត្រាំនៅក្នុងសន្តាននៃបុគ្គលម្នាក់ៗនោះគឺលោភៈ ទោសៈ មោហៈ អវិជ្ជា និងតណ្ហា ដែលជាមូលដ្ឋានធ្វើឱ្យគ្មានសន្តិភាពក្នុងសង្គមមនុស្សនោះទេ។ ហេតុនេះហើយ ដើម្បីទទួលបានសន្តិភាពក្នុងសង្គម គឺមនុស្សគ្រប់គ្នាត្រូវមានភារៈរៀងៗខ្លួនក្នុងការបដិបត្តិនូវទាន សីល ភាវនា (សម្រាប់គ្រហស្ថ) រីឯព្រះសង្ឃវិញ គប្បីបដិបត្តិនូវសីល សមាធិ និងបញ្ញា ដើម្បីបានទទួលផល គឺសន្តិភាពយ៉ាងពិតប្រាកដក្នុងសង្គមមនុស្សគឺក្នុងចិត្តនេះឯង មិនមែនសន្តិភាពបានមកពីខាងក្រៅនោះទេ។

ព្រះពុទ្ធសាសនា អប់រំមនុស្សតាមវិធីសន្តិភាព មិនមែនដោយហិង្សា លទ្ធិផ្តាច់ការនោះទេ អប់រំមនុស្សឱ្យមានព្រហ្មវិហារធម៌ ចេះស្រលាញ់រាប់អានគ្នា និងគោរពគ្នាទៅវិញទៅមក[៤]។ ព្រះសម្មាសម្ពុទ្ធពេលបានត្រាស់ដឹងជាព្រះពុទ្ធហើយ ទ្រង់យកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាសង្គម សេដ្ឋកិច្ច និងរបៀបរបបរដ្ឋាភិបាលក្នុងសម័យនោះ។ ទ្រង់បានពន្យល់យ៉ាងច្បាស់ថា កាលណាប្រមុខរដ្ឋាភិបាលគឺស្តេចក្តី មន្ត្រីក្តី ប្រព្រឹត្តអំពើពុករលួយ ព្រៃផ្សៃ និងអយុត្តិធម៌ហើយ កាលនោះប្រទេសជាតិទាំងមូលមុខជាជួបការបាក់បែក ប៉ះទង្គិចគ្នាជាមិនខាន។ ព្រោះហេតុនោះ ហើយទើបទ្រង់សម្តែងទសពិធរាជធម៌ឡើង សម្រាប់ឱ្យព្រះរាជាប្រព្រឹត្ត ព្រមទាំងណែនាំពួកមន្ត្រី សេនាបតីធំៗ និងពួករាស្ត្រឱ្យប្រព្រឹត្តតាម[៥]។

ជាការពិតណាស់ថា សន្តិភាព គឺសេចក្តីស្ងប់ដោយកាយ វាចា និងចិត្ត ជៀសផុតពីការរំលោភបំពាន ភាពអយុត្តិធម៌ ភាពភ័យខ្លាច និងប៉ះទង្គិចដោយហិង្សាជាដើម ដែលជាបំណងរបស់មនុស្សគ្រប់រូបមិនថាមាន ក្រ អ្នកប្រាជ្ញ ឬបណ្ឌិតនោះឡើយ។ សន្តិភាពមិនមែនកើតឡើងដោយឯងៗនោះទេ គឺកើតឡើងដោយសារការកសាង ឬការប្រព្រឹត្តរបស់បុគ្គលម្នាក់ៗ ប្រកបដោយសុចរិត និងអហិង្សា បើមិនមានការប្រព្រឹត្តនូវសកម្មភាពណាមួយជាកាយសុចរិត វចីសុចរិត និងមនោសុចរិតទេ សន្តិភាពនឹងមិនកើតមានទេ។ ព្រះពុទ្ធសាសនាបានណែនាំអំពីមាគ៌ាជាច្រើនដែលប្រតិបត្តិទៅនាំមកនូវសន្តិភាព ក្នុងនោះមានព្រហ្មវិហារធម៌៤ គឺមេត្តា ករុណា មុទិតា និងឧបេក្ខាជាដើម។ ការកសាងសន្តិភាពត្រូវការផ្លូវប្រកបដោយព្រហ្មវិហារធម៌ ដូច្នេះ បើមនុស្សត្រូវការសន្តិភាព មនុស្សគប្បីកសាងព្រហ្មវិហារធម៌នេះឱ្យមាននៅក្នុងចិត្ត។

## ៣.សកម្មភាពពុទ្ធសាសនិកក្នុងការលើកកម្ពស់សន្តិភាពនៅកម្ពុជា

ពុទ្ធសាសនិក បានដល់អ្នកគោរពជឿព្រះពុទ្ធសាសនាដូចជា ភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី និងអ្នកដែលទ្រទ្រង់នូវគ្រឿងសម្គាល់ថាជាអ្នកបួស តែមានភេទជាគ្រហស្ថដូចជា តាជី ដូនជីជាដើម។ ក្រៅពីនេះ អ្នកដែលកាន់ ជឿ ដើរតាមពុទ្ធសាសនា ដែលយើងហៅថាពុទ្ធបរិស័ទ មានឧបាសក

[៤] ***ពុទ្ធសាសនានិងការអភិវឌ្ឍន៍សង្គមខ្មែរ,*** ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍,បាត់ដំបង, ឆ្នាំ១៩៩៦,ទំព័រ១១២

[៥] សោម ងន, ***ពន្លឺពុទ្ធសាសនា***, បោះពុម្ពលើកទី២, USA, ព.ស.២៥៤៨ គ.ស.២០០៥, ទំព័រ៥៣

ឧបាសិកា ទាយក ទាយិកា ជាដើម[៦]។ សកម្មភាពរបស់ពុទ្ធសាសនិកនៅកម្ពុជា មានច្រើន ក្នុងនោះ សកម្មភាពធំៗដូចជា៖ ការធ្វើបុណ្យ ការកសាងសមិទ្ធផលនានា ការថែរក្សាបរិស្ថាន ការសិក្សា និង ការអប់រំផ្លូវចិត្តជាដើម ដែលជាទង្វើលើកកម្ពស់សន្តិភាពនៅកម្ពុជា។

## ៣.១.ការធ្វើបុណ្យ

បុណ្យមានន័យថា កុសលធម៌ ដែលជម្រះសន្តានចិត្តឱ្យបានស្អាត ឬធម្មជាតិដែលស្អាត បរិសុទ្ធ ផូរផង់ប្រាសចាកមន្ទិលគឺសេចក្តីសៅហ្មងចិត្តមានលោភៈ ទោសៈ មោហៈជាដើម [៧]។ ព្រះសម្មាសម្ពុទ្ធ បានសម្តែងថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំខ្លាចបុណ្យឱ្យសោះ ព្រោះបុណ្យ ជាឈ្មោះនៃ សេចក្តីសុខ។ ពុទ្ធសាសនិកមានជំនឿថាបុណ្យដែលបុគ្គលបានធ្វើហើយរមែងទទួលបាននូវសេចក្តីសុខ សុភមង្គល ទាំងបច្ចុប្បន្ន និងបរលោក ដូច្នេះហើយទើបគេខិតខំ ប្រឹងប្រែង សន្សំ បណ្តុះ ឬ កសាង រៀងៗខ្លួន ដែលបុណ្យនោះប្រព្រឹត្តទៅតាមកាយក្តី វាចាក្តី ឬចិត្តក្តី។ នៅក្នុងព្រះពុទ្ធសាសនាបុណ្យមាន ច្រើនយ៉ាង មានឈ្មោះប្លែកៗទៅតាមវិធីដែលគេបានធ្វើ។ ប៉ុន្តែ បើសរុបឱ្យខ្លីតាមពិធីបុណ្យនោះមាន ពីរយ៉ាងគឺពិធីបុណ្យក្នុងផ្លូវវិន័យ១ និងពិធីបុណ្យក្នុងផ្លូវធម៌ ឬព្រះសូត្រ១[៨]។ បុណ្យតាមផ្លូវព្រះវិន័យ ដូចជា ចូលព្រះវស្សា ចេញព្រះវស្សា កឋិន បញ្ចុះសីមា និងបំបួសជាដើម ដែលមានពុទ្ធប្បញ្ញត្តិ ឬ ពុទ្ធានុញ្ញាតដាក់កម្រិត ដាក់ច្បាប់ឱ្យធ្វើ ពុំមែនចេះតែធ្វើ បានទៅតាមចំណង់សទ្ធារបស់យើងនោះទេ ឯបុណ្យតាមផ្លូវព្រះសូត្រវិញដូចជា ឈាបនកិច្ចភ្ជុំបិណ្ឌ ទេសនាមហាជាតិ មាឃបូជា វិសាខបូជា ចូលឆ្នាំ ទក្ខិណានុប្បទាន កតញ្ញូជាដើម ដែលជាសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទ មិនអនុវត្តទៅតាម ពុទ្ធប្បញ្ញត្តិសុទ្ធនោះទេ។

ការធ្វើបុណ្យ (ធ្វើអំពើល្អ) ជាកល្យាណកម្មមួយដ៏ល្អបំផុត របស់អ្នកស្រលាញ់សន្តិភាព ស្រលាញ់ការគោរពសិទ្ធិមនុស្ស ស្រលាញ់ការអភិវឌ្ឍន៍ប្រកបដោយការទទួលខុសត្រូវ និងចីរភាព ស្រលាញ់សុខដុមសាសនា និងស្រលាញ់តម្លៃនៃមនុស្សជាតិទាំងឡាយតែងតែធ្វើជាប្រក្រតី។

## ៣.២.ការកសាងសមិទ្ធផលនានា

ជំនឿត្រឹមត្រូវរបស់ព្រះពុទ្ធសាសនា គឺជំនឿលើកម្មផល[៩]។ ដោយសារតែទស្សនៈនៃជំនឿគឺជឿ ទៅលើកម្មផលដូច្នេះហើយ ទើបយើងឃើញថា ពុទ្ធសាសនិកទាំងឡាយ ដែលជាអ្នកកាន់ គោរព ជឿ ឬប្រតិបត្តិតាមព្រះពុទ្ធសាសនាបានចំណាយកម្លាំងទ្រព្យធន និងកម្លាំងកាយវាចាចិត្ត ដើម្បីកសាងនូវ សមិទ្ធផលនានាយ៉ាងច្រើនសម្រាប់តម្កល់ទុកនៅក្នុងព្រះពុទ្ធសាសនា។ សមិទ្ធផលទាំងឡាយមានច្រើន តែបើរាប់ដោយសង្ខេបមានពីរសំខាន់ៗគឺ សមិទ្ធផលមានវិញ្ញាណបានដល់ធនជានមនុស្សនិងសមិទ្ធផល

---

[៦] ហេង មណីចិន្តា, ***មគ្គុទ្ទេសជីវិត***, ការផ្សាយរបស់ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍,បាត់ដំបង, ឆ្នាំ១៩៩៧ ទំព័រ៧

[៧] យិន វន់, ***ប្រជុំបុញ្ញប្រវត្តិ***, ការផ្សាយរបស់បណ្ណាគារភ្នំពេញ៥៩បាស្ទ័រ, ឆ្នាំ? ទំព័រ៣

[៨] គុង ឈួន, ***បាបនិទ្ទេស និងបុញ្ញនិទ្ទេស***, បោះពុម្ពលើកទី១,ព.ស.២៥០៨ គ.ស.១៩៦៥, ទំព័រ៥៦

[៩] ហុក សុវណ្ណ, ***តួនាទីរបស់ព្រះសង្ឃក្នុងសង្គមខ្មែរ***, ព.ស.២៥៥២ គ.ស.២០០៨,ទំព័រ៨៥

គ្មានវិញ្ញាណបានដល់សំណង់មានវត្តអារាមជាដើម។ សមិទ្ធផលទាំងពីរនេះពិតជាបានដើរតួយ៉ាងសំខាន់ក្នុងការចូលរួមកសាង និងការថែរក្សាសន្តិភាពនៅកម្ពុជាតាំងពីសម័យបុរាណរហូតបច្ចុប្បន្ន។ ព្រោះប្រទេសជាតិដែលអាចមានសន្តិភាពលុះត្រាមនុស្សរស់នៅក្នុងជីវភាពសមរម្យ ប្រាសចាកការភ័យខ្លាច មានការគោរពសិទ្ធិមនុស្ស មានយុត្តិធម៌ និងមានការអភិវឌ្ឍប្រកបដោយការទទួលខុសត្រូវខ្ពស់ និងចីរភាព។ ព្រះពុទ្ធសាសនាបានកសាងសំណង់មានវិញ្ញាណ និងសំណង់ឥតវិញ្ញាណយ៉ាងច្រើន ដើម្បីចូលរួមអភិវឌ្ឍន៍ប្រទេសជាតិជាមួយរាជរដ្ឋាភិបាលឆ្ពោះទៅកាន់សុខសន្តិភាពជូនសង្គមទាំងមូល។

### ៣.៣.ការថែរក្សាបរិស្ថាន

បរិស្ថាន គឺជាទីកន្លែងដែលមនុស្ស សត្វ និងរុក្ខជាតិរស់នៅៗក្នុងនោះ មាននៅក្នុងខ្យល់អាកាស ឬនៅលើទឹក និងដីជាដើម។ ក្នុងន័យមួយទៀត បរិស្ថាន គឺជាលក្ខខណ្ឌដែលគេរស់នៅ ឬធ្វើការនៅក្នុងនោះ ហើយនិងរបៀបដែលវាមានឥទ្ធិពលមកលើថា តើគេមានអារម្មណ៍យ៉ាងណា ឬថាតើគេអាចធ្វើការប្រកបដោយប្រសិទ្ធភាពយ៉ាងដូចម្តេចបាន។

នៅក្នុងន័យដូចបានរៀបរាប់ខាងលើ បរិស្ថាន គឺជាចំណុចស្នូលដែលព្រះពុទ្ធទ្រង់យកចិត្តទុកដាក់ក្រៃលែង សូម្បីតែនៅពេលគង់ ឬនិមន្តទៅណាម្តងៗ ព្រះតែងតែសូត្រធម៌ សូមឱ្យសព្វសត្វជៀសចេញពីទីអង្គុយ ឬព្រះបាទរបស់ព្រះអង្គ។ តាមគំរូនេះសង្ឃសាវ័កក៏ដូចជាពុទ្ធបរិស័ទក៏ធ្វើបែបនេះដែរ។ ការដាំដើមឈើ ការសង់សាលា ការសង់អណ្តូងទឹក ការជួយក្មេងកំព្រា និងជនក្រីក្រ គឺជាចំណុចលើកស្ទួយរបស់ពុទ្ធសាសនិកជនខ្មែរ ដែលបានទទួលនូវការយល់ដឹងពីព្រះពុទ្ធសាសនានេះឯង។

### ៤.៤.ការសិក្សា (គន្ធធុរៈ និងវិបស្សនាធុរៈ)

នៅក្នុងព្រះពុទ្ធសាសនា មានការសិក្សាចំនួន២សំខាន់គឺ គន្ធធុរៈ និងវិបស្សនាធុរៈ។ គន្ធធុរៈសំដៅយការសិក្សាលើព្រះត្រៃបិដក ឯវិបស្សនាធុរៈ សំដៅយករៀនវិបស្សនាជាគ្រឿងអប់រំចិត្ត[១០]។

ការសិក្សាទាំងពីរផ្នែកនេះមានផលប្រយោជន៍ផ្សេងៗគ្នា ស្របតាមការប្រឹងប្រែង និងការប្រតិបត្តិរបស់ខ្លួន គឺការសិក្សាគន្ធធុរៈតាមរយៈព្រះត្រៃបិដកធ្វើឱ្យបុគ្គលអ្នកសិក្សាទទួលបាននូវផលប្រយោជន៍ដូចជា៖ ១.យល់ដឹងយ៉ាងត្រឹមត្រូវដល់សារៈសំខាន់នៃពុទ្ធឱវាទ ២.យល់ដឹងគោលធម៌ និងគោលជំហររបស់ពុទ្ធសាសនា ៣.បណ្តុះសទ្ធាជ្រះថ្លាកាន់តែកិយ្យោភាពឡើងក្នុងគោលធម៌របស់ព្រះសម្មាសម្ពុទ្ធ ៤.ស្គាល់ការបដិបត្តិត្រូវតាមតួនាទីជាពុទ្ធសាសនិកជន ៥.ជួយជ្រោមជ្រែងពុទ្ធសាសនាឱ្យស្ថិតស្ថេរចីរកាលយូរអង្វែង។ ចំណែកការសិក្សាវិបស្សនាធុរៈវិញ គឺជាមធ្យោបាយជាន់ខ្ពស់ដែលអាចដកររំលើងឫសគល់នៃសេចក្តីទុក្ខឱ្យអស់ដោយគ្មានសេសសល់ បើពុំបានសម្រេចដល់ធម៌ជាន់ខ្ពស់ថ្នាក់ព្រះអរិយបុគ្គលទេ វិបស្សនាអាចកម្ចាត់បង់នូវភាពតានតឹង និងនាំឱ្យជាសះស្បើយនូវជំងឺផ្លូវចិត្ត ព្រមទាំងមានសមត្ថភាពដោះស្រាយបញ្ហាគ្រប់យ៉ាងដែលចោទក្នុងជីវិតទាំងអស់។ បើចិត្តគេបានស្ថិតនៅក្នុងវិបស្សនា រមែងជាចិត្តស្ងប់ស្ងាត់ ជាចិត្តស្ថិតនៅនឹងកណ្តាលពុំញាប់ញ័រទៅតាមអារម្មណ៍ដែលប្រែប្រួលនៅក្នុងជីវិតបច្ចុប្បន្នឡើយ។

---

[១០] ធម្មបទដ្ឋកថាភាគ១,ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ,ភ្នំពេញ, ព.ស.២៥៣៨,ទំព័រ៩

គោលដៅសិក្សាព្រះពុទ្ធសាសនាចុងក្រោយបំផុត គឺព្រះសម្មាសម្ពុទ្ធ ផ្ដល់តម្លៃទៅលើការសិក្សាអប់រំចិត្ត(វិបស្សនាធុរៈ) ឱ្យចិត្តស្ថិតនៅក្នុងសីល សមាធិ បញ្ញា ដើម្បីឱ្យជីវិតរស់នៅប្រចាំថ្ងៃប្រកបដោយមេត្តា ករុណា មុទិតា និងឧបេក្ខា ជាចិត្តស្ងប់ ជាចិត្តប្រាសចាកគ្រឿងសៅហ្មង គឺរស់នៅក្នុងភាពស្ងប់(សន្តិភាព)នេះឯង។

## ៤.៥.ការអប់រំផ្លូវចិត្ត

គេនិយាយថា កាំភ្លើងមិនសាហាវទេ តែចិត្តទេដែលសាហាវ។ ហេតុនេះ គេត្រូវគិត និង ស្វែងមធ្យោបាយដើម្បីអប់រំចិត្ត។ អ្នកសិក្សាពុទ្ធសាសនា ប្រៀបប្រដូចចិត្តទៅនឹងសត្វស្វាដែលនៅមិនស្ងៀមស្ងើរគ្រប់ខណៈ។ ហេតុនេះ ដើម្បីឱ្យមនុស្សរស់នៅបានសុខ បានចម្រើន គេត្រូវអប់រំចិត្តឱ្យនៅស្ងៀម ឱ្យមានលំនឹង និងឱ្យមានតុល្យភាពល្អ ដើម្បីឱ្យងាយស្រួលបញ្ជាវា។ ចិត្តដែលមានការអប់រំ គឺជាប្រភពនៃសេចក្ដីសុខ និងសេចក្ដីចម្រើន ដូចពុទ្ធភាសិតដែលពោលថា "គ្មានសេចក្ដីសុខណាស្មើសេចក្ដីស្ងប់ឡើយ"។ បើនិយាយពីការអប់រំចិត្តមានវិធីសាស្ត្រផ្សេងៗគ្នា ស្របតាមស្ថានភាព គោលការណ៍ ឬការកំណត់យក។ ក្នុងព្រះពុទ្ធសាសនា មានវិធីសាស្ត្រសំខាន់ៗ មួយចំនួនដូចជា ការធ្វើសមាធិ ការធ្វើធុតង្គ ការធ្វើធម្មយាត្រា និងការបដិបត្តិរយៈពេលខ្លីជាដើម ដែលជាវិធីអប់រំចិត្តឱ្យចិត្តស្ងប់ និងទទួលបានសន្តិភាព។

### ក.ការធ្វើសមាធិ

សមាធិ គឺជាការតាំងចិត្តមាំក្នុងអារម្មណ៍តែមួយ ឬការដឹងច្បាស់នូវអារម្មណ៍នោះៗ ដោយសច្ចភាព។ សមាធិមាន ២យ៉ាងគឺ សមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន។ សមថកម្មដ្ឋាន គឺជាការក្រៀកចិត្ត ចងចិត្តឱ្យជាប់ក្នុងអារម្មណ៍តែមួយ មិនបណ្ដោយឱ្យចិត្តត្រាច់ចរទៅរកអារម្មណ៍ផ្សេងៗ[១១]។

សមាធិ គឺជាការហាត់ពត់ចិត្ត អប់រំចិត្តឱ្យជាចិត្តល្អ ចិត្តបរិសុទ្ធប្រាសចាកគ្រឿងសៅហ្មងមានលោភៈ ទោសៈ និងមោហៈជាដើម ដែលជាឫសគល់នៃអំពើអាក្រក់សព្វយ៉ាង។ ដោយសារជីវិតនេះ វាជាប្រភពនៃបញ្ហា ដែលជាហេតុធ្វើឱ្យមានការបាត់បង់នូវសេចក្ដីសុខនៃការរស់នៅប្រចាំថ្ងៃ ដូច្នេះហើយទើបយើងត្រូវការធ្វើសមាធិ ដើម្បីលុបបំបាត់នូវសេចក្ដីទុក្ខ និងឈានទៅរកឱ្យឃើញនូវសេចក្ដីសុខដ៏ពិតប្រាកដ។

### ខ.ការធ្វើធុតង្គ

ធុតង្គ ឬ ធូតង្គ មានន័យថា អង្គរបស់ធម៌ជាគ្រឿងកម្ចាត់នូវកិលេស។ ពាក្យនេះ ជាឈ្មោះវត្តប្រតិបត្តិដោយឡែក សម្រាប់បព្វជិតក្នុងព្រះពុទ្ធសាសនាកាន់តាមកម្លាំងសទ្ធា ដើម្បីទម្រោមធម៌ជាគ្រឿងសៅហ្មងចិត្តឱ្យថយចុះ[១២]។

---

[១១] ព្រំ ឌី, ***ទស្សនវិជ្ជាធម្មនិយាយម***,កំពង់ចាម, ព.ស.២៥៦៣ គ.ស.២០២០,ទំព័រ៩០

[១២] ជួន ណាត, ***វចនានុក្រមខ្មែរ*** ,ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ,បោះពុម្ពលើកទី៤,គ.ស.១៩៦៧, ទំព័រ៥០៨

ការធ្វើធុតង្គនេះ គឺជាវិធីមួយដ៏សំខាន់ក្នុងព្រះពុទ្ធសាសនា ដើម្បីអប់រំចិត្តឱ្យចិត្តស្ងប់ប្រាសចាកគ្រឿងសៅហ្មង ព្រោះចិត្តរបស់យើងវាមានលក្ខណៈជាប់ស្អិតជាមួយនឹងការចង់បាន កំហឹង ច្រណែន និទ្ទា ឈ្នានីស មុខមាត់ កិត្តិយស តំណែង អំណាច ឋានៈ តួនាទីជាដើម។ ដោយសារតែរឿងទាំងអស់នេះបានធ្វើឱ្យមនុស្សមានការបៀតបៀន គៀបសង្កត់ កាប់សម្លាប់ លួចឆក់ ប្លន់ ឬ ប្រព្រឹត្តនូវអំពើអសីលធម៌ណាមួយ ដើម្បីយកមកបំពេញមហិច្ឆិតារបស់ខ្លួន។ ដូច្នេះ កិច្ចប្រតិបត្តិអប់រំផ្លូវចិត្តតាមបែបធុតង្គនេះជាវិធីមួយអាចឱ្យប្រតិបត្តិករ គៀបសង្កត់ចិត្ត កាត់បន្ថយចិត្តឱ្យជាចិត្តត្រេកអរ និងទទួលយករបស់ដែលមាន របស់បានមកដោយសុចរិត និងកម្លាំងស្មុងរបស់ខ្លួនមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។

### គ.ការធ្វើធម្មយាត្រា

ការធ្វើធម្មយាត្រា គឺជាការធ្វើដំណើរដោយភ្ជាប់ជាមួយនឹងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ។ ការធ្វើធម្មយាត្រានេះ ពេលខ្លះទុកដូចជាការសម្តែងមតិ ឬសំណូមពរណាមួយដើម្បីឱ្យមានដំណោះស្រាយនាំមកនូវសុខសន្តិភាព។ សម្តេចព្រះមហាឃោសនន្ទា **វ៉ា យាវ** ដែលជាព្រះសង្ឃ ខ្មែរមួយព្រះអង្គ ដែលកាលព្រះអង្គមានព្រះជន្មាយុនៅឡើយ ព្រះអង្គតែងសព្វព្រះទ័យក្នុងការធ្វើធម្មយាត្រា និងដឹកនាំធម្មយាត្រាទៅកាន់តំបន់ណាមួយក្នុងប្រទេសកម្ពុជា ដែលតំបន់នោះប្រជាជនរស់នៅមិនមានសេចក្តីសុខ ដោយសារការបាញ់ប្រហារ អំពើហិង្សា ការបាញ់បោះដោយប្រើប្រដាប់អាវុធដែលជាការបំផ្លាញនូវសេចក្តីសុខសន្តិភាពរបស់ប្រជាពលរដ្ឋ។ ព្រះអង្គតែងតែនាំយកនូវព្រះធម៌ទៅផ្សព្វផ្សាយ ដើម្បីឱ្យមនុស្សដាក់អាវុធចុះ និងចាប់យកព្រះធម៌។ ព្រះសង្ឃ ដីកាព្រះអង្គមានដូចជា៖[១៣]

-គំនុំដែលមាននៅក្នុងចិត្តរបស់បុគ្គល និងការសងសឹកតបទៅអ្នកឯទៀតនោះ ទោសៈមិនអាចរលត់ទៅបានឡើយ។

-បើគំនុំ និងការសងសឹកមិនមាននៅក្នុងខ្លួនទេ នោះទោសៈប្រាកដជារលត់គ្មានសល់។

-ទោសៈ មិនមែនស្ងប់ដោយទោសៈឡើយ។

-ទោសៈ អាចស្ងប់ទៅបានដោយសារតែមេត្តាព្រហ្មវិហារប៉ុណ្ណោះ។ សូមឱ្យគំនិតនៃមេត្តារបស់អ្នកជ្រួតជ្រាបពាសពេញពិភពលោក។

## ៤.សេចក្តីសន្និដ្ឋាន

ទស្សនវិជ្ជាព្រះពុទ្ធសាសនា គឺជាឱសថដ៏ស័ក្តិសិទ្ធិមួយសម្រាប់ព្យាបាលជំងឺសង្គម។ ប៉ុន្តែ គួរឱ្យសោកស្តាយទស្សនវិជ្ជានេះមិនសូវមានមនុស្សយកទៅប្រតិបត្តិឱ្យបានពិតប្រាកដឡើយ។ ខណៈដែលមនុស្សវ័យចំណាស់មួយចំនួន ដែលតាំងខ្លួនជាអ្នកគោរពនិងប្រតិបត្តិព្រះពុទ្ធសាសនាតែបែរជាប្រព្រឹត្តផ្ទុយពីគោលការណ៍សាសនាទៅវិញនោះ។ យុវវ័យជំនាន់ក្រោយភាគច្រើនបែរជាចាត់ទុកព្រះពុទ្ធសាសនាថាហួសសម័យ ឬក៏ជាកិច្ចការរបស់មនុស្សចាស់ទៅវិញ។ នៅប្រទេសកម្ពុជា ពេលខ្លះ អ្នកតម្រង់ទិសសង្គមហាក់កំពុងមើលរំលងទស្សនវិជ្ជាព្រះពុទ្ធសាសនា ឬក៏នៅមិនទាន់ចេះប្រើប្រាស់ដើម្បីប្រយោជន៍សង្គមឱ្យបានច្រើននៅឡើយទេ។ ជាក់ស្តែង ការបញ្ជ្រាបនូវទស្សនវិជ្ជាពុទ្ធសាសនាដល់

---

[១៣] សម្តេចព្រះមហាឃោសន្ទា, ***មួយជំហានម្តង***, បោះពុម្ពលើកទី៣,គ.ស.១៩៩៦, ទំព័រ២

ស្រទាប់យុវវ័យនៅមានតិចតួចនៅឡើយ។ ទស្សនវិជ្ជាសន្តិភាព និងអហិង្សារបស់ព្រះពុទ្ធសាសនាពិតជាមានតម្លៃខ្លាំងណាស់សម្រាប់សង្គមមនុស្ស ជាពិសេសសង្គមកម្ពុជា ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ គឺត្រូវការចំបាច់នូវធនធានមនុស្សប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវខ្ពស់។ ប៉ុន្តែ បញ្ហានៅត្រង់ថា អ្នកតម្រង់ទិសសង្គមទាំងឡាយមិនបានប្រើប្រាស់ ឬកែច្នៃរបស់មានតម្លៃទាំងនោះ ឱ្យមានប្រយោជន៍សម្រាប់ព្យាបាលជំងឺសង្គមនៅឡើយ។ ប្រសិនបើមនុស្សគ្រប់គ្នាស្គាល់បុណ្យនិងបាប ស្គាល់គុណនិងទោសតាមគន្លងព្រះពុទ្ធសាសនាហើយនោះ សង្គមកម្ពុជានឹងទទួលបាននូវសុខសន្តិភាពជានិរន្តរ៍មិនខាន។

ទាក់ទងពីសកម្មភាពព្រះពុទ្ធសាសនា និយាយដោយឡែកចំពោះពុទ្ធសាសនិក គឺបានធ្វើសកម្មភាពយ៉ាងច្រើន ក្នុងនោះមានការធ្វើបុណ្យ ការកសាងសមិទ្ធផលនានា ការធ្វើសមាធិ ការធ្វើធុតង្គ ការធ្វើធម្មយាត្រា និងការបដិបត្តិរយៈពេលខ្លីជាដើម ដែលជាសកម្មភាពឆ្លុះបញ្ចាំងអំពីការចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់សន្តិភាពនៅកម្ពុជា។ ព្រោះសកម្មភាពទាំងនេះ វាមានតម្លៃនៃគុណធម៌ ចរិយាធម៌ និងគ្រប់រូបភាពនៃឥរិយាបទ ដែលឆ្លុះបញ្ចាំងពីការគោរពជីវិត ការគោរពចំពោះមនុស្សជាតិ និងភាពថ្លៃថ្នូររបស់គេ គោរពសិទ្ធិមនុស្ស និងការបដិសេធចោលនូវរូបភាពនៃអំពើហិង្សា ព្រមទាំងការគោរពនូវគោលការណ៍សេរីភាព យុត្តិធម៌ សាមគ្គីភាព មានអធ្យាស្រ័យ និងការយោគយល់គ្នារវាងក្រុមមនុស្ស និងបុគ្គល។ ផ្ទុយទៅវិញ ប្រសិនបើសង្គមរីកចម្រើន តែមនុស្សខ្វះគុណធម៌ សីលធម៌ ចរិយាធម៌ សុជីវធម៌ និងមិនមានសកម្មភាពល្អៗ (ធ្វើបុណ្យ) រួមចំណែកជាមួយសង្គមទេនោះ ពិតណាស់សង្គមនោះនឹងមិនទទួលបានសុខសន្តិភាពទេ ព្រោះមនុស្សរស់នៅជាមួយនឹងភាពភ័យខ្លាចអំពើហិង្សា គៀបសង្កត់ អយុត្តិធម៌ ពុករលួយ និងបាត់បង់ សន្តិភាព ឬសន្តិភាពគ្មាននិរន្តរ៍។

## គន្ថនិទ្ទេស

### ក.ឯកសារជាភាសាខ្មែរ


១.ជួន ណាត, *វចនានុក្រមខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៤ ព.ស.២៥១១ គ.ស.១៩៦៧

២.គុង ឈួន,***បាបនិទ្ទេស និងបុញ្ញានិទ្ទេស***, បោះពុម្ពលើកទី១,ព.ស.២៥០៨ គ.ស.១៩៦៥

៣.ធម្មបទដ្ឋកថាភាគ១,ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ,ភ្នំពេញ,ព.ស.២៥៣៨

៤.ប៉ាងខាត់,***ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ***,ការផ្សាយពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥០៤

៥.ពុទ្ធសាសនា ២៥០០, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥៤៥

៦.ពុទ្ធសាសនានិងការអភិវឌ្ឍន៍សង្គមខ្មែរ, ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍,បាត់ដំបង, ឆ្នាំ១៩៩៦

៧.យិន វន់,***ប្រជុំបុញ្ញប្រវត្តិ***, ការផ្សាយរបស់បណ្ណាគារភ្នំពេញ៥៩បាស្ទ័រ, ឆ្នាំ ?

៨.សម្តេចព្រះមហាឃោសន្តា,***មួយជំហានម្តង***, បោះពុម្ពលើកទី៣,គ.ស.១៩៩៦

៩.សោម ងន, ***ពន្លឺពុទ្ធសាសនា***, បោះពុម្ពលើកទី២, USA, ព.ស.២៥៤៨ គ.ស.២០០៥

១០.ហេង មណីចិន្តា, ***មគ្គុទ្ទេសជីវិត***, ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍,បាត់ដំបង, ឆ្នាំ១៩៩៧

១១.ហុក សុវណ្ណ, ***តួនាទីរបស់ព្រះសង្ឃក្នុងសង្គមខ្មែរ,*** ព.ស.២៥៥២ គ.ស.២០០៨

១២. វ៉ាន សាឌុំ, ***វប្បធម៌ពុទ្ធសាសនា***, ទស្សនាវដ្តីកម្ពុជសុរិយាឆ្នាំទី៣០ លេខ៦-៧ ខែមិថុនា-កក្កដា,ព.ស.២៥៥០

# ការប្រតិបត្តិរបស់ពុទ្ធសាសនិក
# ក្នុងការលើកកម្ពស់សន្តិភាពនៅកម្ពុជា

បេក្ខជនបណ្ឌិតៈ **ព្រុំ ឌី**
ជំនាញៈ **ទស្សនវិជ្ជា**

## ១. ស្ថានភាពទូទៅនៃព្រះពុទ្ធសាសនា

ធម៌វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង និងបញ្ញត្តិទុកប្រោសសត្វលោក ហៅថា ព្រះពុទ្ធសាសនា។ ព្រះពុទ្ធសាសនាជាវប្បធម៌កើតពីព្រះពុទ្ធ។ ព្រះពុទ្ធ កាលទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ហើយទ្រង់ទេសនាប្រោសសត្វលោកទូទៅ ហៅថា ទ្រង់សាបព្រោះ បណ្តុះ ដាំ ផ្សាំ វប្បធម៌ព្រះពុទ្ធសាសនាក្នុងពិភពលោក[១]។

ពុទ្ធសាសនា ជាសាសនាមានបទនាយកធម៌ធំៗច្រើនជាអនេក មានអហិង្សាជាដើមគឺជាសាសនាខាងបទមិនបៀតបៀនប្រកបដោយមេត្តាករុណា ហើយជាទស្សនវិជ្ជាសម្រាប់បណ្តុះ និស្ស័យមនុស្សឱ្យកាន់សុចរិត យុត្តិធម៌ ឱ្យខ្ពង់ខ្ពស់ ដែលអ្នកត្រូវការសេន្តិភាពគួរសិក្សា គួរប្រតិបត្តិតាម ដើម្បីសុខចម្រើនដល់ខ្លួន ដល់សហគមន៍ និងដល់ប្រទេស[២]។

ពុទ្ធសាសនា ត្រូវបានបង្កើតឡើងអស់រយៈពេលជាង ២៥០០ ឆ្នាំកន្លងមកហើយ ដោយក្សត្រមួយព្រះអង្គព្រះនាមព្រះសិទ្ធត្ថគោតម ជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនៈ និងព្រះនាងសិរិមហាមាយា។ ទ្រង់បានរាជាភិសេកជាមួយព្រះនាងពិម្ពាយសោធរា ដែលមានព្រះជន្មដំណាលគ្នាគឺ ១៦ ព្រះវស្សា មានបុត្រមួយព្រះអង្គព្រះនាម **រាហុល** លុះដល់ព្រះជន្ម២៩ឆ្នាំក៏ចេញសាងព្រះផ្នួសហើយក៏បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធក្នុងព្រះជន្មាយុ ៣៥ព្រះវស្សា និងបរិនិព្វាន ក្នុងព្រះជន្មាយុ ៨០ ព្រះវស្សា។ ពេលដែលទ្រង់បរិនិព្វានទៅព្រះពុទ្ធសាសនាបានធ្លាក់ចុះជាលំដាប់ដោយកត្តាផ្សេងៗមានការមិនចុះសម្រុងគ្នារវាងពុទ្ធសាសនិកខ្លួនឯងជាដើម។

"ព្រះពុទ្ធសាសនា បានចូលមកប្រទេសខ្មែរតាមរយៈព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ ជាសមណទូតនៃព្រះមហាមោគ្គលីបុត្តតិស្ស ដែលជាប្រធានក្នុងតតិយសង្គាយនា បាននាំចូលមកកាន់សុវណ្ណភូមិក្នុងពុទ្ធសករាជ២៣៤ មុនគ្រិស្តសករាជ ៣០៩ឆ្នាំ ក្រោមសាសនូបត្ថម្ភ នៃព្រះបាទធម្មាសោកមហារាជ ដែលជាព្រះមហារាជាកាន់ពុទ្ធសាសនាមុតមាំក្នុងប្រទេសឥណ្ឌា"[៣]។ ព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសកម្មបំផុតក្នុងការកសាង និងថែរក្សាសន្តិភាពនៅប្រទេសខ្មែរតាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ព្រោះហេតុដូច្នោះហើយ ទើបប្រជាជនខ្មែរមិនលះបង់ព្រះពុទ្ធសាសនាចោល ទោះបីជាប្រទេសមានវិបត្តិយ៉ាងណាក៏ដោយ ព្រោះរសជាតិនៃព្រះ ធម៌របស់ព្រះពុទ្ធបានជ្រាបចូលទៅក្នុងជម្រៅ នៃទឹកចិត្តដោយមិនអាចកាត់ចេញបាន។

---

[១] វ៉ាន សាឌុំ, ***វប្បធម៌ពុទ្ធសាសនា,*** ទស្សនាវដ្តីកម្ពុជសុរិយាឆ្នាំទី៣០ លេខ៦-៧ ខែមិថុនា-កក្កដា ,ព.ស.២៥០១

[២] ពុទ្ធសាសនា ២៥០០, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥៤៥, ទំព័រក

[៣] ប៉ាង ខាត់, ***ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ,*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥០៤, ទំព័រច

## ២.ព្រះពុទ្ធសាសនា និងសន្តិភាព

តើអ្វីទៅជាហេតុដែលធ្វើឱ្យគ្មានសន្តិភាពក្នុងសង្គមមនុស្ស? នៅក្នុងព្រះពុទ្ធសាសនាបានចង្អុលបង្ហាញថា មិនមានអ្វីក្រៅពីមូលនៃអកុសលដែលត្រាំនៅក្នុងសន្តានបុគ្គលម្នាក់ៗនោះគឺលោភៈ ទោសៈ មោហៈ អវិជ្ជា និងតណ្ហា ដែលជាមូលដ្ឋានធ្វើឱ្យគ្មានសន្តិភាពក្នុងសង្គមមនុស្សនោះទេ។ ហេតុនេះហើយ ដើម្បីទទួលបានសន្តិភាពក្នុងសង្គម គឺមនុស្សគ្រប់គ្នាត្រូវមានភារៈរៀងៗខ្លួនក្នុងការបដិបត្តិនូវទាន សីល ភាវនា (សម្រាប់គ្រហស្ថ) រីឯព្រះសង្ឃវិញ គប្បីបដិបត្តិនូវសីល សមាធិ និងបញ្ញា ដើម្បីបានទទួលផល គឺសន្តិភាពយ៉ាងពិតប្រាកដក្នុងសង្គមមនុស្សគឺក្នុងចិត្តនេះឯង មិនមែនសន្តិភាពបានមកពីខាងក្រៅនោះទេ។

ព្រះពុទ្ធសាសនា អប់រំមនុស្សតាមវិធីសន្តិភាព មិនមែនដោយហិង្សា លទ្ធិផ្តាច់ការនោះទេ អប់រំមនុស្សឱ្យមានព្រហ្មវិហារធម៌ ចេះស្រលាញ់រាប់អានគ្នា និងគោរពគ្នាទៅវិញទៅមក[៤]។ ព្រះសម្មាសម្ពុទ្ធពេលបានត្រាស់ដឹងជាព្រះពុទ្ធហើយ ទ្រង់យកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាសង្គម សេដ្ឋកិច្ច និងរបៀបរបបរដ្ឋាភិបាលក្នុងសម័យនោះ។ ទ្រង់បានពន្យល់យ៉ាងច្បាស់ថា កាលណាប្រមុខរដ្ឋាភិបាលគឺស្តេចក្តី មន្ត្រីក្តី ប្រព្រឹត្តអំពើពុករលួយ ព្រៃផ្សៃ និងអយុត្តិធម៌ហើយ កាលនោះប្រទេសជាតិទាំងមូលមុខជាជួបការបាក់បែក ប៉ះទង្គិចគ្នាជាមិនខាន។ ព្រោះហេតុនោះ ហើយទើបទ្រង់សម្តែងទសពិធរាជធម៌ឡើង សម្រាប់ឱ្យព្រះរាជាប្រព្រឹត្ត ព្រមទាំងណែនាំពួកមន្ត្រី សេនាបតីធំៗ និងពួករាស្ត្រឱ្យប្រព្រឹត្តតាម[៥]។

ជាការពិតណាស់ថា សន្តិភាព គឺសេចក្តីស្ងប់ដោយកាយ វាចា និងចិត្ត ជៀសផុតពីការរំលោភបំពាន ភាពអយុត្តិធម៌ ភាពភ័យខ្លាច និងប៉ះទង្គិចដោយហិង្សាជាដើម ដែលជាបំណងរបស់មនុស្សគ្រប់រូបមិនថាមាន ក្រ អ្នកប្រាជ្ញ ឬបណ្ឌិតនោះឡើយ។ សន្តិភាពមិនមែនកើតឡើងដោយឯងៗនោះទេ គឺកើតឡើងដោយសារការកសាង ឬការប្រព្រឹត្តរបស់បុគ្គលម្នាក់ៗ ប្រកបដោយសុចរិត និងអហិង្សា បើមិនមានការប្រព្រឹត្តនូវសកម្មភាពណាមួយជាកាយសុចរិត វចីសុចរិត និងមនោសុចរិតទេ សន្តិភាពនឹងមិនកើតមានទេ។ ព្រះពុទ្ធសាសនាបានណែនាំអំពីមាគ៌ាជាច្រើនដែលប្រតិបត្តិទៅនាំមកនូវសន្តិភាព ក្នុងនោះមានព្រហ្មវិហារធម៌៤ គឺមេត្តា ករុណា មុទិតា និងឧបេក្ខាជាដើម។ ការកសាងសន្តិភាពត្រូវការផ្លូវប្រកបដោយព្រហ្មវិហារធម៌ ដូច្នេះ បើមនុស្សត្រូវការសន្តិភាព មនុស្សគប្បីកសាងព្រហ្មវិហារធម៌នេះឱ្យមាននៅក្នុងចិត្ត។

## ៣.សកម្មភាពពុទ្ធសាសនិកក្នុងការលើកកម្ពស់សន្តិភាពនៅកម្ពុជា

ពុទ្ធសាសនិក បានដល់អ្នកគោរពជឿព្រះពុទ្ធសាសនាដូចជា ភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី និងអ្នកដែលទទ្រង់នូវគ្រឿងសម្គាល់ថាជាអ្នកបួស តែមានភេទជាគ្រហស្ថដូចជា តាជី ដូនជីជាដើម។ ក្រៅពីនេះ អ្នកដែលកាន់ ជឿ ដើរតាមពុទ្ធសាសនា ដែលយើងហៅថាពុទ្ធបរិស័ទ មានឧបាសក

---

[៤] ***ពុទ្ធសាសនានិងការអភិវឌ្ឍន៍សង្គមខ្មែរ,*** ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍,បាត់ដំបង, ឆ្នាំ១៩៩៦,ទំព័រ១១២

[៥] សោម ងន, ***ពន្លឺពុទ្ធសាសនា,*** បោះពុម្ពលើកទី២, USA, ព.ស.២៥៤៨ គ.ស.២០០៥, ទំព័រ៥៣

ឧបាសិកា ទាយក ទាយិកា ជាដើម[៦]។ សកម្មភាពរបស់ពុទ្ធសាសនិកនៅកម្ពុជា មានច្រើន ក្នុងនោះ សកម្មភាពធំៗដូចជាៈ ការធ្វើបុណ្យ ការកសាងសមិទ្ធផលនានា ការថែរក្សាបរិស្ថាន ការសិក្សា និង ការអប់រំផ្លូវចិត្តជាដើម ដែលជាទធ្វើលើកកម្ពស់សន្តិភាពនៅកម្ពុជា។

## ៣.១.ការធ្វើបុណ្យ

បុណ្យមានន័យថា កុសលធម៌ ដែលជម្រះសន្តានចិត្តឱ្យបានស្អាត ឬធម្មជាតិដែលស្អាត បរិសុទ្ធ ផូរផង់ប្រាសចាកមន្ទិលគឺសេចក្តីសៅហ្មងចិត្តមានលោភៈ ទោសៈ មោហៈជាដើម [៧]។ ព្រះសម្មាសម្ពុទ្ធ បានសម្តែងថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំខ្លាចបុណ្យឱ្យសោះ ព្រោះបុណ្យ ជាឈ្មោះនៃ សេចក្តីសុខ។ ពុទ្ធសាសនិកមានជំនឿថាបុណ្យដែលបុគ្គលបានធ្វើហើយរមែងទទួលបាននូវសេចក្តីសុខ សុភមង្គល ទាំងបច្ចុប្បន្ន និងបរលោក ដូច្នេះហើយទើបគេខិតខំ ប្រឹងប្រែង សន្សំ បណ្តុះ ឬ កសាង រៀងៗខ្លួន ដែលបុណ្យនោះប្រព្រឹត្តទៅតាមកាយក្តី វាចាក្តី ឬចិត្តក្តី។ នៅក្នុងព្រះពុទ្ធសាសនាបុណ្យមាន ច្រើនយ៉ាង មានឈ្មោះប្លែកៗទៅតាមវិធីដែលគេបានធ្វើ។ ប៉ុន្តែ បើសរុបឱ្យខ្លីតាមពិធីបុណ្យនោះមាន ពីរយ៉ាងគឺពិធីបុណ្យក្នុងផ្លូវវិន័យ១ និងពិធីបុណ្យក្នុងផ្លូវធម៌ ឬព្រះសូត្រ១[៨]។ បុណ្យតាមផ្លូវព្រះវិន័យ ដូចជា ចូលព្រះវស្សា ចេញព្រះវស្សា កឋិន បញ្ចុះសីមា និងបំបួសជាដើម ដែលមានពុទ្ធប្បញ្ញត្តិ ឬ ពុទ្ធានុញ្ញាតដាក់កម្រិត ដាក់ច្បាប់ឱ្យធ្វើ ពុំមែនចេះតែធ្វើ បានទៅតាមចំណង់សទ្ធារបស់យើងនោះទេ ឯបុណ្យតាមផ្លូវព្រះសូត្រវិញដូចជា ឈាបនកិច្ចភ្ជុំបិណ្ឌ ទេសនាមហាជាតិ មាឃបូជា វិសាខបូជា ចូលឆ្នាំ ទក្ខិណានុប្បទាន កតញ្ញូជាដើម ដែលជាសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទ មិនអនុវត្តទៅតាម ពុទ្ធប្បញ្ញត្តិសុទ្ធនោះទេ។

ការធ្វើបុណ្យ (ធ្វើអំពើល្អ) ជាកល្យាណកម្មមួយដ៏ល្អបំផុត របស់អ្នកស្រលាញ់សន្តិភាព ស្រលាញ់ការគោរពសិទ្ធិមនុស្ស ស្រលាញ់ការអភិវឌ្ឍន៍ប្រកបដោយការទទួលខុសត្រូវ និងចីរភាព ស្រលាញ់សុខដុមសាសនា និងស្រលាញ់តម្លៃនៃមនុស្សជាតិទាំងឡាយតែងតែធ្វើជាប្រក្រតី។

## ៣.២.ការកសាងសមិទ្ធផលនានា

ជំនឿត្រឹមត្រូវរបស់ព្រះពុទ្ធសាសនា គឺជំនឿលើកម្មផល[៩]។ ដោយសារតែទស្សនៈនៃជំនឿគឺជឿ ទៅលើកម្មផលដូច្នេះហើយ ទើបយើងឃើញថា ពុទ្ធសាសនិកទាំងឡាយ ដែលជាអ្នកកាន់ គោរព ជឿ ឬប្រតិបត្តិតាមព្រះពុទ្ធសាសនាបានចំណាយកម្លាំងទ្រព្យធន និងកម្លាំងកាយវាចាចិត្ត ដើម្បីកសាងនូវ សមិទ្ធផលនានាយ៉ាងច្រើនសម្រាប់តម្កល់ទុកនៅក្នុងព្រះពុទ្ធសាសនា។ សមិទ្ធផលទាំងឡាយមានច្រើន តែបើរាប់ដោយសង្ខេបមានពីរសំខាន់ៗគឺ សមិទ្ធផលមានវិញ្ញាណបានដល់ធនជានមនុស្សនិងសមិទ្ធផល

---

[៦] ហេង មណីចិន្តា, ***មគ្គុទ្ទេសជីវិត***, ការផ្សាយរបស់ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍,បាត់ដំបង, ឆ្នាំ១៩៩៧ ទំព័រ៧

[៧] យិន វន់, ***ប្រជុំបុញ្ញប្រវត្តិ***, ការផ្សាយរបស់បណ្ណាគារភ្នំពេញ៥៩បាស្ទ័រ, ឆ្នាំ? ទំព័រ៣

[៨] គុង ឈួន, ***បាបនិទ្ទេស និងបុញ្ញនិទ្ទេស***, បោះពុម្ពលើកទី១,ព.ស.២៥០៨ គ.ស.១៩៦៥, ទំព័រ៥៦

[៩] ហុក សុវណ្ណ, ***តួនាទីរបស់ព្រះសង្ឃក្នុងសង្គមខ្មែរ***, ព.ស.២៥៥២ គ.ស.២០០៨,ទំព័រ៨៥

គ្មានវិញ្ញាណបានដល់សំណង់មានវត្តអារាមជាដើម។ សមិទ្ធផលទាំងពីរនេះពិតជាបានដើរតួយ៉ាងសំខាន់ក្នុងការចូលរួមកសាង និងការថែរក្សាសន្តិភាពនៅកម្ពុជាតាំងពីសម័យបុរាណរហូតបច្ចុប្បន្ន។ ព្រោះប្រទេសជាតិដែលអាចមានសន្តិភាពលុះត្រាមនុស្សរស់នៅក្នុងជីវភាពសមរម្យ ប្រាសចាកការភ័យខ្លាច មានការគោរពសិទ្ធិមនុស្ស មានយុត្តិធម៌ និងមានការអភិវឌ្ឍប្រកបដោយការទទួលខុសត្រូវខ្ពស់ និងចីរភាព។ ព្រះពុទ្ធសាសនាបានកសាងសំណង់មានវិញ្ញាណ និងសំណង់ឥតវិញ្ញាណយ៉ាងច្រើន ដើម្បីចូលរួមអភិវឌ្ឍន៍ប្រទេសជាតិជាមួយរាជរដ្ឋាភិបាលឆ្ពោះទៅកាន់សុខសន្តិភាពជូនសង្គមទាំងមូល។

### ៣.៣.ការថែរក្សាបរិស្ថាន

បរិស្ថាន គឺជាទីកន្លែងដែលមនុស្ស សត្វ និងរុក្ខជាតិរស់នៅៗក្នុងនោះ មាននៅក្នុងខ្យល់អាកាស ឬនៅលើទឹក និងដីជាដើម។ ក្នុងន័យមួយទៀត បរិស្ថាន គឺជាលក្ខខណ្ឌដែលគេរស់នៅ ឬធ្វើការនៅក្នុងនោះ ហើយនិងរបៀបដែលវាមានឥទ្ធិពលមកលើថា តើគេមានអារម្មណ៍យ៉ាងណា ឬថាតើគេអាចធ្វើការប្រកបដោយប្រសិទ្ធភាពយ៉ាងដូចម្តេចបាន។

នៅក្នុងន័យដូចបានរៀបរាប់ខាងលើ បរិស្ថាន គឺជាចំណុចស្នូលដែលព្រះពុទ្ធទ្រង់យកចិត្តទុកដាក់ក្រៃលែង សូម្បីតែនៅពេលគង់ ឬនិមន្តទៅណាម្តងៗ ព្រះតែងតែសូត្រធម៌ សូមឱ្យសព្វសត្វជៀសចេញពីទីអង្គុយ ឬព្រះបាទរបស់ព្រះអង្គ។ តាមគំរូនេះសង្ឃសាវ័កក៏ដូចជាពុទ្ធបរិស័ទក៏ធ្វើបែបនេះដែរ។ ការដាំដើមឈើ ការសង់សាលា ការសង់អណ្តូងទឹក ការជួយក្មេងកំព្រា និងជនក្រីក្រ គឺជាចំណុចលើកស្ទួយរបស់ពុទ្ធសាសនិកជនខ្មែរ ដែលបានទទួលនូវការយល់ដឹងពីព្រះពុទ្ធសាសនានេះឯង។

### ៤.៤.ការសិក្សា (គន្ថធុរៈ និងវិបស្សនាធុរៈ)

នៅក្នុងព្រះពុទ្ធសាសនា មានការសិក្សាចំនួន២សំខាន់គឺ គន្ថធុរៈ និងវិបស្សនាធុរៈ។ គន្ថធុរៈសំដៅយកការសិក្សាលើព្រះត្រៃបិដក ឯវិបស្សនាធុរៈ សំដៅយករៀនវិបស្សនាជាគ្រឿងអប់រំចិត្ត[១០]។

ការសិក្សាទាំងពីរផ្នែកនេះមានផលប្រយោជន៍ផ្សេងៗគ្នា ស្របតាមការប្រឹងប្រែង និងការប្រតិបត្តិរបស់ខ្លួន គឺការសិក្សាគន្ថធុរៈតាមរយៈព្រះត្រៃបិដកធ្វើឱ្យបុគ្គលអ្នកសិក្សាទទួលបាននូវផលប្រយោជន៍ដូចជា៖ ១.យល់ដឹងយ៉ាងត្រឹមត្រូវដល់សារៈសំខាន់នៃពុទ្ធឱវាទ ២.យល់ដឹងគោលធម៌ និងគោលជំហររបស់ពុទ្ធសាសនា ៣.បណ្តុះសទ្ធាជ្រះថ្លាកាន់តែកិយ្យោភាពឡើងក្នុងគោលធម៌របស់ព្រះសម្មាសម្ពុទ្ធ ៤.ស្គាល់ការបដិបត្តិត្រូវតាមតួនាទីជាពុទ្ធសាសនិកជន ៥.ជួយជ្រោមជ្រែងពុទ្ធសាសនាឱ្យស្ថិតស្ថេរចីរកាលយូរអង្វែង។ ចំណែកការសិក្សាវិបស្សនាធុរៈវិញ គឺជាមធ្យោបាយជាន់ខ្ពស់ដែលអាចដកររំលើងឫសគល់នៃសេចក្តីទុក្ខឱ្យអស់ដោយគ្មានសេសសល់ បើពុំបានសម្រេចដល់ធម៌ជាន់ខ្ពស់ថ្នាក់ព្រះអរិយបុគ្គលទេ វិបស្សនាអាចកម្ចាត់បង់នូវភាពតានតឹង និងនាំឱ្យជាសះស្បើយនូវជំងឺផ្លូវចិត្ត ព្រមទាំងមានសមត្ថភាពដោះស្រាយបញ្ហាគ្រប់យ៉ាងដែលចោទក្នុងជីវិតទាំងអស់។ បើចិត្តគេបានស្ថិតនៅក្នុងវិបស្សនារមែងជាចិត្តស្ងប់ស្ងាត់ ជាចិត្តស្ថិតនៅនឹងកណ្តាលពុំញាប់ញ័រទៅតាមអារម្មណ៍ដែលប្រែប្រួលនៅក្នុងជីវិតបច្ចុប្បន្នឡើយ។

---

[១០] ធម្មបទដ្ឋកថាភាគ១,ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ,ភ្នំពេញ, ព.ស.២៥៣៨,ទំព័រ៩

គោលដៅសិក្សាព្រះពុទ្ធសាសនាចុងក្រោយបំផុត គឺព្រះសម្មាសម្ពុទ្ធ ផ្តល់តម្លៃទៅលើការសិក្សាអប់រំចិត្ត(វិបស្សនាធុរៈ) ឱ្យចិត្តស្ថិតនៅក្នុងសីល សមាធិ បញ្ញា ដើម្បីឱ្យជីវិតរស់នៅប្រចាំថ្ងៃប្រកបដោយមេត្តា ករុណា មុទិតា និងឧបេក្ខា ជាចិត្តស្ងប់ ជាចិត្តប្រាសចាកគ្រឿងសៅហ្មង គឺរស់នៅក្នុងភាពស្ងប់( សន្តិភាព )នេះឯង។

## ៤.៥.ការអប់រំផ្លូវចិត្ត

គេនិយាយថា កាំភ្លើងមិនសាហាវទេ តែចិត្តទេដែលសាហាវ។ ហេតុនេះ គេត្រូវគិត និង ស្វែងមធ្យបាយដើម្បីអប់រំចិត្ត។ អ្នកសិក្សាពុទ្ធសាសនា ប្រៀបប្រដូចចិត្តទៅនឹងសត្វស្វាដែលនៅមិនស្ងៀមស្ងើរគ្រប់ខណៈ។ ហេតុនេះ ដើម្បីឱ្យមនុស្សរស់នៅបានសុខ បានចម្រើន គេត្រូវអប់រំចិត្តឱ្យនៅស្ងៀមឱ្យមានលំនឹង និងឱ្យមានតុល្យភាពល្អ ដើម្បីឱ្យងាយស្រួលបញ្ញាវា។ ចិត្តដែលមានការអប់រំ គឺជាប្រភពនៃសេចក្តីសុខ និងសេចក្តីចម្រើន ដូចពុទ្ធភាសិតដែលពោលថា “គ្មានសេចក្តីសុខណាស្មើសេចក្តីស្ងប់ឡើយ”។ បើនិយាយពីការអប់រំចិត្តមានវិធីសាស្ត្រផ្សេងៗគ្នា ស្របតាមស្ថានភាព គោលការណ៍ ឬការកំណត់យក។ ក្នុងព្រះពុទ្ធសាសនា មានវិធីសាស្ត្រសំខាន់ៗ មួយចំនួនដូចជា ការធ្វើសមាធិ ការធ្វើធុតង្គ ការធ្វើធម្មយាត្រា និងការបដិបត្តិរយៈពេលខ្លីជាដើម ដែលជាវិធីអប់រំចិត្តឱ្យចិត្តស្ងប់ និងទទួលបានសន្តិភាព។

### ក.ការធ្វើសមាធិ

សមាធិ គឺជាការតាំងចិត្តមាំក្នុងអារម្មណ៍តែមួយ ឬការដឹងច្បាស់នូវអារម្មណ៍នោះៗ ដោយសច្ចភាព។ សមាធិមាន ២យ៉ាងគឺ សមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន។ សមថកម្មដ្ឋាន គឺជាការក្រៀកចិត្ត ចងចិត្តឱ្យជាប់ក្នុងអារម្មណ៍តែមួយ មិនបណ្តោយឱ្យចិត្តត្រាច់ចរទៅរកអារម្មណ៍ផ្សេងៗ[១១]។

សមាធិ គឺជាការហាត់ពត់ចិត្ត អប់រំចិត្តឱ្យជាចិត្តល្អ ចិត្តបរិសុទ្ធប្រាសចាកគ្រឿងសៅហ្មងមានលោភៈ ទោសៈ និងមោហៈជាដើម ដែលជាឫសគល់នៃអំពើអាក្រក់សព្វយ៉ាង។ ដោយសារជីវិតនេះ វាជាប្រភពនៃបញ្ហា ដែលជាហេតុធ្វើឱ្យមានការបាត់បង់នូវសេចក្តីសុខនៃការរស់នៅប្រចាំថ្ងៃ ដូច្នេះហើយទើបយើងត្រូវការធ្វើសមាធិ ដើម្បីលុបបំបាត់នូវសេចក្តីទុក្ខ និងឈានទៅរកឱ្យឃើញនូវសេចក្តីសុខដ៏ពិតប្រាកដ។

### ខ.ការធ្វើធុតង្គ

ធុតង្គ ឬ ធូតង្គ មានន័យថា អង្គរបស់ធម៌ជាគ្រឿងកម្ចាត់នូវកិលេស។ ពាក្យនេះ ជាឈ្មោះវត្តប្រតិបត្តិដោយឡែក សម្រាប់បព្វជិតក្នុងព្រះពុទ្ធសាសនាកាន់តាមកម្លាំងសទ្ធា ដើម្បីទម្រោមធម៌ជាគ្រឿងសៅហ្មងចិត្តឱ្យថយចុះ[១២]។

---

[១១] ព្រំ ឌី,*ទស្សនវិជ្ជាធម្មនិយាយម*,កំពង់ចាម, ព.ស.២៥៦៣ គ.ស.២០២០,ទំព័រ៩០

[១២]ជួន ណាត,*វចនានុក្រមខ្មែរ* ,ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ,បោះពុម្ពលើកទី៤,គ.ស.១៩៦៧, ទំព័រ៥០៨

ការធ្វើធុតង្គនេះ គឺជាវិធីមួយដ៏សំខាន់ក្នុងព្រះពុទ្ធសាសនា ដើម្បីអប់រំចិត្តឱ្យចិត្តស្ងប់ប្រាសចាកគ្រឿងសៅហ្មង ព្រោះចិត្តរបស់យើងវាមានលក្ខណៈជាប់ស្អិតជាមួយនឹងការចង់បាន កំហឹង ច្រណែន និទ្ទា ឈ្នានីស មុខមាត់ កិត្តិយស តំណែង អំណាច ឋានៈ តួនាទីជាដើម។ ដោយសារតែរឿងទាំងអស់នេះបានធ្វើឱ្យមនុស្សមានការបៀតបៀន គៀបសង្កត់ កាប់សម្លាប់ លួចឆក់ ប្លន់ ឬ ប្រព្រឹត្តនូវអំពើអសីលធម៌ណាមួយ ដើម្បីយកមកបំពេញមហិច្ឆិតារបស់ខ្លួន។ ដូច្នេះ កិច្ចប្រតិបត្តិអប់រំផ្លូវចិត្តតាមបែបធុតង្គនេះជាវិធីមួយអាចឱ្យប្រតិបត្តិករ គៀបសង្កត់ចិត្ត កាត់បន្ថយចិត្តឱ្យជាចិត្តត្រេកអរ និងទទួលយករបស់ដែលមាន របស់បានមកដោយសុចរិត និងកម្លាំងស្មូងរបស់ខ្លួនមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។

## គ.ការធ្វើធម្មយាត្រា

ការធ្វើធម្មយាត្រា គឺជាការធ្វើដំណើរដោយភ្ជាប់ជាមួយនឹងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ។ ការធ្វើធម្មយាត្រានេះ ពេលខ្លះទុកដូចជាការសម្តែងមតិ ឬសំណូមពរណាមួយដើម្បីឱ្យមានដំណោះស្រាយនាំមកនូវសុខសន្តិភាព។ សម្តេចព្រះមហាឃោសនន្ទា **វ៉ា យាវ** ដែលជាព្រះសង្ឃ ខ្មែរមួយព្រះអង្គ ដែលកាលព្រះអង្គមានព្រះជន្មាយុនៅឡើយ ព្រះអង្គតែងសព្វព្រះទ័យក្នុងការធ្វើធម្មយាត្រា និងដឹកនាំធម្មយាត្រាទៅកាន់តំបន់ណាមួយក្នុងប្រទេសកម្ពុជា ដែលតំបន់នោះប្រជាជនរស់នៅមិនមានសេចក្តីសុខដោយសារការបាញ់ប្រហារ អំពើហិង្សា ការបាញ់បោះដោយប្រើប្រដាប់អាវុធដែលជាការបំផ្លាញនូវសេចក្តីសុខសន្តិភាពរបស់ប្រជាពលរដ្ឋ។ ព្រះអង្គតែងតែនាំយកនូវព្រះធម៌ទៅផ្សព្វផ្សាយ ដើម្បីឱ្យមនុស្សដាក់អាវុធចុះ និងចាប់យកព្រះធម៌។ ព្រះសង្ឃ ដីកាព្រះអង្គមានដូចជា៖[១៣]

-គំនុំដែលមាននៅក្នុងចិត្តរបស់បុគ្គល និងការសងសឹកតបទៅអ្នកឯទៀតនោះ ទោសៈមិនអាចរលត់ទៅបានឡើយ។

-បើគំនុំ និងការសងសឹកមិនមាននៅក្នុងខ្លួនទេ នោះទោសៈប្រាកដជារលត់គ្មានសល់។

-ទោសៈ មិនមែនស្ងប់ដោយទោសៈឡើយ។

-ទោសៈ អាចស្ងប់ទៅបានដោយសារតែមេត្តាព្រហ្មវិហារប៉ុណ្ណោះ។ សូមឱ្យគំនិតនៃមេត្តារបស់អ្នកជ្រួតជ្រាបពាសពេញពិភពលោក។

## ៤.សេចក្តីសន្និដ្ឋាន

ទស្សនវិជ្ជាព្រះពុទ្ធសាសនា គឺជាឱសថដ៏ស័ក្តិសិទ្ធិមួយសម្រាប់ព្យាបាលជំងឺសង្គម។ ប៉ុន្តែ គួរឱ្យសោកស្តាយទស្សនវិជ្ជានេះមិនសូវមានមនុស្សយកទៅប្រតិបត្តិឱ្យបានពិតប្រាកដឡើយ។ ខណៈដែលមនុស្សវ័យចំណាស់មួយចំនួន ដែលតាំងខ្លួនជាអ្នកគោរពនិងប្រតិបត្តិព្រះពុទ្ធសាសនាតែបែរជាប្រព្រឹត្តផ្ទុយពីគោលការណ៍សាសនាទៅវិញនោះ។ យុវវ័យជំនាន់ក្រោយភាគច្រើនបែរជាចាត់ទុកព្រះពុទ្ធសាសនាថាហួសសម័យ ឬក៏ជាកិច្ចការរបស់មនុស្សចាស់ទៅវិញ។ នៅប្រទេសកម្ពុជា ពេលខ្លះ អ្នកតម្រង់ទិសសង្គមហាក់កំពុងមើលរំលងទស្សនវិជ្ជាព្រះពុទ្ធសាសនា ឬក៏នៅមិនទាន់ចេះប្រើប្រាស់ដើម្បីប្រយោជន៍សង្គមឱ្យបានច្រើននៅឡើយទេ។ ជាក់ស្តែង ការបញ្ជ្រាបនូវទស្សនវិជ្ជាពុទ្ធសាសនាដល់

---

[១៣] សម្តេចព្រះមហាឃោសន្តា,*មួយជំហានម្តង*, បោះពុម្ពលើកទី៣,គ.ស.១៩៩៦, ទំព័រ២

ស្រទាប់យុវវ័យនៅមានតិចតួចនៅឡើយ។ ទស្សនវិជ្ជាសន្តិភាព និងអហិង្សារបស់ព្រះពុទ្ធសាសនាពិតជាមានតម្លៃខ្លាំងណាស់សម្រាប់សង្គមមនុស្ស ជាពិសេសសង្គមកម្ពុជា ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ គឺត្រូវការចំបាច់នូវធនធានមនុស្សប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវខ្ពស់។ ប៉ុន្តែ បញ្ហានៅត្រង់ថា អ្នកតម្រង់ទិសសង្គមទាំងឡាយមិនបានប្រើប្រាស់ ឬកែច្នៃរបស់មានតម្លៃទាំងនោះ ឱ្យមានប្រយោជន៍សម្រាប់ព្យាបាលជំងឺសង្គមនៅឡើយ។ ប្រសិនបើមនុស្សគ្រប់គ្នាស្គាល់បុណ្យនិងបាប ស្គាល់គុណនិងទោសតាមគន្លងព្រះពុទ្ធសាសនាហើយនោះ សង្គមកម្ពុជានឹងទទួលបាននូវសុខសន្តិភាពជានិរន្តរ៍មិនខាន។

ទាក់ទងពីសកម្មភាពព្រះពុទ្ធសាសនា និយាយដោយឡែកចំពោះពុទ្ធសាសនិក គឺបានធ្វើសកម្មភាពយ៉ាងច្រើន ក្នុងនោះមានការធ្វើបុណ្យ ការកសាងសមិទ្ធផលនានា ការធ្វើសមាធិ ការធ្វើធុតង្គ ការធ្វើធម្មយាត្រា និងការបដិបត្តិវិបស្សនាជាដើម ដែលជាសកម្មភាពឆ្លុះបញ្ចាំងអំពីការចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់សន្តិភាពនៅកម្ពុជា។ ព្រោះសកម្មភាពទាំងនេះ វាមានតម្លៃនៃគុណធម៌ ចរិយាធម៌ និងគ្រប់រូបភាពនៃឥរិយាបទ ដែលឆ្លុះបញ្ចាំងពីការគោរពជីវិត ការគោរពចំពោះមនុស្សជាតិ និងភាពថ្លៃថ្នូររបស់គេ គោរពសិទ្ធិមនុស្ស និងការបដិសេធចោលនូវរូបភាពនៃអំពើហិង្សា ព្រមទាំងការគោរពនូវគោលការណ៍សេរីភាព យុត្តិធម៌ សាមគ្គីភាព មានអធ្យាស្រ័យ និងការយោគយល់គ្នារវាងក្រុមមនុស្ស និងបុគ្គល។ ផ្ទុយទៅវិញ ប្រសិនបើសង្គមរីកចម្រើន តែមនុស្សខ្វះគុណធម៌ សីលធម៌ ចរិយាធម៌ សុជីវធម៌ និងមិនមានសកម្មភាពល្អៗ (ធ្វើបុណ្យ) រួមចំណែកជាមួយសង្គមទេនោះ ពិតណាស់សង្គមនោះនឹងមិនទទួលបានសុខសន្តិភាពទេ ព្រោះមនុស្សរស់នៅជាមួយនឹងភាពភ័យខ្លាចអំពើហិង្សា គៀបសង្កត់ អយុត្តិធម៌ ពុករលួយ និងបាត់បង់ សន្តិភាព ឬសន្តិភាពគ្មាននិរន្តរ៍។

## គន្ថនិទ្ទេស

### ក.ឯកសារជាភាសាខ្មែរ


១.ជួន ណាត, *វចនានុក្រមខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៤ ព.ស.២៥១១ គ.ស.១៩៦៧

២.តុង ឈួន, ***បាបនិទ្ទេស និងបុញ្ញនិទ្ទេស***, បោះពុម្ពលើកទី១,ព.ស.២៥០៨ គ.ស.១៩៦៥

៣.ធម្មបទដ្ឋកថាភាគ១,ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ,ភ្នំពេញ,ព.ស.២៥៣៨

៤.ប៉ាងខាត់,***ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ***,ការផ្សាយពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥០៤

៥.ពុទ្ធសាសនា ២៥០០, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥៤៥

៦.ពុទ្ធសាសនានិងការអភិវឌ្ឍន៍សង្គមខ្មែរ, ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍,បាត់ដំបង, ឆ្នាំ១៩៩៦

៧.យិន វន់,***ប្រជុំបុញ្ញប្រវត្តិ***, ការផ្សាយរបស់បណ្ណាគារភ្នំពេញ៥៩បាស្ទ័រ, ឆ្នាំ ?

៨.សម្ដេចព្រះមហាឃោសន្ទា,***មួយជំហានម្ដង***, បោះពុម្ពលើកទី៣,គ.ស.១៩៩៦

៩.សោម ងន, ***ពន្លឺពុទ្ធសាសនា***, បោះពុម្ពលើកទី២, USA, ព.ស.២៥៤៨ គ.ស.២០០៥

១០.ហេង មណីចិន្ដា, ***មគ្គុទ្ទេសជីវិត***, ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍,បាត់ដំបង, ឆ្នាំ១៩៩៧

១១.ហុក សុវណ្ណ, ***តួនាទីរបស់ព្រះសង្ឃក្នុងសង្គមខ្មែរ,*** ព.ស.២៥៥២ គ.ស.២០០៨

១២. វ៉ាន សាឌុំ, ***វប្បធម៌ពុទ្ធសាសនា***, ទស្សនាវដ្ដីកម្ពុជសុរិយាឆ្នាំទី៣០ លេខ៦-៧ ខែមិថុនា-កក្កដា,ព.ស.២៥៥០

# ប្រព័ន្ធគាំពារសង្គមសេដ្ឋកិច្ចកម្ពុជា

បេក្ខជនបណ្ឌិតៈ **អ៊ុង វិសិដ្ឋ**
ជំនាញៈ **វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សេចក្តីផ្តើម

ជាបឋម នៅពេលដែលភាពក្រីក្រត្រូវបានគិតដោយបុគ្គលម្នាក់ៗ តើមានអ្វីកើតឡើងនៅក្នុងចិត្ត? អាចជារូបភាពរបស់មនុស្សម្នាក់ ដែលមិនមានអាហារគ្រប់គ្រាន់ដើម្បីញ៉ាំ រស់នៅក្នុងផ្ទះអាប់អួរ ឬគ្មានផ្ទះសម្បែងទាល់តែសោះ ហើយពួកគេប្រហែលជាមិនអាចមានលទ្ធភាពទិញទំនិញ និងសេវាកម្មដែលអ្នកតែងតែទទួលបានឡើយ។ បុគ្គលទាំងនោះគឺមិនបានខុសទេ ប៉ុន្តែភាពស្មុគស្មាញនៃភាពក្រីក្រអាចធ្វើឱ្យអ្នកភ្ញាក់ផ្អើល។ ភាពក្រីក្រមិនត្រឹមតែទាក់ទងនឹងប្រាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមបញ្ចូលទាំងបញ្ហានៃការទទួលបានសេវាកម្ម ដូចជា ការថែទាំសុខភាពនិងការអប់រំក្រុមជនងាយរងគ្រោះជាដើម ។ តើភាពក្រីក្រជាអ្វី? ភាពក្រីក្រ សំដៅលើការខ្វះធនធានគ្រប់គ្រាន់ ដើម្បីផ្តល់នូវភាពចាំបាច់នៃជីវិត ដូចជាអាហារ ទឹកស្អាត ទីជម្រក និងសំលៀកបំពាក់ ហើយបច្ចុប្បន្ននេះ ធនាគារពិភពលោកបានបន្ថែម ការទទួលបានការថែទាំសុខភាព ការអប់រំ និងសូម្បីតែការដឹកជញ្ជូន។ សូមបញ្ជាក់ផងដែរថា ធនាគារពិភពលោកជាស្ថាប័នដែលមានការយកចិត្តទុកដាក់ខ្លាំងជាងគេចំពោះបញ្ហាភាពក្រីក្រ។ នៅឆ្នាំ២០១៥ ធនាគារពិភពលោកបានកំណត់និយមន័យនៃ*ភាពក្រីក្រខ្លាំង* ដល់អ្នកដែលរស់នៅតិចជាង ១,៩០ ដុល្លារអាម៉េរិកក្នុងមួយថ្ងៃ រីឯអ្នកដែលមានប្រាក់ចំណូលចន្លោះពី ១,៩០ ទៅ ៣,១០ ដុល្លារអាម៉េរិកក្នុងមួយថ្ងៃត្រូវបានចាត់ថ្នាក់ជា *អ្នកក្រីក្រកម្រិតមធ្យម* ហើយចំនួននេះគឺផ្អែកទៅលើតម្លៃរូបិយវត្ថុនៃការប្រើប្រាស់របស់មនុស្សម្នាក់ ជាជាងប្រាក់ចំណូលតែម្នាក់ឯង[១]។

នៅក្នុងរង្វង់រដ្ឋាភិបាល ភាពក្រីក្រជារឿយៗត្រូវបានគេកំណត់ថាជា " ភាពក្រីក្រដាច់ខាត[២]" និង" ភាពក្រីក្រប្រៀបធៀប[៣]" ។ ប្រទេសនីមួយៗ មានវិធានការផ្ទាល់ខ្លួនសម្រាប់លុបបំបាត់ភាពក្រីក្រ។ ទន្ទឹមនឹងនេះ អ្នកនយោបាយ អ្នកធ្វើសេចក្តីសម្រេចចិត្ត អ្នកបច្ចេកទេស អ្នកស្រាវជ្រាវ វិញ្ញូជន មានជំនឿយ៉ាង

---

[១] World Vision: What is poverty? It's not as simple as you think, Updated May 20, 2021. In: https://www.worldvision.ca/stories/child-sponsorship/what-is-poverty. Retrieved on 30 August 2021.

[២] ភាពក្រីក្រដាច់ខាត សំដៅលើអ្នកដែលប្រាក់ចំណូលធ្លាក់ចុះក្រោមបន្ទាត់កំណត់ដោយប្រទេសដែលបានកំណត់។ នៅខាងក្រោមបន្ទាត់នេះ គឺជាមនុស្សមិនអាចបំពេញតម្រូវការមូលដ្ឋានរបស់ពួកគេសម្រាប់អាហារ ទឹក និងទីជម្រកបានទេ ហើយពួកគេក៏មិនមានលទ្ធភាពទទួលបានសេវាសង្គម ដូចជាការថែទាំសុខភាព ការអប់រំ និងឧបករណ៍ប្រើប្រាស់។

[៣] ភាពក្រីក្រប្រៀបធៀប សំដៅលើមនុស្សដែលមានប្រាក់ចំណូលសរុបតិចជាងភាគរយជាក់លាក់មួយ - ជាធម្មតាគឺ ៥០% នៃប្រាក់ចំណូលជាមធ្យមរបស់ប្រទេស ដែលអាចប្រែប្រួលជាលទ្ធផលនៃកំណើនសេដ្ឋកិច្ចនឹងធ្វើឱ្យបន្ទាត់នេះអាចផ្លាស់ប្តូរបាន និងនៅពេលភាពក្រីក្រត្រូវបានកំណត់ ដើម្បីរួមបញ្ចូលការទទួលបានសេវា និងសន្តិសុខដែលមានសារៈសំខាន់ចំពោះសុខុមាលភាព ហើយមិនត្រឹមតែប្រាក់ចំណូល និងការប្រើប្រាស់ប៉ុណ្ណោះទេ។

មុតមាំថា ការធ្វើអភិបាលកិច្ចល្អជាស្នូលនៃការអភិវឌ្ឍនិងចីរភាពនៃកំណើនសេដ្ឋកិច្ច ដែលក្នុងនោះកិច្ចគាំពារសង្គម-សេដ្ឋកិច្ចនឹងជួយទ្រទ្រង់ និងជាកាតាលីករឬជាកំលាំងជំរុញសម្រាប់ការស្តារសេដ្ឋកិច្ចប្រកបដោយភាពធន់ និងចីរភាពរបស់ប្រទេសមួយឡើងវិញ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ហើយការអនុវត្តក្របខណ្ឌគោលនយោបាយជាតិនានានៅកម្ពុជា បានបញ្ចូលនូវទស្សនៈអភិវឌ្ឍន៍ដើម្បីក្លាយជាសង្គមបរិយាបន្ន មានន័យថា "**មិនបោះបង់ពលរដ្ឋណាម្នាក់**" (leave no one behind) ។ សម្រាប់ការគាំពារសង្គមសេដ្ឋកិច្ចកម្ពុជា គឺជាជន្ទល់ដើម្បីទប់អតិផរណានិងវិបត្តិនានា ជាក់ស្តែងក្នុងអំឡុងពេលនៃវិបត្តិនៃជំងឺរាតត្បាតសកលកូវីដ១៩នេះ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ចេញកញ្ចប់ថវិកាជាតិជាច្រើនក្នុងការជួយស្តារសេដ្ឋកិច្ចជាតិឡើងវិញ តាមរយៈកម្មវិធីគាំពារសង្គមសេដ្ឋកិច្ច ជាពិសេសដល់ក្រុមគោលដៅជាគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ដែលបានបាត់បង់ចំណូល ការបិទខ្ទប់ទីក្រុង ការបញ្ឈប់ការបញ្ញាទិញពីក្រៅប្រទេស ទេសចរធ្លាក់ចុះជាដើម។ តាមការស្រាវជ្រាវ ទោះបីអត្រាភាពក្រីក្រត្រូវបានថយចុះក្នុងរយៈពេលពីរទសវត្សរ៍នេះ ប៉ុន្តែកម្រិតជីវភាពរស់នៅរបស់ប្រជាជនតាមបណ្តារាជធានីខេត្តគឺពុំទាន់ប្រសើរឡើងទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋនិងធនធាន រួមមានវិស័យសុខាភិបាល សុវត្ថិភាពសង្គម គ្រឿងញៀន ការអប់រំ ជាដើម។ ការទទួលបានសេវានានាពីវិស័យទាំងនេះបានបង្ហាញថា មានលក្ខណៈរីកចម្រើននៅទីប្រជុំជន និងទីក្រុង ប៉ុន្តែនៅតាមបណ្តាខេត្តនៃទីជនបទ និងតំបន់ដាច់ស្រយាលប្រជាជនកំពុងតែជួបប្រទះនឹងផលវិបាកក្នុងការទទួលយករបបសេវាសង្គមនិងឱកាសនានា។ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងជួយដល់ប្រជាមូលដ្ឋាន តាមរយៈថវិកាវិនិយោគអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានជាពិសេស កម្មវិធីអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចបានអនុវត្តដោយក្រសួង/ស្ថានប័នជំនាញ ប៉ុន្តែលទ្ធផលសម្រេចគឺមិនទាន់ជាទីគាប់ចិត្តពីលទ្ធផលនៃការអនុវត្តកម្មវិធីទាំងនោះនៅឡើយទេ។ ហេតុដូច្នេះ ទើបរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រៀបចំក្របខណ្ឌគោលនយោបាយគាំពារសង្គមកម្ពុជាឡើង ដែលមានយន្តការការងារសំខាន់ៗមួយចំនួនដូចខាងក្រោមនេះ៖

## ១- ប្រព័ន្ធគាំពារសង្គមកម្ពុជា

ប្រព័ន្ធគាំពារសង្គមកម្ពុជា សំដៅលើគោលនយោបាយ កម្មវិធី សកម្មភាព រួមទាំងក្របខណ្ឌគតិយុត្តិ និងស្ថាប័នដែលត្រូវបានរៀបចំឡើងដើម្បីផ្តល់ការគាំពារនិងពង្រឹងសមត្ថភាពដល់ប្រជាជនកម្ពុជាក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច និងភាពងាយរងគ្រោះនានា ដែលកើតឡើងដោយសារប្រែប្រួលនៃលក្ខខណ្ឌរស់នៅ និងការងារ។ ប្រព័ន្ធគាំពារសង្គមត្រូវបានកសាងឡើងដើម្បីកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ព្រមទាំងរួមចំណែកដល់ការអភិវឌ្ឍនិងការគាំពារធនធានមនុស្សឱ្យកាន់តែរឹងមាំនិងទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ស្របតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥។ ប្រព័ន្ធគាំពារសង្គម មានសសរស្តម្ភចំនួន២គឺ[៤]៖

---

[៤] ការគាំពារសង្គមកម្ពុជា-Social Protection in Cambodia៖ "តើអ្វីគឺជាប្រព័ន្ធគាំពារសង្គម?"។ នៅក្នុង៖ https://m.facebook.com/socialprotectioncambodia/videos/តើអ្វីគឺជាប្រព័ន្ធគាំពារសង្គម/212994957671944។ ដកស្រង់ចេញថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២។

**ក- ប្រព័ន្ធជំនួយសង្គម៖** ផ្ដល់ការគាំពារតាមរយៈកម្មវិធីជាតិជំនួយសង្គមដល់ប្រជាជនដែលរស់នៅក្រោម និងក្បែរបន្ទាត់ភាពក្រីក្រ ដែលផ្ដោតជាពិសេសលើកុមារ ស្ត្រីមានផ្ទៃពោះ ជនមានពិការភាព និងជនចាស់ជរាគ្មានទីពឹង តាមរយៈហរិញ្ញប្បទានដោយចំណូលថវិកាជាតិ និងជំនួយអភិវឌ្ឍន៍ផ្លូវការ។ ប្រព័ន្ធជំនួយសង្គមមានធាតុផ្សំសំខាន់ៗចំនួន៤រួមមាន ការឆ្លើយតបនឹងគ្រោះអាសន្ន ការអភិវឌ្ឍន៍មូលធនមនុស្ស ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងសុខុមាលភាពរបស់ប្រជាជនងាយរងគ្រោះ។

**ខ- ប្រព័ន្ធសន្តិសុខសង្គម៖** បង្កើតយន្តការមានលក្ខណៈកាតព្វកិច្ចនិងខ្លួនទីពឹងខ្លួន ដែលលើកទឹកចិត្ត និងជំរុញឱ្យប្រជាជនស្វែងរកការគាំពារចំពោះហានិភ័យ ដែលអាចផ្ដល់ផលប៉ះពាល់ជាអវិជ្ជមានដល់សន្តិសុខប្រាក់ចំណូលរបស់ខ្លួន តាមរយៈការជំរុញឱ្យប្រជាជនគ្រប់រូបចូលរួមសន្សំប្រាក់ ឬបង់ភាគទាននៅក្នុងមូលនិធិរួមមួយ។ ប្រព័ន្ធសន្តិសុខសង្គមមានធាតុផ្សំសំខាន់ៗចំនួន៤គឺ របបសន្តិសុខសង្គមផ្នែកប្រាក់សោធន របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និង របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ។

ប្រព័ន្ធគាំពារសង្គមនៅកម្ពុជាត្រូវបានរៀបចំឡើង ដើម្បីផ្ដល់ការគាំពារនិងជំនួយដល់ប្រជាពលរដ្ឋទាំងអស់ដោយមិនប្រកាន់ពូជសាសន៍ ឬឋានៈ និងដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើននៅថ្ងៃអនាគត។

យោងតាមគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (Economic and Social Commission for Asia and the Pacific: ESCAP) បានកំណត់ខ្លឹមសារថា ការគាំពារសង្គម សំដៅលើសំណុំគោលនយោបាយដើម្បីជួយស្ត្រី បុរស និងកុមារឈានដល់ឬរក្សាបាននូវស្តង់ដាររស់នៅសមរម្យ និងសុខភាពល្អពេញមួយជីវិតរបស់ពួកគេ ហើយយើងអាចមើលឃើញទិដ្ឋភាពទាំងនោះនៅក្នុងទម្រង់មូលដ្ឋានសាមញ្ញបំផុតដូចខាងក្រោម[៥]៖

- សន្តិសុខប្រាក់ចំណូលមូលដ្ឋានសម្រាប់កុមារ ការផ្ដល់លទ្ធភាពទទួលបានអាហារូបត្ថម្ភ ការអប់រំ ការថែទាំ និងទំនិញនិងសេវាកម្មចាំបាច់ផ្សេងទៀត
- សន្តិសុខប្រាក់ចំណូលមូលដ្ឋានសម្រាប់មនុស្សដែលមានអាយុសកម្ម(active age)ដែលមិនអាចរកប្រាក់បានគ្រប់គ្រាន់ រួមទាំងករណីឈឺ និកម្មភាព ធ្វើមាតុភាព និងពិការភាព
- សន្តិសុខប្រាក់ចំណូលមូលដ្ឋានសម្រាប់មនុស្សចាស់ និង
- ការថែទាំសុខភាពចាំបាច់សម្រាប់ទាំងអស់គ្នា រួមទាំងការថែទាំសម្ភពដែលបំពេញតាមលក្ខណៈវិនិច្ឆ័យលើលទ្ធភាពភាពងាយស្រួល និងគុណភាព។

ផ្អែកលើនិយមន័យពីអគ្គលេខាធិការដ្ឋានអាស៊ាន ឆ្នាំ២០១៨ ការគាំពារសង្គមគឺជាកិច្ចអន្តរាគមន៍ដែលមានគោលនយោបាយ និងកម្មវិធីដែលត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយភាពក្រីក្រ វិសមភាព និងភាពងាយរងគ្រោះដោយការជួយដល់ក្រុមអ្នកក្រីក្រ មានហានិភ័យ ក្រុមងាយរងគ្រោះ ដោយមិនកំណត់

---

[៥] ESCAP: Why We Need Social Protection. Bangkok 10200, Thailand. 2018. p.1.

លើជនពិការ មនុស្សចាស់ យុវជន ស្ត្រី កុមារ កង្វះអាហារូបត្ថម្ភ ជនរងគ្រោះដោយគ្រោះមហន្តរាយ កម្មករចំណាកស្រុក និងក៏ដូចជាក្រុមគ្រួសារនិងសហគមន៍ ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេ ដើម្បីគ្រប់គ្រងហានិភ័យឱ្យបានកាន់តែប្រសើរ និងលើកកម្ពស់សិទ្ធិស្មើគ្នាលើសេវាកម្មសំខាន់ៗ និងឱកាសផ្អែកលើវិធីសាស្ត្រជាមូលដ្ឋាន/តម្រូវការត្រឹមត្រូវ[៦]។ បន្ថែមពីនេះ ការគាំពារសង្គម គឺជាសិទ្ធិមនុស្ស និងជាផ្នែកសំខាន់មួយនៃរបៀបវារៈឆ្នាំ២០៣០សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព[៧]។

ដោយឡែកកម្ពុជាបានកំណត់និយមការគាំពារសង្គមគឺជា *ការឧបត្ថម្ភដែលផ្តល់ទៅដល់ប្រជាជនដើម្បីឆ្លើយតបទៅនឹងបញ្ហាជាឫសគល់នៃភាពក្រីក្រ និងភាពងាយរងគ្រោះព្រមទាំងដើម្បីបង្កើនការអភិវឌ្ឍមូលធនមនុស្សក្នុងពេលជាមួយគ្នា។* ការគាំពារសង្គមរួមបញ្ចូលនូវការរៀបចំ និងប្រើប្រាស់ឧបករណ៍ជាច្រើនប្រភេទ ដើម្បីការពារបុគ្គល គ្រួសារ និងសហគមន៍ ពីប្រភេទផ្សេងៗនៃផលវិបាកផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ច និងសង្គម ដែលកើតឡើងពីហានិភ័យឬវិបត្តិ ដើម្បីជួយពួកគាត់ឲ្យចាកផុតពីភាពក្រីក្រ។ អន្តរាគមន៍នៃការគាំពារសង្គមក្នុងកម្រិតអប្បបរមា រួមមានការធានារ៉ាប់រងសង្គម គោលនយោបាយទីផ្សារពលកម្ម បណ្តាញសុវត្ថិភាពសង្គម និងសេវាកម្មសុខុមាលភាពសង្គម[៨]។

## ២- កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

អត្តសញ្ញាណកម្មគ្រួសារក្រីក្រសំដៅលើកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលស្ថិតនៅក្រោមអាណាត្តិកិច្ចរបស់ក្រសួងផែនការ និងសំដៅដល់ការកំណត់គ្រួសារក្រីក្រ កម្រិតភាពក្រីក្រ និងអត្រាភាពក្រីក្រតាមតំបន់[៩] និងត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តអនុក្រឹត្យលេខ២៩១ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីអនុវត្តកម្មវិធីនេះប្រកបដោយប្រសិទ្ធភាព។ អនុក្រឹត្យនេះបានកំណត់ពីការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ការគ្រប់គ្រង និងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ និងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រជាឧបករណ៍ដែលមានលក្ខណៈស្តង់ដាររួមមួយសម្រាប់ស្ថាប័ននានា ដែលចង់កំណត់គោលដៅផ្តល់សេវាសង្គមនានាដល់គ្រួសារក្រីក្រ និងងាយរងហានិភ័យនៅក្នុងប្រទេសកម្ពុជាទាំងមូល។ ជាជំហានដំបូងកម្មវិធីនេះត្រូវបានធ្វើឡើងនៅក្នុងរាជធានី/ខេត្តត្រឹមតែ៨ទៅ៩ប៉ុណ្ណោះក្នុងមួយឆ្នាំ ហើយទិន្នន័យគ្រួសារ

---

[៦] ASEAN Secretariat: ASEAN Declaration on Strengthening Social Protection and Regional Framework and Action Plan to Implement the ASEAN Declaration on Strengthening Social Protection, the Public Outreach and Civil Society Division of the ASEAN Secretariat, Jakarta, 1st Reprint: November 2018. p.11.

[៧] ILO: Social Protection Floors Recommendation. In: http://www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:12100:0::NO::P12100_ILO_CODE:R202. Retrieved on 14 September 2021.

[៨] រាជរដ្ឋាភិបាលកម្ពុជា ៖ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ២០១១-២០១៥ ភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ ទំព័រ២៣។

[៩] អនុក្រឹត្យចុះលេខ២៩១ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្រីក្រត្រូវបានធ្វើបច្ចុប្បន្នភាពតាមជុំវៀងរាល់៣ឆ្នាំម្តង។ ប៉ុន្តែដើម្បីឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ១៩ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រសួងផែនការអនុវត្តកម្មវិធីនេះជាប្រចាំ និងតាមការស្នើសុំនៅទូទាំងប្រទេសនៅឆ្នាំ២០២០។ ការប្រមូលទិន្នន័យគ្រួសារក្រីក្រនេះ បានផ្លាស់ប្តូរពីប្រព័ន្ធប្រើប្រាស់ក្រដាសទៅជាការប្រើប្រាស់ឧបករណ៍ឌីជីថលទំនើប និងរាល់បណ្តាព័ត៌មានស្តីពីស្ថានភាពរបស់គ្រួសារទាំងនោះនឹងមានផ្តល់ជូនដល់ក្រសួង/ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត តាមរយៈកម្មវិធីអេភីអាយ (Application Programming Interface : API) ឬគេហទំព័រ។ ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ត្រូវបានពង្រីកវិសាលភាពដល់ការកំណត់អត្តសញ្ញាណគ្រួសារងាយរងហានិភ័យដែលជាគ្រួសារងាយធ្លាក់ចូលទៅក្នុងភាពក្រីក្រ ចាប់ពីឆ្នាំ២០២២[១០]។

## ២.១- គោលបំណងនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

គោលបំណងនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រមានៈ ក)ការប្រើប្រាស់នីតិវិធីរួមមួយក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងងាយរងហានិភ័យពិតប្រាកដ ខ)ការផលិតជារបាយការណ៍ និងផ្តល់ទិន្នន័យគ្រួសារក្រីក្រនិងងាយរងហានិភ័យនិងនៅតាមតំបន់ភូមិសាស្ត្រ និងគ)ការផ្តល់បណ្ណសមធម៌ឱ្យគ្រួសារក្រីក្រ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការស្វែងរកសេវាគាំពារសង្គមនានា។

ស្ថាប័នឬអង្គការអាចប្រើប្រាស់ទិន្នន័យទាំងនេះ សម្រាប់កំណត់ក្រុមគោលដៅ ដើម្បីផ្តល់សេវាកម្ម និងជំនួយដល់គ្រួសារក្រីក្រ និងដោយសារតែបញ្ជីគ្រួសារក្រីក្រនិងងាយរងហានិភ័យបានទទួលការឯកភាព និងទទួលស្គាល់ពីអាជ្ញាធរឃុំ/សង្កាត់ និងអ្នកពាក់ព័ន្ធ ផ្តល់ឱ្យអាជ្ញាធរនិងប្រជាពលរដ្ឋនៅតាមមូលដ្ឋាននឹងកាន់តែងាយស្រួលជ្រើសរើសអ្នកទទួលផល។

## ២.២- ការចំណាត់ថ្នាក់ភាពក្រីក្រ

ចំណាត់ថ្នាក់គ្រួសារមានចែកចេញជាចំនួន៤ប្រភេទគឺៈ ក) ក្រកម្រិត១ (ទីទ័លក្រ) ខ) ក្រកម្រិត២ (ក្រ) គ) ងាយរងហានិភ័យ និង ឃ) ពុំក្រីក្រ។ បន្ថែមពីនេះ វិធីសាស្ត្រដើម្បីដាក់ចំណាត់ថ្នាក់ទាំងនេះធ្វើឡើងដោយប្រើប្រាស់ពិន្ទុទទួលបានពីបញ្ជីសំណួរភាពងាយរងគ្រោះ និងស្ថានភាពពិសេសនៃគ្រួសារដែលបានធ្វើការសម្ភាសន៍។

## ២.៣- ការកំណត់ភាពងាយរងហានិភ័យ

ការកំណត់ភាពងាយរងហានិភ័យគឺជាការងាររបស់ក្រុមការងារឃុំ/សង្កាត់ទូទាំងប្រទេស ដោយប្រើប្រាស់យន្តការប្រជុំពិភាក្សា អនុម័តតាមគោលការណ៍ណែនាំបច្ចេកទេសដែលមាន និងពីកម្រងសំណួរដែលមានស្រាប់ ធ្វើការកំណត់គ្រួសារកំពុងរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលងាយនឹងធ្លាក់ទៅក្នុងភាពក្រីក្រ។

---

[១០] ក្រសួងផែនការៈ កម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ប្រទេសកម្ពុជា នៅក្នុង៖ https://idpoor.gov.kh/ អំពីយើង គេហទំព័រផ្លូវការរបស់នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រង់ផ្នែកព័ត៌មានអំពីយើង ឆ្នាំ២០២៣។ ដកស្រង់ចេញថ្ងៃទី ១១ ខែមករា ឆ្នាំ២០២៣។

## ២.៤- គ្រួសារងាយរងហានិភ័យ

គ្រួសារងាយរងហានិភ័យសំដៅលើបណ្តាក្រុមគោលដៅនៃគ្រួសារដែលកំពុងរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ ហើយយ៉ាងហោចណាស់គ្រួសារនោះមានភាពងាយរងគ្រោះមួយយ៉ាងតិចក្នុងចំណោមប្រាំ ដោយគោរពតាមលក្ខខណ្ឌបានកំណត់[១១]៖ ក)សមាជិកយ៉ាងតិចម្នាក់មានពិការភាព ខ)មានសមាជិកអាយុស្មើឬលើស៦០ឆ្នាំ គ)មានកុមារតូចអាយុតិចជាង២ឆ្នាំ ឃ)សមាជិកជាកុមារអាយុក្រោម ១៨ឆ្នាំទាំងអស់ និង ង)មេគ្រួសារជាស្ត្រីកំពុងរស់នៅម្នាក់ឯងឬមេម៉ាយ ។

## ២.៥- បណ្ណសមធម៌

ការប្រើបណ្ណសមធម៌គេអាចទទួលបាន[១២] ក)សេវាថែទាំសុខភាពដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ខ)ប្រាក់ឧបត្ថម្ភពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ គ)ប្រាក់ឧបត្ថម្ភពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ១៩ និង ឃ)អត្ថប្រយោជន៍ពីកម្មវិធីផ្សេងៗទៀតជាច្រើន។

# ៣- កម្មវិធីជាតិជំនួយសង្គមនៅកម្ពុជា

កម្មវិធីជាតិជំនួយសង្គមក្នុងប្រទេសកម្ពុជា ត្រូវបានផ្តោតទៅលើក្រុមគោលដៅ[១៣] ប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ប្រជាជនដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ និងប្រជាជនដែលងាយរងគ្រោះ។ ប្រជាជនដែលងាយរងគ្រោះរាប់បញ្ចូលទាំងទារកនិងកុមារ ស្ត្រីមានផ្ទៃពោះ គ្រួសារដែលខ្វះអាហារូបត្ថម្ភ ជនមានពិការភាព ទាំងជនចាស់ជរាគ្មានទីពឹង។ ដោយឡែកសម្រាប់ជនពិការ និងជនចាស់ជរា ត្រូវបានចាត់ទុកជាក្រុមប្រជាជនងាយរងគ្រោះ ដោយសារពួកគាត់មានឱកាសតិចតួចក្នុងការស្វែងរកចំណូល និងការទទួលយកសេវាសង្គម ព្រមទាំង មានតម្រូវការច្រើនលើជំនួយអាហារូបត្ថម្ភ ទាំងសេវាថែទាំសុខភាព[១៤]។ ដោយឡែកភាពងាយរងគ្រោះ បានកំណត់ក្នុងទិន្នន័យមូលដ្ឋានឃុំ/សង្កាត់(CDB) គឺសំដៅដល់ជនពិការ កុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំ កុមារកំព្រានិងជនចាស់ជរា ជនអនាថា គ្រួសាររស់នៅលើដីសាធារណៈ កុមាររស់នៅតាមចិញ្ចើមថ្នល់ និងជនពិការដោយសារមីន សំណល់ជាតិផ្ទុះ[១៥]។

---

[១១] -ដ- ទំព័រ៤។

[១២] គាំពារសង្គមកម្ពុជា - Social Protection in Cambodia៖ តើប័ណ្ណសមធម័មានអត្ថប្រយោជន៍អ្វីខ្លះ?។ នៅក្នុង៖ https://www.facebook.com/socialprotectioncambodia/photos។ ដកស្រង់ចេញថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ។

[១៣] មូលនិធិជាតិជំនួយសង្គម៖ តើកម្មវិធីជាតិជំនួយសង្គមក្នុងប្រទេសកម្ពុជាផ្តោតលើក្រុមគោលដៅណាខ្លះ? ។ នៅក្នុង៖ Telegram គាំពារសង្គមកម្ពុជា Social Protection in Cambodia ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។

[១៤] រាជរដ្ឋាភិបាលកម្ពុជា៖ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ ភ្នំពេញ ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ទំព័រ១៩។

[១៥] មន្ទីរផែនការខេត្តបាត់ដំបង ៖ ឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០២១ នៃខេត្តបាត់ដំបង ខែមីនា ឆ្នាំ

## ៤- បេឡាជាតិសន្តិសុខសង្គម

នៅឆ្នាំ១៩៥៥ សន្តិសុខសង្គមត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា យោងតាមព្រះរាជក្រឹត្យលេខ៥៥ និង៣០៦[១៦]។ ប៉ុន្តែកំឡុងពេលរបបប្រល័យពូជសាសន៍ (១៩៧៥-១៩៧៩) សន្តិសុខសង្គមនេះត្រូវបានបំផ្លាញចោលទាំងស្រុង។ ប្រជាជនកម្ពុជាបានទទួលសេវាថែទាំសុខភាពដោយឥតគិតថ្លៃពីឆ្នាំ១៩៧៩-១៩៩៣ និងនាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើង បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ ដោយមានតួនាទីនិងភារកិច្ចគាំពារសន្តិសុខសង្គមដល់ប្រជាជន ដែលធ្វើការក្នុងវិស័យឯកជន។ នៅឆ្នាំ១៩៩២ មានការកែប្រែបទប្បញ្ញត្តិស្តីពីច្បាប់ការងារកម្ពុជាបច្ចុប្បន្ន ដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ដោយទទួលបានការអនុម័តនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧[១៧]។ នៅឆ្នាំ២០០២ ច្បាប់សន្តិសុខសង្គមត្រូវបានអនុម័តដោយសភាជាតិ ដែលថ្មីៗនេះត្រូវបានស្គាល់ថាច្បាប់របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ បន្ទាប់មក អនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ត្រូវបានអនុម័ត ដែលបង្កើតឡើងដើម្បីជំនួសនាយកដ្ឋានសន្តិសុខសង្គម។ ប.ស.ស. មានតួនាទីនិងភារកិច្ចគ្រប់គ្រងផ្នែកកិច្ចគាំពារសន្តិសុខសង្គមឱ្យស្របតាមច្បាប់សន្តិសុខសង្គមជាតិ និងបទប្បញ្ញត្តិសន្តិសុខសង្គមអនុលោមតាមអនុក្រឹត្យ ហើយត្រូវបានដំណើរការនៅចុងឆ្នាំ២០០៨[១៨]។ ប.ស.ស. កំពុងអភិវឌ្ឍន៍ខ្លួនតាមរយៈការរៀបចំពង្រីក ពង្រឹង និងអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនដោយបានរៀបចំផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំជាមួយនឹងចក្ខុវិស័យ និងបេសកកម្មដ៏ច្បាស់លាស់ ក្នុងការប្រតិបត្តិផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា និងឱ្យទទួលបាននូវសេវាសន្តិសុខសង្គម នៅពេលជួបប្រទះនូវយថាភាពផ្សេងៗ ដូចជា ជរាភាព ហានិភ័យការងារ ទុព្វលភាព មរណភាព ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ និងមាតុភាពជាដើម។ និយាយជារួមការជានាផ្នែកសន្តិសុខសង្គមមានសារៈសំខាន់ខ្លាំងណាស់ ព្រោះបានផ្តល់នូវការគាំពារចំពោះប្រជាជនកម្ពុជា និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិត ដែលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ដោយផ្អែកលើទស្សនាទាននៃការចែករំលែក និងគោលការណ៍សាមគ្គីធម៌ក្នុងសង្គម ដោយធានាបាននូវសន្តិសុខប្រាក់ចំណូល ពោលគឺមានន័យថា គ្មានសមាជិកសង្គមណាម្នាក់ធ្លាក់ទៅក្នុងហានិភ័យនៃភាពក្រីក្រ ដោយមិនអាចងើបរួចបានឡើយ។ បន្ថែមពីនេះ គោលនយោបាយសន្តិសុខសង្គម បានរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ស្តែងចេញតាមរយៈគោលការណ៍នៃការវិភាគទានឬចែករំលែកប្រាក់ចំណូល តាមខ្សែ

---

២០២១។ ទំព័រ៤៤-៤៩។

[១៦] បេឡាជាតិរបបសន្តិសុខសង្គម ៖ ប្រវត្តិសង្ខេប នៅក្នុង៖ https://nssf.gov.kh/អំពី%e2%80%8b-ប-ស-ស/ប្រវត្តិរូប។ ដកស្រង់ចេញថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១។

[១៧] ព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ច្បាប់ស្តីពីការងាររបស់រាជរដ្ឋាភិបាលកម្ពុជា។

[១៨] អនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនាឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម។

បណ្តោយ និងខ្សែទទឹង គឺអ្នកមានប្រាក់ចំណូលទាបត្រូវបានជួយដោយអ្នកមានប្រាក់ចំណូលខ្ពស់ អ្នកមានសុខភាពល្អ ជួយអ្នកមានជំងឺ ជនពិការ ឬអ្នកដែលទទួលរងនូវគ្រោះថ្នាក់ផ្សេងៗ ជនមានវ័យក្មេងជួយដល់ជនចាស់ជរា យន្តការនេះធ្វើឲ្យមនុស្សក្នុងសង្គមទាំងមូល ទទួលបាននូវភាពកក់ក្តៅក្នុងជីវភាពរស់នៅ ធានារក្សាបានសន្តិភាពនិងស្ថិរភាព និងភាពសុខដុមរមនារួមគ្នានៅក្នុងសង្គម។ ប.ស.ស. បានប្រតិបត្តិរបបសន្តិសុខសង្គម រួមមាន៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនគ្រោងអនុវត្តនៅពេលឆាប់ៗខាងមុខនេះ ហើយរាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចឱ្យប.ស.ស. ជាអ្នករៀបចំ និងគ្រប់គ្រងការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជននៅឆ្នាំ២០១៧ ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម ដោយការធានាឱ្យបាននូវសន្តិសុខប្រាក់ចំណូលរួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ស្ថិរភាពសង្គម។

## សេចក្តីសន្និដ្ឋាន

ជារួម រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំប្រព័ន្ធគាំពារសង្គមកម្ពុជាដោយសំដៅលើគោលនយោបាយ កម្មវិធី សកម្មភាព រួមទាំងក្របខណ្ឌគតិយុត្តិ និងស្ថាប័នជាប្រតិបត្តិការ ហើយបានបែងចែកប្រព័ន្ធនេះចេញជាពីរផ្នែក រួមមាន៖ ក)ប្រព័ន្ធជំនួយសង្គម និង ខ)ប្រព័ន្ធសន្តិសុខសង្គម។ ប្រព័ន្ធគាំពារសង្គមកម្ពុជា ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដោយផ្តល់អាទិភាពពិសេសលើកិច្ចគាំពារ និងការពង្រឹងសមត្ថភាពដល់ប្រជាជនកម្ពុជាក្នុងការឆ្លើយតបចំពោះហានិភ័យ វិបត្តិនានា និងភាពធន់ខាងសេដ្ឋកិច្ចគ្រួសារ ជាពិសេស ការកាត់បន្ថយនិងការទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ព្រមទាំងការចូលរួមចំណែករក្សាបាននូវកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព និងសង្គមបរិយាបន្ន។ ទន្ទឹមនឹងនេះ ក្រុមគោលដៅនៃគ្រួសារដែលកំពុងរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ ដែលគ្រួសារនោះមានភាពងាយរងគ្រោះមួយយ៉ាងតិចក្នុងចំណោមប្រាំតាមលក្ខខណ្ឌបានកំណត់នឹងទទួលបានបណ្ណសមធម៌សម្រាប់សេវាថែទាំសុខភាពដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ និងអត្ថប្រយោជន៍ពីកម្មវិធីផ្សេងៗទៀតជាច្រើន។ល។ ដោយឡែកសម្រាប់ ប.ស.ស. បានប្រតិបត្តិរបបសន្តិសុខសង្គម គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដោយហេតុថាបានផ្តល់នូវកិច្ចគាំពារចំពោះប្រជាជនពលរដ្ឋកម្ពុជា ជាពិសេសកិច្ចគាំពារសម្រាប់កម្មករនិយោជិត ដែលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ដើម្បីធានាបាននូវសន្តិសុខប្រាក់ចំណូល និងគ្មានសមាជិកសង្គមណាម្នាក់ធ្លាក់ទៅក្នុងហានិភ័យនៃភាពក្រីក្រឡើយ។ សរុបសេចក្តីមក ប្រព័ន្ធគាំពារសង្គមកម្ពុជា ពិតជាផ្តល់នូវឧត្តមប្រយោជន៍ក្នុងការចូលរួមលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ការរក្សាបាននូវកំណើនសេដ្ឋកិច្ច ស្ថិរភាពសង្គម និងប្រែក្លាយកម្ពុជាទៅជាសង្គមបរិយាបន្ន ជាពិសេសការកាត់បន្ថយគ្រួសារក្រីក្រ និងងាយរងគ្រោះ។

# គន្ថនិទ្ទេស


## លិខិតបទដ្ឋានគតិយុត្តិ

១- ព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ច្បាប់ស្តីពីការងាររបស់រាជរដ្ឋាភិបាលកម្ពុជា។

២- អនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនាឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម។

៣- អនុក្រឹត្យចុះលេខ២៩១ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

## ស្លាដែបោះពុម្ព

### ក)-ភាសាខ្មែរ

៤- មន្ទីរផែនការខេត្តបាត់ដំបង ៖ ឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០២១ នៃខេត្តបាត់ដំបង ខែមីនា ឆ្នាំ២០២១។ ទំព័រ៤៤-៤៩។

៥- រាជរដ្ឋាភិបាលកម្ពុជា៖ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ ភ្នំពេញ ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។

៦- រាជរដ្ឋាភិបាលកម្ពុជា ៖ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ២០១១-២០១៥ ភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១។

### ខ)-ភាសាបរទេស

៧- ASEAN Secretariat: ASEAN Declaration on Strengthening Social Protection and Regional Framework and Action Plan to Implement the ASEAN Declaration on Strengthening Social Protection, the Public Outreach and Civil Society Division of the ASEAN Secretariat, Jakarta, 1st Reprint: November 2018.

៨- ESCAP: Why We Need Social Protection. Bangkok 10200, Thailand. 2018.

## គេហទំព័រ

៩- ក្រសួងផែនការ ៖ កម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ប្រទេសកម្ពុជា នៅក្នុង៖ https://idpoor.gov.kh/អំពីយើង គេហទំព័រផ្លូវការរបស់នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រង់ផ្នែកព័ត៌មានអំពីយើង ឆ្នាំ២០២៣។ ដកស្រង់ចេញថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣។

១០- មូលនិធិជាតិជំនួយសង្គម៖ តើកម្មវិធីជាតិជំនួយសង្គមក្នុងប្រទេសកម្ពុជាផ្តោតលើក្រុមគោលដៅណាខ្លះ? ។ នៅក្នុង៖ Telegram គាំពារសង្គមកម្ពុជា Social Protection in Cambodia ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។

១១- ការគាំពារសង្គមកម្ពុជា-Social Protection in Cambodia៖ "តើអ្វីគឺជាប្រព័ន្ធគាំពារសង្គម?"។ នៅក្នុង៖ https://m.facebook.com/socialprotectioncambodia/videos/តើអ្វីគឺជាប្រព័ន្ធគាំពារសង្គម/212994957671944។ ដកស្រង់ចេញថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២។

១២- គាំពារសង្គមកម្ពុជា - Social Protection in Cambodia៖ តើប័ណ្ណសមធម៌មានអត្ថប្រយោជន៍អ្វីខ្លះ? ។ នៅក្នុង៖ https://www.facebook.com/socialprotectioncambodia/photos។ ដកស្រង់ចេញថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ។

១៣- បេឡាជាតិរបបសន្តិសុខសង្គម ៖ ប្រវត្តិសង្ខេប នៅក្នុង៖ https://nssf.gov.kh/អំពី%e2%80%8b-ប-ស-ស/ប្រវត្តិរូប។ ដកស្រង់ចេញថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១។

១៤- ILO: Social Protection Floors Recommendation. In: http://www.ilo.org/dyn/normlex/en/f?p=NORMLEXP UB:12100:0::NO::P12100_ILO_CODE:R202. Retrieved on 14 September 2021.

១៥- World Vision: What is poverty? It's not as simple as you think, Updated May 20, 2021. In: https://www.worldvision.ca/stories/child-sponsorship/what-is-poverty. Retrieved on 30 August 2021.

# គោលគំនិតនៃការវិវត្តន៍ និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងវិស័យរដ្ឋបាលសាធារណៈ

បេក្ខជនបណ្ឌិត៖ **ភួន ភូម៉ូនីរតន៍**
ជំនាញ៖ **រដ្ឋបាលសាធារណៈ**

## មូលន័យសង្ខេប

ស្របតាមនិន្នាការក្នុងតំបន់ និងសកលលោកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជីថលត្រូវបានគេកំណត់ថា ជាអាទិភាពសំខាន់នៅក្នុងផែនការមេឌីជីថលអាស៊ាននៅឆ្នាំ២០២៥ និងស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ២០២២ដល់២០៣៥ រដ្ឋាភិបាលឌីជីថលសំដៅដល់ការធ្វើទំនើបកម្ម និងសមាហរណកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាល និងសេវាសាធារណៈដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនិងបម្រើសេវាសាធារណៈឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ ដោយយុត្តិធម៌ សមធម៌ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្ន។ គោលគំនិតជាមូលដ្ឋានគឺការផ្តល់សេវាសាធារណៈឌីជីថលដែលមានគុណភាពខ្ពស់ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៃបណ្តាប្រទេសនិមួយៗក្នុងសកលលោក ដែលទីក្រុងជាច្រើនកំពុងឆ្លងកាត់ការផ្លាស់ប្តូរឆ្ពោះទៅរកទីក្រុងឆ្លាតវៃប្រែកបដោយនិរន្តរន៍ភាពនៃការកើតឡើងលើហេដ្ឋារចនាសម្ព័ន្ធការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងព័ត៌មានធានាបានដល់ការគាំទ្រអោយមានសុច្ចរិតភាព តម្លាភាព និងមានយុត្តិធម៌ក្នុងសង្គមនៃបណ្តាប្រទេសនិមួយៗនោះ។ ដើម្បីសម្រេចបានការផ្លាស់ប្តូរដោយភាពរលូន និងមានប្រសិទ្ធភាពទៅកាន់រដ្ឋាភិបាលវៃឆ្លាតជានិរន្តរន៍នោះគោលនយោបាយ និងយន្តការនៃការផ្តល់សេវាសាធារណៈគួរត្រូវបានដាក់ឱ្យដំណើរការក្នុងការត្រៀមខ្លួនរបស់រដ្ឋាភិបាល និងសង្គមប្រជាពលរដ្ឋត្រូវបានវាយតម្លៃលើកត្តាធនធានមនុស្សជាវិស័យអាទិភាពទីមួយសម្រាប់កម្ពុជា គឺការកសាងរដ្ឋាភិបាលឌីជីថលក្នុងកំណែទម្រង់វិស័យសាធារណៈលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទាំងថ្នាក់ជាតិ និងក្រោមជាតិ ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ជំរុញការវិនិយោគ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច វប្បធម៌ នយោបាយ និងសង្គម។

ចាប់ផ្តើមពីទ្រឹស្តី និងការអនុវត្តន៍លើការវាយតម្លៃការគ្រប់គ្រងធនធានមនុស្ស និងការផ្លាស់ប្តូរធនធានមនុស្សនៅក្នុងកំណែទម្រង់វិស័យសាធារណៈជាដំណើរការធ្វើឱ្យប្រាកដថា សេវាសាធារណៈពិតជាបានឆ្លើយតបយ៉ាងត្រឹមត្រូវចំពោះការផ្លាស់ប្តូរនៅក្នុងបរិយាកាសខាងក្នុង និងខាងក្រៅ តាមតម្រូវការនៅក្នុងបរិបទសង្គមនៃការផ្លាស់ប្តូរការដាក់ឱ្យអនុវត្តតាមយន្តការតាមដាន ត្រួតពិនិត្យ និងប្រើប្រាស់ការវាយតម្លៃធនធានមនុស្សថាជាគុណសម្បត្តិក្នុងការប្រកួតប្រជែង និងរួមបញ្ចូលគ្នាជាផ្លូងមួយក្នុងស្ថាប័ននាំអោយមានការផ្លាស់ប្តូរនូវចក្ខុវិស័យ ឬក្នុងគោលបំណង និងតាមគោលដៅរបស់ស្ថាប័នរដ្ឋាភិបាលដើម្បីក្លាយជាការប្រកួតប្រជែងរកផលប្រយោជន៍ និងផលចំណេញកាន់តែច្រើនជូនសង្គម និងប្រទេសជាតិ។ ក៏ប៉ុន្តែ វាមិនត្រូវបានធានាថាការផ្លាស់ប្តូរយុទ្ធសាស្ត្រនឹងតែងតែទទួលបានជោគជ័យ

នោះទេ ចំពោះដំណើរវាយតម្លៃការគ្រប់គ្រងធនធានមនុស្សនៅក្នុងការផ្លាស់ប្តូរនៃកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល ជាដំណើរការនៃការធ្វើឱ្យប្រាកដប្រជាលើគុណភាពសេវាសាធារណៈថាវាពិតជាបានឆ្លើយតបយ៉ាងត្រឹមត្រូវចំពោះការផ្លាស់ប្តូរនៅក្នុងបរិយាកាសខាងក្នុង និងខាងក្រៅរបស់វាពិតមែនដែរឬទេ?

តាមគោលនយោបាយរបស់រដ្ឋាភិបាលអាចត្រូវបានកំណត់ថាជា " **ការផ្លាស់ប្តូរខ្លឹមសារក្នុងការធ្វើឱ្យមានទំនើបកម្មផ្នែករដ្ឋបាលសាធារណៈក្នុងស្ថាប័នរដ្ឋ** ដែលត្រូវបានកំណត់ដោយដែនកំណត់ និងវិសាលភាពការវាយតម្លៃដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល លើការបណ្តុះបណ្តាលធនធានមនុស្ស គឺជាគុណសម្បត្តិក្នុងការប្រកួតប្រជែងអនុវត្តតាមផែនការដាក់លាក់មួយបានត្រឹមត្រូវដោយការផ្លាស់ប្តូរអាចជាការបង្កើនយឺតៗ និងផ្លាស់បន្តិចម្តងៗក្នុងវប្បធម៌ស្ថាប័នដែលបានដើរតួនាទីយ៉ាងធំក្នុងការផ្លាស់ប្តូរយុទ្ធសាស្ត្រនាពេលអនាគត ដើម្បីធានាឱ្យការផ្លាស់ប្តូរយុទ្ធសាស្ត្រមានប្រសិទ្ធភាពប្រសិទ្ធផល និងមានស័ក្តិសិទ្ធិភាពនៃការផ្លាស់ប្តូរត្រូវតែបញ្ចូលទៅក្នុងវប្បធម៌ផ្ទៃក្នុងរបស់ស្ថាប័នឱ្យបានស៊ីជម្រៅ និងដែលអាចបត់បែនបានថា ជាស្ថាប័នមួយដែលអាចឆ្លើយតបយ៉ាងឆាប់រហ័សចំពោះការផ្លាស់ប្តូរនៅក្នុងតំបន់ និងសាកលលោកដោយបានបង្កើតគំរូមួយសម្រាប់ការយកឈ្នះលើការតស៊ូដើម្បីការផ្លាស់ប្តូរតាមវិធីសាស្ត្រ៖ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសជំនាញ ការចូលរួមការងារពីមន្ត្រីការសម្របសម្រួលរវាងអន្តរស្ថាប័ន ការសិក្សាស្វែងយល់ក្នុងវិស័យបច្ចេកវិទ្យា និងព័ត៌មាន ការផ្តុកទិន្នន័យរួម និងពេលខ្លះដោយការបង្ខិតបង្ខំក្នុងផ្លូវច្បាប់តាមការវិភាគលើទិដ្ឋភាពទូទៅនៃបញ្ហាផ្សេងៗដែលមានឥទ្ធិពលលើការផ្លាស់ប្តូរក្នុងស្ថាប័ននីមួយៗ ហើយការផ្លាស់ប្តូរយុទ្ធសាស្ត្រជាជំហានដ៏ធំមួយសម្រាប់រាជរដ្ឋាភិបាលដែលទាមទារការយកចិត្តទុកដាក់ច្រើនដោយការវាយតម្លៃ និងគ្រប់គ្រងធនធានមនុស្សឱ្យបានត្រឹមត្រូវតាមសមត្ថភាពជំនាញក្នុងករណីផ្សេងគ្នានូវការឆ្លើយតបការតស៊ូមតិ យោបល់របស់មន្ត្រីរាជការតាមមុខងារ តួនាទី និងភារៈកិច្ចដែលមិនត្រឹមត្រូវ និងមិនមានយុត្តិធម៌សង្គម។

ដូច្នេះ **តើស្ថាប័នរដ្ឋអាចយកឈ្នះការតស៊ូនេះដោយរបៀបណា?** តាមរយៈការវាយតម្លៃធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ និងការផ្លាស់ប្តូរ ការដំឡើង តែងតាំងតួនាទី និងមុខតំណែងក្នុងស្ថាប័ន? ស្ថាប័នមួយត្រូវបានបង្កើតឡើងតាមផែនការជាក់លាក់ និងត្រឹមត្រូវវាជាតួនាទីរបស់អ្នកគ្រប់គ្រងធនធានមនុស្សក្នុងការបង្កើនការផ្លាស់ប្តូរទៅកាន់បុគ្គលិក និងបណ្តាអគ្គនាយកដ្ឋាននីមួយៗ ហើយជាទូទៅការផ្លាស់ប្តូរអាចជាការបង្កើតដោយធ្វើឡើងក្នុងជំហានតូចៗ និងក្នុងរយៈពេលយូរជំនួសដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកទេសឌីជីថលលើកត្តាសំខាន់ៗនៃការផ្លាស់ប្តូរដោយមានហេតុផលមួយចំនួនដែលថា៖ **ហេតុអ្វីបានជាស្ថាប័ននីមួយៗនឹងពិចារណាការផ្លាស់ប្តូរយុទ្ធសាស្ត្រដោយសារមានឥទ្ធិពលពីកត្តាខាងក្រៅ?** គោលគំនិតការគិតបែបប្រពៃណីក្នុងការគ្រប់គ្រងរដ្ឋបាលធារណៈ និងរចនាសម្ព័ន្ធពីតួនាទីក្នុងស្ថាប័នវាទាមទារឱ្យមានយុត្តិកម្មយ៉ាងសំខាន់នៅក្នុងសតវត្សទី២២ហើយព័ត៌មាននិងទំនាក់ទំនងបច្ចេកវិទ្យាព័តមានបានវិវត្តគួរឱ្យកត់សម្គាល់ក្នុងវិស័យរដ្ឋបាលសាធារណៈរដ្ឋ និងឯកជនដែលបានផ្តល់ឱ្យមានការផ្លាស់ប្តូរមនោគមវិជ្ជាថ្មីៗនៅក្នុងកំណែទម្រង់មុខងារសាធារណៈ។ បច្ចេកវិទ្យាចុង

ក្រោយបានអនុញ្ញាតឱ្យមានគំនិតផ្តួចផ្តើមថ្មី ដើម្បីបង្កើនអន្តរកម្មក្នុងចំណោមភ្នាក់ងារទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មានលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងរដ្ឋបាលសាធារណៈនៃទំនាក់ទំនង និងការផ្តល់សេវាកម្មថ្មីរួមទាំងរដ្ឋបាលតាមប្រព័ន្ធអេឡិចត្រូនិក សេវាអេឡិចត្រូនិក លទ្ធិប្រជាធិបតេយ្យ និងការទូតអេឡិចត្រូនិក ការផ្លាស់ប្តូរគំរូថ្មីនេះគឺហៅថា " **គំនិតផ្តួចផ្តើមរដ្ឋាភិបាលអេឡិចត្រូនិក** " ។ គំនិតនៃការបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាទៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលផ្នែករដ្ឋបាលសាធារណៈ គឺក្នុងគោលបំណងដើម្បីលើកកម្ពស់ការអនុវត្តការងារសម្រាប់បង្កើនប្រសិទ្ធភាពចំណាយឱ្យកាន់តែមានភាពប្រសើរឡើងពីតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាលដើម្បីបង្ហាញពីបរិយាកាសអំណោយផលសម្រាប់ការវិនិយោគក្នុងស្រុក និងក្រៅស្រុកផងដែរ ហើយវាជាឥន្ទនៈសម្រាប់ការលូតលាស់ក្នុងការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ដោយយល់ឃើញថាការកៀគររដ្ឋបាលសាធារណៈបែបប្រពៃណីទៅទំនើបនៃរដ្ឋបាលមុខងារសាធារណៈ ក្នុងទម្រង់ជារដ្ឋាភិបាលអេឡិចត្រូនិកពីទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មានអាចពង្រីកអត្ថប្រយោជន៍យ៉ាងច្រើនក្នុងការពង្រឹងប្រសិទ្ធភាពក្នុងជួររដ្ឋាភិបាលលើការគ្រប់គ្រង និងផ្តល់ទិសដៅសម្រាប់វិស័យឯកជន និងអ្នកជាប់គាំងពាក់ព័ន្ធនានាជាមួយនឹងការអនុវត្តគោលនយោបាយកាត់បន្ថយភាពអសកម្មកាន់តែតិចៗទៅ។ លើសពីនេះទៀតវាត្រូវបានចង្អុលបង្ហាញថាការវិនិយោគនៅក្នុងរដ្ឋាភិបាលអេឡិចត្រូនិក គឺជាផ្នែកមួយក្នុងចំណោមកម្លាំងជំរុញម៉ាស៊ីនរបស់កម្ពុជាដោយធានាបានដល់ភាពរីកចម្រើនសម្រាប់គោលដៅអភិវឌ្ឍន៍ ជាពិសេសឆ្ពោះទៅរកការសម្រេចបាននូវនិរន្តរភាពរបស់អង្គការសហប្រជាជាតិគោលដៅអភិវឌ្ឍ ឆ្នាំ២០៣០ ជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងឆ្នាំ២០៥០ ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ ដោយបច្ចុប្បន្នអក្ខរកម្មឌីជីថលធនធានមនុស្សនៅមានកម្រិតទាបនៅឡើយ ដែលត្រូវបានចាត់ទុកថាជាឧបសគ្គចម្បងសម្រាប់គំនិតផ្តួចផ្តើមរដ្ឋាភិបាលឌីជីថលនៃឧស្សាហកម្មទី៤.០។

**អ្វីជាគោលគំនិតឌីជីថល** ជាសមត្ថភាពទាក់ទងពីម៉ាស៊ីនមួយទៅម៉ាស៊ីនមួយតាមរយៈបណ្តាញឥតខ្សែ ឬមានខ្សែដោយប្រព័ន្ធបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងប្រព័ន្ធរៀនចេះចាំដោយម៉ាស៊ីនប្រព័ន្ធវិភាគទិន្នន័យធំ និងដោះស្រាយកម្រិតខ្ពស់វាជាគំនិតផ្តួចផ្តើមដែលបានធ្វើឱ្យប្រសើរឡើងការកែលម្អដោយទទួលបានជោគជ័យ ហើយភាគច្រើននៃប្រទេសជឿនលឿនលើសកលលោក ការផ្លាស់ប្តូរការប្រើប្រាស់អាជីវកម្មសេវាកម្មឌីជីថលបានលេចឡើងនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ក្នុងការផ្លាស់ប្តូរការងារ និងសេវាកម្មត្រូវផ្អែកលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាយ៉ាងខ្លាំង ដើម្បីពន្លឿនសេដ្ឋកិច្ចឌីជីថលការបង្កើនល្បឿនការងារ និងការរីករាលដាលនៃសកលូបនីយកម្មឌីជីថលយ៉ាងច្រើនតាមរយៈការចូលប្រើប្រាស់ឧបករណ៍ឌីជីថលលើចំណេះដឹង និងឱកាសរកប្រាក់ចំណូលលឿន រហ័ស ចំណេញពេលវេលា មានប្រសិទ្ធភាព ប្រសិទ្ធផល យុត្តិធម៌ តម្លាភាព និងមានគណនេយ្យភាពសង្គម។

**អ្វីជាបច្ចេកវិទ្យាឌីជីថល?** វាបានក្លាយជាមាគ៌ានៃបដិវត្តន៍ឧស្សាហកម្មទី៤.០ មិនត្រឹមតែកែប្រែអាជីវកម្មបែបប្រពៃណីបានប៉ុណ្ណោះទេ វាមានការច្នៃប្រឌិតពីគំរូអាជីវកម្មដោយសារភាពរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យាឌីជីថលរួមមាន៖ ទូរស័ព្ទដៃ កុំព្យូទ័រ អ៊ីនធឺណិត រ៉ូប័រអុបទិក បញ្ញាសិប្បនិមិត្ត

កម្មវិធីសុសវែរ បច្ចេកវិទ្យាចល័ត ឧបករណ៍ចល័ត បច្ចេកវិទ្យារូបភាព និងបច្ចេកវិទ្យាសម្រាប់ការវិភាគទិន្នន័យក្នុងការបង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ។ បច្ចេកវិទ្យាឌីជីថលទាំងនេះបានផ្លាស់ប្តូររបៀបរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងបានជំរុញឱ្យរដ្ឋាភិបាលផ្លាស់ប្តូរវិធីដែលពួកគេផ្តល់សេវាកម្ម និងទំនាក់ទំនងជាមួយមនុស្ស និងអាជីវកម្មលើវិធីសាស្ត្ររដ្ឋបាលសាធារណៈបែបប្រពៃណីទៅរដ្ឋបាលសាធារណៈតាមគន្លងថ្មីនេះត្រូវបានសំដៅជាទូទៅថាជារដ្ឋាភិបាលឌីជីថលក្នុងពេលបច្ចុប្បន្ន។ សំណួរថា៖ **ហេតុអ្វីកម្ពុជាត្រូវការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងឧស្សាហកម្មទី៤.០?** ដោយសារឌីជីថលក្នុងសកលលោកបានរីកចម្រើនលឿនជាងការច្នៃប្រឌិត ហើយណាមួយនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោកឈានដល់ជាង ៦០ភាគរយនៃចំនួនប្រជាពលរដ្ឋសកលលោកដែលកំពុងអភិវឌ្ឍដោយគិតត្រឹមឆ្នាំ២០២១ មានការផ្លាស់ប្តូរច្រើន តាមរយៈការបង្កើនការតភ្ជាប់ ការដាក់បញ្ចូលហិរញ្ញវត្ថុ ការទទួលបានពាណិជ្ជកម្មសេរី សេវាកម្មសាធារណៈ និងបច្ចេកវិទ្យាអាចជាភាពស្មើគ្នាដ៏អស្ចារ្យ។ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលអាចធ្វើឱ្យការប្រកបរបរចិញ្ចឹមជីវិតរបស់មនុស្ស និងអាជីវកម្មមានភាពកាន់តែល្អប្រសើរឡើង ប្រសិនបើយើងអាចសម្របខ្លួនបានត្រឹមត្រូវការងារមួយចំនួនដែលរ៉ូបូត ឬម៉ាស៊ីនមិនអាចធ្វើកើតមានដូចជាការដោះស្រាយបញ្ហាស្មុគស្មាញ ការគិតគូរថ្លឹងថ្លែង ភាពច្នៃប្រឌិត ការវាយតម្លៃការគ្រប់គ្រងធនធានមនុស្ស ការសម្របសម្រួលជាមួយអ្នកដទៃ ភាពវៃឆ្លាតផ្នែកអារម្មណ៍ សុភវិនិច្ឆ័យការសម្រេចចិត្ត ការតម្រង់ទិស សេវាកម្ម ការចរចា និងភាពបត់បែនក្នុងការស្វែងយល់ផ្សេងៗនោះនឹងមានតម្រូវការការងារកាន់តែខ្ពស់ក្នុងឧស្សាហកម្ម៤.០ ជាមួយការតម្រង់ទិសឆ្ពោះទៅការវាយតម្លៃការគ្រប់គ្រងធនធានមនុស្សលើវិស័យសាធារណៈក្នុងរដ្ឋបាលសាធារណៈ។ តើអ្វីជា**ពាក្យរដ្ឋបាលសាធារណៈ?** ពាក់ព័ន្ធទៅនឹងនិយមន័យរដ្ឋបាលសាធារណៈនេះ Shafritz, Russell, Borick and Hyde (**២០១៧: ៤៥-៦៨**) បានផ្តល់ជាអនុសាសន៍ថា វាគឺជាការលំបាកក្នុងការកំណត់និយមន័យរដ្ឋបាលសាធារណៈមួយដែលអាចទទួលយកដោយគ្រប់ភាគី។ អាស្រ័យហេតុនេះ អ្នកទាំងបួនបានផ្តល់និយមន័យជាបួនផ្នែកធំគឺ **ផ្នែកនយោបាយ ច្បាប់ ការគ្រប់គ្រង និងវិជ្ជាជីវៈ។**

- ផ្តោតលើផ្នែកនយោបាយ
  - អ្វីដែលរដ្ឋាភិបាលធ្វើ
  - ដំណាក់កាលមួយនៃការបង្កើតគោលនយោបាយសាធារណៈ
  - ការអនុវត្តន៍ផលប្រយោជន៍សាធារណៈ
  - សកម្មភាពដែលអនុវត្តមានលក្ខណៈជារួម ព្រោះថាបុគ្គលមិនអាចអនុវត្តបាន។
- ផ្តោតទៅលើផ្នែកច្បាប់
  - ការអនុវត្តន៍ច្បាប់
  - បទបញ្ញា
  - សកម្មភាពរបស់អ្នកគ្រប់គ្រងឬព្រះរាជាក្នុងការផ្តល់ឬប្រទានអ្វីមួយដល់ប្រជាពលរដ្ឋ។

- ផ្អែកទៅលើផ្នែកការគ្រប់គ្រង
    - មុខងារប្រតិបត្តិនៅក្នុងរដ្ឋាភិបាល
    - សិល្បៈហើយមិនមែនជាវិទ្យាសាស្ត្រ។
- ផ្អែកទៅលើផ្នែកវិជ្ជាជីវៈ
    - ការអនុវត្តឧត្តមគតិនិយម
    - ផ្នែកសិក្សាមួយដែលតែងតែសិក្សាអំពីសិល្បៈ និងវិទ្យាសាស្ត្រគ្រប់គ្រងសម្រាប់យកទៅអនុវត្តនៅក្នុងផ្នែកសាធារណៈ។

ពាក្យ **«រដ្ឋបាលសាធារណៈ»** នេះ ពេលខ្លះត្រូវបានអ្នកនយោបាយយកមកប្រើ ដែលជំនួសដោយពាក្យ "ការិយាធិបតេយ្យ" ការយកមកប្រើបែបនេះដោយហេតុថា ប្រជាពលរដ្ឋសាមញ្ញយល់ពាក្យការិយាធិបតេយ្យនេះជាងពាក្យរដ្ឋបាលសាធារណៈ។ ផ្សេងពីការប្រើពាក្យជំនួសខាងលើក៏នៅមានទស្សនៈផ្សេងគ្នាក្នុងការប្រើពាក្យ រដ្ឋបាលសាធារណៈ នេះដែរ ការប្រើពាក្យខុសគ្នានេះ ដោយសារការវិវត្តន៍ និងរីកចម្រើននៃរដ្ឋបាលសាធារណៈ (Prof. Dr. Yeremias T. Keban ២០០៨:៤)។ មានន័យថារដ្ឋាភិបាលមានតួនាទីជានិយតករ រដ្ឋាភិបាលជាអ្នកបង្កើត កំណត់ និងសម្រេចចិត្ត ចំណែកប្រជាពលរដ្ឋមានតួនាទីចាំតែទទួលអ្វីដែលរដ្ឋផ្តល់ឱ្យ និងមានន័យថារដ្ឋាភិបាលមានតួនាទីជាអ្នកផ្តល់សេវាដែលស្វែងយល់ពីតម្រូវការរបស់ប្រជាពលរដ្ឋ។

- មានន័យថាសកម្មភាពរបស់រដ្ឋាភិបាល គឺឆ្ពោះទៅរកការផ្តល់នូវសិទ្ធិអំណាច ដោយរដ្ឋមានតួនាទីជាអ្នកសម្របសម្រួល ចំណែកប្រជាពលរដ្ឋមានតួនាទីចូលរួម។ ការកំណត់ផ្សេងៗគ្នានេះ ដោយសារការវិវឌ្ឍន៍រីកចំរើននៃរដ្ឋបាលសាធារណៈពីរដ្ឋបាលសាធារណៈដែលគ្មានប្រជាធិបតេយ្យរហូតដល់រដ្ឋបាលសាធារណៈដែលមានប្រជាធិបតេយ្យ (Prof. Dr. Yeremias T. Keban ២០០៨:៤៥)។
- ដោយផ្អែកលើនិយមន័យខាងលើ Prof. Dr. Yeremias T. Keban (២០០៤) បានធ្វើការសំយោគដូចខាងក្រោម៖
- រដ្ឋបាលសាធារណៈមានទំនាក់ទំនងទៅនឹងផ្នែកនីតិប្រតិបត្តិច្រើនជាងផ្នែកនីតិបញ្ញត្តិ និងតុលាការ
- រដ្ឋបាលសាធារណៈមានទំនាក់ទំនងជាមួយបញ្ហាមនុស្ស និងការសហការគ្នាដើម្បីដំណើរការការងាររដ្ឋាភិបាល
- ទោះបីជារដ្ឋបាលសាធារណៈមានការខុសគ្នាជាមួយនឹងរដ្ឋបាលឯកជន ប៉ុន្តែវាគ្របដណ្តប់ទៅលើរដ្ឋបាលឯកជន
- រដ្ឋបាលសាធារណៈមានលក្ខណៈតម្រង់ទិស សម្រាប់ផលិតសេវា និងទំនិញក្នុងវិស័យសេវារដ្ឋបាលសាធារណៈ។

**តើវិស័យសាធារណៈគឺជាអ្វី?** ទោះបីជាមានភាពស្មុគស្មាញនៃវិស័យសាធារណៈនៅក្នុងការជជែកវែកញែកចំពោះបរិបទឧស្សាហកម្មទី៤.០ ក៏ពិតមែន តែវិស័យមួយនេះវាមានសារៈសំខាន់ណាស់សម្រាប់ស្វែងយល់ពីការអនុវត្តន៍ និងវាយតម្លៃការងារគ្រប់គ្រងធនធានមនុស្ស ហើយវាក៏មានឥទ្ធិពលលើគោលដៅសំខាន់ៗបីដែលជះឥទ្ធិពលដល់ការគ្រប់គ្រងនិយោជិករបស់ខ្លួន **ទីមួយៈ** វាត្រូវបានជះឥទ្ធិពលយ៉ាងខ្លាំងដោយកត្តាបរិបទសង្គម ជាពិសេសនៅក្នុងគោលនយោបាយសាធារណៈ **ទីពីរៈ** លក្ខណៈចម្រុះនៃការងារ និងកម្លាំងពលកម្ម គឺជាបញ្ហាប្រឈមក្នុងស្ថាប័នលើវិស័យសាធារណៈមានភាពចម្រុះលើទំហំប្រភេទការងារដែលត្រូវបានអនុវត្ត និងជាប្រវត្តិសាស្ត្រផ្នែកខ្លះនៃវិស័យសាធារណៈ និង **ទីបី ៖** វិសាលភាពនៃវិស័យសាធារណៈក៏អាចត្រូវបានគេមើលយោងទៅតាមស្ថានភាពការងាររបស់និយោជិករបស់ខ្លួនតាមរយៈគំរូ **«មុខងារសាធារណៈ»** ដែលជាប្រពៃណីខុសគ្នារវាងលក្ខខណ្ឌការងារក្នុងស្ថាប័នសាធារណៈរដ្ឋ និងឯកជនពីអាកប្បកិរិយាដែលរំពឹងទុករបស់និយោជិកបានកើតឡើងនូវគំរូនៃសេវាសាធារណៈ គឺផ្អែកលើមុខងារសាធារណៈជាជាងច្បាប់ការងារឯកជនដែលមានភាពខុសគ្នាជាសំខាន់។ **តើអ្វីជាគោលដៅនៃការផ្លាស់ប្តូរឌីជីថលក្នុងការគ្រប់គ្រងសាធារណៈ? ហើយតើការបំប្លែងឌីជីថលមានឥទ្ធិពលលើស្ថាប័នរដ្ឋាភិបាលជុំវិញពិភពលោកយ៉ាងដូចម្តេច?** ហើយអ្វីជាទំនាក់ទំនងនិងការប្រើប្រាស់បច្ចេកវិទ្យាដែលនឹងឈានដល់ការបំប្លែងឌីជីថលក្នុងរដ្ឋបាលសាធារណៈ? និយាយជារួមការប្រើប្រាស់បច្ចេកវិជ្ជាថ្មី និងការផ្លាស់ប្តូរឌីជីថលកំពុងពង្រឹងការគ្រប់គ្រងនៃរដ្ឋបាលសាធារណៈ និងការលើកទឹកចិត្តដល់ការប្រើប្រាស់ទម្រង់រដ្ឋបាលសាធារណៈ នៅក្នុងវិស័យសាធារណៈរវាងប្រជាពលរដ្ឋនិងស្ថាប័នរដ្ឋាភិបាលដោយការដាក់បញ្ចូលនូវកម្រងកម្មវិធីថ្មីទៅក្នុងការប្រើប្រាស់ និងគ្រប់គ្រងក្នុងវិស័យសាធារណៈតាមរយៈការបំប្លែងឌីជីថលជាមធ្យោបាយមួយ ដើម្បីភ្ជាប់សាធារណជនជាមួយរដ្ឋាភិបាល ហើយដើម្បីឱ្យដំណើរការនេះអនុវត្តទៅបានល្អ គ្រប់អ្នកគ្រប់គ្រង និងដឹកនាំសាធារណៈត្រូវស្គាល់ពីវិធីក្នុងការអនុវត្ត និងប្រើប្រាស់ឧបករណ៍នៅកន្លែងធ្វើការឌីជីថល។ ក្នុងន័យនេះ តាមរយៈការសិក្សាខ្ញុំបានរកឃើញអំពីការប្រើប្រាស់បច្ចេកវិទ្យាសំខាន់ៗចំនួនប្រាំ ដើម្បីផ្លាស់ប្តូរការគ្រប់គ្រង និងប្រើប្រាស់ក្នុងរដ្ឋបាលសាធារណៈតាមប្រព័ន្ធឌីជីថលពីគោលបំណងនៃការផ្លាស់ប្តូរ និងឥទ្ធិពលរបស់វាទៅលើការគ្រប់គ្រងរដ្ឋបាលសាធារណៈជាសកលផងដែរនោះគឺទី១៖របៃផតថលសេវាកម្ម និងការតាមដាន ទី២៖ការគ្រប់គ្រងឯកសារ ឬទិន្នន័យ និងការរក្សាសុវត្ថិភាព ទី៣៖ការវិភាគទិន្នន័យ ទី៤៖កម្មវិធីជាសេវាកម្មក្នុងវិស័យសាធារណៈ និង៥. កុំព្យូទ័រលើពពក។ និយាយជារួមការផ្លាស់ប្តូរឌីជីថលមានសារៈសំខាន់ព្រោះវាអាចជួយឱ្យអាជីវកម្មបង្កើនបាននូវសុចរិតភាព តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងប្រសិទ្ធផលនៃដំណើរការរដ្ឋបាលសាធារណៈថ្មីលើកែលម្អការប្រើប្រាស់ធនធានមនុស្ស ក្នុងការប្រើប្រាស់កិច្ចការរដ្ឋបាលនៃផ្នែកសេវាសាធារណៈ និងបន្តការអភិវឌ្ឍទៅអនាគតដោយផ្តល់ឱ្យពួកគេនូវគុណសម្បត្តិល្អៗក្នុងការប្រកួតប្រជែងក្នុងទីផ្សារ ហើយទាំងអស់នេះគឺអាចធ្វើទៅបានដោយសារដំណើរការសាមញ្ញពីការប្រើប្រាស់ត្រឹមត្រូវនៃបច្ចេកវិទ្យា និងទិន្នន័យដែលបានបង្កើតបានឈានដល់ការសម្រេចចិត្តកាន់តែប្រសើរឡើងពីតម្រូវការក្នុងការផ្លាស់ប្តូរឌីជីថល។

## សេចក្តីសន្និដ្ឋាន

តាមទ្រឹស្តី និងការរៀបរាប់ខាងលើសម្រាប់កម្ពុជាបច្ចុប្បន្នបញ្ហាអក្ខរកម្មឌីជីថលជាកត្តាកំណត់ក្នុងគោលដៅមួយសម្រាប់ការអភិវឌ្ឍ និងអនុវត្តដោយរដ្ឋាភិបាលអេឡិចត្រូនិកមួយដែលអាចប្រកបដោយភាពជោគជ័យលើគោលនយោបាយមួយចំនួនជានាដល់ការលើកកម្ពស់ចំណេះដឹងឌីជីថលលើកដំបូងនៅក្នុងប្រព័ន្ធកម្មវិធីសិក្សាអប់រំ ហើយក្នុងករណីនេះក្រសួងអប់រំយុវជន និងកីឡា គឺជាអ្នកនាំមុខគេដោយក្រសួងត្រូវយកចិត្តទុកដាក់កែលម្អដល់ការបណ្តុះបណ្តាលមន្ត្រីរាជការទូទៅ ជាពិសេសគ្រូបង្រៀនឱ្យយល់ដឹងជាមូលដ្ឋាននៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកលើសេវាកម្មដូចជា ៖ បណ្ណាល័យអេឡិចត្រូនិក ឬសៀវភៅអេឡិចត្រូនិក រៀនតាមប្រព័ន្ធអេឡិចត្រូនិក និងសេវាអេឡិចត្រូនិកផ្សេងទៀតដើម្បីផ្តល់ជាមេរៀន និងបទពិសោធន៍ដល់សិស្សានុសិស្សអំពីសេវារដ្ឋាភិបាលអេឡិចត្រូនិក និងសេវាសាធារណៈអេឡិចត្រូនិក ពីសារៈសំខាន់នៃការប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យាឌីជីថលរបស់រដ្ឋាភិបាលសង្គមស៊ីវិល និងតួអង្គពាក់ព័ន្ធ។ តាមការសិក្សារបស់ខ្ញុំកម្ពុជានៅមានបញ្ហាប្រឈមសំខាន់បួនសម្រាប់រដ្ឋាភិបាលឌីជីថលគឺ ៖

១. ខ្វះខាតហេដ្ឋារចនាសម្ព័ន្ធទំនាក់ទំនងបច្ចេកវិទ្យាព័តមាន និងគោលនយោបាយ ទំនាក់ទំនងបច្ចេកវិទ្យាព័តមាន ២. ការប្រើប្រាស់ឌីជីថលនៅតែជាបញ្ហាអក្ខរកម្ម ៣. ការគាំទ្រផ្នែកហិរញ្ញវត្ថុនូវមានកម្រិតសម្រាប់ថ្នាក់ជាតិ និងក្រោមជាតិ និង៤. ខ្វះឆន្ទៈ និងមនសិការក្នុងការផ្សព្វផ្សាយ និងបណ្តុះបណ្តាលឱ្យបានទូលំទូលាយ ដោយមិនមានវិធានការតឹងរ៉ឹងច្បាស់លាស់ពីភាគីទាំងរដ្ឋាភិបាល និងភាគីដៃគូពាក់ព័ន្ធផ្សេងទៀត ។

ចំពោះដំណោះស្រាយបញ្ហាប្រឈមទាំងនោះ ទាមទារនូវការរៀបចំផែនការជាប្រព័ន្ធផ្តោតលើការកែលម្អទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មានហេដ្ឋារចនាសម្ព័ន្ធ និងគោលយោបាយលើការទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្រប តាមរយៈផ្តល់ការអប់រំផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក និងភាសាខ្មែរឱ្យមានប្រសិទ្ធភាព ដោយបញ្ចូលកម្រងកម្មវិធីបច្ចេកវិទ្យាទៅក្នុងមហាវិទ្យាល័យ វិទ្យាល័យ និងមន្ត្រីរាជការចាស់ៗដែលធ្វើការក្នុងស្ថាប័នរដ្ឋលើកម្មវិធីអេឡិចត្រូនិក ដើម្បីទទួលបានការយល់ដឹងពីសេវាអេឡិចត្រូនិកលើការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាតាមអ៊ីនធឺណិត និងកុំព្យូទ័រចល័តដែលមានសមត្ថភាពក្នុងការផ្លាស់ប្តូរទំនាក់ទំនងអាជីវកម្ម និងការងាររដ្ឋបាលសាធារណៈរបស់រដ្ឋាភិបាលមានបីសំខាន់ ៖ ១. ការផ្តល់សេវារដ្ឋាភិបាលកាន់តែប្រសើរឡើងជាមួយប្រជាពលរដ្ឋ ២. ធ្វើឱ្យប្រសើរឡើងនូវអន្តរកម្មជាមួយអាជីវកម្ម និងឧស្សាហកម្ម និង៣.ការពង្រឹងសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋតាមរយៈការទទួលបានព័ត៌យ៉ាងទូលំទូលាយពីការអនុម័តរបស់រដ្ឋាភិបាល ដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល។

សរុបសេចក្តីមកគោលគំនិតនៃការវិវត្ត និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យរដ្ឋបាលសាធារណៈនៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល ជាការរួមចំណែកក្នុងការបង្កើតគោលនយោបាយរដ្ឋបាលសាធារណៈតាមគន្លងថ្មីនឹងជួយជំរុញឱ្យមានការផ្លាស់ប្តូរនៃការគ្រប់គ្រង ក្នុងវិស័យរដ្ឋបាលសាធារណៈ

ចាស់ពីការគ្រប់គ្រងមិនសូវទទួលបានលទ្ធផលទៅជាការគ្រប់គ្រងដែលទទួលបានលទ្ធផលអាចនិយាយផងដែរថា គោលនយោបាយថ្មីមួយនេះជាការកែលម្អ និងបង្កើតរចនាសម្ព័ន្ធរដ្ឋាភិបាលមួយដែលជួយជំរុញឱ្យមានការផ្លាស់ប្តូរការគ្រប់គ្រងក្នុងវិស័យសាធារណៈចាស់ប្រព័ន្ធបញ្ជា និងត្រួតពិនិត្យ (បែបប្រពៃណី) តាមនីតិវិធីដែលមាននៅក្នុងបទដ្ឋានគោលការណ៍ច្បាប់ និងបញ្ញាតិ។ នេះជាហេតុផលដែលស្ថាប័នពិចារណាលើការផ្លាស់ប្តូររដ្ឋបាលសាធារណៈតាមគន្លងថ្មី ទៅជាយន្តការការគ្រប់គ្រងមួយដែលមានគោលដៅទៅរកការគ្រប់គ្រងដែលប្រើប្រាស់ការប្រកួតប្រជែងទៅរកទីផ្សារជាក់ស្តែង នៃការផ្លាស់ប្តូរតាមរយៈឌីជីថល ដោយផ្តោតលើដំណើរការងាររួមដើម្បីផ្លាស់ប្តូរការផលិតការងារ និងវប្បធម៌ចែករំលែកតាមរយៈការបំប្លែងទៅជាឌីជីថល និងការធ្វើកម្មវិធីឌីជីថល ដោយបញ្ចូលវាទៅក្នុងស្ថាប័នទាំងមូលនូវការផ្លាស់ប្តូរវប្បធម៌ការិយាធិបតេយ្យក្នុងស្ថាប័ន និងទំនាក់ទំនងទៅភាគីពាក់ព័ន្ធជាមួយទិន្ន័យរយៈពេលខ្លីផ្តោតលើការកើនឡើងដែលអាចវាស់វែងបាន នៅក្នុងវិស័យរដ្ឋបាលសាធារណៈផ្នែកសេវាកម្មឌីជីថលថ្មីរយៈពេលវែងដោយមានគណនេយ្យភាពសង្គមបង្កើននូវប្រសិទ្ធភាព ប្រសិទ្ធផលពីសំណាក់សង្គមប្រជាពលរដ្ឋនៅទូទាំងប្រទេស។

## គន្ថនិទេស

### ១. ភាសាខ្មែរ


១. Alsherhri, M., & Drew, S. (២០១០) ការអនុវត្តនៃរដ្ឋាភិបាលអេឡិចត្រូនិក៖ គុណសម្បត្តិនិងបញ្ហាប្រឈមដំណើរការនៃសន្និសីទអន្តរជាតិ E-Activity និងបច្ចេកវិទ្យាឈានមុខគេ និងអន្តរ TIC ឆ្នាំ 2010។

២. https://doi.org/ 10.1016/j.infoecopol.2008. 11.003Becker, J., Nihaves, B., Bergener, P., &Rackers, M. (២០០៨, សីហា) ការបែងចែកឌីជីថលនៅក្នុង eGovernment: គម្លាត Inclusion គំរូ នៅក្នុងសន្និសីទអន្តរជាតិស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក (ទំព័រ 231-242)។

៣. ការអនុវត្ត និងការគ្រប់គ្រងរដ្ឋាភិបាលអេឡិចត្រូនិក៖ អត្ថបទអន្តរជាតិ។ ទីក្រុងឡុងដ៏៖ ការបោះពុម្ពផ្សាយ Sage Infocomm អាជ្ញាធរអភិវឌ្ឍន៍សិង្ហបុរី។ (ឆ្នាំ ២០២០) គំនិតផ្តួចផ្តើមបទពិសោធន៍របស់សិង្ហបុរីដើម្បីលើកកម្ពស់ការចូលរួមតាមអេឡិចត្រូនិក។

៤. https://www.un.org/ 2013 ទំនាក់ទំនងបច្ចេកវិទ្យាព័តមានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ២០១៤ ផែនការមេទំនាក់ទំនងបច្ចេកវិទ្យាព័តមានកម្ពុជាឆ្នាំ ២០២០។

៥. និយតករទូរគមនាគមន៍កម្ពុជា Lio, M.C., Liu, M.C., & Ou, Y.P.(2011) អ៊ីនធឺណិតកាត់បន្ថយអំពើពុករលួយ? ការសិក្សាឆ្លងប្រទេសដោយផ្អែកលើបន្ទះថាមវន្តគំរូទិន្នន័យ។ ព័ត៌មានរបស់រដ្ឋាភិបាលប្រចាំត្រីមាស២៨(១) ៤៧-៥៣។ Majeed, M.T.,&Malik,A. (2016) ១១. រដ្ឋាភិបាលអេឡិចត្រូនិក ការអភិវឌ្ឍហិរញ្ញវត្ថុនិងសេដ្ឋកិច្ចកំណើន Pakistan Journal of Applied សេដ្ឋកិច្ច, 26(2), 107-128។

៦. ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) (២០០៩)[QUOTE] ផែនការមេសម្រាប់ព័ត៌មាន និងទំនាក់ទំនងបច្ចេកវិទ្យាក្នុងការអប់រំ កម្ពុជាធនាគារជាតិនៃកម្ពុជា (ឆ្នាំ ២០២០)។

៧. https://www.nbc.org.kh រដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់ការអភិវឌ្ឍប្រទេស៖ ឱកាស និងបញ្ហាប្រឈម

៨. ទិនានុប្បវត្តិអេឡិចត្រូនិកនៃរដ្ឋាភិបាលអេឡិចត្រូនិក ១១(១) Nkwe, N. (2012) រដ្ឋាភិបាលអេឡិចត្រូនិក៖ បញ្ហាប្រឈមនិងឱកាសនៅ Botswana អន្តរជាតិទិនានុប្បវត្តិរបស់មនុស្ស និងសង្គមវិទ្យាសាស្ត្រ 2(17) 39-48។

៩. ផ្លូវទៅកាន់រដ្ឋាភិបាលអេឡិចត្រូនិករបស់កម្ពុជា៖ ការវិភាគដ៏ទូលំទូលាយនៃគម្រោងរដ្ឋាភិបាលអេឡិចត្រូនិក។ ភ្នំពេញៈ នី ជា. រាជរដ្ឋាភិបាលកម្ពុជា។ នៅឆ្នាំ2013។ ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស។
១០. ជាតិផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ (NSDP) 2014-ឆ្នាំ 2018 រាជរដ្ឋាភិបាលកម្ពុជា (2019) ជាតិផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ (NSDP) 2019-២០២៣។ Schware, R., & Deane, A. (2003) ការដាក់ពង្រាយ E-កម្មវិធីរដ្ឋាភិបាល ៖ យុទ្ធសាស្ត្រសារៈសំខាន់នៃ "ខ្ញុំ" មុន "អ៊ី"។ ព័ត៌មាន គាំទ្រការផ្លាស់ប្តូរសេដ្ឋកិច្ច (ខែកក្កដា ឆ្នាំ ២០២០) ជំរុញឌីជីថលដែលរួមបញ្ចូលកែច្នៃនៅកម្ពុជា។
១១. https://set.odi.org/Fostering-an Inclusive-Digitalisation-Transformation-in Cambodia-Final.pdfShim, D.C., & Eom, T.H. (2008)។
១២. រដ្ឋាភិបាលអេឡិចត្រូនិកនិងការប្រឆាំងអំពើពុករលួយ៖ ការវិភាគជាក់ស្តែងនៃទិន្នន័យអន្តរជាតិ ទិនានុប្បវត្តិអន្តរជាតិនៃរដ្ឋបាលសាធារណៈ 31(3) 298-316 Shin, S. (2008)។
១៣.ពីhttp://195.130.87.21:8080/dspace/handle/1២៣៤៥៦៧៨៩/១០២៥ Sinawong, S. (2010)
១៤. E Government Adoption in ASEAN: The ករណីកម្ពុជា ការស្រាវជ្រាវតាមអ៊ីនធឺណិត, ១៩៥(៥១៩), ៥១៧-៥៣៤។ Srivastava, S.C., & Teo, T.S.H. (2010) E-Government, E-Business, និងជាតិការអនុវត្តសេដ្ឋកិច្ច។ ទំនាក់ទំនងនៃសមាគមសម្រាប់ប្រព័ន្ធព័ត៌មាន ២៦(១៤) ២៦៨-២៨៦។ Sun, K., & Weiss, R. (2019)។
១៥. ជំរុញការរួមបញ្ចូលការផ្លាស់ប្តូរឌីជីថលនៅកម្ពុជាមកពី Supporting Economics ការផ្លាស់ប្តូរ៖ https://set.odi.org/wp ontent/uploads/2020/06/ Fostering-an Inclusive-Digitalisation-Transformation in Cambodia-Final.pdf និយតករទូរគមនាគមន៍កម្ពុជា (2020 ក) ការជាវទូរស័ព្ទដៃ។
១៦. https://www.trc.gov.kh/en/internet subscribers/ ប្រៃសណីយ៍អាស៊ាន (2018)។ ការពង្រឹងសន្តិសុខតាមអ៊ីនធឺណិតរបស់អាស៊ាន។
១៧. https://theaseanpost.com/article/strengthening-aseans-cybersecurity-0 អង្គការតម្លាភាពអន្តរជាតិ។ (២០១៤) អំពើពុករលួយសន្ទស្សន៍ការយល់ឃើញ៣០.

## ២. ភាសាបរទេស

1. Big DATA GOVERNANCE MODERN DATA MANAGEMENT Principles FOOR HADOOP, NOSOL& BIG DATA ANALYTICS PETER GHAVAMI, PHD.
2. Best Masters Christoph Jan Bartodziej. The Concept Industry 4.0 An Empirical Analysis of Technologies and Applications in Production Logistics, Springer Gabler.
3. BANK 4.0 Banking Everywhere, Never at a Bank. BRETT KING www.Brettking.com WILEY
4. Brought to you by : Amplitude Product Analytics dummies Gains insight about customers' Behavior Create Excellent Prodact Experience Drive Revenue with Digital Products. Brittany Fuller Anastasis Fullerton
5. Complete Guide to Digital Project Management From Free - Sales to Post -Product Shailesh Kumar ShivaKumar Apress
6. Data Science for business, What You Need to Know about Data Mining and Data Analytics Thinking Foster Provost and Tom Fawcett
7. Decision Engineering John Stark Product Lifecycle Management 21st Century paradigm for Product Realizations 2™ Edition Springer.
8. Digital Bank STRATEGIES TO LAUNCH OR BECOME DIGITAL BANK CHRIS SKINNER

9. Edited by Annabeth Aagard Digital Business Models Driving Transformation andInnovation Palgrave Macmillan.
10. Ferri Albolhassan Editor, The Drivers of Digital Transformation. Why There No Way around the Cloud, Springer.
11. FINTECH IN A FLASH FINANCIAL TECHNOLOGY MADE EASY VISION FUNDING IDEA INNOVATION AGUSTIN RUBINI
12. Lecture notes in Management and Industrial Engineering Angel oritz . Carlos Andres Romano Raul Poler Jose Pedro Garcia Sabater. Editor Engineering Digital Transformation Proceedings of the 11 International Conference on Industrial Engineering and Industrial Management, Springer.
13. Managing, engineering, Construction and Manufacturing Projects to PMI, APM and BSI Standards, Albert Lester. Project Management, Planning and Control, 7 Edition.
14. PALGRAVE STUDIES FINANCIAL TECHNOLOGY THE FUTURE OF FINTECH Integrating finance and technology in financial services. BERNARDO NECOLETTI
15. PMI, Project Management Institute, GLOBAL STANDARD A guide to the Project Management Body of Knowledge PMBOK QUIDE SIXTH EDITION INCLUDE: THE STANDARD FOR PROJECTMANAGEMENT ANSL/PML 99-011-2017
16. PMI, Project Management Institute, GLOBAL STANDARD A guide to the Project Management Body of Knowledge, PMBOK QUIDE SIXTH EDITION INCLUDE THE STANDARD FOR PROJECTMANAGEMENT ANSL/PML 99-011-202.
17. PMI, Project Management Institute, GLOBAL STANDARD GOVERNANCE OF PORTFOLIOS, PROGRAMS AND PROJECTS APRACTICE GUIDE
18. IT AUDITING USING CONTROLS TO PROTECT INFORMATION ASSETS Chris Davis and Mike Schiller with Kevin Wheeler, Second Edition.

© ២០២៣ រាជបណ្ឌិត្យសភាកម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង

គ្មានផ្នែកណាមួយនៃទស្សនាវដ្ដីនេះនឹងត្រូវបានបោះពុម្ពឡើងវិញ
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ។

©2023 Royal Academy of Cambodia

All rights reserved,
no part of this book may be reproduced,
in any form, by any means, without permission in writing from
Royal Academy of Cambodia.




**Royal Academy of Cambodia**
Russian Federation Blvd
P.O.Box: 531 Phnom Penh
Kingdom of Cambodia
Tel: (855) 23 890 180
Fax: (855) 23 890 180
Email: info@rac.gov.kh
Website: www.rac.gov.kh

**រាជបណ្ឌិត្យសភាកម្ពុជា**
មហាវិថីសហព័ន្ធរុស្ស៊ី
ប្រអប់សំបុត្រលេខ ៥៣១ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ: (៨៥៥)២៣ ៨៩០១៨០
ទូរសារលេខ: (៨៥៥)២៣ ៨៩០១៨០
អ៊ីមែល: info@rac.gov.kh
វេបសាយ: www.rac.gov.kh